Food and Agriculture Organization of the United Nations



# ការពង្រឹង អភិបាលកិច្ច លើសិទ្ធិកាន់កាប់ព្រៃឈើ

សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែង



សៀវភៅណែនាំបច្ចេកទេសស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់លេខ២

# ការពង្រឹង អភិបាលកិច្ច លើសិទ្ធិកាន់កាប់ព្រៃឈើ

សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែង



អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
ទីក្រុងរ៉ូម ឆ្នាំ២០២១

**គុណភាគថា**

Mayers, J., Morrison, E., Rolington, L., Studd, K. and Turrall, S. ២០២១។ ការពង្រឹង អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ – សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែង។ សៀវភៅណែនាំបច្ចេកទេសស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់លេខ២។ ភ្នំពេញ។ វិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាន និងការអភិវឌ្ឍ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

ការប្រើឈ្មោះទាំងឡាយ និងព័ត៌មានផ្សេងៗដែលមានបង្ហាញក្នុងឯកសារនេះមិនមែនជាការសម្តែងមតិណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។ ការលើកឡើងជាក់លាក់អំពីក្រុមហ៊ុន ឬផលិតផលរបស់ផលិតករណាមួយ ទោះបីជាក្រុមហ៊ុន ឬផលិតផលទាំងនេះមាន ឬគ្មានប្រកាសនីយបត្រតក្កកម្មក្តី មិនមែនមានន័យថាក្រុមហ៊ុន ឬផលិតផលទាំងនេះត្រូវបានគាំទ្រ ឬណែនាំដោយអង្គការ FAO ថាមានឧត្តមភាពជាងក្រុមហ៊ុន ឬផលិតផលស្រដៀងគ្នាដទៃទៀតដែលមិនបានលើកឡើងនោះទេ។

ទស្សនៈដែលបានស្តែងចេញនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងពុំបានឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយ របស់អង្គការ FAO ឡើយ។

ISBN 978-92-5-134328-9

© FAO, ២០២១

© FAO, ២០១៣ [ភាសាអង់គ្លេស]

Some rights reserved. This work is made available under the Creative Commons Attribution-NonCommercial-ShareAlike 3.0 IGO licence (CC BY-NC-SA 3.0 IGO; https://creativecommons.org/licenses/by-nc-sa/3.0/igo/legalcode).

ក្រោមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ Creative Commons ឯកសារនេះ អាចត្រូវបានថតចម្លង ចែកចាយ និងកែសម្រួលសម្រាប់គោលបំណងដែលមិនមែនជាអាជីវកម្ម ក្នុងករណីដែលមានការធ្វើសេចក្តីយោងមកឯកសារនេះឱ្យបានត្រឹមត្រូវ។ ក្នុងការប្រើប្រាស់ណាមួយក៏ដោយនៃឯកសារនេះ មិនត្រូវលើកឡើងថាអង្គការ FAO គាំទ្រដល់ អង្គការ ផលិតផល ឬសេវាកម្មជាក់លាក់ណាមួយឡើយ។ ការប្រើប្រាស់រូបសញ្ញារបស់អង្គការ FAO មិនត្រូវបានអនុញ្ញាតឡើយ។ ប្រសិនបើ ឯកសារនេះ ត្រូវបានកែសម្រួលនោះ តម្រូវឱ្យមានអាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ Creative Commons ដូចគ្នា ឬប្រហាក់ប្រហែលនេះ។ ប្រសិនបើ មានការបកប្រែឯកសារនេះ តម្រូវឱ្យមានប្រយោគបដិសេធ ព្រមទាំងការបង្ហាញសេចក្តីយោងមកឯកសារនេះ ហើយប្រយោគបដិសេធមានខ្លឹមសារដូចតទៅ៖"ការបកប្រែនេះ មិនត្រូវបានធ្វើឡើងដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)ទេ។ អង្គការ FAO មិនទទួលខុសត្រូវចំពោះខ្លឹមសារ ឬភាពត្រឹមត្រូវនៃការបកប្រែនេះឡើយ។ ការបោះពុម្ព ក្នុងភាសាដើម គឺជាការបោះពុម្ពផ្សាយជាផ្លូវការ។"

វិវាទដែលកើតឡើងក្រោមអាជ្ញាប័ណ្ណដែលមិនអាចដោះស្រាយដោយមេត្រីភាព នឹងត្រូវដោះស្រាយដោយការសម្រុះសម្រួល និងអាជ្ញាកណ្តាលដូចដែលមានចែងក្នុងមាត្រាទី ៨ នៃអាជ្ញាប័ណ្ណ លើកលែងតែមានចែងនៅទីនេះ។ វិធាននៃការសម្រុះសម្រួលដែលអាចអនុវត្តបាន គឺជាវិធាននៃការសម្រុះសម្រួលរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកhttp://www.wipo.int/amc/en/mediation/rules ហើយរាល់ការធ្វើអាជ្ញាកណ្តាលណាមួយ នឹងត្រូវធ្វើឡើងស្របតាមវិធានអាជ្ញាកណ្តាលរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពី ច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ។

**សម្ភារៈរបស់ភាគីទីបី៖** អ្នកប្រើប្រាស់ ដែលមានបំណងប្រើប្រាស់ ព័ត៌មានក្នុងឯកសារនេះ ដែល ជាកម្មសិទ្ធិរបស់ភាគីទីបី ដូចជា តារាង តួលេខ ឬរូបភាព មានទំនួលខុសត្រូវក្នុងការកំណត់លើតម្រូវការនៃការស្នើសុំ ការអនុញ្ញាត និងសម្រាប់ការទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិក្នុងការប្រើប្រាស់ឡើងវិញនៃព័ត៌មានទាំងនេះ។ ហានិភ័យនៃការទាមទារដែលបណ្តាលមកពីការរំលោភលើសមាសធាតុដែលជាកម្មសិទ្ធិរបស់ភាគីទីបីនៅក្នុងឯកសារនេះ គឺស្ថិតនៅក្រោមទំនួលខុសត្រូវរបស់អ្នកប្រើប្រាស់ប៉ុណ្ណោះ។

**ការលក់ សិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណ៖** ការបោះពុម្ពផ្សាយរបស់អង្គការ FAO មាននៅលើគេហទំព័រ (www.fao.org/publications) ហើយអាចរកជាវបានតាមរយៈ publications-sales@fao.org។ សំណើរសម្រាប់ប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម តម្រូវឱ្យមានការស្នើសុំតាមរយៈ៖ www.fao.org/contact-us/licence-request ។ សំណួរទាក់ទងនឹងសិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណគួរធ្វើឡើងតាមរយៈសារអេឡិចត្រូនិចទៅកាន់ ៖ copyright@fao.org ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំបច្ចេកទេសស្តីពី ការពង្រឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ ត្រូវបានរៀបរៀងដោយក្រុមមួយដែលដឹកនាំដោយ James Mayers នៃវិទ្យាស្ថានបរិស្ថាន និងអភិវឌ្ឍន៍អន្តរជាតិ (IIED) ដោយមានការគាំទ្រពី Francesca Romano មកពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

ឯកសារណែនាំនេះត្រូវបានព្រាងដោយ James Mayers, Elaine Morrison, Leianne Rolington, Kate Studd និង Susanne Turrall។

អត្ថបទនេះបានទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីមតិយោបល់ និងការរួមចំណែកពីសំណាក់អ្នកដែលបានចូលរួមសិក្ខាសាលាដើម្បីពិភាក្សាសេចក្តីព្រាងលើកដំបូង នៅខែឧសភា ឆ្នាំ២០១១ និងបានផ្តល់យោបល់លើសេចក្តីព្រាងដែលបានកែសម្រួលនៅឆ្នាំ២០១២ ពី Tom Blomley, Janette Bulkan, Jane Carter, Ronnie De Camino, Eva Muller, Isilda Nhantunmbo, Francesca Romano, Ken Rosenbaum, Patrice Talla, Godber Tumushable, Sanjay Upadhyay និង David Young។ នៅមានមតិសំណើដ៏មានសារប្រយោជន៍ និងការពិនិត្យពេញលេញពីសំណាក់ Simon Anstey, Juergen Blaser, Irina Buttoud Kouplevatskaya, Nora Heil, Robert Kafakoma, Fred Kafeero, Megan MacInnes, Duncan Macqueen, Jasper Makala, Elisa Manukjan, Ewald Rametsteiner, Olivia Rickenbach, Matthias Schoererer និង Bright Sibale។ Anna Barnett បានធ្វើការកែសម្រួល ចំណែកឯ Luca Feliziani បានរៀបចំរចនាទម្រង់ចុងក្រោយនៃឯកសារនេះ។

អង្គការ FAO សូមថ្លែងអំណរគុណចំពោះសហព័ន្ធស្បៀង និងកសិកម្ម និងការការពារអ្នកប្រើប្រាស់នៃប្រទេសអាល្លឺម៉ង់ ដែលបានផ្តល់មូលនិធិសម្រាប់ការបង្កើត និងការរៀបចំឯកសារណែនាំបច្ចេកទេសនេះ។ គំនិតផ្តួចផ្តើមនេះក៏បានទទួលការគាំទ្រ និងគំនិតរបស់អ្នកចូលរួមយ៉ាងច្រើននៅក្នុងក្រុមសិក្សា អភិបាលកិច្ច ព្រៃឈើ ដែលសម្របសម្រួលដោយ IIED និងទទួលមូលនិធិមួយផ្នែកពីគណៈកម្មការអឺរ៉ុប និងក្រសួងអភិវឌ្ឍន៍អន្តរជាតិ ចក្រភពអង់គ្លេសផងដែរ។

# បុព្វកថា

សេចក្ដីសម្រេចអំពីសិទ្ធិកាន់កាប់ធនធាន ឬនរណាអាចប្រើធនធានអ្វីខ្លះនៃដីធ្លីសម្រាប់រយៈពេលប៉ុន្មាន និងក្នុងលក្ខខណ្ឌណាខ្លះ ទាំងអស់នេះសុទ្ធសឹងជាកត្តាសំខាន់បំផុតសម្រាប់ព្រៃឈើ និងការចិញ្ចឹមជីវិតក្នុងបរិបទជាច្រើន។ ខណៈប្រព័ន្ធកាន់កាប់ដីធ្លីប្រឈមមុខកាន់តែខ្លាំងទៅនឹងសម្ពាធនៃកំណើនប្រជាជន ដែលតម្រូវឱ្យមានសន្តិសុខស្បៀង ភាពសិករិចរិលនៃបរិស្ថាន និងការប្រែប្រួលអាកាសធាតុដែលនាំឱ្យបរិមាណដី និងព្រៃឈើមានការថយចុះ ដូច្នេះ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លីកាន់តែមានសារសំខាន់ថែមទៀតក្នុងការកំណត់អំពីការអាចទទួលបានសិទ្ធិប្រើប្រាស់ គ្រប់គ្រងដីធ្លី និងព្រៃឈើ ហើយនិងការទទួលខុសត្រូវពាក់ព័ន្ធផ្សេងៗរបស់ប្រជាជន និងដោយរបៀបណា។

ដោយទទួលស្គាល់តម្រូវការកើនឡើងក្នុងការជួយដោះស្រាយបញ្ហាប្រឈមទាំងនេះ ជាពិសេស ពីភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន អង្គការ FAO បានផ្ដួចផ្ដើមឱ្យមានដំណើរការភាគីពាក់ព័ន្ធចម្រុះមួយ ដែលបានបញ្ចប់កាលពីខែឧសភា ឆ្នាំ ២០១២ ដោយគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក ផ្ដល់ការឯកភាពលើគោលការណ៍ណែនាំស្ម័គ្រចិត្ត ស្ដីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ ដីធ្លី ជលផល និងព្រៃឈើនៅក្នុងបរិបទនៃ សន្តិសុខស្បៀងជាតិ ('គោលការណ៍ណែនាំ')។ ដោយផ្អែកលើគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងមុខងារគ្រឹះនៃដីធ្លីនៅក្នុងការចិញ្ចឹមជីវិតរបស់ប្រជាជន និងភាពធន់នឹងបរិស្ថាន គោលការណ៍ណែនាំនេះមានបំណងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកល និងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រដោយលើកកម្ពស់សិទ្ធិកាន់កាប់ដីធ្លីមានសុវត្ថិភាព និងលទ្ធភាពទាញផលពីដីធ្លី ជលផល និងព្រៃឈើ ប្រកបដោយសមធម៌។

ដោយមានការលើកទឹកចិត្តពីគោលការណ៍ណែនាំទាំងនេះ និងដោយទទួលស្គាល់ការកាន់កាប់ព្រៃឈើថា ជាផ្នែកមួយដ៏សំខាន់នៃបញ្ហាប្រឈម ឯកសារណែនាំដែលផ្អែកលើការអនុវត្តជាក់ស្ដែងស្ដីពីការកែលម្អអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ គឺជាឯកសារសម្រាប់លោកអ្នក ប្រសិនបើលោកអ្នកចង់ឆ្លើយតបទៅនឹងបញ្ហាប្រឈមនោះ។ ឯកសារនេះជាឯកសារសម្រាប់លោកអ្នកទាំងឡាយណាដែលចង់ព្យាយាមកែលម្អអភិបាលកិច្ចលើការកាន់កាប់ព្រៃឈើ ហើយវាជួយលោកអ្នកក្នុងការចាត់វិធានការលើទិដ្ឋភាពបួនផ្នែកសំខាន់ៗពោលគឺការយល់ដឹង ការចាត់តាំង ការចូលរួម និងការធានា ដើម្បីលើកកម្ពស់ការសម្រេចចិត្តចំពោះទំនិញ និងសេវាព្រៃឈើ។ ឯកសារនេះចាប់ផ្ដើម ដោយការរំលេចចេញនូវឱកាស និងបញ្ហាប្រឈមសំខាន់ៗមួយចំនួននៅក្នុងអភិបាលកិច្ចបច្ចុប្បន្ន រួចនាំលោកអ្នកទៅកាន់ព័ត៌មានបន្ថែមសមស្របទៅនឹងរបៀបដែលលោកអ្នកកំណត់អត្តសញ្ញាណខ្លួនឯង ថាជាភាគីពាក់ព័ន្ធម្នាក់ ហើយថាតើលោកអ្នកប្រឈមមុខទៅនឹងឱកាស ឬបញ្ហាប្រឈមប្រភេទណា។ បន្ទាប់មកឯកសារនេះលាតត្រដាងសម្ភារឧបទេស មានឧបករណ៍ចំនួន៨៦ ដែលពិពណ៌នាក្នុងទម្រង់សង្ខេប និងឧបករណ៍គន្លឹះសំខាន់ចំនួន៩ដែលត្រូវបានពន្យល់ពិស្ដារ។ ឧបករណ៍ទាំងនេះត្រូវបានដាក់ឈ្មោះអំពីភាពសមស្របរបស់វានៅក្នុងបរិបទអភិបាលកិច្ចផ្សេងគ្នា និងបរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ក្នុងការប្រើប្រាស់ឧបករណ៍ទាំងនោះ។ ជាមួយគ្នានេះ ក៏មានសទ្ទានុក្រម និងគន្ថនិទ្ទេស ដែលមានទំនាក់ទំនងជាមួយគេហទំព័រទូលំទូលាយសម្រាប់បំផុសគំនិតបន្ថែមទៀតផងដែរ។

**Maria Helena Semedo**
អគ្គនាយករង
នាយកដ្ឋានគ្រប់គ្រងធនធានធម្មជាតិ
និងបរិស្ថានរបស់អង្គការ FAO

**Camilla Toulmin**
នាយក
IIED

# ពាក្យកាត់

| | |
|---|---|
| **API** | ការទទួលបានព័ត៌មានសាធារណៈ |
| **CEDAW** | អនុសញ្ញាស្តីពីការលុប បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ |
| **CRC** | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| **CSC** | ប័ណ្ណពិន្ទុសហគមន៍ |
| **EITI** | គំនិតផ្តួចផ្តើមស្តីពីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម |
| **FAO** | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| **FLEGT** | ការអនុវត្តច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម |
| **FSC** | ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ |
| **FPIC** | ការយល់ព្រមដោយពេញចិត្ត និងប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន) |
| **GIS** | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| **GPS** | ប្រព័ន្ធកំណត់ទីតាំងសាកល |
| **HCV** | តម្លៃអភិរក្សខ្ពស់ |
| **ICCPR** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| **ICERD** | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| **ICESCR** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| **ICT** | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| **IIED** | វិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាន និងអភិវឌ្ឍន៍ |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **LAS** | ប្រព័ន្ធធានានីត្យានុកូលភាព |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **PCA** | ការវិភាគអំណាច និងការផ្លាស់ប្តូរ |
| **PES** | បណ្តាញភាពក្រីក្រ និងបរិស្ថាន |
| **PM&E** | ការតាមដាននិងការវាយតម្លៃដែលមានការចូលរួម |
| **PROFOR** | កម្មវិធីស្តីពីព្រៃឈើ |
| **RAFT** | ការសិក្សាវាយតម្លៃរហ័សអំពីការប្រតិបត្តិ ប្រព័ន្ធ និងបច្ចេកវិទ្យាកសិរុក្ខកម្ម |
| **RaTA** | ការសិក្សាវាយតម្លៃរហ័សលើសិទ្ធិកាន់កាប់ដីធ្លី |
| **REDD** | ការបំភាយឧស្ម័នដែលបានកាត់បន្ថយពីការកាប់ឈើ និងការសឹករេចរឹលនៃព្រៃឈើ |
| **REDD+** | ការបំភាយឧស្ម័នដែលបានកាត់បន្ថយពីការកាប់ឈើនិងការសឹករេចរឹលនៃព្រៃឈើ ការអភិរក្ស ការគ្រប់គ្រងព្រៃឈើ និងការលើកកម្ពស់សន្និធិកាបូន |

| | |
|---|---|
| **RTI** | សិទ្ធិទទួលបានព័ត៌មាន |
| **SFM** | ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព |
| **SWOT** | ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង |
| **TI** | អង្គការតម្លាភាពអន្តរជាតិ |
| **UDHR** | សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស |
| **UNDRIP UN** | សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច |
| **UNECE** | គណៈកម្មការសេដ្ឋកិច្ចសហប្រជាតិសម្រាប់តំបន់អឺរ៉ុប |
| **VPA** | កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត |

# មាតិកា


សេចក្តីថ្លែងអំណរគុណ . . . . . . . . . . . . . . . . . IV
បុព្វកថា . . . . . . . . . . . . . . . . . . . . V
ពាក្យកាត់ . . . . . . . . . . . . . . . . . . . . VI


## សេចក្តីផ្តើម


១. មូលហេតុដែលអ្នកត្រូវការសៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ . . . . . . . 1
២. ហេតុអ្វីបានជាសិទ្ធិកាន់កាប់ និងអភិបាលកិច្ចមានសារសំខាន់យ៉ាងខ្លាំង? . . . . . . . 3
៣. កំណត់ចំណុចចាប់ផ្តើម និងការកំណត់គោលបំណងរបស់លោកអ្នក . . . . . . . 4
៤. ការប្រើសម្ភារឧបទេសដើម្បីជួយឱ្យសម្រេចគោលដៅរបស់លោកអ្នក . . . . . . . 10


## A. ឧបករណ៍សម្រាប់ការយល់ដឹង


ហេតុអ្វីបានជាការយល់ដឹងមានសារសំខាន់សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ . . . . . 17
ពិនិត្យមើល និងការអនុវត្តឧបករណ៍នានានៅក្នុងផ្នែកនេះ . . . . . . . . . . 18
ឧបករណ៍និងវិធីសាស្រ្តនានាសម្រាប់យល់ដឹង . . . . . . . . . . . . 19

**A1.** ការវាយតម្លៃមូលដ្ឋានធនធានជីវសាស្រ្ត . . . . . . . . . . 19

A1.1 សារពើភណ្ឌព្រៃឈើជាតិ និងការវាយតម្លៃធនធានព្រៃឈើ . . . . . . . 20
A1.2 ការវាស់ស្ទង់និងការតាមដានព្រៃឈើពីសំណាក់សហគមន៍គិតទាំងសន្និធិកាបូនផងដែរ . . 20
A1.3 ការវាយតម្លៃសន្និធិកាបូន . . . . . . . . . . . . 21
A1.4 ការសិក្សាវាយតម្លៃរហ័សអំពីការប្រតិបត្តិ ប្រព័ន្ធ និងបច្ចេកវិទ្យាកសិរុក្ខកម្ម . . . . 22
A1.5 កំណត់កន្លែងដែលមានតម្លៃអភិរក្សខ្ពស់. . . . . . . . . . 22
A1.6 ការវាយតម្លៃទិដ្ឋភាពតំបន់ទេសភាពចម្រុះ . . . . . . . . . 23
A1.7 បញ្ជីជីវចម្រុះរបស់ប្រជាជន . . . . . . . . . . . 23
A1.8 ការវាយតម្លៃការប្រែប្រួលគម្របព្រៃលើមូលដ្ឋានដើមឈើ . . . . . . . 24

**A2.** ការយល់ដឹងមុខងារនៃធនធាន និងសេវាកម្មព្រៃឈើក្នុងការទ្រទ្រង់ការចិញ្ចឹមជីវិត. . . . . 24

A2.1 សម្ភារឧបទេសអំពីទំនាក់ទំនងរវាងភាពក្រីក្រ និងព្រៃឈើ . . . . . . . 25
A2.2 ការវិភាគដែលមានការចូលរួមអំពីភាពក្រីក្រ ការចិញ្ចឹមជីវិត និងការប្រែប្រួលបរិស្ថាន . 25
A2.3 ការណែនាំអំពីការវាយតម្លៃជាមូលដ្ឋានសម្រាប់សុខុមាលភាពរបស់មនុស្ស . . . . 26
A2.4 កម្រងសំណួរគំរូដើមអំពីបណ្តាញភាពក្រីក្រ និងបរិស្ថាន . . . . . . 26

**A3.** ការទទួលស្គាល់ការចាត់ចែងបច្ចុប្បន្ន និងការចាត់ចែងកន្លងមក និងប្រកួតប្រជែងទាមទារសិទ្ធិកាន់កាប់ព្រៃឈើ . . . . . . . . . . . . . . 27

A3.1 ការវាយតម្លៃរហ័សចំពោះសិទ្ធិកាន់កាប់ដីធ្លី . . . . . . . . . 27
A3.2 ការកសាងផែនទីដែលមានការចូលរួម . . . . . . . . . . 28
A3.3 ការវិភាគទំនាស់តាមកាលកំណត់ និងកិច្ចសម្ភាសន៍ដែលបានព្រាងសំណួរ . . . . 28

**A4.** ការគូសផែនទីបរិបទនយោបាយ និងស្ថាប័ន . . . . . . . . . . . . . . 29
A4.1 ការវិភាគគោលនយោបាយ និងការវិភាគផ្លូវច្បាប់ . . . . . . . . . 30
A4.2 ការវិភាគកម្លាំងជំរុញ . . . . . . . . . . . . . . . . . . 30
A4.3 ការរៀបចំផែនទីស្ថាប័នភាគីពាក់ព័ន្ធក្នុងស្រុក . . . . . . . . . 31
A4.4 ការវិភាគអំពីកត្តាជំរុញឱ្យមានការផ្លាស់ប្តូរ . . . . . . . . . . 31
A4.5 ការវិភាគអំណាច និងការផ្លាស់ប្តូរ . . . . . . . . . . . . . . 32
A4.6 ការគូសផែនទីឥទ្ធិពលរបស់ភាគីពាក់ព័ន្ធ និងការវិភាគអំណាច . . . . . 32
A4.7 អក្សរ R ទាំងបួន . . . . . . . . . . . . . . . . . . . 33
A4.8 ការវិភាគសាវតារ . . . . . . . . . . . . . . . . . . . 33
A4.9 ការសម្រេចបាននូវអភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ . . . 34
A4.10 ឧបករណ៍វាយតម្លៃអភិបាលកិច្ច . . . . . . . . . . . . . . . 34
**A5.** ការកំណត់កាលានុវត្តភាពសម្រាប់ផ្លាស់ប្តូរ . . . . . . . . . . . . . 35
A5.1 ការវិភាគសេណារីយ៉ូ និងការកសាងផែនការ . . . . . . . . . . . 35
A5.2 ការវិភាគដើមឈើបញ្ហា . . . . . . . . . . . . . . . . . 36
A5.3 ការវិភាគទ្រឹស្តីនៃការផ្លាស់ប្តូរ . . . . . . . . . . . . . . . 37
A5.4 ការកសាងផែនការដែលផ្តោតលើសហគមន៍ . . . . . . . . . . . 37

## B. ឧបករណ៍សម្រាប់ការចងក្រង

ហេតុអ្វីបានជាការចងក្រងមានសារសំខាន់ចំពោះអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ . . . . . . 43
ការរកមើល និងការអនុវត្តឧបករណ៍នៅក្នុងផ្នែកនេះ . . . . . . . . . . . . . 44
**B1.** ការពង្រឹងសមត្ថភាពសហគមន៍ដើម្បីចូលរួម . . . . . . . . . . . . . 45
B1.1 ការចងក្រងក្រុមអ្នកប្រើប្រាស់ធនធានព្រៃឈើដើម្បីចូលរួម . . . . . . . 46
B1.2 ការកសាងជំនាញតស៊ូមតិ ការបញ្ចុះបញ្ចូល និងការចរចា សម្រាប់ថ្នាក់ដឹកនាំ ជនជាតិដើមភាគតិចក្នុងការចូលរួមជាមួយ REDD+ . . . . . . . . . . . 46
B1.3 សម្ភារឧបទេសសម្រាប់អ្នកចងក្រងសហគមន៍ . . . . . . . . . . . . 47
B1.4 ចាប់ពីក្រោមឡើងលើ៖ការពង្រឹងសមត្ថភាពស្ថាប័នតាមរយៈស្វ័យវាយតម្លៃដែលមានការតម្រង់ទិស 47
B1.5 ការវាយតម្លៃអភិបាលកិច្ចដោយមានការចូលរួម . . . . . . . . . . . 48
B1.6 ការគ្រប់គ្រងទំនាស់ធនធានព្រៃឈើនៅតាមសហគមន៍ . . . . . . . . . 48
B1.7 ការប្រាស្រ័យទាក់ទងជាមួយស្ថាប័ន ដែលជាមជ្ឈមណ្ឌលសម្របសម្រួលថ្នាក់ជាតិ . . . 48
B1.8 ការណែនាំដើម្បីរៀបចំផែនការតស៊ូមតិ . . . . . . . . . . . . . 49
**B2.** ការកសាងវិស័យសាធារណៈដែលមានការឆ្លើយតប . . . . . . . . . . . 49
B2.1 ការសម្រួលដល់ការផ្លាស់ប្តូរផ្នែកអង្គការចាត់តាំង និងផ្នែកស្ថាប័ន . . . . . . 50
B2.2 ការសាកសួរបែបទទួលស្គាល់តម្លៃ . . . . . . . . . . . . . . . 51
B2.3 ដំណើរការគម្រោងសាកល្បង . . . . . . . . . . . . . . . . 51
B2.4 ការបង្វឹកវិធីសាស្ត្រដែលមានការចូលរួមដល់មន្ត្រីរដ្ឋាភិបាលក្នុងពេលបំពេញការងារ . . 52
B2.5 ប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកដើម្បីធានាដល់សិទ្ធិព្រៃឈើ . . . . . . . 52

**B3.** ការរៀបចំវិស័យឯកជនឱ្យដំណើរការត្រឹមត្រូវ និងប្រកបដោយបរិយាប័ន្ន . . . . . . . . 53
B3.1 ការវិភាគទីផ្សារ និងការអភិវឌ្ឍសម្រាប់សហគ្រាសដែលផ្ដោតលើឈើសហគមន៍ និងសហគ្រាសផលិតផលឈើ . . . . . . . . . . . . . . . 54
B3.2 ការពង្រឹងអភិបាលកិច្ច និងរចនាសម្ព័ន្ធសហគ្រាសសហគមន៍ . . . . . . . . . 54
B3.3 ការវិនិយោគលើសហគ្រាសព្រៃឈើប្រកបដោយនិរន្តរភាព . . . . . . . . 55
B3.4 ភាពជាដៃគូរវាងក្រុមហ៊ុន និងសហគមន៍ព្រៃឈើ . . . . . . . . . 55
B3.5 ស្តង់ដារពាណិជ្ជកម្មត្រឹមត្រូវសម្រាប់ឈើដែលមានប្រភពចេញពីផលិតករខ្នាតតូច និងផលិតករនៅសហគមន៍ . . . . . . . . . . . . . 56
**B4.** ការកសាងឬការពង្រឹងសម្ព័ន្ធភាព បណ្ដាញ និងសហព័ន្ធ . . . . . . . . 56
B4.1 ការគ្រប់គ្រងក្រុមរៀនសូត្របែបមិត្តអប់រំមិត្តដើម្បីពង្រឹងអភិបាលកិច្ចព្រៃឈើ . . . . 57
B4.2 បណ្ដាញសង្គម៖ ៣៨ ដីក្រេនិងកត្តាផ្សេងទៀត . . . . . . . . . 58
B4.3 ការកសាងសម្ព័ន្ធភាព និងសម្ព័ន្ធដើម្បីតស៊ូមតិ . . . . . . . . . 58

## C. ឧបករណ៍សម្រាប់ការចូលរួម

ហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់ . . . . . . . . . . . . . 61
សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ . . . . . . . . . . . . 61
ការអាន និងការប្រើឧបករណ៍ក្នុងផ្នែកនេះ . . . . . . . . . . . . . 62
**C1.** គាំទ្រសង្គមស៊ីវិលក្នុងការប្រមូលភស្តុតាង តស៊ូមតិ ធ្វើយុទ្ធនាការ និងចរចា . . 63
C1.1 ឧបករណ៍តស៊ូមតិ និងគោលការណ៍ណែនាំ . . . . . . . . . . 63
C1.2 ការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព . . . . . . . . . . 64
C1.3 ការយល់ព្រម ដោយសេរី និងជូនដំណឹងជាមុន– តាំងពីគោលការណ៍រហូតដល់ការអនុវត្ត . 64
C1.4 គាំទ្រសហគមន៍ដើម្បីចរចា និងគ្រប់គ្រងផលប៉ះពាល់ និងកិច្ចព្រមព្រៀងស្តីពីអត្ថប្រយោជន៍ជាមួយក្រុមហ៊ុន . . . . . . . . . . . . . 65
C1.5 បណ្ដាញសារព័ត៌មាន និងយុទ្ធវិធីបញ្ចុះបញ្ចូលសម្រាប់ក្រុមមូលដ្ឋាន . . . . . 66
C1.6 ការប្រើធនធានមហាជន . . . . . . . . . . . . . . 66
C1.7 Ushahidi: សូហ្វវែរបើកទូលាយឥតបង់ប្រាក់ ( open-source software ) និងការគូសផែនទីក្នុងលក្ខណៈសហការ. . . . . . . . . . . . . 67
C1.8 វិទ្យុសហគមន៍ . . . . . . . . . . . . . . . . 67
C1.9 ការចូលរួមតាមរយៈរូបថត និងខ្សែវីដេអូ. . . . . . . . . . . 68
C1.10 ការស្រាវជ្រាវគោលនយោបាយដើម្បីឱ្យមានការផ្លាស់ប្ដូរ. . . . . . . . . 69
**C2.** ដំណើរការពិគ្រោះយោបល់ ការចូលរួម និងកិច្ចដំណើរការពហុភាគីពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព . 69
C2.1 ពីរ៉ាមីត៖ ឧបករណ៍ស្ទង់ និងធ្វើផែនការសម្រាប់អភិបាលកិច្ចព្រៃឈើ . . . . . . 70
C2.2 ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងកម្មវិធីព្រៃឈើជាតិ . . . . . . . . 71
C2.3 ផែនទីបង្ហាញផ្លូវសម្រាប់គ្រប់គ្រងកិច្ចដំណើរការសន្ទនាបែបចូលរួម . . . . . . 71
C2.4 ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដោយអ្នកដទៃ . . . . . . . . 72
C2.5 Pathfinder: ដឹកនាំក្រុមការងារពហុភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍស្តង់ដារព្រៃឈើ . . . . 72

C2.6 ការផ្តល់វិញ្ញាបនបត្រព្រៃឈើ . . . . . . . . . . . . . . . 73

## D. ឧបករណ៍សម្រាប់ធានា

ហេតុអ្វីបានជាការធានាមានសារសំខាន់សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ . . . . . . 77
ការអាន និងការប្រើការណែនាំក្នុងផ្នែកនេះ . . . . . . . . . . . . . . . . . . 78
**D1.** ការតាមដាន និងការវាយតម្លៃ គណនេយ្យភាព និងតម្លាភាព . . . . . . . . . 78
D1.1 ប័ណ្ណរាយការណ៍ពលរដ្ឋ . . . . . . . . . . . . . . 79
D1.2 ប័ណ្ណពិន្ទុសហគមន៍ . . . . . . . . . . . . . . . 80
D1.3 ប័ណ្ណរាយការណ៍តម្លាភាពវិស័យព្រៃឈើ . . . . . . . . . . 80
D1.4 ក្របខ័ណ្ឌសម្រាប់វាយតម្លៃ និងតាមដានអភិបាលកិច្ចព្រៃឈើ . . . . . . 81
D1.5 ការតាមដានគោលនយោបាយរដ្ឋាភិបាល៖ ក្បួនណែនាំមួយសម្រាប់អង្គការសង្គមស៊ីវិល . 81
D1.6 ការទទួលបានព័ត៌មានសាធារណៈ. . . . . . . . . . . . . . 82
D1.7 ការពិនិត្យពិច័យនីតិកម្មដោយសហគមន៍ . . . . . . . . . . 83
D1.8 សកម្មភាពពលរដ្ឋដើម្បីកាត់បន្ថយអំពើពុករលួយព្រៃឈើ . . . . . . . 83
D1.9 គេហទំព័រប្រឆាំងអំពើពុករលួយៈ ចូរផ្តិតកញ្ចែរបស់អ្នក . . . . . . . 84
D1.10 គណៈវិនិច្ឆ័យរបស់ពលរដ្ឋ . . . . . . . . . . . . . . 84
**D2.** យន្តការសម្រាប់តវ៉ាដោះស្រាយវិវាទ និងការទទួលបានការគាំទ្រពីជំនួយការមេធាវី ( Paralegal Support ) 85
D2.1 បង្កើតនីតិវិធីប្តឹងតវ៉ា . . . . . . . . . . . . . . . 86
D2.2 ពង្រឹងសមត្ថភាពមេធាវីនៅក្នុងសហគមន៍ព្រៃឈើ . . . . . . . . . 86
D2.3 ជំរំអក្ខរកម្មច្បាប់ . . . . . . . . . . . . . . . . 87
D2.4 សវនាការសាធារណៈ និងការធ្វើសវនកម្ម . . . . . . . . . . 87
**D3.** ឧបាស្រ័យទៅកាន់តុលាការ កម្រិតខ្ពស់នៃរដ្ឋាភិបាល ឬគោលនយោបាយ និងមជ្ឈោបាយអន្តរជាតិ . 88
D3.1 ធានាឱ្យបានសិទ្ធិរបស់ស្ត្រី ដោយប្រើប្រព័ន្ធសិទ្ធិមនុស្សនៅអាហ្វ្រិក . . . . . 89
D3.2 សិទ្ធិរបស់ជនជាតិដើមភាគតិចនៅក្នុងអង្គការពលកម្មអន្តរជាតិ ( ILO ) . . . . . 89
D3.3 សិទ្ធិដឹងរបស់សាធារណជនៈ គោលការណ៍ស្តីពីច្បាប់សេរីភាពព័ត៌មាន . . . . . 90
D3.4 ប្រើយន្តការពិនិត្យមើលអនុលោមភាពនៃអនុសញ្ញាអារុស ( Aarhus Convention ) . . 90
D3.5 ការបញ្ជាក់អំពីតម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម . . . . . . . 91
D3.6 កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត ( VPAs ) ស្តីពីអភិបាលកិច្ចព្រៃឈើ . . . 92

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ឧបករណ៍ស៊ីជម្រៅ . . . . . . . . . . . . . . . 97
XL A3.1 ការសិក្សាវាយតម្លៃរហ័សអំពីសិទ្ធិកាន់កាប់ដីធ្លី ( RaTA ). . . . . . . . 97
XL A3.2 ការគូសផែនទីដែលមានការចូលរួមនៃសិទ្ធិកាន់កាប់ព្រៃឈើ . . . . . . . 99
XL A4.6 ការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធ . . . . . . . . . . . 101
XL B1.1 ការរៀបចំក្រុមអ្នកប្រើប្រាស់ព្រៃឈើដើម្បីចូលរួម . . . . . . . . 104
XL B2.4 ការផ្តល់ប្រឹក្សាធ្វើការបណ្តើរអនុវត្តបណ្តើរនូវវិធីសាស្ត្រ ដែលមានការចូលរួមដល់មន្ត្រីរដ្ឋាភិបាល 106

XL C1.3 ការធានាឱ្យមានការយល់ព្រម ជាមុនដោយស្ម័គ្រចិត្ត (FPIC) . . . . . . 107
XL C1.5 ប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធវិធីបញ្ចូលសម្រាប់ក្រុមនៅមូលដ្ឋាន . . . . . 110
XL D1.3 បណ្ណាយការណ៍អំពីតម្លាភាពលើវិស័យព្រៃឈើ . . . . . . . . 112
XL D1.6 ការទទួលបានព័ត៌មានសាធារណៈ (API) . . . . . . . . . 114
ឧបសម្ព័ន្ធ២៖ សន្ទានុក្រម . . . . . . . . . . . . . . . . 116
ឧបសម្ព័ន្ធ៣៖ គន្ថនិទ្ទេស . . . . . . . . . . . . . . . . 122

# សេចក្តីផ្តើម

## ១. មូលហេតុដែលអ្នកត្រូវការសៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ

### សៀវភៅនេះនិយាយអំពីអ្វី

ព្រៃឈើជួយឱ្យយើងក្នុងការដកដង្ហើម ហើយព្រៃឈើផ្តល់ឱ្យយើងនូវផ្ទះសម្បែង អាហារ និងថាមពល។ លើសពីនេះទៅទៀត សុខុមាលភាពរបស់មនុស្ស និងសុខភាពរបស់ភពផែនដីទាំងមូលរបស់យើង អាស្រ័យលើថាតើ យើងដាំព្រៃឈើដែរឬទេ ហើយតើយើងដាំ និងថែទាំព្រៃឈើយ៉ាងដូចម្តេច។ ដូច្នេះអភិបាលកិច្ចព្រៃឈើ ឬអ្នកដែលត្រូវបានអនុញ្ញាតឱ្យធ្វើការសម្រេចចិត្តអំពីព្រៃឈើ និងសម្រេចយ៉ាងណានោះ គឺជាបញ្ហាស្លាប់រស់សម្រាប់មនុស្សរាប់លាននាក់នៅជុំវិញពិភពលោក ហើយពាក់ព័ន្ធយ៉ាងជ្រាលជ្រៅសម្រាប់យើងទាំងអស់គ្នា។ ប៉ុន្តែការសម្រេចចិត្តអំពីព្រៃឈើ និងដើមឈើ ច្រើនស្ថិតក្នុងការគ្រប់គ្រងមិនត្រឹមត្រូវ ឬជាការសេចក្តីសម្រេចចិត្តមិនត្រឹមត្រូវ ។ ភាគច្រើន ពឹងផ្អែកលើ 'សិទ្ធិកាន់កាប់' ពោលគឺ នរណាជាម្ចាស់ និងជាអ្នកគ្រប់គ្រងព្រៃឈើ និងដើមឈើ ។ ម្ចាស់អាចជាអ្នកទាំងឡាយណាដែលត្រូវការព្រៃឈើ និងថែទាំព្រៃឈើបានល្អ ឬអ្នកដែលធ្វើឱ្យព្រៃឈើរេចរឹលដោយមិនគិតដល់សុខុមាលភាពរបស់អ្នកដទៃ។ សរុបមកសិទ្ធិកាន់កាប់ជារឿងដែលពាក់ព័ន្ធនឹងអំណាច។ សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ មានគោលបំណងបំផុស និងផ្តល់មធ្យោបាយដល់អ្នកទាំងឡាយណាដែលមានបំណងព្យាយាមធ្វើអ្វីៗឱ្យប្រសើរឡើង ដើម្បីឱ្យការប្រើប្រាស់អំណាចប្រព្រឹត្តទៅបានល្អចំពោះព្រៃឈើ។ សៀវភៅនេះព័ណនាអំពីរបៀបអនុវត្តឧបករណ៍ជាក់ស្តែង ដើម្បីរៀបចំអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើឱ្យបានប្រសើរជាងមុន។

### តើសៀវភៅនេះសម្រាប់នរណា

ប្រសិនបើលោកអ្នកជាអ្នកបង្កើតគោលនយោបាយរបស់រដ្ឋាភិបាល ឬជាអ្នកពាក់ព័ន្ធមកពីវិស័យសាធារណៈដទៃមកពីវិស័យឯកជន ឬមកពីសង្គមស៊ីវិល ព្រួយបារម្ភអំពីអភិបាលកិច្ចព្រៃឈើ និងកំណែទម្រង់កាន់កាប់ដីធ្លី សៀវភៅណែនាំនេះត្រូវបានរៀបរៀងឡើងដោយបានគិតគូរដល់លោកអ្នក។ ប៉ុន្តែយើងសង្ឃឹមថា អ្នកដទៃអាចជ្រើសយក និងគិតថាសៀវភៅណែនាំនេះមានប្រយោជន៍ផងដែរ។ យើងកំពុងផ្តោតការយកចិត្តទុកដាក់លើអ្នកអានទូទៅ ដោយទទួលស្គាល់ថា អ្នកស្ថិតក្នុងស្ថានភាពផ្សេងគ្នា មានទស្សនៈផ្សេងគ្នាលើបញ្ហានេះ ហើយចាំបាច់ត្រូវប្រកាន់យកវិធីសាស្ត្រខុសគ្នាក្នុងការដោះស្រាយបញ្ហាទាំងនោះ។

### តើសៀវភៅណែនាំនេះអាចមានប្រយោជន៍នៅពេលណា

លោកអ្នកអាចពិនិត្យឃើញថាសៀវភៅនេះមានប្រយោជន៍ នៅពេលដែលលោកអ្នកទទួលស្គាល់ថាត្រូវមានការផ្លាស់ប្តូរជាចាំបាច់ ហើយលោកអ្នកត្រូវការជំនួយដើម្បីសម្រេចឱ្យបាននូវការផ្លាស់ប្តូរនោះ។ នៅពេលដែលការសម្រេចចិត្តអំពីព្រៃឈើត្រូវបានធ្វើដោយមនុស្សខុសជំនាញ នៅពេលដែលការសម្រេចចិត្តនោះមិនត្រឹមត្រូវ នៅពេលមានមន្ទិលអំពីដំណើរការ ឬនៅពេលមានការសម្រេចចិត្តត្រឹមត្រូវ ប៉ុន្តែពួកគេមានសមត្ថភាពតិចតួច ពោលគឺ នៅពេលនោះហើយដែលសៀវភៅណែនាំនេះអាចមានសារប្រយោជន៍។ ផ្ទុយទៅវិញ លោកអ្នកអាចត្រូវការជំនួយក្នុងការស្វែងរកវិធីដ៏ល្អបំផុត ដើម្បីឆ្លើយតបទៅនឹងឱកាសវិជ្ជមានសម្រាប់កំណែទម្រង់គោលនយោបាយ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ស្ថាប័ន។ ទាំងនេះច្រើនតែមានលក្ខណៈពិសេសចំពោះកម្មវិធីក្នុងប្រទេស និងចំពោះការផ្លាស់ប្តូរនយោបាយ ប៉ុន្តែមានគំនិតផ្តួចផ្តើមអន្តរជាតិសំខាន់ៗជាច្រើន ដែលជំរុញយ៉ាងខ្លាំងក្លាឱ្យមានកំណែទម្រង់លើអភិបាល

កិច្ចចំពោះសិទ្ធិកាន់កាប់ព្រៃឈើ។ គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ជលផល និងព្រៃឈើនៅក្នុងបរិបទនៃសន្តិសុខស្បៀងនៅថ្នាក់ជាតិ ('គោលការណ៍ណែនាំ') (2012a អង្គការ FAO - សូមមើលគន្ថនិទ្ទេសចំពោះឯកសារយោង ដែលបានប្រើក្នុងសៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ) បានផ្តល់នូវឧបករណ៍សាកលពេញលេញលើកដំបូងអំពីសិទ្ធិកាន់កាប់ និងការគ្រប់គ្រងធនធានទាំងនេះ។ ទន្ទឹមនឹងនោះដែរ បណ្តាប្រទេសផលិតឈើមួយចំនួនកំពុងបង្កើតភាពជាដៃគូជាមួយសហភាពអឺរ៉ុប ដើម្បីកែលម្អអភិបាលកិច្ចក្រោមកម្មវិធីស្តីពីការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការគ្រប់គ្រងព្រៃឈើនិងពាណិជ្ជកម្មព្រៃឈើ (FLEGT)។ មួយវិញទៀត កង្វល់ស្តីពីការប្រែប្រួលអាកាសធាតុ ក៏កំពុងនាំមកនូវកម្មវិធីកាត់បន្ថយការបំភាយឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD +) ផងដែរដែលត្រូវផ្អែកលើការកែលម្អនៅក្នុងអភិបាលកិច្ចព្រៃឈើ។ សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ មានគោលបំណងជួយដល់អ្នកដែលកំពុងព្យាយាមឆ្លើយតបទៅនឹងឱកាសទាំងនេះ។

## សៀវភៅណែនាំនេះជួយអ្វីខ្លះ

ការណែនាំដែលលើកឡើងខាងក្រោមនេះ នឹងជួយអ្នកក្នុងការកំណត់ទីតាំងចំណុចចាប់ផ្តើមរបស់អ្នក ពោលគឺគោលបំណងរបស់អ្នកក្នុងការព្យាយាមកែលម្អអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ និងកំណត់សកម្មភាពអ្វីខ្លះដែលអាចអនុវត្តជាក់ស្តែងនៅក្នុងបរិបទរបស់លោកអ្នក។ បន្ទាប់មកការណែនាំនេះក៏ជួយអ្នកក្នុងការកំណត់លំដាប់នៃសកម្មភាព ឧបករណ៍ដែលអាចអនុវត្តបាន ដែលអាចមានសារប្រយោជន៍ ហើយលោកអ្នកអាចរកឃើញចំណុចទាំងនោះនៅក្នុងសម្ភារឧបទេសជាបន្តបន្ទាប់។ សម្ភារឧបទេសនេះផ្តល់ឧបករណ៍ចំនួន៨៦ ចែកចេញជាបួនផ្នែកសំខាន់ផ្នែកនីមួយៗជា ដំណាក់កាលវដ្តសកម្មភាពកំពុងដំណើរការ និងការពិចារណាអំពីការកែលម្អអភិបាលកិច្ចព្រៃឈើ។ ឧបករណ៍ចំនួនប្រាំបួនក៏ត្រូវបានពិពណ៌នាស៊ីជម្រៅផងដែរ គោលបំណងនៃការធ្វើបែបនេះគឺដើម្បីផ្តល់សម្ភារឧបទេសចម្បងមួយដែលមានប្រយោជន៍ជាទូទៅជាមួយនឹងចំណេះធ្វើដែលមានលក្ខណៈអនុវត្តជាក់ស្តែងគ្រប់គ្រាន់ ដើម្បីឱ្យលោកអ្នកយល់ដឹងពីរបៀបប្រើឧបករណ៍នីមួយៗឱ្យមានប្រសិទ្ធភាព។ នៅចុងបញ្ចប់មានសទ្ទានុក្រមនៃពាក្យគន្លឹះសំខាន់ៗ និងគន្ថនិទ្ទេសដែលមានតំណច្បាស់លាស់ទៅគេហទំព័រនានា ដែលគេអាចរកបាននូវព័ត៌មានបន្ថែម។

## ដែនកំណត់នៃសៀវភៅណែនាំ

សៀវភៅណែនាំនេះជំរុញឲ្យលោកអ្នកចាប់ផ្តើមធ្វើសកម្មភាព និងមានចម្ងល់ជាច្រើន ប៉ុន្តែលោកអ្នកនឹងមិនអាចរកចម្លើយទាំងអស់នៅក្នុងសៀវភៅណែនាំនេះទេ។ ឯកសារនេះមិនផ្តល់នូវការពិនិត្យពេញលេញអំពីបញ្ហា កាន់កាប់ និងអភិបាលកិច្ចព្រៃឈើឡើយ។ ការពិនិត្យមើលឡើងវិញយ៉ាងស៊ីជម្រៅ លើបញ្ហាទាំងនេះ ដែលពិពណ៌នាអំពីសារសំខាន់នៃការរៀបចំអភិបាលកិច្ចល្អត្រូវបានធ្វើឡើងដោយអ្នកដទៃ ចំនែកឯផ្នែក "ទូទៅ" នៃគន្ថនិទ្ទេសអាចចង្អុលបង្ហាញឱ្យអ្នកបានដឹងអំពីសារសំខាន់ទាំងនេះមួយចំនួន។ ហើយសៀវភៅណែនាំនេះក៏ពុំមែនជាសៀវភៅដែលបង្ហាញជំហានបន្តបន្ទាប់ដែលត្រូវអនុវត្តនោះដែរ។ ការព្យាយាមភាគច្រើនក្នុងការពង្រឹងអភិបាលកិច្ចមានលក្ខណៈប្រឬកប្រចប់ ហើយចំណុចជាច្រើនមានលក្ខណៈស្មុគស្មាញ និងពិបាក។ ក្នុងសភាពជាក់ស្តែងដំណាក់កាលនានានៃការវិភាគ ការតាក់តែង សកម្មភាព និងការតាមដានដែលមានរៀបរាប់ក្នុង "សៀវភៅសិក្សា" កម្រអនុវត្តបានណាស់។ ហើយសៀវភៅនេះក៏គ្មានចេតនាគ្របដណ្តប់រាល់ឧបករណ៍ និងវិធីសាស្ត្រដែលអាចធ្វើបានសព្វគ្រប់នោះទេ។ ឯកសារណែនាំនេះមានគោលបំណងផ្តល់នូវឧបករណ៍ និងប្រភពទាក់ទាញចំពោះស្ថានភាពទូទៅមួយចំនួន សំដៅបំផុសគំនិតជាជាងការដាក់ចេញជាទ្រង់ទ្រាយតឹងរឹងនិងបង្កលក្ខណៈឱ្យលោកអ្នកជ្រើសឧបករណ៍និងវិធីសាស្ត្រសាកល្បងអភិវឌ្ឍបន្ថែម និងរួមបញ្ចូលគ្នានូវវិធីថ្មីៗ។ លោក អ្នកមួយចំនួនមានបទពិសោធន៍ច្រើនក្នុងការប្រើប្រាស់ឧបករណ៍មួយចំនួន ជាងអ្វីដែលសៀវភៅណែនាំនេះអាចផ្តល់ឱ្យ ប៉ុន្តែលោកអ្នកប្រហែលជាមានចំណាប់អារម្មណ៍ចំពោះឧបករណ៍ថ្មីមួយចំនួន។

# ២. ហេតុអ្វីបានជាសិទ្ធិកាន់កាប់ និងអភិបាលកិច្ចមានសារសំខាន់យ៉ាងខ្លាំង ?

## សិទ្ធិកាន់កាប់ជាឫសគល់នៃបញ្ហានិងក្ដីសង្ឃឹមនៃព្រៃឈើទៅថ្ងៃអនាគត

នៅក្នុងបរិបទជាច្រើន ការសម្រេចចិត្តអំពីសិទ្ធិកាន់កាប់ធនធាន - ឬនរណាអាចប្រើប្រាស់ធនធានអ្វីខ្លះ ដែលមានលើដីសម្រាប់រយៈពេលយូរប៉ុណ្ណា និងនៅក្រោមលក្ខខណ្ឌអ្វីខ្លះ - ជាចំណុចដែលមានសារសំខាន់បំផុតក្នុងចំណោមបណ្ដាចំណុចសំខាន់ៗចំពោះព្រៃឈើ និងជីវភាពរស់នៅ។ សិទ្ធិកាន់កាប់ព្រៃឈើនិយាយអំពីលទ្ធភាពចូលទៅក្នុងព្រៃ និងសិទ្ធិប្រើប្រាស់ ឬដកហូតធនធានព្រៃឈើ ការសម្រេចចិត្តអំពីលំនាំនៃការប្រើប្រាស់ ឬការផ្លាស់ប្ដូរក្នុងការសម្រេចចិត្តថានរណាខ្លះអាចប្រើប្រាស់ និងត្រូវបានរារាំងមិនឱ្យប្រើប្រាស់ និងផ្ទេរលក់ ឬជួលធនធានទាំងនេះ។ ការផ្លាស់ប្ដូរការកាន់កាប់ព្រៃឈើនាំទៅដល់ការផ្លាស់ប្ដូរក្នុងការបែងចែកសិទ្ធិក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងគ្នា។ នៅពេលដែលប្រព័ន្ធកាន់កាប់កាន់តែប្រឈមមុខនឹងភាពតានតឹងដោយកំណើនប្រជាជនដែលតម្រូវឱ្យមានសន្តិសុខស្បៀង ជាមួយនឹងការធ្លាក់ចុះផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដែលកាត់បន្ថយអត្ថិភាពដី និងព្រៃឈើ អភិបាលកិច្ចលើសិទ្ធិកាន់កាប់កាន់តែមានសារសំខាន់ ក្នុងការកំណត់ថាតើអ្នកផងទាំងពួងមានលទ្ធភាព និងធ្វើដូចម្ដេចដើម្បីទទួលបានសិទ្ធិក្នុងការប្រើប្រាស់និងគ្រប់គ្រងដី និងព្រៃឈើទាំងនេះ ជាមួយនឹងការទទួលខុសត្រូវដែលពាក់ព័ន្ធ។

## ស្ថានភាពនីមួយៗខុសពីគ្នា ប៉ុន្តែមានបញ្ហាគន្លឹះដូចគ្នា

មានការធ្វើការងារដែលមានសារប្រយោជន៍ខ្លាំង ដើម្បីបង្កើតភស្ដុតាង និងវិភាគចំណោទនានាលើទិដ្ឋភាពបញ្ហា និងឱកាសជុំវិញសិទ្ធិកាន់កាប់ព្រៃឈើ។ ឧទាហរណ៍ស្ថានភាពមានភាពខុសគ្នាយ៉ាងខ្លាំងនៅអាហ្វ្រិក (អង្គការ FAO ឆ្នាំ២០០៨ Oyono ឆ្នាំ២០០៩ Wily ឆ្នាំ២០១១) អាស៊ី (Contreras-Hermosillaand Fay ឆ្នាំ២០០៥ អង្គការ FAO ឆ្នាំ២០០៦ Nguyen et al ឆ្នាំ២០០៨ អង្គកា FAO ឆ្នាំ២០១០) និងអាមេរិកឡាទីន (Larson et. al ឆ្នាំ២០០៨ អង្គការ FAO ឆ្នាំ២០០៩) ។ ប៉ុន្តែក៏មានបញ្ហារួមផងដែរ៖

- មុខងារ ភារកិច្ច និងសិទ្ធិជាច្រើនមានភាពមិនច្បាស់លាស់ ឬមិនប្រាកដប្រជា ហើយប្រការនេះអាចបង្កឱ្យមានទំនាស់ ។
- ភាពអយុត្តិធម៌និងការបដិសេធសិទ្ធិរបស់ប្រជាជនក្រីក្រនិងអ្នកទន់ខ្សោយ ជាទូទៅច្រើនកើតមានចំពោះស្ត្រី។
- គេឃើញមានសិទ្ធិប្រពៃណី និងសិទ្ធិជនជាតិដើមភាគតិច និងស្ថាប័ននានា ប៉ុន្តែមិនសូវត្រូវបានទទួលស្គាល់តាមរយៈការប្រើប្រាស់គោលនយោបាយ និងច្បាប់ឡើយ ។
- អ្នកកាន់កាប់ច្រើនមិនសូវមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព និងអភិវឌ្ឍការចិញ្ចឹមជីវិតដោយខ្លួនឯង ។
- សមត្ថភាពរបស់ស្ថាប័នរដ្ឋក្នុងការគាំទ្រដល់អ្នកកាន់កាប់ និងលើកកម្ពស់ការរៀបចំគ្រប់គ្រងជាទូទៅ មិនបានគ្រប់គ្រាន់ទេ។

## ការកែទម្រង់សិទ្ធិកាន់កាប់អាចប្រព្រឹត្តទៅបាន និងវត្តមាននៃការណែនាំ

ជាមួយគ្នានេះក៏មានភស្ដុតាងល្អដែលបញ្ហាខាងលើនេះអាចត្រូវបានដោះស្រាយ ប្រសិនបើអាចធ្វើឱ្យមានឥទ្ធិពលគ្រប់គ្រាន់នូវ 'នយោបាយដែលមានលក្ខណៈអនុវត្តជាក់ស្ដែង' អំពីព្រៃឈើតាមរយៈការធ្វើការរួមគ្នា (Mayers និង Bass ឆ្នាំ២០០៤ Paudel et al ឆ្នាំ២០០៨)។ ជាតុសំខាន់ក្នុងការកែទម្រង់ សិទ្ធិកាន់កាប់ព្រៃឈើត្រូវបានវិភាគ និងជំរុញយ៉ាងល្អ (Ellsworth and White ឆ្នាំ២០០៤ អង្គការ FAO ឆ្នាំ២០១១a; Fish et al. ឆ្នាំ២០០៥ និង ឆ្នាំ២០០៨ Sunderlin et al. ឆ្នាំ២០០៨ White និង Martin ឆ្នាំ២០០២) ។ ជាតុទាំងនេះរួមមាន៖

- **កំណែទម្រង់ច្បាប់និង សមត្ថភាពអនុវត្តកំណែទម្រង់ ពោលគឺ** ការកែលម្អក្របខ័ណ្ឌ និងស្ថាប័នដែលមានការត្រួតពិនិត្យ ដើម្បីឱ្យស្ថាប័នទាំងនោះកំណត់ និងចាត់ចែងសិទ្ធិកាន់កាប់ស្របច្បាប់ មានប្រសិទ្ធភាព ប្រកបដោយសមធម៌ និងប្រែក្លាយច្បាប់ និងសមត្ថភាពឱ្យទៅជាលទ្ធផលដែលមានប្រយោជន៍ ( Christy et al ឆ្នាំ២០០៧ Colchester et al. ឆ្នាំ២០០៦ )
- **អនុវត្តឱ្យបានសម្រេចនូវសិទ្ធិដែលបានប្រគល់ និងសិទ្ធិប្រពៃណី**-ដោយជានាថាសិទ្ធិដែលបានប្រគល់ នាំទៅដល់ការគ្រប់គ្រងធនធានព្រៃឈើនៅមូលដ្ឋាន មានប្រសិទ្ធភាព ហើយការចាត់ចែងគ្រប់គ្រងព្រៃឈើប្រពៃណីត្រូវបានទទួលស្គាល់ និងទទួលការគាំទ្រ ( Cronkleton et al. ឆ្នាំ២០១០ Ribot ឆ្នាំ២០០២ )
- **កសាងសហគ្រាសលើមូលដ្ឋានសិទ្ធិ ពោលគឺ** គាំទ្រការចាត់តាំង និងគាំទ្រសមត្ថភាពក្នុងការកសាងសហគ្រាសឱ្យលូតលាស់ និងមាននិរន្តរភាព នៅពេលដែលមានការទទួលស្គាល់សិទ្ធិប្រពៃណីមុនការទទួលស្គាល់បច្ចុប្បន្ន ឬនៅពេលដែលសិទ្ធិថ្មីត្រូវបានផ្តល់ជាផ្លូវការ ( FAO ឆ្នាំ២០១១b ; Macqueen et al. ឆ្នាំ២០១២ )
- **បង្កើតឱកាសកំណែទម្រង់ ជាមួយនឹងការផ្លាស់ប្តូរជាសកល ពោលគឺ** ទទួលស្គាល់នូវការស្ទុះស្ទា រត់រកដីធ្លីជាសកល ការកើនឡើងនូវបញ្ហាប្រឈមពីការផ្លាស់ប្តូរអាកាសធាតុ និងឱកាសក្នុងការឆ្លើយតបចំពោះតម្រូវការចំពោះមុខ និងភាពអនុវត្តជាក់ស្តែងនៃកំណែទម្រង់ការ កាន់កាប់ព្រៃឈើ ( Cotula និង Mayers ឆ្នាំ២០០៩ RRI ឆ្នាំ២០១២ ) ។

ជាពិសេស គោលការណ៍ណែនាំ ( អង្គការ FAO ឆ្នាំ២០១២a ) ផ្តល់នូវមធ្យោបាយមួយដ៏សំខាន់ឆ្ពោះទៅអនាគត។ គោលការណ៍ណែនាំទាំងនោះបង្ហាញការកើនឡើងនូវការយល់ដឹងអំពីមុខងារ ដែលបានបំពេញក្នុងចំណោមរដ្ឋាភិបាលនានាដោយជានាសិទ្ធិកាន់កាប់តាមបែបប្រពៃណី និងធ្វើការជាមួយភាគីពាក់ព័ន្ធដទៃទៀត ដើម្បីគ្រប់គ្រងការលើកកម្ពស់សិទ្ធិកាន់កាប់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ និងពិភពលោក។ សៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែងនេះ ត្រូវបានរៀបរៀងឡើងដើម្បីបំពេញប្រភពគាំទ្រផ្សេងទៀត ដើម្បីជួយអនុវត្តគោលការណ៍ណែនាំនេះ។

## ៣. កំណត់ចំណុចចាប់ផ្តើម និងការកំណត់គោលបំណងរបស់លោកអ្នក

### ការជំរុញទឹកចិត្តទូទៅដើម្បីឱ្យមានការចូលរួម

តើលោកអ្នកធ្វើការចាប់ផ្តើមដោយរបៀបណា? ការយល់ដឹងច្បាស់លាស់អំពីទីតាំងអភិបាលកិច្ចនៃការកាន់កាប់ព្រៃឈើរបស់អ្នក និងគោលដៅដែលអ្នកចង់ទៅមានសារសំខាន់ណាស់។ ខាងក្រោមនេះជាស្ថានភាពមួយចំនួនដែលអ្នកអាចដឹងថាកិច្ចខិតខំប្រឹងប្រែង អាចនឹងផ្តល់ផ្លែផ្កាយ៉ាងពិតប្រាកដ៖

### ត្រូវការបង្កើនការយល់ដឹងព្រោះថា៖

- ព័ត៌មាន និងការយល់ដឹងលើបញ្ហាណាមួយមានកម្រិតតិចតួច ហើយការជជែកពិភាក្សាគ្នានៅមិនទាន់មានភាពចាស់ទុំនៅឡើយ ។
- កត្តាជំរុញថ្មីចំពោះការប្រើប្រាស់ដីព្រៃកើតមាន និងបង្កើតឱ្យមានបញ្ហា ឬឱកាសដូចជាទីផ្សារថ្មីសម្រាប់ការវិនិយោគលើព្រៃ ឬលើផលិតផលកសិកម្ម ទំនិញ ជីវឥន្ទនៈ ឬកាបូន។

### ចាំបាច់ត្រូវមានការចាត់តាំងច្បាស់លាស់ ព្រោះថា៖

- ខ្វះសមត្ថភាពក្នុងការប្រែក្លាយការសម្រេចចិត្តដ៏ល្អឱ្យទៅជាការអនុវត្តជាក់ស្តែង។
- ឱកាសល្អកើតចេញពីការផ្លាស់ប្តូរនយោបាយ ឬពីក្របខ័ណ្ឌថ្មី ដូចជា FLEGT ឬ REDD+។

## ចាំបាច់ត្រូវមានការចូលរួមខ្លាំងក្លា ព្រោះថា៖

- បញ្ហាគន្លឹះ - ដូចជាការបញ្ជាក់ច្បាស់លាស់ និងការធានាសុវត្ថិភាពកាន់កាប់ - 'ត្រូវបាននិយាយច្រើនលើកច្រើនសា' ទោះជាមានការយល់ដឹងក្តី ហើយកិច្ចព្រមព្រៀងជាក់ស្តែងត្រូវមានភាពរឹងមាំ។
- ការមិនចុះសម្រុងរយៈពេលយូរ និងអរិភាពតិចតួចចំពោះធនធានព្រៃឈើ និងជីវភាពទៅកេភាពធ្ងន់ធ្ងរ ឬមានការបើកច្រកដើម្បីការឈ្វេងយល់ និងការផ្សះផ្សាជំហរផ្សេងគ្នារបស់ភាគីពាក់ព័ន្ធ។

## ចាំបាច់ត្រូវមានគណនេយ្យភាព ព្រោះថា៖

- គ្មានការសម្រេចចិត្តរបស់ ឬការសម្រេចចិត្តកំពុងជាប់គាំងដោយសារតែភាពមិនចុះសម្រុងពីមុន ភាពអសកម្មផ្នែកគោលនយោបាយ ឬអសមត្ថភាពផ្នែកស្ថាប័ន។
- អយុត្តិធម៌ក្រាស់ក្រែល និងការមិនទទួលស្គាល់សិទ្ធិរបស់ស្ត្រី និងជនក្រីក្រលេចចេញជារូបរាងច្បាស់លាស់ ឬការគំរាមកំហែងណាមួយចំពោះព្រៃឈើកើតឡើងពីសំណើវិនិយោគមិនត្រឹមត្រូវ។

ប្រសិនបើអ្នកកំពុងតែស្ថិតនៅក្នុងចំណោមស្ថានភាពទាំងនេះ ឬស្ថានភាពស្រដៀងគ្នានេះ ជំហានដំបូងសំខាន់គឺត្រូវធ្វើការវាយតម្លៃ និងពណ៌នាស្ថានភាពនោះ និងមានការលើកទឹកចិត្តអ្នក ក្នុងការធ្វើអ្វីម៉្យាងចំពោះស្ថានភាពនោះ។

## បរិបទអភិបាលកិច្ចព្រៃឈើទូទៅមួយចំនួន

សំខាន់ត្រូវដឹងថាមិនមែនមានតែលោកអ្នកតែឯងនោះទេ។ ពិតណាស់ថាប្រទេសនីមួយៗ និងបរិបទនីមួយៗនៅក្នុងប្រទេសនីមួយៗមានលក្ខណៈខុសគ្នា។ ប៉ុន្តែគេអាចយល់ដឹងស្ថានភាពមួយចំនួនអំពីសភាពទូទៅនៃអភិបាលកិច្ចព្រៃឈើ - និងយល់ដឹងកត្តាចម្បង ជំរុញឱ្យមានការផ្លាស់ប្តូរ ឬរក្សាអ្វីៗនៅដដែល។ តារាងទី១ បង្ហាញស្ថានភាពទូទៅមួយចំនួននៃស្ថានភាពទូទៅទាំងនេះ និងច្រកចូលដែលស្ថានភាពទាំងនោះផ្តល់ ដល់ការងារអភិបាលកិច្ចព្រៃឈើ។ តារាងនេះក៏កត់សម្គាល់ផ្នែកនានានៅក្នុងសម្ភារឧបទេសផងដែរ (សូមមើលតារាងមាតិកា) ដែលផ្តល់ឧបករណ៍អាចមានប្រយោជន៍នៅក្នុងការងារនេះ។ ប្រយោគក្នុងតារាងដែលព្យាយាមក្តោបបរិបទផ្សេងគ្នាជៀសមិនរួចពីការកំណត់លក្ខណៈបែបសាមញ្ញ ប៉ុន្តែលោកអ្នកប្រហែលជាពិនិត្យឃើញការឆ្លើយតបមួយចំនួនចំពោះស្ថានភាពរបស់លោកអ្នក។ លោកអ្នកក៏អាចពិនិត្យឃើញថា ស្ថានភាពរបស់លោកអ្នកគឺទិដ្ឋភាពចម្រុះបែបនៃបរិបទនេះផងដែរ។ ទោះជាយ៉ាងណាក្តី យើងសង្ឃឹមថា ការចែកតាមប្រភេទនេះនឹងជួយលោកអ្នកចាប់ផ្តើមកំណត់បង្គុំដែលមានលក្ខណៈអនុវត្តជាក់ស្តែងរវាងចំនុចចាប់ផ្តើម និងឧបករណ៍នានា។

**តារាងទី១ បង្ហាញស្ថានភាពទូទៅមួយចំនួននៃស្ថានភាពទូទៅទាំងនេះ និងចំនុចចាប់ផ្តើមដែលស្ថានភាពទាំងនោះផ្តល់ដល់ការងារអភិបាលកិច្ចព្រៃឈើ។**

| បរិបទអភិបាលកិច្ចព្រៃឈើរបស់លោកអ្នក | ចំនុចចាប់ផ្តើមដើម្បីកែលម្អអភិបាលកិច្ចព្រៃឈើ | ឧបករណ៍ដែលលោកអ្នកគិតថាមានសារប្រយោជន៍(យោងទៅកាន់ផ្នែកនានានៃសម្ភារឧបទេស) |
|---|---|---|
| **១.ការគ្រប់គ្រង និងបញ្ញត្តិរបស់រដ្ឋ** | នៅពេលដែលមានសមត្ថភាពគ្រប់គ្រងរឹងមាំ៖<br>• ព័ត៌មាន និងការផ្សព្វផ្សាយ<br>• ការរៀបចំគោលនយោបាយ និងនីតិកម្ម<br>• គណនេយ្យភាពរបស់អាជ្ញាធរ | • កសាងវិស័យសាធារណៈ មួយដែលមានលក្ខណៈឆ្លើយតប(B2)<br>• ការតាមដាន និងការវាយតម្លៃគណនេយ្យភាព និងតម្លាភាព (D1) |
| | នៅពេលដែលមានសមត្ថភាពទន់ខ្សោយ៖<br>• គ្មានអនុលោមភាព និងមានអំពើពុករលួយ<br>• ទំនាស់ជាមួយសិទ្ធិកាន់កាប់តាមបែបប្រពៃណី<br>• មុខងារសង្គមស៊ីវិលនិងវិស័យឯកជន | • កសាងបរិបទនយោបាយ និងស្ថាប័ន (A4)<br>• អនុវត្តដំណើរការពិគ្រោះយោបល់ដំណើរការចូលរួម និងដំណើរការភាគីពាក់ព័ន្ធចម្រុះដែលមានប្រសិទ្ធភាព (C2) |

| | | |
|---|---|---|
| **២.ឯកជនភាវូបនីយកម្ម ដើម្បីដាក់បញ្ចូលផលប្រយោជន៍** | • លុបបំបាត់បទប្បញ្ញត្តិ និងធ្វើកំណែទម្រង់ទីផ្សារ<br>• ស្តង់ដារ និងការតាមដាន<br>• ការយល់ព្រម ដោយសេរី និងជូនដំណឹងជាមុន | • ពង្រឹងសហគមន៍ឱ្យចូលរួម (B1)<br>• រៀបចំឱ្យវិស័យឯកជនដំណើរការដោយយុត្តិធម៌ និងពេញលេញ (B3) |
| **៣.វិមជ្ឈការទៅកាន់អាជ្ញាធរ ឬសហគមន៍មូលដ្ឋាន** | • ភាពច្បាស់លាស់ និងសុវត្ថិភាពនៃការកាន់កាប់<br>• សមត្ថភាពសហគមន៍ សង្គមស៊ីវិលនិងអាជ្ញាធរមូលដ្ឋាន<br>• ដំណើរការនានា និងគណនេយ្យភាពនៃភាគីពាក់ព័ន្ធចម្រុះ | • ការទទួលស្គាល់នូវការចាត់ចែង និងការទាមទារសិទ្ធិកាន់កាប់ព្រៃឈើ (A3)<br>• គាំទ្រសង្គមស៊ីវិលឱ្យថែរក្សាកស្តុតាងតស៊ូមតិ ធ្វើយុទ្ធនាការ និងចរចា (C4) |
| **៤.ការទទួលខុសត្រូវចំពោះពាណិជ្ជកម្មឈើ-FLEG និងការបញ្ជាក់** | • កំណត់មូលដ្ឋានគោលនៃភាពស្របច្បាប់និងធនធាន<br>• សមត្ថភាពស្ថាប័ន<br>• ការផ្ទៀងផ្ទាត់ និងការបញ្ជាក់ | • កំណត់ឱកាសសម្រាប់ការផ្លាស់ប្តូរ (A2)<br>• យន្តការបណ្តឹងសាទុក្ខ ការដោះស្រាយវិវាទ និងលទ្ធភាពទទួលបានការគាំទ្រពីជំនួយការច្បាប់ (D2) |
| **៥. ព្រៃឈើសម្រាប់ដោះស្រាយការប្រែប្រួលធាតុអាកាស-REDD+និងយុទ្ធសាស្ត្របន្សាំ** | • កាបូន និងសិទ្ធិព្រៃឈើ<br>• យន្តការចែកប្រាក់ចំណេញ<br>• ការសម្របសម្រួលឆ្លងវិស័យ | • ការយល់ដឹងអំពីមុខងារទំនិញ និងសេវាព្រៃឈើក្នុងការចិញ្ចឹមជីវិត (A2)<br>• ឧបាស្រ័យទៅកាន់តុលាការ ថ្នាក់លើរបស់រដ្ឋាភិបាលឬគោលនយោបាយ និងគំនាស់អន្តរជាតិ (D3) |
| **៦. អភិបាលកិច្ចព្រៃឈើតាមរូបភាពចម្រុះជាមួយវិស័យដទៃ** | • ការចូលរួមក្នុងយន្តការអន្តរក្រសួង<br>• គម្លាតព័ត៌មាននិងសមត្ថភាព<br>• ការចូលរួមរបស់សង្គមស៊ីវិល | • ការវាយតម្លៃមូលដ្ឋានធនធានជីវសាស្ត្រ (A1)<br>• កសាង ឬពង្រឹងសម្ព័ន្ធភាពបណ្តាញ និងសហព័ន្ធ (B4) |

## ការជំរុញទឹកចិត្តពីគោលការណ៍នៃអភិបាលកិច្ចព្រៃឈើល្អ

គំនិតផ្តួចផ្តើមផ្សេងៗជាមួយភាគីពាក់ព័ន្ធព្រៃឈើ ដើម្បីបង្កើតវិធីជាប្រព័ន្ធសំដៅវាយតម្លៃអភិបាលកិច្ចព្រៃឈើក្នុងបរិបទណាមួយ និងបង្កលក្ខណៈឱ្យក្រុម និងបុគ្គលទាំងឡាយកំណត់ទីតាំងចំណុចចាប់ផ្តើមរបស់ខ្លួនដើម្បីចាត់វិធានការកែលម្អស្ថានភាពនោះ - ផ្តល់នូវការណែនាំដែលមានប្រយោជន៍ដល់យើង (Mayers et al. ឆ្នាំ២០០៥ ។) ។ FAO និងកម្មវិធីស្តីពីព្រៃឈើ (PROFOR) បានធ្វើការងារប្រកបដោយប្រសិទ្ធភាពក្នុងការសំយោគគំនិតផ្តួចផ្តើមថ្មីៗនេះ និងបានដាក់ចេញនូវក្របខ័ណ្ឌមួយសម្រាប់វាយតម្លៃ និងតាមដានអភិបាលកិច្ចព្រៃឈើ ដោយផ្អែកលើសំណុំនៃគោលការណ៍ និង'សសរស្តម្ភ' (សូមមើលរូបភាពទី១) (អង្គការ FAO និង PROFOR ឆ្នាំ២០១១) ។

**រូបទី១. សំណើ 'សសរស្តម្ភ' និងគោលការណ៍នៃអភិបាលកិច្ច 'ល្អ'**

*ប្រភព៖ FAO និង PROFOR ឆ្នាំ២០១១*



ដោយយោងទៅតាមគោលការណ៍ទាំងនេះ អង្គការ FAO និង PROFOR កត់សម្គាល់ថា អភិបាលកិច្ចជាទូទៅត្រូវបានចាត់ទុកថា 'ល្អ' ប្រសិនអភិបាលកិច្ចនោះមានការចូលរួមពីភាគីពាក់ព័ន្ធ មានតម្លាភាពក្នុងការសម្រេចចិត្ត មានគណនេយ្យភាពរបស់តួអង្គ និងអ្នកសម្រេចចិត្ត មាននីតិរដ្ឋ និងអាចប៉ាន់ប្រមាណបាន។ 'អភិបាលកិច្ចល្អ' ក៏មានទំនាក់ទំនងជាមួយការគ្រប់គ្រងដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលនៃធនធានធម្មជាតិ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ព្រមទាំងការបែងចែកធនធាន និងផលប្រយោជន៍ដោយយុត្តិធម៌ និងសមធម៌ផងដែរ។ ស្ថាប័នទាំងពីរនេះពណ៌នាសសរស្តម្ភដូចខាងក្រោម៖

- **សសរស្តម្ភទី១៖** ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងបទប្បញ្ញត្តិ - ប្រព័ន្ធរយៈពេលវែងនៃគោលនយោបាយ ច្បាប់ វិធាន និងបទប្បញ្ញត្តិនៅក្នុងវិស័យព្រៃឈើ និងវិស័យដទៃដែលមានឥទ្ធិពលមកលើព្រៃឈើ
- **សសរស្តម្ភទី២៖** ដំណើរការកសាងផែនការ និងដំណើរការនៃការសម្រេចចិត្ត-កម្រិតនៃតម្លាភាព គណនេយ្យភាព និងភាពពេញនៃដំណើរការអភិបាលកិច្ច និងស្ថាប័ន
- **សសរស្តម្ភទី៣៖** ការអនុវត្ត ការបង្ខំឱ្យអនុវត្ត និងអនុលោមភាព - វិសាលភាពដែលក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ននិងក្របខ័ណ្ឌបទប្បញ្ញត្តិ ត្រូវបានអនុវត្ត។

ហេតុមកដល់ពេលនេះបទពិសោធន៍ជាមួយនឹងក្របខ័ណ្ឌនេះ បង្ហាញថាគោលការណ៍នេះអាចជួយឱ្យភាគីពាក់ព័ន្ធកំណត់គោលបំណងប្រកបដោយប្រសិទ្ធភាព និងចាត់វិធានការដើម្បីធ្វើឱ្យមានភាពប្រសើរឡើង ( FAO ឆ្នាំ២០១២b )។

## ការផ្ដោតការយកចិត្តទុកដាក់លើអភិបាលកិច្ចលើសិទ្ធិកាន់កាប់

គោលការណ៍ណែនាំ ( FAO 2012a ) មានឫសគល់ចេញពីជំនឿច្បាស់លាស់បានមកពីបទពិសោធន៍ជាក់ស្ដែងដូចបានកត់សម្គាល់ខាងលើដែលថា កំណែទម្រង់វិជ្ជមានលើសិទ្ធិកាន់កាប់មានសារសំខាន់ និងអាចអនុវត្តបាន។ ពិសេសគោលការណ៍ណែនាំនេះទទួលស្គាល់ថា ប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាស្ដីពីសិទ្ធិកាន់កាប់ ចំណុះលើវិសាលភាពដ៏ធំលើគុណភាពនៃអភិបាលកិច្ច។

*ប្រភព៖*
*FAO (2012a)*

**អភិបាលកិច្ចលើសិទ្ធិកាន់កាប់ដែលមានការទទួលខុសត្រូវតម្រូវឱ្យ៖**

- ទទួលស្គាល់ និងគោរពសិទ្ធិកាន់កាប់ស្របច្បាប់ និងទទួលស្គាល់ និងគោរពអ្នកកាន់កាប់
- ការពារសិទ្ធិកាន់កាប់ស្របច្បាប់ប្រឆាំងនឹងការគំរាមកំហែង
- លើកកម្ពស់ និងសម្រួលការអាស្រ័យផលនៃសិទ្ធិកាន់កាប់ស្របច្បាប់
- ផ្ដល់លទ្ធភាពទទួលបានយុត្តិធម៌ក្នុងការដោះស្រាយការរំលោភបំពាន
- ទប់ស្កាត់ជម្លោះកាន់កាប់ ទប់ស្កាត់ទំនាស់ហិង្សា និងឱកាសប្រព្រឹត្តអំពើពុករលួយ។

តារាងខាងក្រោមនេះបង្ហាញធាតុសំខាន់ៗនៃគោលការណ៍ណែនាំនេះ និងឧទាហរណ៍អំពីឧបករណ៍នានានៅក្នុងសម្ភារឧបទេសដែលអាចយកមកអនុវត្តបាន។

**តារាងទី២. គោលការណ៍ណែនាំ និងឧបករណ៍ដែលអាចប្រើប្រាស់សម្រាប់អនុវត្ត**

| រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ | មាតិកានៃគោលការណ៍ណែនាំ | ឧទាហរណ៍នៅក្នុងក្បួនណែនាំដែលលោកអ្នកអាចប្រើដើម្បីអនុវត្តគោលការណ៍ |
|---|---|---|
| **១. បឋម** | គោលបំណង សារជាតិ ជាតុដើម? និង វិសាលភាពនៃគោលការណ៍ណែនាំ | |
| **២. បញ្ហាទូទៅ** | មូលដ្ឋានគ្រឹះ៖ ជាតុសំខាន់ៗ និងចាំបាច់ត្រូវមានការយល់ដឹងរួម ចំពោះអភិបាលកិច្ចនៃសិទ្ធិកាន់កាប់៖<br>• គោលការណ៍ណែនាំអំពី អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ៖<br>• សិទ្ធិនិងការទទួលខុសត្រូវដែលទាក់ទងនឹងសិទ្ធិកាន់កាប់<br>• ក្របខ័ណ្ឌគោលនយោបាយក្របខ័ណ្ឌច្បាប់ក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់<br>• ការផ្ដល់សេវា | • ការវាយតម្លៃទិដ្ឋភាពចម្រុះ(A1-6)<br>• ការវិភាគដែលមានការចូលរួមអំពីភាពក្រីក្រ ជីវភាពរស់នៅ និងថាមវន្តបរិស្ថាន (A2-2)<br>• កាសិក្សាដែលមានការចូលរួម(A3-2)<br>• ការវិភាគគោលនយោបាយនិងការវិភាគផ្លូវច្បាប់ (A4-1)<br>• ការវិភាគសាវតារ(A4-8)<br>• ការវាយតម្លៃអភិបាលកិច្ចដោយមានការចូលរួម (B1-5) |
| **៣. ការទទួលស្គាល់ស្របច្បាប់និងការបែងចែកសិទ្ធិកាន់កាប់និងករណីយកិច្ច** | អភិបាលកិច្ចលើ៖<br>• ការទទួលស្គាល់សិទ្ធិកាន់កាប់ របស់ជនជាតិដើមភាគតិច និងរបស់សហគមន៍ដទៃទៀតដែលមាន<br>• ប្រព័ន្ធកាន់កាប់តាមបែបប្រពៃណី និងសិទ្ធិកាន់កាប់ក្រៅផ្លូវការ<br>• ការបែងចែកដីគ្រាដំបូងនៃសិទ្ធិកាន់កាប់ជាកម្មសិទ្ធិ ឬដែលគ្រប់គ្រងដោយវិស័យសាធារណៈ | • ការវាយតម្លៃហ័សអំពីសិទ្ធិកាន់កាប់ដីធ្លី (A3-1)<br>• រៀបចំក្រុមប្រើប្រាស់ព្រៃឈើឱ្យចូលរួម(B1-1)<br>• ការយល់ព្រម ដោយសេរី និងជូនដំណឹងជាមុនពីគោលការណ៍ដល់ការអនុវត្ត(C1-3)<br>• ពង្រឹងសមត្ថភាពរបស់ ជំនួយការច្បាប់អំពីព័ត៌មានសហគមន៍ (D2-2)<br>• សិទ្ធិរបស់ជនជាតិដើមភាគតិចនៅក្នុងអង្គការអន្តរជាតិខាងការងារ(D3-2) |
| **៤. ការផ្ទេរ និងការផ្លាស់ប្តូរទៅកាន់សិទ្ធិកាន់កាប់ និងករណីយកិច្ច** | អភិបាលកិច្ចលើសិទ្ធិកាន់កាប់នៅពេលដែលសិទ្ធិនិងករណីយកិច្ចពាក់ព័ន្ធត្រូវបានផ្ទេរឬបែងចែកជាថ្មីតាមរយៈ<br>• ទីផ្សារ<br>• ប្រតិបត្តិការ(ទិញលក់)សិទ្ធិកាន់កាប់ជាផលនៃការវិនិយោគ<br>• ការបង្រួមក្បាលដី ឬ វិធីសាស្ត្រកែសម្រួលក្បាលដីដទៃទៀត<br>• បដិទាន កំណែទម្រង់ បែងចែកសាជាថ្មី ឬអស្សាមិករណ៍ | • កត្តាជំរុញការវិភាគអំពីការផ្លាស់ប្តូរ (A4-4)<br>• ការកសាងផែនទីឥទ្ធិពល របស់ភាគីពាក់ព័ន្ធ និងការវិភាគអំណាច(A4-6)<br>• ការគ្រប់គ្រងក្រុមសិក្សា មិត្តអប់រំមិត្តដើម្បីលើកកម្ពស់អភិបាលកិច្ចព្រៃឈើ (B4-1)<br>• គាំទ្រសហគមន៍ក្នុងការចរចា និងអនុវត្តកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុននានា(C1-4)<br>• ប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធវិធីបញ្ចុះបញ្ចូលសម្រាប់ក្រុមនៅមូលដ្ឋាន (C1-5)<br>• ផែនទីបង្ហាញផ្លូវសម្រាប់ ដំណើរការពិភាក្សាដែលមានការចូលរួម(C2-3) |

| | | |
|---|---|---|
| **៥. អភិបាលកិច្ចលើសិទ្ធិកាន់កាប់** | អភិបាលកិច្ចលើការគ្រប់គ្រង៖<br>• ទិន្នន័យអំពីសិទ្ធិកាន់កាប់<br>• ការវាយតម្លៃ<br>• ការយកពន្ធ<br>• ការកសាងផែនការគ្រប់គ្រងទឹកដី<br>• ការដោះស្រាយទំនាស់អំពីសិទ្ធិនៃសិទ្ធិកាន់កាប់<br>• បញ្ហាព្រំឆ្លងកាត់ | • ការគ្រប់គ្រងទំនាស់ ធនធានព្រៃឈើនៅសហគមន៍(B1-6)<br>• ប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ធានាសិទ្ធិព្រៃឈើ (B2-5)<br>• ការពង្រឹងអភិបាលកិច្ច និងរចនាសម្ព័ន្ធសហគ្រាសនៅសហគមន៍ (B3-2)<br>• ភាពជាដៃគូព្រៃឈើរវាងក្រុមហ៊ុន និងសហគមន៍ (B3-4)<br>• ការទទួលបានព័ត៌មាន សាធារណៈ (D1-6)<br>• សកម្មភាពពលរដ្ឋក្នុងការកាត់បន្ថយអំពើពុករលួយ (D1-8)<br>• បង្កើតនីតិវិធីប្ដឹងសាទុក្ខ និងនីតិវិធីប្ដឹងផ្ដល់(D2-1) |
| **៦. ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ និងសង្គ្រោះបន្ទាន់** | អភិបាលកិច្ចលើសិទ្ធិកាន់កាប់ក្នុងបរិបទនៃ៖<br>• ការប្រែប្រួលអាកាសធាតុ<br>• គ្រោះមហន្តរាយ<br>• ទំនាស់ហិង្សា | • សម្ភារឧបទេសទំនាក់ទំនងរវាងភាពក្រីក្រ និងព្រៃឈើ(A2-1)<br>• ការវិភាគដល់ទីកន្លែងអំពីកម្លាំង(A4-2)<br>• ការវិភាគសេណារីយ៉ូនិងការកសាងផែណការ(A5-1)<br>• សម្របសម្រួលការផ្លាស់ ប្ដូរផ្នែកស្ថាប័ន (B2-1) |
| **៧. ការជំរុញ ការអនុវត្ត ការតាមដាន និងការវាយតម្លៃ** | • ការតស៊ូមតិ ការប្រើនិងការពិនិត្យមើលគោលការណែនាំ | • ដំណើរការគម្រោងសាកល្បង(B2-3)<br>• ការបង្វឹកក្នុងពេលបំពេញការងារចំពោះមន្ត្រីរដ្ឋាភិបាលក្នុងវិធីសាស្ត្រដែលមានការចូលរួម (B2-4)<br>• កសាងសម្ព័ន្ធមេត្រី និងសម្ព័ន្ធភាពដើម្បីតស៊ូមតិ (B4-3)<br>• ប័ណ្ណរបាយការណ៍ស្ដីពី តម្លាភាពនៃវិស័យព្រៃឈើ (D1-3)<br>• សវនាការសាធារណៈ និងសវនកម្ម (D2-4)<br>• ប្រើយន្តការត្រួតពិនិត្យ អនុលោមភាពនៃអនុសញ្ញាអាហ៊ុស (Aarhus Convention) (D3-4) |

ប្រភេទបរិបទអភិបាលកិច្ចក្របខ័ណ្ឌខាងលើ សម្រាប់អភិបាលកិច្ចព្រៃឈើ និងសម្រាប់ធាតុសំខាន់ៗនៃគោលការណ៍ណែនាំ គប្បីជួយឱ្យលោកអ្នកកំណត់គោលបំណងរបស់លោកអ្នកបាន។ គោលបំណងមានសារសំខាន់ ខ្លាំងសំដៅដោះស្រាយបញ្ហាដ៏ធំៗ និងបញ្ហាដែលពីមុនមកមិនអាចតាមដានបាន។ គោលបំណងមួយចំនួនទៀតមានរយៈពេលខ្លី សំដៅច្បាមយកឱកាស និងការជំរុញឱ្យមានការផ្លាស់ប្ដូរជាដុំកំភួន។ ផ្នែកផ្សេងទៀតនៃសៀវភៅណែនាំដែលមានលក្ខណៈអនុវត្តន៍ជាក់ស្ដែងនេះនឹងអាចជួយលោកអ្នកឱ្យដឹងទំហំ និងអាំងតង់ស៊ីតេនៃបញ្ហាប្រឈម និងប្រភេទនានានៃធនធានដែលលោកអ្នកអាចត្រូវការ។

# ៤. ការប្រើសម្ភារឧបទេសដើម្បីជួយឱ្យសម្រេចគោលដៅរបស់លោកអ្នក

## ការបង្ហាញសម្ភារឧបទេស

ផ្នែកផ្សេងទៀតនៃសៀវភៅណែនាំអនុវត្តន៍ជាក់ស្តែងនេះ មានសម្ភារឧបទេសដែលត្រូវបានរៀបចំឡើងសម្រាប់អ្នកទាំងឡាយណា ដែលចង់កែលម្អអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ។ ក្បួនណែនាំនេះផ្តល់ឧបករណ៍មួយចំនួនដើម្បីបង្កើនការយល់ដឹង ការរៀបចំ ការចូលរួម និងការធ្វើឱ្យប្រាកដក្នុងបរិបទនៃអភិបាលកិច្ច។ ឧបករណ៍ទាំងនេះត្រូវបានដាក់ឈ្មោះសមស្របក្នុងបរិបទអភិបាលកិច្ចផ្សេងគ្នា និងបរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីប្រើឧបករណ៍ទាំងនេះ។

ក្តីសង្ឃឹមគឺតាមរយៈការផ្តោតការយកចិត្តទុកដាក់លើឧបករណ៍ - ជំនួសឱ្យបញ្ហា ឬទំនាស់ បញ្ហាប្រឈម - លោកអ្នកត្រូវបានលើកទឹកចិត្តឱ្យចាត់វិធានការអនុវត្តជាក់ស្តែង។ ដោយមានការណែនាំអំពីឧបករណ៍អនុវត្ត យើងចង់លើកទឹកចិត្តដល់លោកអ្នកថា លោកអ្នក "អាចធ្វើដោយខ្លួនឯង" បាន។ ឧបករណ៍ទាំងនេះត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងធនធានធម្មជាតិពិតចំពោះមុខ ហើយយើងសង្ឃឹមថា ការរៀនអំពីវិធីសាស្ត្រក្នុងស្រុកបែបនេះលោកអ្នកនឹងមានការជំរុញទឹកចិត្តនៅកន្លែង ដែលលោកអ្នកប្រឈមមុខជាមួយបញ្ហាស្រដៀងគ្នានេះ។

សម្ភារឧបទេសនេះផ្តល់នូវខ្លឹមសារសង្ខេបឧបករណ៍ចំនួន ៨៦ ផ្អែកលើបទពិសោធន៍មកពីជុំវិញពិភពលោក។ សម្ភារឧបទេសនេះក៏ពិពណ៌នាស៊ីជម្រៅអំពីឧបករណ៍ដែលមានប្រយោជន៍ទូទៅចំនួន៩។ គោលបំណងគឺទាក់ទាញចំណាប់អារម្មណ៍ជាជាងការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ យើងគ្មានបំណងរៀបរាប់ឧបករណ៍នីមួយៗដែលមានសក្តានុពល ឬគ្របដណ្តប់រាល់ទិដ្ឋភាពនៃគោលនយោបាយ និងការផ្លាស់ប្តូរផ្នែកស្ថាប័នឡើយ។ សម្ភារឧបទេសនេះក៏មានបង្ហាញឯកសារយោងជាច្រើនរវាងឧបករណ៍ទាំងនោះផងដែរ។

## លក្ខណៈទូទៅនៃឧបករណ៍

លក្ខណៈពិសេសសំខាន់ចំនួនពីរនៃឧបករណ៍មួយដែលមានសារប្រយោជន៍ គឺការនាំលោកអ្នកពីបញ្ហាទៅកាន់ដំណោះស្រាយ និងអាចផ្ទេរយកទៅអនុវត្តពីបរិបទមួយទៅអនុវត្តនៅកន្លែងដទៃទៀត ជាផែនការដែលគ្មានចរិតចាប់បង្ខំ និងមិនងាប់ក្រឡា។ ឧបករណ៍ចម្រុះទូលំទូលាយដែលមានច្រើនប្រភេទ គប្បីជាឧបករណ៍ជំរុញការបង្កើត និងការសាកពិសោធន៍។ លក្ខណៈសំខាន់ដទៃទៀតនៃឧបករណ៍ដែលបានបង្ហាញនៅទីនេះមានភាពសាមញ្ញ (ងាយត្រង់ត្រាប់ និងងាយប្រាស្រ័យទាក់ទង) និងមានប្រសិទ្ធភាពតម្លៃ (លើការចំណាយពេលវាលា ប្រាក់កាស ជំនាញ និងបរិក្ខារ។

## វដ្តសកម្មភាពនៃការពិចារណាលើសម្ភារឧបទេស

សេចក្តីសង្ខេបអំពីឧបករណ៍ត្រូវបានចងក្រងជាបួនផ្នែក ហើយផ្នែកនីមួយៗជាដំណាក់កាលត្រួតលើគ្នា វដ្តសកម្មភាពកំពុងដំណើរការ និងការពិចារណាក្នុងការកែលម្អអភិបាលកិច្ច៖

- ឧបករណ៍សម្រាប់យល់ដឹង។ ជារឿយៗជំហានទីមួយក្នុងការកែលម្អអភិបាលកិច្ចគឺ ពិនិត្យមើលយ៉ាងល្អិតល្អន់នូវស្ថានភាព និងកាលានុវត្តភាពបច្ចុប្បន្ន ហើយផ្តើមចេញពីនេះ កសាងផែនការសកម្មភាព។
- ឧបករណ៍សម្រាប់រៀបចំ។ ឥទ្ធិពលលើសេចក្តីសម្រេចចិត្ត ពិសេសចំពោះផលប្រយោជន៍តិចតួចច្រើនតែតម្រូវឱ្យមានកម្លាំងច្រើន។ ប៉ុន្តែការបង្កើតស្ថាប័នដែលមានប្រសិទ្ធភាពពុំមែនជាការងាយស្រួលឡើយ ហេតុនេះចាំបាច់ត្រូវមានឧបករណ៍ដើម្បីកសាងភាពស្របច្បាប់ គណនេយ្យភាព និងប្រសិទ្ធភាព។
- ឧបករណ៍សម្រាប់ការចូលរួម។ ក្រុមដែលទទួលបានដំណឹងច្បាស់លាស់ និងដែលចងក្រងបានល្អ ចាំបាច់ត្រូវតែចូលរួមនៅក្នុងដំណើរការនៃការសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ពួកគេ។ ការចូលរួមអាចប្រព្រឹត្តិទៅ

តាមរយៈកិច្ចពិភាក្សារួមគ្នា ឬតាមរយៈការតស៊ូ។ ក្រុមដែលមានប្រសិទ្ធភាពជាច្រើនប្រើប្រាស់យុទ្ធសាស្ត្រទាំងពីរ។

- ឧបករណ៍សម្រាប់ការជានា។ ការមានសំឡេង មិនទាន់គ្រប់គ្រាន់នៅឡើយទេ ចាំបាច់ត្រូវមានយន្តការដើម្បីឱ្យមានការទទួលខុសត្រូវធ្វើយ៉ាងណាឱ្យកិច្ចពិភាក្សា និងការសន្យាក្លាយជាសកម្មភាពជាក់ស្តែង។

ផ្នែកនីមួយៗនៃផ្នែកទាំងបួននេះពន្យល់បន្ថែមអំពីសារសំខាន់នៃបញ្ហាទាំងនេះ និងពណ៌នាអំពីវិធីពិនិត្យមើលផ្នែកនេះទាំងមូល។ បន្ទាប់មកឧបករណ៍ត្រូវបានសង្ខេបចំពោះបញ្ហាប្រឈមចម្បងៗនីមួយៗនៃអភិបាលកិច្ច។ ប្រភពព័ត៌មានបន្ថែមមានបង្ហាញនៅចុងខ្លឹមសារសង្ខេបអំពីឧបករណ៍នីមួយៗ ហើយធនធានបន្ថែមអាចរកបាននៅក្នុងគន្ថនិទ្ទេស។ ជាមួយគ្នានេះ នៅខាងចុងខ្លឹមសារសង្ខេបនីមួយៗ មានតារាងឧបករណ៍ដទៃទៀត ដែលអាចមានប្រយោជន៍។ ទាំងនេះគឺជាឧបករណ៍នៅកន្លែងផ្សេងនៅក្នុងសម្ភារឧបទេស ដែលអាចបង្ហាញថាមានប្រយោជន៍បន្ថែមលើឧបករណ៍ដែលមាននៅក្នុងក្រុមចំពោះមុខ។



## ភាពត្រឹមត្រូវនៃឧបករណ៍

មានរូបសញ្ញាពីរប្រភេទត្រូវបានប្រើនៅក្នុងសម្ភារឧបទេសនេះ ដើម្បីផ្តល់សញ្ញាអំពីភាពត្រឹមត្រូវនៃឧបករណ៍មួយៗ។ អាយខនទាំងនោះមានន័យដូចខាងក្រោម៖



**១. កម្រិតនិងគុណភាពនៃព័ត៌មាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

ជាកម្រិតនិងគុណភាពបច្ចុប្បន្ននៃព័ត៌មាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធដែលឧបករណ៍នោះជាឧបករណ៍សមស្រប។ កងស្ពឺមួយជាកម្រិតមួយទាប (មានន័យថាមិនចាំបាច់ មានព័ត៌មានច្រើន និងមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឧបករណ៍នេះ) ។ កងស្ពឺបួនជាកម្រិតខ្ពស់ (ពោលគឺចាំបាច់ត្រូវមានព័ត៌មានច្រើននិងមានការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការប្រើប្រាស់ឧបករណ៍នេះ)។



**២. តម្រូវការធនធាន**

បរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍មានដំណើរការ។ ដើមឈើមួយដើមតំណាងឱ្យបរិមាណដែលមានកម្រិតទាប ដើមឈើបួនដើមជាបរិមាណច្រើន។

## ឧបករណ៍ស៊ីជម្រៅ

ឧបករណ៍សង្ខេបចំនួនប្រាំបួន ក៏ត្រូវបានពណ៌នាលម្អិតនៅក្នុងឧបសម្ព័ន្ធ ១ នៃសម្ភារឧបទេសនេះ (ឧបករណ៍ទាំងនេះត្រូវបានសម្គាល់ដោយអក្សរ 'XL')។ ផ្នែកនេះមានគោលបំណងផ្តល់ ចំណេះដឹងចំណេះធ្វើ នូវសំណុំស្នូលនៃឧបករណ៍មានប្រយោជន៍ជាទូទៅ ដែលមានលក្ខណៈអនុវត្តជាក់ស្តែង ដើម្បីឱ្យលោកអ្នកយល់ដឹងអំពី ការប្រើប្រាស់ឧបករណ៍នីមួយៗឱ្យមានប្រសិទ្ធភាព។ ក្នុងការប្រើប្រាស់សម្ភារឧបទេសនេះ ប្រាកដណាស់ថាឧបករណ៍ជាច្រើនត្រូវបានបង្កើតឡើងដោយមិនបានដឹងពីឧបករណ៍ដទៃឡើយ ពេលខ្លះមានការប្រកួតប្រជែងគ្នា ហេតុនេះការត្រួតជាន់គ្នា និងការប្រទាំងប្រទើសគ្នា មុខជាកើតមានដោយជៀសមិនរួច។ ហេតុនេះ ការបង្កើត 'ក្បួន' ដែលល្អឥតខ្ចោះ ផ្តើមចេញពីឧបករណ៍ទាំងនោះជាការលំបាក។ ការណ៍នេះអាចធ្វើបានតែតាមរយៈការសាកល្បងស្ទានៗ និងតាមរយៈការសម្របតាមកាល វេលាពីសំណាក់អ្នកប្រើប្រាស់តែប៉ុណ្ណោះ។

## សទ្ទានុក្រមនិងគន្ថនិទ្ទេស

សទ្ទានុក្រមនៅក្នុងឧបសម្ព័ន្ធ២ ពន្យល់បច្ចេកសព្ទដែលបានប្រើនៅក្នុងសៀវភៅណែនាំដែលផ្អែកលើការអនុវត្តជាក់ស្តែង។ គន្ថនិទ្ទេសនៅក្នុងឧបសម្ព័ន្ធ៣ ត្រូវបានអ្នកនិពន្ធរៀបរៀងទៅតាមអក្ខរាក្រមដែលចែកចេញជាចំណងជើងចំនួនប្រាំគឺ លក្ខណៈទូទៅ ការយល់ដឹង ការរៀបចំ ការចូលរួម និងការជានា។ ព័ត៌មាននីមួយៗនៅក្នុងគន្ថនិទ្ទេសគឺជាព័ត៌មានយោងដែលមានលក្ខណៈស្តង់ដារពេញលេញ មានទំនាក់ទំនងជិតស្និទ្ធជាមួយគេហទំព័រ ដែលអាចរកមើលឯកសារបាន។

## ការដាក់បញ្ចូលគ្នា៖ ឧបករណ៍សម្រាប់បណ្តាសកម្មភាពដែលលោកអ្នកត្រូវប្រកាន់យក

នៅពេលដែលលោកអ្នកកំណត់បាននូវគោលដៅសមស្របនៅក្នុងបរិបទរបស់លោកអ្នករួចហើយ និងចងចាំក្នុងចិត្តនូវការណែនាំខាងលើអំពីលក្ខណៈ និងចំណុចសំខាន់នៃឧបករណ៍ និងដឹងកន្លែងដែលត្រូវរកមើលឧបករណ៍ទាំង

នោះ សម្ភារឧបទេសនេះអាចនឹងជួយលោកអ្នកក្នុងការសម្រេចចិត្តអំពីសកម្មភាពមួយចំនួន។ សម្ភារឧបទេសនេះអាចជួយលោកអ្នកឱ្យ៖

- ជ្រើសរើសឧបករណ៍ល្អបំផុតសម្រាប់ស្ថានភាពរបស់លោកអ្នក ជា 'កញ្ចប់' សកម្មភាពក្នុងការយល់ដឹង ការរៀបចំ ការចូលរួម និងការជានា
- ដឹងថាឧបករណ៍មួយចំនួនមានសារសំខាន់ខ្លាំងក្នុងការត្រៀមខ្លួនសម្រាប់ការងារ អភិបាលកិច្ចជាជាងសម្រាប់តែការងារអភិបាលកិច្ចដោយផ្ទាល់
- កំណត់ចំណងទាក់ទងសំខាន់ៗ និងលំដាប់លំដោយដែលអាចមានក្នុងចំណោមឧបករណ៍ និងសកម្មភាពនានា
- វាយតម្លៃវិធីដែលលោកអ្នកអាចធ្វើការជាមួយភាគីពាក់ព័ន្ធដទៃក៏ដូចជាធ្វើការដោយខ្លួនឯង
- កំណត់អត្តសញ្ញាណអ្នកដែលត្រូវចូលរួមនៅក្នុងសកម្មភាពនីមួយៗ និងអាចកំណត់ប្រភេទសមត្ថភាព និងអ្នកឯកទេសដែលអាចជួយ
- គណនាពេលវេលា និងធនធានដែលត្រូវការក្នុងការអនុវត្តសកម្មភាពនានា

ជាចុងក្រោយ យើងសង្ឃឹមថាលោក-អ្នកនឹងធ្វើការទាក់ទងគ្នា។ ប្រសិនបើលោកអ្នកមានបំណងផ្តល់មតិលើទិដ្ឋភាពណាមួយនៃសៀវភៅណែនាំ និងសម្ភារឧបទេសនេះ យើងមានសេចក្តីសោមនស្សរីករាយក្នុងការស្តាប់ និងទទួលជ្រាបពីលោកអ្នក។ បទពិសោធន៍ និងគំនិតរបស់លោកអ្នក និងបណ្តាញទំនាក់ទំនងដែលលោកអ្នកបង្កើតចំពោះព័ត៌មានបន្ថែមអាចជួយកែលម្អ សៀវភៅណែនាំអនុវត្តជាក់ស្តែងនេះ។

ឧបករណ៍សម្រាប់យល់ដឹង

## វិធីប្រើប្រាស់សញ្ញាសម្គាល់

**កម្រិតនិងគុណភាពនៃព័ត៌មាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

កម្រិតនិងគុណភាពព័ត៌មានដែលមានស្រាប់ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ ដែលឧបករណ៍នេះមានភាពសមស្រប។ កងស្ពឺមួយជា កម្រិតទាប (មានន័យថា មិនចាំបាច់មានព័ត៌មានច្រើនឡើយនិងមានការ រួមបញ្ចូលភាគីពាក់ព័ន្ធដើម្បីប្រើប្រាស់ឧបករណ៍នេះ) កងស្ពឺបួនគឺជាកម្រិតខ្ពស់ (មានន័យថាចាំបាច់ត្រូវមានព័ត៌មានសម្បូណ៌បែបហើយមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ដើម្បីប្រើឧបករណ៍នេះ)។

**តម្រូវការធនធាន**

បរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍នេះ ដំណើរការបាន។ ដើមឈើមួយដើម គឺបរិមាណតិច ដើមឈើបួនដើម គឺបរិមាណច្រើន។

# A. ឧបករណ៍សម្រាប់ការយល់ដឹង




## ហេតុអ្វីបានជាការយល់ដឹងមានសារសំខាន់ សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ

ការយល់ដឹងអំពីបរិបទនៃសិទ្ធិកាន់កាប់ និងអភិបាលកិច្ចបច្ចុប្បន្ន គឺជាជំហានសំខាន់មួយក្នុងកិច្ចប្រឹងប្រែងរៀបចំ និងផ្លាស់ប្តូរអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើដែលមានការទទួលខុសត្រូវ។ ការយល់ដឹងអំពីសម្បត្តិនិងសេវាព្រៃឈើ យល់ដឹងអំពីមុខងាររបស់វានៅក្នុងជីវភាពរស់នៅរបស់ប្រជាជន យល់ដឹងអំពីការរៀបចំសិទ្ធិកាន់កាប់ និងយល់ដឹងអំពី បរិបទនយោបាយ និងស្ថាប័នសុទ្ធសឹងមានលក្ខណៈជាសារវន្តក្នុងការកសាងរូបភាពអំពីវិធីរៀបចំការកាន់កាប់បច្ចុប្បន្ន ឱ្យត្រូវគ្នាជាមួយជីវភាព និងបំណងប្រាថ្នារបស់ប្រជាជន។ ចំណុចសំខាន់គឺគប្បីយល់ដឹងស្ថានភាពពិតជាក់ស្តែង ដែលអាចមានភាពខុសគ្នាជាខ្លាំងរវាងឯកសារគោលនយោបាយ និងអ្វីដែលកើតមានជាក់ស្តែង។

សំខាន់ ទស្សនវិស័យ បទពិសោធន៍និងចំណេះដឹងនានាគឺត្រូវតែទទួលបានមកពីប្រជាជនរងគ្រោះ ដែលការណ៍ នេះមានសារសំខាន់ចំពោះអភិបាលកិច្ចលើសិទ្ធិកាន់កាប់។ ហេតុនេះហើយការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធ សមស្របគឺជាគន្លឹះ។

ការប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រដែលមានការចូលរួមមានគោលបំណងពីរយ៉ាង។ ការធ្វើបែបនេះនឹងជួយ ដល់ដំណើរការជាក់ស្តែងអំពីទស្សនវិស័យរបស់ភាគីពាក់ព័ន្ធហើយក៏ធានាថា អ្នកទាំងឡាយណាដែលបានរួមចំណែក មានឱកាសកសាងការយល់ដឹងផ្ទាល់របស់ខ្លួន អំពីរូបភាពកាន់តែធំក្នុងការរៀបចំការចរចា និងពិភាក្សាក្នុងពេល អនាគតជុំវិញសិទ្ធិកាន់កាប់ និងអភិបាលកិច្ចព្រៃឈើ។

ការបន្តពិចារណា និងការពិនិត្យបញ្ហាទាំងនេះមានសារសំខាន់ជាខ្លាំង។ អ្វីដែលកាលពីដំបូង ទំនងជា 'បញ្ហា' អាច មានមូលហេតុចម្បងដែលត្រូវដោះស្រាយឱ្យបានកាន់តែឆាប់ហើសតាមរយៈ ការស្រាវជ្រាវបន្ថែម។ ការវាយតម្លៃបឋម អាចមិនបានរួមបញ្ចូលនូវទស្សនៈរបស់អ្នកពាក់ព័ន្ធឡើយ ហេតុនេះគប្បីពិនិត្យវិសាលភាពនៃភាគីពាក់ព័ន្ធដែលត្រូវ ពិគ្រោះយោបល់ និងដែលត្រូវចូលរួម។ ការបង្កើតឱកាសសម្រាប់ពិចារណា និងរៀនសូត្រមានសារសំខាន់ជាខ្លាំង។

## ពិនិត្យមើល និងការអនុវត្តឧបករណ៍នានានៅក្នុងផ្នែកនេះ

ផ្នែកនេះផ្តល់ជូននូវឧបករណ៍មួយចំនួនដើម្បីបង្កើនការយល់ដឹង។ ឧបករណ៍ទាំងនោះត្រូវបានរៀបចំជុំវិញបញ្ហាបរិបទសំខាន់ៗដែលប៉ះពាល់ដល់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធានព្រៃឈើ។ ចាំបាច់ត្រូវយល់ដឹងបញ្ហាទាំងនេះឱ្យបានល្អមុនពេលធ្វើអន្តរាគមន៍៖

- A1. **ការវាយតម្លៃមូលដ្ឋានធនធានជីវសាស្ត្រ**-ការកំណត់ទំហំ និងស្ថានភាពនៃសម្បត្តិ និងសេវាព្រៃឈើដែលត្រូវឬដែលអាចជាកម្មវត្ថុនៃការរៀបចំសិទ្ធិកាន់កាប់ផ្លូវការ និងក្រៅផ្លូវការ។
- A2. **ការយល់ដឹងមុខងារនៃសម្បត្តិ និងសេវាព្រៃឈើក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន**-ការណ៍នេះរួមមានការពិចារណាទស្សនវិស័យរបស់ស្ត្រីជនជាតិដើមភាគតិច និង/ឬប្រជាជនក្រីក្រតាមផ្នែកផ្សេងៗក្នុងសង្គមហើយក៏ពិចារណាមុខងារព្រៃឈើនៅក្នុងប្រព័ន្ធទូលំទូលាយដូចជាកសិកម្មវិលជុំជាដើម។
- A3. **ការទទួលស្គាល់ការរៀបចំក្នុងពេលបច្ចុប្បន្ន និងអតីតកាល និងការដណ្តើមកាន់កាប់ព្រៃឈើ**-ការយល់ដឹងអំពីរបៀបដែលសុវត្ថិភាពនៃសិទ្ធិកាន់កាប់ និងការអនុវត្តព្រៃឈើរងផលប៉ះពាល់ដោយសារបរិបទ និងទំនាស់នៃការកាន់កាប់ក្នុងពេលកន្លងទៅ និងក្នុងពេលបច្ចុប្បន្នក៏ដូចជាការកាន់កាប់ផ្លូវការ និងក្រៅផ្លូវការ។
- A4. **ការសិក្សាបរិបទនយោបាយ និងស្ថាប័ន**-ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធស្ថាប័ន និងគោលនយោបាយសំខាន់ៗដែលមានឥទ្ធិពល និងដែលរងផលប៉ះពាល់ដោយប្រព័ន្ធកាន់កាប់ព្រៃឈើនានាព្រមទាំងការវាយតម្លៃភាពយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាពនៃប្រព័ន្ធទាំងនេះ។
- A5. **ការកំណត់ឱកាសសម្រាប់ផ្លាស់ប្តូរ**ជាការរៀបចំសិទ្ធិកាន់កាប់ ជាពិសេសសម្រាប់ពលរដ្ឋក្រីក្រ និងក្រុមអ្នកមិនត្រូវបានយកចិត្តទុកដាក់ដើម្បីបង្កើនសំឡេងរបស់ពួកគេ។

ការស្រាវជ្រាវបញ្ហាបរិបទទាំងនេះនឹងជួយបំភ្លឺឱកាស និងច្រកចូលដែលមានសក្តានុពលដើម្បីកែលម្អអភិបាលកិច្ចនៃសិទ្ធិកាន់កាប់ព្រៃឈើប្រកបដោយស្មារតីទទួលខុសត្រូវ។ មានលទ្ធភាពជាច្រើនដែលថានឹងមានចំណងទាក់ទងគ្នានឹងគ្នារវាងបញ្ហាទាំងនេះ។ ឧទាហរណ៍ ស្ថាប័នមូលដ្ឋានអាចបង្កើតឱ្យមានការរៀបចំសិទ្ធិកាន់កាប់ក្នុងពេលកន្លងទៅតាមបែបប្រពៃណី ប៉ុន្តែមិនត្រូវគ្នាជាមួយអាទិភាពនយោបាយបច្ចុប្បន្ន។ លោកអ្នកចាំបាច់ត្រូវចងចាំចំណុចនេះ នៅពេលប្រើប្រាស់ឧបករណ៍ដែលនឹងលើកយកមកបង្ហាញ និងនៅពេលធ្វើការសម្រេចចិត្តជ្រើសយកឧបករណ៍មួយ ឬឧបករណ៍ច្រើនដែលសមស្របបំផុតសម្រាប់បរិបទរបស់លោកអ្នក។

លោកអ្នកអាចជ្រើសយកឧបករណ៍ចេញពីឧបករណ៍ដែលបានផ្តល់ជូននៅទីនេះ ទៅតាមតម្រូវការរបស់លោកអ្នកទៅតាមបរិបទអភិបាលកិច្ចដែលលោកអ្នកកំពុងប្រតិបត្តិ និងទៅតាមកម្រិតធនធានរបស់លោកអ្នក។ មានវិធីសាស្ត្រច្រើនបែប វិធីសាស្ត្រមួយចំនួនមានលក្ខណៈផ្លូវការ និងមានមូលដ្ឋានវិទ្យាសាស្ត្រជាងវិធីសាស្ត្រដទៃដែលមានមូលដ្ឋានផ្អែកលើសហគមន៍។ ក្នុងស្ថានភាពជាច្រើនសំខាន់ត្រូវមានវិធីសាស្ត្រចម្រុះដើម្បីកសាងរូបភាពមួយដែលមានគុណភាពប្រសើរជាងមុន។ ឧបករណ៍ទាំងនោះក៏ប្រែប្រួលនៅក្នុងបរិយាកាសរបស់វាផងដែរ ពោលគឺ ប្រែប្រួលទីតាមស្ថានភាពសហគមន៍ព្រៃឈើស្ថាប័នជាតិជាដើម។ក្នុងករណីជាច្រើនគេអាចសម្របឧបករណ៍ទាំងនោះទៅតាមស្ថានភាពរបស់អ្នកប្រើ។

ឧបករណ៍នេះអាចបង្កើតព័ត៌មានជាច្រើន។ ផ្នែក A5 គឺជាការវិភាគទិន្នន័យ ដែលបានប្រមូលអមដោយការយកចិត្តទុកដាក់ផ្តោតលើការកំណត់ឱកាស និងកំណត់រកច្រកចូលដើម្បីធ្វើការផ្លាស់ប្តូរ។

តាមរយៈការទទួលយកមកប្រើប្រាស់ និងការសម្របសម្រួលឧបករណ៍នៅក្នុងផ្នែកនេះលោកអ្នកនឹង៖

- យល់ដឹងបានច្បាស់លាស់អំពីបរិបទបច្ចុប្បន្ន អំពីរបៀបគ្រប់គ្រងសិទ្ធិកាន់កាប់ព្រៃឈើ និងអំពីទំនាក់ទំនងរវាងបញ្ហាផ្សេងគ្នាក្នុងការបង្កើតស្ថានភាពបច្ចុប្បន្ន (រាប់ទាំងទំនាស់ផងដែរ)
- កំណត់កន្លែងដែលត្រូវយកចិត្តទុកដាក់ និងចាត់សកម្មភាពបន្ថែមទៀត

# ឧបករណ៍និងវិធីសាស្ត្រនានាសម្រាប់យល់ដឹង

## A1. ការវាយតម្លៃមូលដ្ឋានធនធានជីវសាស្ត្រ

អ្វីជាស្ថានភាពនៃធនធានព្រៃឈើ?តើអ្វីជាទំនិញនិងសេវាដែលផ្តល់ដោយព្រៃឈើ? តើទំនិញនិងសេវានេះអាចប្រែប្រួលតាមកាលកំណត់យ៉ាងដូចម្តេច? ដើម្បីឱ្យមានការយល់ដឹងអំពីធនធានព្រៃឈើក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត សំខាន់ត្រូវប៉ាន់ប្រមាណតម្លៃអភិរក្សក៏ដូចជាសម្បត្តិ និងសេវាដែលព្រៃឈើផ្តល់ឱ្យ។

ទំហំ និងគុណភាពនៃធនធាន និងតម្លៃអភិរក្សអាចត្រូវបានវាយតម្លៃតាមវិធីផ្សេងគ្នា - ពីការវាយតម្លៃនៅសហគមន៍ដើម្បីកសាងផែនទីដោយប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)ចំពោះការគួបផ្សំចំណុចទាំងពីរ។ បន្ថែមលើនេះ គប្បីវិភាគការគំរាមកំហែង និងឱកាសទាក់ទងនឹងធនធានព្រៃឈើ។ គេក៏អាចប្រើវិធីសាស្ត្រដែលកាន់តែមានភាពរស់រវើក ដើម្បីពិនិត្យមើលលទ្ធភាពប្រែប្រួលនៃធនធានទៅតាមកាលកំណត់ផងដែរ។

សំខាន់ត្រូវឱ្យដឹងប្រាកដថានរណាមានសិទ្ធិចំពោះសម្បត្តិ និងសេវាព្រៃឈើទាំងនេះហើយតើសម្បត្តិ និងសេវាទាំងនោះកំពុងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ហើយនរណាជាអ្នកប្រើប្រាស់។ សិទ្ធិនានាទាក់ទងនឹងព្រៃឈើ និងធនធានព្រៃឈើដែលត្រូវពិចារណារួមមានសិទ្ធិលើដីព្រៃ សិទ្ធិលើដើមឈើ (ដូចជាដើម Brazil-nut) និងផលិតផលមិនមែនព្រៃឈើ (ស្មៅ ផ្លែឈើ ឈើប្រឡេះគ្រាប់។ល។) ក៏ដូចជាសិទ្ធិបរបាញ់ សិទ្ធិបន្សុីស្មៅ និងសិទ្ធិទទួលបាន និងសិទ្ធិកម្មសិទ្ធិបញ្ញាចំពោះរុក្ខជាតិឱសថ។

ចំពោះដីព្រៃឈើ សម្បត្តិ និងសេវាដែលស្ថិតនៅក្រោម ឬអាចស្ថិតនៅក្រោមការចាត់ចែង សិទ្ធិកាន់កាប់ដែលកាន់តែមានលក្ខណៈស្មុគស្មាញ និងប្រកួតប្រជែងដោយសារសក្តានុពលក្នុងការទទួលផលប្រយោជន៍ពីមុខងាររបស់ព្រៃឈើ ក្នុងការចាប់យក និងរក្សាទុកកាបូន ព្រមទាំងសេវាបរិស្ថានដទៃទៀតមានសារសំខាន់ផ្នែកនយោបាយ។ អនាគតភាពព្រៃឈើ ពិតជាបានរួមចំណែកក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវចម្រុះ និងការការពារជីវភាពរស់នៅរបស់ប្រជាជនបានផ្តោតយ៉ាងខ្លាំងលើម្ចាស់កម្មសិទ្ធិ អ្នកគ្រប់គ្រង និងអ្នកទទួលផលពីធនធានព្រៃឈើ។

គំនិតផ្តួចផ្តើមពីដោគំនិតផ្តួចផ្តើមគន្លឹះគឺការកាត់បន្ថយការបំភាយឧស្ម័នពីការកាប់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD) និងការបង់ថ្លៃសេវាបរិស្ថាន (PES)។ REDD គឺជាកិច្ចប្រឹងប្រែងមួយ ដើម្បីបង្កើតតម្លៃហិរញ្ញវត្ថុ ចំពោះកាបូនដែលស្តុកទុកក្នុងព្រៃ ជាថវិការលើកទឹកចិត្តឱ្យប្រទេសកំពុងអភិវឌ្ឍន៍កាត់បន្ថយការបំភាយឧស្ម័ន ពីដីព្រៃ និងវិនិយោគលើមាគ៌ាទៅកាន់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែលមានកាបូនទាប។ REDD+ មានវិសាលភាពលើសពីការកាប់ព្រៃឈើ និងការរេចរឹលព្រៃឈើក្នុងការរួមបញ្ចូលឥទ្ធិពលនៃការអភិរក្សការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការបង្កើនសន្និធិកាបូនព្រៃឈើ។ PES (ច្រើនតែផ្អែកលើទីផ្សារ) គឺជាយន្តការផ្តល់ការលើកទឹកចិត្តដល់កសិករ ម្ចាស់ព្រៃឈើ ឬម្ចាស់ដីជាថ្នូរនឹងការគ្រប់គ្រងដី ឬព្រៃឈើរបស់ពួកគេក្នុងការផ្តល់សេវាជាក់លាក់ ដូចជាការចាប់យក និងសន្និធិកាបូនការការពារទីជម្រាល ការអភិរក្សជីវចម្រុះ ឬសោភ័ណភាពនៃទេសភាព (សណ្ឋានដី)។

## ឧបករណ៍គួរប្រើ

### A1.1 សារពើភណ្ឌព្រៃឈើជាតិ និងការវាយតម្លៃធនធានព្រៃឈើ

| | |
|---|---|
| **នេះជាអ្វី?** | ការវាយតម្លៃគុណភាព និងបរិមាណនៃសម្បត្តិ និងសេវាព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការវាយតម្លៃនេះផ្តល់ព័ត៌មានពេញលេញអំពីស្ថានភាព ថាមវន្តប្រែប្រួលនិងការឆ្លើយតបនៃប្រព័ន្ធបរិស្ថានព្រៃឈើ។ ការវាយតម្លៃនេះអាចប្រើសម្រាប់ជូនដំណឹង អំពីគោលនយោបាយ រៀបចំផែនការ និងយុទ្ធសាស្ត្រ គ្រប់គ្រង និងដើម្បីព្យាករណ៍សម្រាប់អនាគតកាល។ |
| **ធាតុផ្សំសំខាន់ៗ** | ការវាយតម្លៃធនធានព្រៃឈើពិនិត្យមើលផលប្រយោជន៍ ពីព្រៃឈើនិងការប្រែប្រួលធនធានទាំងនោះទៅតាមកាលកំណត់។ ទាំងនេះរួមមានទំហំនៃធនធានព្រៃឈើ សុខភាព និងអនុភាពប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ជីវសាស្ត្រចម្រុះ មុខងារផលិតនៃព្រៃឈើ និងមុខងារការពារនៃព្រៃឈើ ព្រមទាំងមុខងារសង្គមសេដ្ឋកិច្ចនៃព្រៃឈើ។ វិធីសាស្ត្រនេះ ជាវិធីរៀបចំសំណាកនៅទូទាំងប្រទេស និងការប្រមូលទិន្នន័យនៅតាមមូលដ្ឋាន ហើយអាចច្របាច់បញ្ចូលជាមួយ ទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ចលើការចិញ្ចឹមជីវិតនៅមូលដ្ឋាន។ |
| **ព័ត៌មានបន្ថែម** | FAO. 2009. National forest monitoring and assessment – manual for integrated field data collection. Version 2.3. FAO National Forest Monitoring and Assessment Working Paper NFMA 37/E. Rome. http://www.fao.org/forestry/19900-026212d9ecb093f72c140429df893aea7.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3.2, C2.6 |

### A1.2 ការវាស់ស្ទង់និងការតាមដានព្រៃឈើពីសំណាក់សហគមន៍គិតទាំងសន្និធិកាបូនផងដែរ

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍សម្រាប់សហគមន៍ប៉ាន់ប្រមាណនិងតាមដានស្តុក និងលំហូរផលិតផល និងសេវានានានៅក្នុងព្រៃឈើរបស់ពួកគេ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ព័ត៌មានដែលប្រមូលបានអំពីការអភិវឌ្ឍនិងការប្រើប្រាស់សម្បត្តិនិងសេវាព្រៃឈើអាចត្រូវបានប្រើសម្រាប់តាមដានការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាននិងដើម្បីបង្កើតនិងដំណើរការគម្រោង REDD+ និងគម្រោង PES។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍ទាំងនេះផ្តល់វិធីសាស្ត្រដែលមានលក្ខណៈអនុវត្តជាក់ស្តែងចំពោះការតាមដានព្រៃឈើក្នុងស្រុក។ គេអាចប្រើវិធានទាក់យកកាបូនទាំងនេះដើម្បីប៉ាន់ស្មាននិងតាមដានកាបូននៅក្នុងព្រៃតាមរយៈការអង្កេតមើលដើមឈើ ស្មៅ តិណជាតិ សំរាម និងដី។ មានប្រព័ន្ធចល័តមួយសម្រាប់កត់ត្រានិងរាយការណ៍ការវាស់វែងទាំងនេះទម្រង់អេឡិចត្រូនិក។ ហើយក៏រួមមានការណែនាំអំពីវិធីប្រើប្រាស់ប្រព័ន្ធ GPS ចល័តសម្រាប់កំណត់ទីតាំងលើផែនទី កត់ត្រាទិន្នន័យ និងកំណត់ខ័ណ្ឌសីមា ព្រមទាំងរបៀបធ្វើការវាយតម្លៃកាបូនជាមូលដ្ឋានជាមួយប្រព័ន្ធនេះផងដែរ។<br><br>ឧបករណ៍នេះចែកចេញជាបីផ្នែក៖ សម្រាប់សហគមន៍មូលដ្ឋានដែលត្រូវអនុវត្តការងារនេះ សម្រាប់អ្នកបណ្តុះបណ្តាលដើម្បីគាំទ្រសហគមន៍ និងអ្នកធ្វើគោលនយោបាយដែលត្រូវប្រើប្រាស់ព័ត៌មានដែលបានប្រមូល។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Mhina, M., Topp-Jørgensen, E. & Poulsen, M.K. 2003. Preliminary manual for community based monitoring of natural resource use and forest quality (English and Swahili versions). Iringa, Tanzania, District Lands, Natural Resources and Environmental Office. http://www.nordeco.dk/assets/279/Tz%20Monitoring %20Manual%20English.pdf<br>Gibson, D. 2011. Manual for the introduction and implementation of the management oriented monitoring system. Gland, Switzerland, WWF. http://www.sacfnet. org/index.php/the-news/natural-resources-management/natural-resources-management?download=97%3Amanagement-orientedmonitoring-systems-manualpdf<br>Lewis, J. & Nkuintchua, T. 2012. Accessible technologies and FPIC: independent monitoring with forest communities in Cameroon. Participatory Learning and Action, 65: 151–165. http://pubs.iied.org/14618IIED.html<br>Verplanke, J.J. & Zahabu, E. (eds.) 2009. A field guide for assessing and monitoring reduced forest degradation and carbon sequestration by local communities. Twente, The Netherlands, Project team KYOTO: Think Global, Act Local (K:TGAL). http://www.communitycarbonforestry.org/Online%20Fieldguide%20 full%20123.pdf<br>Skutsch, M. 2010. Community forest monitoring for the carbon market. London, Earthscan. |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A3.2 |

## ការវាយតម្លៃសន្និធិកាបូន

**A1.3**

| | |
|---|---|
| **អ្វីទៅហៅថាការវាយតម្លៃសន្និធិកាបូន ?** | ជាក្របខ័ណ្ឌវិធីសាស្ត្រសម្រាប់វាស់វែងនិងវិភាគអាងស្រូបកាបូន ( Carbon sinks ) នៅត្រង់ទីកន្លែងណាមួយ ។ |
| **តើគេអាចប្រើការវាយតម្លៃនេះសម្រាប់ធ្វើអ្វី ?** | ផ្តល់ចំណេះដឹងដែលពាក់ព័ន្ធអំពីអាងស្រូបកាបូនផ្អែកលើក្របខ័ណ្ឌត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ ដែលគេអាចប្រើប្រាស់ខណៈពិចារណាអំពីសកម្មភាពនានាក្នុងការលើកកម្ពស់ជីវភាពក្នុងស្រុក និងកាត់បន្ថយភាពក្រីក្រ ។ |
| **ធាតុផ្សំសំខាន់ៗ** | ជំហាននានាដើម្បីវាយតម្លៃសន្និធិកាបូន រួមមានការសិក្សាទិដ្ឋភាពសណ្ឋានដី ចំណេះដឹងផ្អែកបរិស្ថាននៅមូលដ្ឋាន អង្កេតសេដ្ឋកិច្ចសង្គម ការសិក្សាពីចម្ងាយ ( Remote sensing ) និងការសិក្សាសេណារីយ៉ូអំពីការប្រែប្រួលនៅក្នុងសន្និធិកាបូន និងសុខុមាលភាព ។ បន្ទាប់មកត្រូវយកព័ត៌មាននោះទៅវិភាគជាមួយបរិបទគោលនយោបាយ ការប្រើប្រាស់ដីធ្លី និងជីវភាពរស់នៅរបស់ប្រជាជនដើម្បីពិនិត្យលទ្ធភាពផ្លាស់ប្តូរការអនុវត្តនិងគោលនយោបាយដើម្បីបង្កើនការស្រូបទុក ។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>ICRAF. Rapid Carbon Stock Appraisal (RaCSA): a rapid but integrated way to assess landscape carbon stocks [Online Resource]. http://www.worldagroforestrycentre.org/Sea/Projects/tulsea2/racsa |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A2 |

## A1.4 ការសិក្សាវាយតម្លៃរហ័សអំពីការប្រតិបត្តិ ប្រព័ន្ធ និងបច្ចេកវិទ្យាកសិរុក្ខកម្ម

| | |
|---|---|
| **ការសិក្សាវាយតម្លៃរហ័សអំពីការប្រតិបត្តិ ប្រព័ន្ធ និងបច្ចេកវិទ្យាកសិរុក្ខកម្មជាអ្វី?** | ឧបករណ៍ផ្តល់ព័ត៌មានច្បាស់លាស់អំពីការប្រើប្រាស់ដើមឈើនិងការគ្រប់គ្រងប្រព័ន្ធកសិរុក្ខកម្ម |
| **តើគេអាចប្រើការសិក្សាវាយតម្លៃនេះ សម្រាប់ធ្វើអ្វី?** | ដើម្បីយល់ដឹងអំពីរបៀបប្រើប្រាស់ប្រព័ន្ធកសិរុក្ខកម្ម និងការប្រើប្រាស់ក្នុងការចិញ្ចឹមជីវិតនៅជនបទ |
| **ធាតុផ្សំសំខាន់ៗ** | ដំណើរការសិក្សាវាយតម្លៃរហ័សអំពីការអនុវត្តប្រព័ន្ធ និងបច្ចេកវិទ្យាកសិរុក្ខកម្ម រួមមាន ការព្រមព្រៀងគ្នាលើបច្ចេកសព្ទសម្រាប់ចាត់ថ្នាក់ការប្រើប្រាស់ផ្សេងគ្នាចំពោះដីនិងដើមឈើ ការអង្កេតប្រភព កម្មសិទ្ធិភាព ការប្រើប្រាស់ និងការគ្រប់គ្រងព្រៃឈើ ការវាយតម្លៃចំណេះដឹងផ្នែកបរិស្ថានក្នុងស្រុក និងកម្មសិទ្ធិបញ្ញាទាក់ទងនឹងដើមឈើ ការវាយតម្លៃអន្តរកម្មរវាងប្រភេទដើមឈើ និងផ្នែកផ្សេងទៀតនៃប្រព័ន្ធបរិស្ថាន ការវាយតម្លៃសេដ្ឋកិច្ច និងការវាយតម្លៃលទ្ធភាពទទួលបានផលចំណេញ ពីប្រព័ន្ធនេះ ការវាយតម្លៃផលប៉ះពាល់នៃដើមឈើ និងសិទ្ធិកាន់កាប់ដីធ្លី និងអំពីបញ្ហាគោលនយោបាយ ព្រមទាំងវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងនៅក្នុងប្រព័ន្ធបច្ចុប្បន្ន ដើម្បីសំយោគរបកគំហើញនានា។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>ICRAF. 2009. RAFT: Rapid appraisal of agroforestry practices, systems and tech-nology. Bogor, Indonesia, World Agroforestry Centre (ICRAF). http://www.worldagroforestry.org/sea/vn/publication?do=view_pub_detail&pub_no=LE0152-09 |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A.2.2, A4.5 |

## A1.5 កំណត់កន្លែងដែលមានតម្លៃអភិរក្សខ្ពស់

| | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រកំណត់រកទីកន្លែងដែលប្រភេទសម្បត្តិ និងសេវាមានតម្លៃអភិរក្សខ្ពស់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីព្រមព្រៀងលើជម្រើសគ្រប់គ្រងចំពោះកន្លែងដែលមានតម្លៃអភិរក្សខ្ពស់ដើម្បីឱ្យប្រាកដថាតម្លៃទាំងនោះត្រូវបានរក្សា ឬលើកកម្ពស់ និងតាមដាន។ |
| **ធាតុផ្សំសំខាន់ៗ** | ដំណើរការនេះរួមមានការវាយតម្លៃកន្លែងមួយដើម្បីកំណត់ទីតាំងតម្លៃអភិរក្សខ្ពស់ (ទាំងតម្លៃសង្គម និងបរិស្ថាន) និងកំណត់ការគំរាមកំហែងចំពោះតម្លៃទាំងនោះ។ លំហាត់នេះនឹងជួយកំណត់សារសំខាន់នៃការអភិរក្សកន្លែងនោះតាមគោលការណ៍ដែលបានកំណត់នៅថ្នាក់ជាតិ។ គោលការណ៍ទាំងនោះក៏ត្រូវពិចារណាដល់អភិបាលកិច្ចលើការកាន់កាប់ព្រៃឈើពាក់ព័ន្ធផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>Proforest. 2008. Good practice guidelines for High conservation value assessments: Toolkit – Part 3: Identifying and managing high conservation values forests: a guide for forest managers. Oxford, UK. http://www.hcvnetwork.org/ resources/global-hcv-toolkits/hcvf-toolkit-part-3.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A2.1, A4.9 |

## ការវាយតម្លៃទិដ្ឋភាពតំបន់ទេសភាពចម្រុះ

**A1.6**

| | |
|---|---|
| **នេះជាអ្វី?** | អង្កេតអន្តរវិស័យដើម្បីបង្កើតរូបភាពតម្លៃស៊ីសង្វាក់គ្នានៃ ធនធាននៅក្នុងតំបន់ទេសភាពណាមួយ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីផ្តល់ដំណឹងដល់អាជ្ញាធរមូលដ្ឋានឬរដ្ឋាភិបាលថ្នាក់ជាតិអំពីតម្លៃនៃតំបន់ទេសភាពនោះទៅកាន់សហគមន៍មូលដ្ឋាន។ |
| **ធាតុផ្សំសំខាន់ៗ** | ការរួមផ្សំនៃអង្កេតបរិស្ថាន និងអង្កេតសេដ្ឋកិច្ចសង្គមរបស់ភូមិបន្ទាន់មួយ។ បច្ចេកទេសបរិស្ថានរួមមានការពណ៌នាអំពីទីតាំង ការកសាងសំណាកដើមឈើ និងការអង្កេតដី។ អង្កេតភូមិរួមមានការសម្ភាសដែលបានព្រាងសំណួរជាមុន អង្កេតគ្រួសារ និងលំហាត់ដែលមានការចូលរួម ដើម្បីពិនិត្យរកមើលទិដ្ឋភាពតំបន់ទេសភាពដែលមានសារសំខាន់ ចំពោះសហគមន៍មូលដ្ឋាន។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>CIFOR. Multi-disciplinary landscape assessment [Online Resource]. http://www. cifor. cgiar.org/mla/_ref/home/index.htm |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A4.9 |

## បញ្ជីជីវចម្រុះរបស់ប្រជាជន

**A1.7**

| | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រ និងកម្រងទិន្នន័យសម្រាប់ប្រមូលចំណេះដឹងក្នុងស្រុក អំពីជីវចម្រុះតាមបែបក្រៅផ្លូវការ។ |
| **តើគេអាចប្រើការវាយតម្លៃនេះសម្រាប់ធ្វើអ្វី?** | បញ្ជីជីវចម្រុះត្រូវបានបង្កើតនៅប្រទេសឥណ្ឌាដែលគេអាចកត់ត្រា ប្រមូល និងប្រើប្រាស់ ចំណេះដឹងក្រៅផ្លូវការធ្វើជាធនធានតាមបែបវិទ្យាសាស្ត្រ។ |
| **ធាតុផ្សំសំខាន់ៗ** | បញ្ជីនីមួយៗមានព័ត៌មានពេញលេញអំពីអត្តិភាព និងចំណេះដឹងអំពីធនធានជីវសាស្ត្រ នៅក្នុងស្រុក អំពីការប្រើជាថ្នាំព្យាបាល ឬប្រើសម្រាប់គោលដៅផ្សេងព្រមទាំងចំណេះដឹង ប្រពៃណីពាក់ព័ន្ធដទៃទៀត។ បញ្ជីទាំងនោះពឹងផ្អែកលើកិច្ចសហប្រតិបត្តិការ និងធាតុចូល យ៉ាងច្រើនពីសហគមន៍មូលដ្ឋាន និងហាក់មានទំនោរផ្តោតលើការគ្រប់គ្រងលទ្ធភាពទទួលបានធនធានសេនេទិក និងការការពារចំណេះដឹងប្រពៃណី។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>National Biodiversity Authority. 2008. People's biodiversity register: simplified methodology. Chennai, India. http://nbaindia.in/uploaded/docs/simplified_ methodology_onpbr.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A3.2 |

| A1.8 | ការវាយតម្លៃការប្រែប្រួលគម្របព្រៃលើមូលដ្ឋានដើមឈើ |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រសម្រាប់វាយតម្លៃគម្របព្រៃទូទៅនៅតំបន់ត្រូពិក និងសម្រាប់តាមដានការកាប់ព្រៃឈើ។ |
| **តើគេអាចប្រើការវាយតម្លៃនេះសម្រាប់ធ្វើអ្វី?** | ការសង្កេត និងការវាយតម្លៃអំពីការប្រែប្រួលគម្របព្រៃសើមនៅតំបន់ត្រូពិក |
| **ធាតុផ្សំសំខាន់ៗ** | វិធីនេះយកទិន្នន័យ និងធាតុចូលយ៉ាងច្រើនដែលទទួលបានពីផ្កាយរណប និងពីបណ្តាញអ្នកជំនាញយកមកប្រើប្រាស់។ ល្បឿននៃការកាប់បំផ្លាញព្រៃឈើមានមូលដ្ឋានផ្អែកលើស្ថិតិ រួមមានការកសាងសំណាកឯកតាអង្កេតជាមួយនឹងសំណាកដែលមានល្បឿនខ្ពស់ចំពោះតំបន់ ដែលមានការប្រែប្រួលឆាប់រហ័ស។ វិធីសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីធ្វើឱ្យព័ត៌មាន មានទម្រង់សមស្របសម្រាប់សហគមន៍អ្នកប្រើប្រាស់តាមរយៈប្រព័ន្ធព័ត៌មានព្រៃឈើតំបន់ត្រូពិក។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>Achard, F., Stibig, H.J., Eva, H. & Mayaux, P. 2002. Tropical forest cover monitoring in the humid tropics – TREES project. Tropical Ecology, 43(1): 9–20. http://www.tropecol.com/pdf/open/PDF_43_1/43102.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A4.4 |

## A2. ការយល់ដឹងមុខងារនៃធនធាន និងសេវាកម្មព្រៃឈើក្នុងការទ្រទ្រង់ការចិញ្ចឹមជីវិត

តើព្រៃឈើទ្រទ្រង់ការចិញ្ចឹមជីវិតមនុស្សផ្សេងគ្នាយ៉ាងដូចម្តេច? តើមានទំនាក់ទំនងអ្វីខ្លះរវាងព្រៃឈើ និងភាពក្រីក្រ? តើការចាត់ចែងអំពីសិទ្ធិកាន់កាប់បច្ចុប្បន្ន ទ្រទ្រង់ដល់ប្រជាជនក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេដែរឬទេ? សំខាន់ត្រូវយល់ដឹងអំពីការប្រើប្រាស់សម្បត្តិ និងសេវាព្រៃឈើរបស់ប្រជាជនមូលដ្ឋាន និងមុខងារនៃការចាត់ចែងអំពីសិទ្ធិកាន់កាប់ចំពោះការវិភាគ ប្រព័ន្ធកាន់កាប់ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែមានសុវត្ថិភាព។

ទោះបីជាការរួមចំណែកនៃព្រៃឈើចំពោះការចិញ្ចឹមជីវិតនៅជនបទត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយក្តី ប៉ុន្តែជាញឹកញាប់វាមិនត្រូវបានគេ យល់ដឹងឱ្យបានត្រឹមត្រូវនោះទេ។ ជាអាទិ៍ មានឯកសារតិចតួចប៉ុណ្ណោះដែលមានព័ត៌មានអំពីរបៀបពឹងអាស្រ័យរបស់គ្រួសារជនបទចំពោះព្រៃឈើ និងធនធានដើមឈើក្នុងការបំពេញសេចក្តីត្រូវការប្រចាំថ្ងៃរបស់ពួកគេនិងការពឹងផ្អែកតិចតួចលើសក្តានុពលនៃធនធាននេះក្នុងការកាត់បន្ថយភាពក្រីក្រ។ជាលទ្ធផលអ្នករៀបចំគោលនយោបាយច្រើនតែមើលរំលងបញ្ហាទាំងនេះ។

នៅពេលវាយតម្លៃមុខងារធនធាន និងសេវាកម្មព្រៃឈើចំពោះជីវភាពរស់នៅរបស់ប្រជាជន សំខាន់ត្រូវទទួលស្គាល់និងយល់ដឹងអំពីរបៀបដែលភូមិណាមួយប្រើប្រាស់ធនធានព្រៃឈើនិងការពឹងអាស្រ័យលើធនធាននេះ តាមបែបផ្សេងៗគ្នា។ ធនធានទាំងនោះអាចមានសារសំខាន់ជាមូលដ្ឋានចំពោះជីវភាព ឬត្រូវបានប្រើប្រាស់ធ្វើជាសំណាញ់ សុវត្ថិភាពប្រចាំរដូវកាល ឬប្រើជាឱកាសដើម្បីចាកចេញពីភាពក្រីក្រ ឬប្រើប្រាស់វិធីទាំងពីរនេះរួមបញ្ចូលគ្នា។ ជាមួយគ្នានេះក៏មានភាពខុសគ្នាអំពីកម្រិតអំណាច លទ្ធភាពបានប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើ ស្របតាមទំហំនៃភាពក្រីក្រ កម្រិតនៃភាពអសន្តិសុខ និងលទ្ធភាពក្នុងការប្រើប្រាស់សម្បត្តិ និងឱកាសដទៃទៀតផងដែរ។

ការសិក្សាពីប្រភេទដែលមានសារប្រយោជន៍ ដែលបានបង្កើតឡើងនៅក្នុងបរិបទព្រៃឈើ បានបែងចែកភាពក្រីក្រជាបីប្រភេទ រួមមានការធ្លាក់ចុះនៃភាពក្រីក្រ ការសម្របតាមភាពក្រីក្រ និងការសម្រាលភាពក្រីក្រ។ អ្នកនៅក្នុងក្រុមទាំងនេះមានអសន្តិសុខ និងសមត្ថភាព ក្នុងកម្រិតខុសគ្នាក្នុងការទាមទារផលពីព្រៃឈើ ហេតុនេះមានកម្រិតចំណាប់អារម្មណ៍ខុសគ្នាលើសុវត្ថិភាព សម្បត្តិទ្រព្យ និងសិទ្ធិកាន់កាប់។

ស្ត្រី និងបុរសប្រើប្រាស់ និងគ្រប់គ្រងឈើមិនដូចគ្នាឡើយ។ ជារឿយៗ ស្ត្រីច្រើនតែជាអ្នកប្រើប្រាស់ព្រៃឈើជាចម្បង តាមរយៈការចូលរួមរបស់ពួកគេនៅក្នុងការផលិតអាហារចិញ្ចឹមក្រពះ ការប្រមែប្រមូលរុក្ខជាតិឱសថ ការរើសអុស និងរោងសិប្បកម្មព្រៃឈើខ្នាតតូច ក្នុងការបង្កើតផលិតផលសម្រាប់លក់យកប្រាក់កាស ប៉ុន្តែអាចរារាំងឱកាសរបស់ស្ត្រីក្នុងការកាត់បន្ថយភាពក្រីក្រ។

## ឧបករណ៍គួរប្រើ

### សម្ភារឧបទេសអំពីទំនាក់ទំនងរវាងភាពក្រីក្រ និងព្រៃឈើ — A2.1

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍សម្រាប់វាយតម្លៃព្រៃឈើជាក់លាក់នៅជនបទដែលមានការចូលរួម |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | សម្រាប់វិភាគយល់ដឹង និងជូនដំណឹងអំពីការរួមចំណែកនៃព្រៃឈើចំពោះជីវភាពរស់នៅរបស់ប្រជាជនក្រីក្រដែលរស់នៅក្នុង និងជុំវិញព្រៃឈើ |
| **ធាតុផ្សំសំខាន់ៗ** | ធនធានដែលមាននៅលើអ៊ីនធើណិតរួមមានការណែនាំជាជំហានៗ ដោយប្រើបច្ចេកទេសសិក្សាវាយតម្លៃនៅជនបទដែលមានការចូលរួម ដែលបានជ្រើសរើស និងធ្វើតេស្តយ៉ាងប្រុងប្រយ័ត្ន រួមមានការចាត់ថ្នាក់សម្បត្តិទ្រព្យ ការវិភាគជីវភាពរស់នៅ បញ្ហាព្រៃឈើ និងតារាងដំណោះស្រាយ និងការណែនាំអំពីការបណ្តុះបណ្តាលក៏ដូចជាឧទាហរណ៍ស្តីពីការករណីសិក្សានានា។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>PROFOR. 2009. Field manual: poverty–forests linkages oolkit. Washington, DC, The Program on Forests. http://www.profor.info/profor/content/poverty-forests-linkages-toolkit-table-contents |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A1.5, A4.9, A4.1 |

### ការវិភាគដែលមានការចូលរួមអំពីភាពក្រីក្រ ការចិញ្ចឹមជីវិត និងការប្រែប្រួលបរិស្ថាន — A2.2

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍ដែលមានការចូលរួមដើម្បីស្វែងរកមើលយុទ្ធសាស្ត្រចិញ្ចឹមជីវិតសំដៅកាត់បន្ថយភាពក្រីក្រ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | យល់ដឹងអំពីចំណងទាក់ទងរវាងការចិញ្ចឹមជីវិតរបស់ប្រជាជន កម្រិតនៃភាពក្រីក្រ និងបរិស្ថាន |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍នេះប្រើជំហានចំនួនប្រាំ ដើម្បីវិភាគយុទ្ធសាស្ត្រចិញ្ចឹមជីវិតដែលប្រជាជនប្រើ ដើម្បីចាកផុតពីភាពក្រីក្រ និងទំហំឥទ្ធិពលនៃយុទ្ធសាស្ត្រសំខាន់ៗទាំងនេះព្រមទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានមកលើបរិស្ថាន។ ជំហានទាំងនេះផ្តោតលើការវាយតម្លៃក្នុងស្រុកអំពីភាពក្រីក្រ និងបរិស្ថាន អំពីសកម្មភាពចិញ្ចឹមជីវិត ចំណងទាក់ទងរវាងធនធានធម្មជាតិ និងសកម្មភាព ចិញ្ចឹមជីវិត អត្តសញ្ញាណកម្មនៃវិបត្តិ ហានិភ័យនិងភាពងាយរងគ្រោះ ព្រមទាំងបញ្ហាស្ថាប័ននិងបញ្ហាគោលនយោបាយ។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>ICRAF. Participatory analysis of poverty, livelihoods and environment dynamics (PAPOLD) [Online Resource]. http://www.worldagroforestrycentre.org/Sea/ Projects/tulsea2/node/5<br>Krishna, A. Stages of progress: disaggregating poverty for better policy impact [Online Resource]. http://www.pubpol.duke.edu/krishna/ |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A1.5, A4.9, A4.1 |

## A2.3 ការណែនាំអំពីការវាយតម្លៃជាមូលដ្ឋានសម្រាប់សុខុមាលភាពរបស់មនុស្ស

| | |
|---|---|
| **នេះជាអ្វី?** | សៀវភៅណែនាំស្តីពីការស្វែងរកចំណងទាក់ទងរវាងសុខុមាលភាពមនុស្ស និងធនធានព្រៃឈើ។ |
| **តើគេអាចប្រើការណែនាំនេះសម្រាប់ធ្វើអ្វី?** | ត្រូវបានរៀបរៀងសម្រាប់ក្រុមហ៊ុនឈើវិស័យឯកជន សៀវភៅនេះផ្តល់ឧបករណ៍ដើម្បីបង្កើនការយល់ដឹងអំពីប្រជាជនដែលរស់នៅក្បែរ និងពឹងផ្អែកលើធនធានព្រៃឈើ |
| **ធាតុផ្សំសំខាន់ៗ** | ដំណើរការនេះមានប្រាំជំហាន៖ អត្តសញ្ញាណកម្មភាគីពាក់ព័ន្ធ ការវាយតម្លៃ អំពីសុវត្ថិភាពចំពោះលទ្ធភាពប្រើប្រាស់ធនធានពីជំនាន់មួយទៅជំនាន់មួយ ការវាយតម្លៃសិទ្ធិ និងកាតព្វកិច្ចក្នុងការគ្រប់គ្រងព្រៃឈើតាមបែបសហការណ៍ ការវាយតម្លៃសុខភាពព្រៃឈើ តួអង្គ និងវប្បធម៌ព្រៃឈើ និងវិធីដាក់ពិន្ទុតាមបែបបំប្រួញ។ |
| **ចំពោះព័ត៌មានបន្ថែម** | សូមអាន<br>Colfer, C.J.P. et al. 1999. The BAG: Basic assessment guide for human well-being. Criteria and Indicators Toolbox Series No. 5. Bogor, Indonesia, Center for International Forestry Research (CIFOR). http://www.cifor.org/livesinforests/ publications/pdf_files/ toolbox-5c.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A1.5, A4.9, A4.1 |

## A2.4 កម្រងសំណួរគំរូដើមអំពីបណ្តាញភាពក្រីក្រ និងបរិស្ថាន

| | |
|---|---|
| **នេះជាអ្វី?** | ជាឧបករណ៍មួយសម្រាប់ប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ច ដែលអាចប្រៀបធៀបគ្នាបាននៅកម្រិតគ្រួសារ និងកម្រិតភូមិ។ |
| **តើគេអាចប្រើការណែនាំនេះសម្រាប់ធ្វើអ្វី?** | ភាពក្រីក្រនិងបណ្តាញបរិស្ថាន (PEN) គឺជាគម្រោងនិងបណ្តាញស្រាវជ្រាវអន្តរជាតិដែលផ្តល់ការវិភាគទូទៅពេញលេញអំពីព្រៃឈើ និងភាពក្រីក្រនៅតំបន់ត្រូពិក។ ទោះបីជាត្រូវបានរៀបចំសម្រាប់ភាពក្រីក្រ និងបណ្តាញ បរិស្ថានក្តី មានកម្រងសំណួរដើមដែលអាចយកមកប្រើ (និងសម្របតាម ប្រសិនបើចាំបាច់) សម្រាប់អង្កេតព្រៃឈើ និងភាពក្រីក្រនៅកម្រិតក្នុងស្រុក។ ភាពក្រីក្រនិងបណ្តាញបរិស្ថានគប្បីប្រើជាមួយគោលការណ៍ណែនាំបច្ចេកទេស និងអាចប្រើសម្រាប់ការវិភាគប្រៀបធៀប។ |
| **ធាតុផ្សំសំខាន់ៗ** | កម្រងសំណួរនេះរួមមានព័ត៌មានសេដ្ឋកិច្ចសង្គមកិច្ចស្តីពីតំបន់ក្នុងស្រុក មូលដ្ឋានធនធានព្រៃឈើ ការប្រែប្រួលចំពោះការប្រើប្រាស់ព្រៃឈើ ស្ថាប័នព្រៃឈើ និងព័ត៌មានកម្រិតគ្រួសារ។ កម្រងសំណួរនេះគ្រោងដាក់ឱ្យប្រើប្រចាំត្រីមាស និងប្រចាំឆ្នាំដើម្បីកត់ត្រានិន្នាការ និងការប្រែប្រួលស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងធនធានព្រៃឈើផងដែរ។ ដោយប្រកាន់ខ្ជាប់ទៅនឹង និយមន័យដែលមានលក្ខណៈស្តង់ដារ កម្រងសំណួរ និងវិធីសាស្ត្រនានាអាចធ្វើការប្រៀបធៀបទិន្នន័យរវាងតំបន់ភូមិសាស្ត្រផ្សេងគ្នាអំពីប្រភេទព្រៃឈើ របបកាន់កាប់ព្រៃឈើ ដង់ស៊ីតេប្រជាជន និងកម្រិតនៃភាពក្រីក្រ ហេដ្ឋារចនាសម្ព័ន្ធ និងលទ្ធភាពចូលទៅកាន់ទីផ្សារតាមកាលកំណត់ផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | CIFOR. 2007. The Poverty and environment network: a comprehensive global analysis of tropical forests and poverty. Bogor, Indonesia, Center for International Forestry Research. http://www.cifor.org/pen/research-tools/tools.html |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | D1.1 |

## A3. ការទទួលស្គាល់ការចាត់ចែងបច្ចុប្បន្ន និងការចាត់ចែងកន្លងមក និងប្រកួតប្រជែងទាមទារសិទ្ធិកាន់កាប់ព្រៃឈើ

តើអ្វីទៅជាការចាត់ចែងផ្លូវការសព្វថ្ងៃ និងវិធានកាន់កាប់បែបប្រពៃណី? តើមានការទាមទារដណ្តើមធនធានព្រៃឈើដែរឬទេ? ការយល់ដឹងអំពីបរិបទអតីតកាល និងបច្ចុប្បន្នកាលជាជំហានចាំបាច់ដំបូងបង្អស់ក្នុងការលើកកម្ពស់សុវត្ថិភាពកាន់កាប់ព្រៃឈើ និងសិទ្ធិកាន់កាប់ដែលមានការទទួលខុសត្រូវ។

វិវាទជាច្រើនក្នុងការគ្រប់គ្រងព្រៃឈើបណ្តាលមកពីការដណ្តើមសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីព្រៃ និងធនធានព្រៃឈើ។ ចំណុចនេះកើតមានឡើងដោយសារគោលនយោបាយស្តីពីសិទ្ធិកាន់កាប់ខ្វះភាពច្បាស់លាស់ ខ្វះភាពស្របច្បាប់ និងខ្វះនីត្យានុកូលភាព។ គោលនយោបាយនានាអាចមិនស៊ីសង្វាក់គ្នា ឬអាចត្រូវបានបកស្រាយផ្សេងគ្នាក្នុងការអនុវត្តគោលនយោបាយទាំងនោះ។ វិវាទអាចកើតឡើង ប្រសិនបើប្រព័ន្ធកាន់កាប់ផ្លូវច្បាប់មិនទទួលស្គាល់ប្រព័ន្ធគ្រប់គ្រងបែបប្រពៃណី រួមទាំងប្រព័ន្ធគ្រប់គ្រងរបស់អ្នករស់នៅដែលតែងផ្លាស់ប្តូរទីតាំងជារឿយៗផងដែរ។ ដំណើរការកំណែទម្រង់សិទ្ធិកាន់កាប់ត្រូវផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ ក្នុងការលើកយកការទាមទារកាន់កាប់មកពិចារណា និងដោះស្រាយដោយសមធម៌ហើយធានាបាននូវការគោរពតាមគោលការណ៍សិទ្ធិមនុស្ស។

ចំពោះគោលនយោបាយដែលមិនចុះសម្រុងគ្នា មានពិភាក្សានៅក្នុងចំណុច A4។

## ឧបករណ៍គួរប្រើ

**A3.1**

| ការវាយតម្លៃរហ័សចំពោះសិទ្ធិកាន់កាប់ដីធ្លី | |
|---|---|
| **នេះជាអ្វី?** | វិធីមួយដើម្បីពិនិត្យមើលនឹងដោះស្រាយការដណ្តើមគ្នាទាមទារសិទ្ធិ និងផលប្រយោជន៍ចំពោះដី និងធនធាននានា។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | ការវាយតម្លៃរហ័សចំពោះសិទ្ធិកាន់កាប់ដីធ្លីផ្តល់នូវការណែនាំអំពីការរក និងទទួលបានទិន្នន័យដើម ចាំបាច់សម្រាប់អ្នករៀបចំគោលនយោបាយ ឬអ្នកសម្រុះសម្រួលក្នុងការរៀបចំយន្តការដោះស្រាយវិវាទ ខណៈជួបករណីនៃការដណ្តើមគ្នាកាន់កាប់ដី។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍នេះលើកឡើងនូវគោលដៅចំនួនប្រាំដើម្បីឱ្យយល់វិវាទ និងការដណ្តើមគ្នាទាមទារសិទ្ធិកាន់កាប់ពីសំណាក់តួអង្គផ្សេងគ្នា និងលើកឡើងនូវការពិភាក្សាគោលនយោបាយ ដើម្បីដោះស្រាយការដណ្តើមគ្នាទាមទារការកាន់កាប់។ ឧបករណ៍នេះត្រូវបានរៀបចំសម្រាប់សិទ្ធិកាន់កាប់ដីធ្លី ប៉ុន្តែអាចកែសម្រួល ចំពោះសិទ្ធិកាន់កាប់ធនធានព្រៃឈើផងដែរ។<br><br>ឧបករណ៍ពិសេសៗជាច្រើនដែលមាននៅក្នុងឯកសារណែនាំនេះមាននៅក្នុង RaTA ដូចជាការកសាងផែនទីដែលមានការចូលរួមការវិភាគវិវាទលើការកាន់កាប់ ការវិភាគតួអង្គ ការវិភាគគោលនយោបាយ និងការដោះសាយ្រទំនាស់។ |
| **ចំពោះព័ត៌មានបន្ថែម** | ICRAF. Rapid Land Tenure Assessment (RaTA): A tool for identifying the nature of land tenure conflicts [Online Resource]. http://www.worldagroforestrycentre.org/Sea/Projects/tulsea2/node/19 |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A4.9, B1.6, D2.2<br>ឧបករណ៍ស៊ីជម្រៅ: XL A3.1 |

## A3.2 ការកសាងផែនទីដែលមានការចូលរួម

| | |
|---|---|
| **នេះជាអ្វី ?** | សហគមន៍មូលដ្ឋានបង្កើតផែនទីដែលមានបញ្ជាក់អំពីលក្ខណៈធម្មជាតិ លក្ខណៈរូបវន្ត សង្គម និងវប្បធម៌ និងធនធាននានា។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី ?** | ក្នុងបរិបទនៃការដណ្តើមគ្នាកាន់កាប់ គេអាចប្រើវិធីកសាងផែនទីដែលមានការចូលរួមដើម្បីកំណត់ទីតាំងភូមិសាស្ត្រជាក់ស្តែង។ ដំណើរការនេះក៏អាចជួយអ្នកដែលមានគំនិតផ្សេងគ្នាក្នុងការគូសផែនទីជាមួយគ្នានិងយល់ដឹងអំពីបទពិសោធន៍ និងទស្សនៈរបស់អ្នកឯទៀត។ |
| **ធាតុផ្សំសំខាន់ៗ** | ការកសាងផែនទីដែលមានការចូលរួមផ្តោតលើការសម្រួលសមាជិកសហគមន៍ ឱ្យពួកគេគូសផែនទីដោយខ្លួនឯង ដើម្បីតំណាងការយល់ដឹងរបស់សមាជិក សហគមន៍ និងដើម្បីឱ្យសមាជិកសហគមន៍កំណត់វិធីផ្តល់ព័ត៌មាន (ទៅកាន់នរណា)។ ផែនទីត្រូវបានចងក្រងហើយអាចបង្ហាញសិទ្ធិបានទទួល សិទ្ធិប្រើប្រាស់ និងសិទ្ធិគ្រប់គ្រងដីនិងធនធានព្រៃឈើក្នុងពេលបច្ចុប្បន្ន និងកាលពីមុន។ មានការពណ៌នាច្រើនអំពីឧបករណ៍ផ្សេងៗ។ |
| **ចំពោះព័ត៌មានបន្ថែម** | IFAD. 2009. Good practices in participatory mapping. Rome, International Fund for Agricultural Development. http://www.ifad.org/pub/map/pm_web.pdf<br>Rainforest Foundation UK. Mapping for Rights [Online Resource]. http://www.mappingforrights.org/ |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A1.1, A1.2, A1.7, B2.5<br>ឧបករណ៍ស៊ីជម្រៅ: XL A3.2 |

## A3.3 ការវិភាគទំនាស់តាមកាលកំណត់ និងកិច្ចសម្ភាសន៍ដែលបានព្រាងសំណួរ

| | |
|---|---|
| **នេះជាអ្វី ?** | ដំណើរការមួយនៃការបង្កើតនូវកាលប្បវត្តិ ដើម្បីបង្កើនការយល់ដឹងរបស់ភាគីពាក់ព័ន្ធអំពីហេតុការណ៍នានាដែលបណ្តាលឱ្យមានទំនាស់។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី ?** | ពិនិត្យមើលសារតារនៃទំនាស់ និងបង្កឱ្យមានការយល់ដឹងនូវទស្សនៈផ្សេងគ្នា។ កិច្ចសម្ភាសន៍ដែលបានព្រាងសំណួរជាមុនអាចជួយពិនិត្យមើលស៊ី ជម្រៅបន្ថែមនូវទំនាស់ស្តីពីសិទ្ធិកាន់កាប់។ |
| **ធាតុផ្សំសំខាន់ៗ** | ភាគីពាក់ព័ន្ធរៀបរាប់រឿងរ៉ាវរបស់ពួកគេ ចំណែកឯអ្នកសម្រុះសម្រួលកត់ត្រាលំដាប់នៃព្រឹត្តិការណ៍នៅលើផ្ទាំងក្រដាស ។នៅពេលបញ្ចប់កាលប្បវត្តិ រួចហើយ គេគិតពិចារណាដោយលើកសំណួរថា តើអ្នកចូលរួមបានយល់ដឹងអ្វីខ្លះអំពីទំនាស់នេះ ហើយមូលហេតុអ្វីពួកគេគិតថាគូភាគីទាំងនោះធ្វើសកម្មភាពតាមបែបដែលពួកគេបានធ្វើ។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2005. Field guide to conflict analysis. Negotiation and mediation techniques for natural resource management, Annex II, A. Engel and B. Korf. Rome. http:// www.fao.org/docrep/008/a0032e/a0032e0d.htm#bm13.1<br>ICRAF. Rapid Land Tenure Assessment (RaTA): A Tool for identifying the nature of land tenure conflicts [Online Resource]. http://www.worldagroforestrycentre. org/Sea/Projects/tulsea2/node/19 |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A4.9, B1.6 |

## A4. ការគូសផែនទីបរិបទនយោបាយ និងស្ថាប័ន

តើមានគោលនយោបាយ ស្ថាប័ន និងដំណើរការសំខាន់ៗអ្វីខ្លះ ដែលចែងអំពីសិទ្ធិកាន់កាប់ព្រៃឈើ ហើយមាននិយាយអំពីដំណើរការកែកទម្រង់ដែរឬទេ? តើគោលនយោបាយ ស្ថាប័ន និងដំណើរការសំខាន់ៗទាំងនោះជួយសម្រួល ឬបង្អាក់ការផ្លាស់ប្តូរ? បរិបទនយោបាយ និងស្ថាប័នអាចបង្កើតឧបសគ្គធំៗ ដែលច្រើនតែបន្ទុចបង្អាក់ការផ្លាស់ប្តូរជាជុំកំភួនជាក់ស្តែង ពិសេសថាតើក្រុមពលរដ្ឋក្រីក្រ និងក្រីក្រខ្លាំងអាចចូលរួមដែរ ឬយ៉ាងណា។ ចាំបាច់ត្រូវកំណត់ វិភាគ និងយល់ដឹងអំពីស្ថាប័នសំខាន់ៗពោលគឺ ពីក្បួនច្បាប់ផ្លូវការរហូតដល់បទដ្ឋានសង្គម មិនផ្លូវការ និងទំនាក់ទំនងរវាងស្ថាប័នទាំងនោះនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ ក្រោមជាតិ និងនៅថ្នាក់មូលដ្ឋាន។ នេះគឺជាជំហានសំខាន់ក្នុងការយល់ដឹងទីតាំងឧបសគ្គនៃការចាត់ចែងសិទ្ធិកាន់កាប់ដែលមានប្រសិទ្ធភាព និងដែលត្រឹមត្រូវ ហើយតើមានកាលានុវត្តភាពអ្វីខ្លះសម្រាប់ការផ្លាស់ប្តូរ។

ជាញឹកញាប់គេមិនបានយកចិត្តទុកដាក់ចំពោះទំនាក់ទំនងអំណាច នៅក្នុងកំណែទម្រង់ស្តីពីសិទ្ធិកាន់កាប់ឡើយ។ ទំនាក់ទំនងអំណាចកំណត់ពីរបៀប នៃទំនាក់ទំនងរវាងសង្គម និងនយោបាយសម្របសម្រួលសមត្ថភាពរបស់ប្រជាជន ក្នុងការបន្តទាមទារព្រៃឈើ និងដើម្បីអាចចូលទៅកាន់ព្រមទាំងប្រើប្រាស់ដីព្រៃនិងធនធានព្រៃឈើឱ្យមានប្រសិទ្ធភាព។ ជាពិសេសត្រូវយល់ដឹងអំពីមុខងាររបស់បុគ្គលដែលមានអំណាច ពោលគឺអ្នកដែលសម្របសម្រួលឬគ្រប់គ្រងប្រជាជនក្រីក្រ ក្នុងការប្រើប្រាស់ ធនធានព្រៃឈើ និងជាអ្នកសម្រេចចិត្តលើការធ្វើឱ្យកាន់តែមានភាពប្រសើរឡើង ឬកាន់តែយាប់យឺន។ បុគ្គលដែលមានអំណាចនៅក្នុងសង្គម ជាអ្នកចាប់ផ្តើម និងមានឥទ្ធិពលទៅលើថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។ ឧទាហរណ៍ វិធីសាស្ត្រវិភាគភាគីពាក់ព័ន្ធអាចជួយកំណត់អត្តសញ្ញាណបុគ្គលទាំងនេះ និងកំណត់ឥទ្ធិពលរបស់ពួកគេ។ ទិដ្ឋភាព "យេនឌ័រ" គួរគប្បីលើកយកមកប្រើផងដែរ ដើម្បីពិនិត្យមើលស្ថានភាពរបស់ស្ត្រី ថាតើមានឥទ្ធិពលយ៉ាងដូចម្តេចមកលើលទ្ធភាពប្រើប្រាស់ ដីធ្លី និងធនធាន ព្រមទាំង ពិនិត្យមើលការបន្តទាមទារសិទ្ធិកាន់កាប់របស់ពួកគេ។

ទំនាក់ទំនងរវាងសង្គម និងនយោបាយក្នុងស្រុករងឥទ្ធិពលយ៉ាងខ្លាំងពីចរិតលក្ខណៈ និងរចនាសម្ព័ន្ធ របស់រដ្ឋ សមត្ថភាពរបស់ប្រព័ន្ធរដ្ឋបាលព្រៃឈើ និងទំនាក់ទំនងរវាងរដ្ឋជាមួយសង្គមស៊ីវិល (សូមអាន ‘ឧបករណ៍សម្រាប់រៀបចំ’ និង ‘ឧបករណ៍សម្រាប់ការចូលរួម’)។ វិធីសាស្ត្រដែលកាន់តែមានការចូលរួម និងដែលកាន់តែមានកិច្ចសហការចំពោះការចូលរួមរបស់រុក្ខាប្រមាញ់ តម្រូវឱ្យផ្លាស់ប្តូរប្រភេទទំនាក់ទំនងដែលមាន រវាងបុគ្គលិកនាយកដ្ឋានព្រៃឈើរបស់រដ្ឋ និងអ្នកតាំងទីលំនៅក្នុងព្រៃ និងអ្នកប្រើប្រាស់ព្រៃឈើជាមួយនឹងការបង្កើនការវិនិយោគលើរចនាសម្ព័ន្ធ គណនេយ្យភាពមូលដ្ឋាន។ ក្នុងការអនុវត្តជាក់ស្តែង ចាំបាច់ត្រូវយល់ដឹងថាតើទំនាក់ទំនងទាំងនេះប្រព្រឹត្តទៅបានប្រសើរយ៉ាងដូចម្តេច។

ប្រព័ន្ធផ្សព្វផ្សាយសង្គម និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) បានកែប្រែទិដ្ឋភាពស្ថាប័នជាខ្លាំងមួយផ្នែកគឺដោយសារប្រព័ន្ធទាំងនោះមានព័ត៌មានប្រជាធិបតេយ្យ។ ប្រការនេះមានផលប៉ះពាល់យ៉ាងធំ៖ ភាគីពាក់ព័ន្ធនានាអាចទទួលបានព័ត៌មានចូលរួមក្នុងការតស៊ូមតិ និងកសាងកម្លាំងយ៉ាងសំខាន់បានកាន់តែប្រសើរដើម្បីគាំទ្រ ឬទប់ទល់នឹងការផ្លាស់ប្តូរនានាក្នុងសិទ្ធិកាន់កាប់ព្រៃឈើ។

ទំនាស់ និងការយល់មិនច្បាស់លាស់ចំពោះសិទ្ធិកាន់កាប់ដែលអាចកើតមានឡើង ដោយសារគោលនយោបាយតាមវិស័យផ្សេងៗគ្នាអាចកំពុងដំណើរការផ្ទុយគ្នា។ ឧបករណ៍វិភាគគោលនយោបាយ និងឧបករណ៍វិភាគគតិយុត្តអាចជួយញែក និងកំណត់ផ្នែកផ្ទុយគ្នា និងការយល់មិនច្បាស់លាស់ទាំងនេះ។

ការលើកកម្ពស់ការយល់ដឹងអំពីកត្តានានា ដែលប៉ះពាល់ដល់សិទ្ធិកាន់កាប់ធនធានព្រៃឈើ គប្បីគួបផ្សំជាមួយដំណើរការសំយោគផងដែរ។ ការទាញយករបកគំហើញសំខាន់ៗ អាចជួយកំណត់កន្លែងដែលត្រូវមានការផ្លាស់ប្តូរ អាចជាការផ្លាស់ប្តូរគោលនយោបាយផ្លាស់ប្តូរស្ថាប័ន ឬដំណើរការនានាដើម្បីពង្រឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់។ រាល់ឧបករណ៍ដែលបានសង្ខេបខាងក្រោម មានការសង្កត់ធ្ងន់លើកាលានុវត្តភាព និងសកម្មភាពដែលអាចអនុវត្តលើការវាយតម្លៃ និងការវិភាគដែលមានមូលដ្ឋានត្រឹមត្រូវ។

## ឧបករណ៍គួរប្រើ

### A4.1 ការវិភាគគោលនយោបាយ និងការវិភាគផ្លូវច្បាប់

| | |
|---|---|
| **នេះជាអ្វី?** | ការវិភាគដែលមានលក្ខណៈជាប្រព័ន្ធនូវផ្នែកណាមួយ និងផ្នែកទាំងអស់នៃគោលនយោបាយ ឬប្រព័ន្ធច្បាប់ និងដំណើរការនានា។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | ដើម្បីវាយតម្លៃឥទ្ធិពល និងប្រសិទ្ធភាពនៃគោលនយោបាយ ឬបញ្ញត្តិច្បាប់ស្តីពីបញ្ហាជាក់លាក់ ដូចជាសិទ្ធិកាន់កាប់ព្រៃឈើ និងកំណត់ឧបសគ្គ និងឱកាសចំពោះការផ្លាស់ប្តូរនានានៅក្នុងប្រព័ន្ធនេះ។ ការវិភាគអាចកំណត់កន្លែងប្រទាំងប្រទើសគ្នា ផ្ទុយគ្នារវាងគោលនយោបាយ និងច្បាប់ ឬចំណុចខ្វះខាត។ |
| **ធាតុផ្សំសំខាន់ៗ** | ការពិនិត្យមើលឡើងវិញនូវគោលនយោបាយ ឬច្បាប់ដំបូងត្រូវកំណត់ គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ឬច្បាប់នានាដែលមាន ផលប៉ះពាល់មកលើបញ្ហាកាន់កាប់ព្រៃឈើ។ សំខាន់ការពិនិត្យនេះគប្បី រួមបញ្ចូលនូវច្បាប់គោលនយោបាយ ឬគំនិតផ្តួចផ្តើមដទៃផងដែរ។ ការវិភាគនេះពិនិត្យមើលឡើងវិញនូវខ្លឹមសារគោលនយោបាយ ឬ ខ្លឹមសារច្បាប់ ព្រមទាំងការអនុវត្តផងដែរ។ ចំពោះការវិភាគបែបនេះ អាចមានទិដ្ឋភាពបួនយ៉ាង គឺការវិភាគមាតិកា សំដៅទៅលើដំណើរការពិនិត្យលើមាតិកានៃគោលនយោបាយ និងច្បាប់ ការវិភាគសាវតា សំដៅលើការពិចារណាអំពីរបៀបដែលប្រវត្តិសាស្ត្រជំរុញឱ្យមានគោលនយោបាយនិងច្បាប់បច្ចុប្បន្ន ការវិភាគដំណើរការនៃរបៀបដែលប្រព័ន្ធនយោបាយជះឥទ្ធិពលទៅលើគោលនយោបាយ និងច្បាប់ ព្រមទាំងការវាយតម្លៃដែលត្រូតពិនិត្យទៅលើសង្គតិភាពរវាងគោលនយោបាយ ឬច្បាប់ជាមួយតថភាពជាក់ស្តែង និងឥទ្ធិពលមកលើគោលដៅដែលបានគ្រោងទុក។ |
| **ចំពោះព័ត៌មានបន្ថែម** | UNEP/IISD. 2007. Integrated environmental assessment training manual, module 5, Step 6 – What is policy analysis? Nairobi, United Nations Environment Programme, and Winnipeg, Manitoba, Canada, International Institute for Sustainable Development. http://www.unep.org/IEACP/iea/training/manual/module5/1231.aspx<br>Pasteur, K. 2001. Tools for sustainable livelihoods: policy analysis. Brighton, UK, Institute of Development Studies.<br>ICRAF. Rapid Land Tenure Assessment (RaTA): A tool for identifying the nature of land tenure conflicts [Online Resource]. http://www.worldagroforestrycentre.org/ Sea/ Projects/tulsea2/node/19 |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A5.1, A5.2, B4.1, C1.10, C2.1, D1.4, D1.7, D2.2, D3.6 |

### A4.2 ការវិភាគកម្លាំងជំរុញ

| | |
|---|---|
| **នេះជាអ្វី?** | ការវិភាគអំពីកម្លាំងដែលធ្វើឱ្យមានការផ្លាស់ប្តូរ ឬរារាំងមិនឱ្យមានការផ្លាស់ប្តូរ។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | ដើម្បីឱ្យទទួលបាននូវទិដ្ឋភាពទូទៅពេញលេញនិងវិភាគកម្លាំងជំរុញផ្សេងៗ ដែលមានមកលើបញ្ហាគោលនយោបាយណាមួយ។ |
| **ធាតុផ្សំសំខាន់ៗ** | ចំណុចចាប់ផ្តើមគឺការកំណត់អត្តសញ្ញាណ និងការវិភាគកម្លាំង ឬក្រុមភាគីពាក់ព័ន្ធដែលកំពុងគាំទ្រការផ្លាស់ប្តូរ (កម្លាំងជំរុញ) និងកម្លាំងដែលធ្វើសកម្មភាពប្រឆាំងនឹងការផ្លាស់ប្តូរ(កម្លាំងទប់)។ បន្ទាប់មកអ្នកប្រើប្រាស់កំណត់វិធីជំរុញ ពង្រឹង ឬពង្រីក ជាអតិបរមានូវកម្លាំងជំរុញ និងវិធីកាត់បន្ថយធ្វើឱ្យថមថយ ឬកាត់បន្ថយជាអតិបរមានូវកម្លាំងទប់នានា។ |
| **ចំពោះព័ត៌មានបន្ថែម** | Start, D. & Hovland, I. 2004. Force field analysis. Tools for policy impact: a handbook for researchers. London, Overseas Development Institute (ODI). http://www.odi. org. uk/rapid/tools/Toolkits/Policy_Impact/Forcefield_analysis.html |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | C1.1, D1.7 |

## ការរៀបចំផែនទីស្ថាប័នភាគីពាក់ព័ន្ធក្នុងស្រុក

**A4.3**

| | |
|---|---|
| **នេះជាអ្វី ?** | ឧបករណ៍មួយសម្រាប់កំណត់ និងតំណាងទស្សនៈ និងទំនាក់ទំនងជាមួយស្ថាប័ននិងបុគ្គលសំខាន់ៗពីខាងក្នុងនិងខាងក្រៅសហគមន៍ណាមួយ។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី ?** | បង្កលក្ខណៈឱ្យមានការយល់ដឹងអំពីរបៀបដែលសមាជិកសហគមន៍ផ្សេងគ្នាយល់ដឹងអំពីស្ថាប័ននានានៅក្នុងសហគមន៍ (អំពីការសម្រេចចិត្ត លទ្ធភាពទទួលបាន និងសេវាផ្សេងៗ) និងនៅខាងក្រៅសហគមន៍ (អំពីការចូលរួម លទ្ធភាពទទួលបាន និងសេវាផ្សេងៗ)។ |
| **ធាតុផ្សំសំខាន់ៗ** | អ្នកសម្របសម្រួលសួរទៅកាន់អ្នកដែលបានចូលរួមឱ្យប្រាប់ឈ្មោះ 'តួអង្គ' ដែលពួកគេប្រាស្រ័យទាក់ទងក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម ឬនយោបាយរបស់ពួកគេ។ គេពន្យល់ថាតួអង្គទាំងនេះអាចមានវត្តមាននៅក្នុងកន្លែងនោះ ឬអាចមានទំនាក់ទំនងដោយផ្ទាល់ឬដោយប្រយោល (ដូចជាអ្នកនយោបាយជាដើម) និងអាចជាបុគ្គល ក្រុម ឬអង្គការ។ ទាំងអស់នេះត្រូវបានគូសទីតាំងលើផែនទី និងវាយតម្លៃអំពីសារសំខាន់ចំពោះអ្នកចូលរួមទាំងឡាយ។ ទន្ទឹមនឹងនេះក៏មានការពិនិត្យមើលទំនាក់ទំនង រវាងអ្នកទាំងនោះផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | Matsaert, H. 2002. Institutional analysis in natural resources research. Greenwich, UK, Natural Resources Institute. http://www.nri.org/publications/bpg/bpg11.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | B2.1, B4.1, C2.1 |

## ការវិភាគអំពីកត្តាជំរុញឱ្យមានការផ្លាស់ប្តូរ

**A4.4**

| | |
|---|---|
| **នេះជាអ្វី ?** | ឧបករណ៍មួយដើម្បីយល់ដឹងបរិបទទូលំទូលាយនៃកត្តាជំរុញឱ្យមានការផ្លាស់ប្តូរនៅថ្នាក់ជាតិ និងនៅថ្នាក់តំបន់។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី ?** | ដើម្បីទទួលបាននូវការយល់ដឹងទូលំទូលាយទ្រង់ទ្រាយធំនៃកម្លាំងនយោបាយ កម្លាំងសេដ្ឋកិច្ច និងកម្លាំងវប្បធម៌ដែលធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងបរិបទតំបន់ និងប្រទេសដើម្បីកំណត់កត្តាជំរុញផ្នែកគោលនយោបាយ និងស្ថាប័ននៃការផ្លាស់ប្តូរ។ |
| **ធាតុផ្សំសំខាន់ៗ** | មានធាតុសំខាន់ៗចំនួនប្រាំមួយ៖ ការវិភាគជាមូលដ្ឋានកម្រិតប្រទេស ដែលពិនិត្យមើលស្ថាប័ននយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សង្គមណាមួយពីអតីតកាល និងបច្ចុប្បន្នកាល និងអនាគតរយៈពេលវែង ថាមវន្តរយៈពេលមធ្យម ដែលពណ៌នាអំពីកត្តាលើកទឹកចិត្ត និងសមត្ថភាពរបស់ភ្នាក់ងារ នានា និងរបៀបកើតឡើងនូវការផ្លាស់ប្តូរក្នុងរយៈពេលមធ្យម។ កម្លាំងខាងក្រៅដែលមានឥទ្ធិពលមកលើសម្មភាពរបស់ម្ចាស់ជំនួយ ការផ្លាស់ប្តូរដែលបានរំពឹងទុក និងរបៀបដែលការផ្លាស់ប្តូរទាំងនោះមានឥទ្ធិពលមកលើភាពក្រីក្រ និងផលប៉ះពាល់ផ្នែកប្រតិបត្តិ ដូចជាច្រកចូលដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរវិធីថ្មីៗនៃការធ្វើការ និងការបង្កើតប្លង់គម្រោងបែបច្នៃប្រឌិត។ |
| **ចំពោះព័ត៌មានបន្ថែម** | ODI. 2009. Mapping political context: drivers of change. London, Overseas Development Institute. http://www.odi.org.uk/resources/details.asp?id=5399&title=drivers-change-dfid-doc |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | C1.10, D1.3, D1.4 |

## A4.5 ការវិភាគអំណាច និងការផ្លាស់ប្តូរ

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសម្រាប់ពិនិត្យមើលការអនុវត្តប្រព័ន្ធ និងវិធានក្រៅផ្លូវការ និងទំនាក់ទំនង/សម្ព័ន្ធភាពរវាងស្ថាប័នផ្លូវការ និងក្រៅផ្លូវការ។ |
| **តើគេអាចប្រើឧបករណ៍នេះសម្រាប់ធ្វើអ្វី?** | ការវិភាគអំណាច និងការផ្លាស់ប្តូរ (PCA) ជាស្នូលនៃការវិភាគអំពីអភិបាលកិច្ច និងការវិភាគអំពីការប្រឆាំងនឹងអំពើពុករលួយដែលមានលក្ខណៈយុទ្ធសាស្ត្រ។ ការវិភាគនេះត្រូវបានបង្កើតជាពិសេសសម្រាប់ជួយរដ្ឋាភិបាលហូឡង់ក្នុងការធ្វើការជាមួយបណ្តាប្រទេសដៃគូឱ្យកាន់តែមានប្រសិទ្ធភាព ប៉ុន្តែអាចកែប្រែសម្រាប់ឱ្យប្រទេសដទៃប្រើប្រាស់បាន។ ឧបករណ៍នេះត្រូវបានរៀបចំឡើងដើម្បីពិនិត្យមើលមូលហេតុក្រៅផ្លូវការ និងមូលហេតុអរូបី ដែលមានចំពោះស្ថានភាពអភិបាលកិច្ច។ |
| **ធាតុផ្សំសំខាន់ៗ** | មានទិដ្ឋភាពបីចំពោះ PCA: 'កត្តាគ្រឹះ' កត្តាសង្គម និងសេដ្ឋកិច្ចដែលរៀបចំប្រព័ន្ធនយោបាយ 'ក្បួនល្បែង' ស្ថាប័នផ្លូវការ និងក្រៅផ្លូវការដែលមានឥទ្ធិពលលើរបៀបគ្រប់គ្រងទំនាក់ទំនង និងរបៀបអនុវត្តសកម្មភាព និង'បច្ចុប្បន្ន' តួអង្គសំខាន់ៗ ព្រមទាំងព្រឹត្តការណ៍ និងសម្ពាធដែលពួកគេកំពុងឆ្លើយតប។ PCA អាចប្រព្រឹត្តទៅជា 'ការពិនិត្យមួយគ្រួស' ឬតម្រូវឱ្យស្រាវជ្រាវស៊ីជម្រៅ បន្ថែមទៀត អាស្រ័យលើពេលវេលា និងទិន្នន័យដែលមាន។ |
| **ចំពោះព័ត៌មានបន្ថែម** | Unsworth, S. & Conflict Research Unit. 2007. Framework for strategic governance and corruption analysis: developing strategic responses towards good governance. The Hague, Conflict Research Unit, Netherlands Institute of International Relations. http://www.clingendael.nl/publications/2007/20071 000_cru_occ_unsworth.pdf |
| **ឧបករណ៍ដទៃទៀតដែលអាចមានប្រយោជន៍** | A1.4, B4.1, D1.4 |

## A4.6 ការគូសផែនទីឥទ្ធិពលរបស់ភាគីពាក់ព័ន្ធ និងការវិភាគអំណាច

| | |
|---|---|
| **នេះជាអ្វី?** | បច្ចេកទេសមួយចំនួនក្នុងការពិនិត្យ និងបង្ហាញឱ្យឃើញនឹងភ្នែកនូវឥទ្ធិពល និងផលប៉ះពាល់របស់ភាគីពាក់ព័ន្ធមកលើកំណែទម្រង់ជាក់លាក់ណាមួយ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ធ្វើឱ្យមានការយល់ដឹងបានកាន់តែប្រសើរ និងធ្វើឱ្យមានការពិភាក្សាច្បាស់លាស់តាមរយៈការគូសផែនទី និងការយល់ដឹងនូវអំណាច តួនាទី និងទស្សនៈរបស់បុគ្គល និងក្រុមផ្សេងៗ។ |
| **ធាតុផ្សំសំខាន់ៗ** | មានជំហានជាច្រើនចំពោះដំណើរការនេះ បញ្ហាគោលនយោបាយមួយត្រូវបានជ្រើសរើស អំឡុងពេលសំខាន់មួយ ឬច្រើន (ប្រសិនបើពិនិត្យ មើលការផ្លាស់ប្តូរគោលនយោបាយ) ត្រូវបានជ្រើសរើសភាគីពាក់ព័ន្ធ នឹងគោលនយោបាយទាក់ទិនត្រូវបានកំណត់ ហើយឥទ្ធិពល និងទំនាក់ទំនងទាំងនោះត្រូវបានគូសនៅលើផែនទី។ |
| **ចំពោះព័ត៌មានបន្ថែម** | Mayers, J. & Vermeulen, S. 2005. Stakeholder influence mapping. Power Tools Series. London, IIED. http://www.policy-powertools.org/Tools/Understanding/ SIM.html<br>Mayers, J. 2005. Stakeholder power analysis. Power Tools Series. London, IIED. http://www.policy-powertools.org/Tools/Understanding/SPA.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B4.2<br>ឧបករណ៍ស៊ីជម្រៅ: XL A4.6 |

## អក្សរ R ទាំងបួន

**A4.7**

| | |
|---|---|
| **នេះជាអ្វី?** | ក្របខ័ណ្ឌ និងឧបករណ៍មួយសម្រាប់បញ្ជាក់មុខងារដែលបំពេញ ដោយភាគីពាក់ព័ន្ធផ្សេងគ្នា និងប្រភេទទំនាក់ទំនងរវាងពួកគេ។ |
| **តើគេអាចប្រើវា សម្រាប់ធ្វើអ្វី?** | មានប្រយោជន៍ជាពិសេសក្នុងបរិបទដែលត្រូវគិតសាជាថ្មី ត្រូវចរចា និងបង្កើតមុខងារ។ វាអាចជាការបំពេញបន្ថែមចំពោះការវិភាគភាគី ពាក់ព័ន្ធ។ |
| **ធាតុផ្សំសំខាន់ៗ** | អក្សរ R ទាំងបួនបង្ហាញមុខងាររបស់ភាគីពាក់ព័ន្ធចំពោះ សិទ្ធិ ការទទួលខុសត្រូវ និងប្រាក់ចំណូល (ផលប្រយោជន៍)។ អក្សរ R ទីបួនគឺទំនាក់ទំនង ដែលផ្តោតលើ អន្តរកម្មរវាងភាគីពាក់ព័ន្ធនានា។ សារតារ និងបរិបទត្រូវបានស្រាវជ្រាវ ការយល់ដឹងអំពី មុខងារបច្ចុប្បន្នរបស់ភាគីពាក់ព័ន្ធត្រូវបានរៀបចំជាមួយគ្នានេះ ក៏មាន ការងារគូសផែនទីសមត្ថភាពដើម្បីជួយគ្រប់គ្រងការផ្លាស់ប្តូរមុខងារនានាផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | Mayers, J. 2005. The Four Rs. Power Tools Series. London, IIED. http://www. policy-powertools.org/Tools/Understanding/TFR.html |
| **ឯកសារដទៃទៀត ដែលអាចមានប្រយោជន៍** | B2.4, C2.3, C2.4 |

## ការវិភាគសាវតារ

**A4.8**

| | |
|---|---|
| **នេះជាអ្វី?** | ការវិភាគប្រវត្តិនៃការវិវត្តអំពីការប្រើប្រាស់ទំនាស់ និងនិន្នាការនានា ចំពោះធនធានធម្មជាតិ។ |
| **តើគេអាចប្រើវា សម្រាប់ធ្វើអ្វី?** | ឱ្យយល់ដឹងច្បាស់លាស់អំពីមូលហេតុ និងរបៀបវិវត្តនៃស្ថានភាពមួយ មកកាន់ស្ថានភាពបច្ចុប្បន្ន។ ការវិភាគនេះបង្កើតឱ្យមានក្របខ័ណ្ឌរលូន មួយដើម្បីបង្ហាញមូលហេតុនៃការដណ្តើមគ្នាកាន់កាប់ បង្ហាញចក្ខុវិស័យ របស់ភាគីពាក់ព័ន្ធ អំពីលទ្ធភាពអាស្រ័យផល និងប្រើប្រាស់ធនធានធម្មជាតិ ថាមវន្តបច្ចុប្បន្ន និងនិន្នាការនានាដែលអាចមាន។ |
| **ធាតុផ្សំសំខាន់ៗ** | ការវិភាគប្រវត្តិរួមមានការយល់ដឹងអំពីអតីតកាល និងការវិវត្តនៃ៖ ទំនាស់ ធនធានព្រៃឈើ របបកាន់កាប់ដី និងព្រៃ ស្ថាប័ន និងទំនាក់ទំនងរវាង ក្រុមដែលមានផលប្រយោជន៍ផ្សេងគ្នា ប្រព័ន្ធបរិស្ថាន ទិដ្ឋភាព និងលំនាំ នៃការប្រើប្រាស់ព្រៃឈើ យុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ប្រជាជន និង គម្រោងដទៃទៀតដែលអនុវត្តនៅក្នុងតំបន់នោះ។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2005. Participatory and Negotiated Territorial Development (PNTD). Rome. http://www.fao.org/sd/dim_pe2/pe2_050402a1_en.htm |
| **ឯកសារដទៃទៀត ដែលអាចមានប្រយោជន៍** | A2.1, A2.2, A3.1, A3.3 |

## A4.9 ការសម្រេចបាននូវអភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

| | |
|---|---|
| **នេះជាអ្វី?** | ឯកសារយោងមួយដែលផ្តល់ការណែនាំ និងឧទាហរណ៍អំពីកិច្ចប្រតិបត្តិល្អ ប្រសើរ ពោលគឺអ្វីដែលអនុវត្តបានជោគជ័យ ទីកន្លែង និងរបៀបអនុវត្តក្នុង បេសកកម្មធ្វើឱ្យអភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លីមានសមធម៌រវាងយេនឌ័រ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ធ្វើការឆ្ពោះទៅរកសមភាពយេនឌ័រពិតប្រាកដ និងមាននិរន្តរភាព តាមរយៈការចូលរួមប្រកបដោយសមធម៌នៃយេនឌ័រនៅក្នុងដំណើរការនានា និងស្ថាប័នដែលបានចូលរួមនៅក្នុងការសម្រេចចិត្តអំពីដីធ្លី។ |
| **ធាតុផ្សំសំខាន់ៗ** | ការណែនាំនេះបង្ហាញម៉ូឌុល និងឧបករណ៍ឆ្ពោះទៅកាន់ការបញ្ជ្រាបបញ្ហាយេនឌ័រ។ ការណែនាំនេះផ្តោតលើខ្លឹមសារក្នុងការអនុវត្តជាក់ស្តែងនៃអភិបាលកិច្ចដែលមានការទទួលខុសត្រូវមានសមធម៌ផ្នែកយេនឌ័រអំពីការកាន់កាប់ដីចំពោះមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងមូលដ្ឋាន ចំពោះក្រុមសង្គម ស៊ីវិល និងអ្នកអភិបាលដីធ្លី អ្នកបច្ចេកទេស និងអ្នកមានអាជីព ធ្វើការ នៅក្នុងវិស័យដីធ្លីនៅជុំវិញពិភពលោក និងពិនិត្យលទ្ធភាពអំពីវិធីដែលអាចសម្រេចបាននូវគោលគំនិតនេះ។ ការណែនាំនេះ រួមមានម៉ូឌុលលម្អិតស្តីពីបញ្ហាជាច្រើន ដែលត្រូវបានចងក្រងជាការរៀបចំគោលនយោបាយ បញ្ហាច្បាប់ បញ្ហាស្ថាប័ន បញ្ហាបច្ចេកទេស និងការប្រាស្រ័យទាក់ទង។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2013. Governing land for women and men: a technical guide to support the achievement of responsible gender-equitable governance of land tenure. Governance of Tenure Technical Guide no. 1. Rome. |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A2.1, A2.2, A2.3, B1.3, C1.2 |

## A4.10 ឧបករណ៍វាយតម្លៃអភិបាលកិច្ច

| | |
|---|---|
| **នេះជាអ្វី?** | ឯកសារដែលមានចំណងជើងថា "ខ្លឹមសារសង្ខេបនៃឧបករណ៍វាយតម្លៃអភិបាលកិច្ច និងសូចនាករ" គឺជាឯកសារណែនាំដែលមានទម្រង់ជាតារាងធនធានធម្មជាតិ និងការវាយតម្លៃអភិបាលកិច្ចបរិស្ថាន សន្ទស្សន៍ ប្រៀបធៀបសាកល និងមានឧបករណ៍វាយតម្លៃទូលំទូលាយដែលផលិតសម្រាប់សហជីពអន្តរជាតិសម្រាប់អភិរក្សធម្មជាតិ (IUCN)។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ឯកសារណែនាំនេះអាចប្រើដើម្បីទទួលបាននូវទិដ្ឋភាពរួមនៃឧទាហរណ៍ផ្សេងៗអំពីឧបករណ៍វាយតម្លៃ និងដើម្បីយល់ដឹង និងប្រៀបធៀបទម្រង់ទ្រាយ និងលក្ខណៈសំខាន់ៗ។ |
| **ធាតុផ្សំសំខាន់ៗ** | ខ្លឹមសារសង្ខេបនេះពណ៌នាអំពីគោលបំណង និងគោលការណ៍នៃការវាយតម្លៃ និងសន្ទស្សន៍ផ្សេងៗគ្នាទ្រង់ទ្រាយពិសេស និងវិធីសាស្ត្រនៃការវាយតម្លៃទាំងនោះ លក្ខណៈស្នូលនៃការវាយតម្លៃ ដូចជាកន្លែងដែលត្រូវយកចិត្តទុកដាក់ និងធនធានដែលត្រូវការ និងជាចុងក្រោយពណ៌នាអំពីចំណុចខ្លាំង និងកំហិតនៃការវាយតម្លៃ ជាពិសេសសម្រាប់ IUCN ប៉ុន្តែក៏អាចអនុវត្តជាទូទៅផងដែរ។ ព័ត៌មាននេះត្រូវបានផ្តល់ចំពោះការវាយតម្លៃអំពីអភិបាលកិច្ចធនធានធម្មជាតិជាច្រើន សន្ទស្សន៍ប្រៀបធៀបជាសាកល គិតទាំងសន្ទស្សន៍ដែលផ្តោតលើគណនេយ្យភាព សិទ្ធិមនុស្ស និងយេនឌ័រ អង្កេតទស្សនៈរបស់សាធារណជនប្រចាំតំបន់ ការវាយតម្លៃដឹកនាំដោយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការវាយតម្លៃដឹកនាំដោយអង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ។ |
| **ចំពោះព័ត៌មានបន្ថែម** | Campese, J., Oviedo, G. & Surkin, J. 2012. Summary of Governance Assessment Tools and Indicators. Gland, Switzerland, IUCN. http://cmsdata.iucn.org/downloads/governance_assessment_tools_matrix_final_26_4.docx<br>Recanatini, F. Undated. Overview of Governance Assessment Tools: Prepared for the Core Course on Governance and Anticorruption. Washington, DC, World Bank. http://www1.worldbank.org/publicsector/anticorrupt/feb06course/ recanatini%20Gov%20Tools.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | C2.1, D1, D3 |

## A5. ការកំណត់កាលានុវត្តភាពសម្រាប់ផ្លាស់ប្តូរ

ការជ្រើសយកសូម្បីតែឧបករណ៍តិចតួចដែលមានចែងនៅក្នុងចំណុច A1-A4 ទំនងជាបង្កើតបាននូវព័ត៌មានយ៉ាងច្រើន។ ព័ត៌មាននេះចាំបាច់ត្រូវតែមានភាពស៊ីសង្វាក់គ្នា ដើម្បីបញ្ជាក់ស្ថានភាពស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើហើយបន្ទាប់មកកំណត់ទិសដៅតទៅអនាគត។

នៅក្នុងដំណាក់កាលចុងក្រោយ ការយល់ដឹងពីបញ្ហាដែលកំពុងប៉ះពាល់ និងត្រូវបានរងផលប៉ះពាល់ដោយប្រព័ន្ធសិទ្ធិកាន់កាប់ដីធ្លី៖

- ខ្សែស្រឡាយផ្សេងគ្នានៃការវិភាគត្រូវបានប្រមូលផ្តុំ
- លទ្ធផលត្រូវបានបញ្ជាក់ជាមួយក្រុមភាគីពាក់ព័ន្ធសំខាន់ៗ (សមាជិកសហគមន៍ បុគ្គលិកនាយកដ្ឋានព្រៃឈើ។ល។)
- ចំណុចមេរៀនសំខាន់ៗត្រូវបានចម្រាញ់យក
- ទិសដៅតទៅអនាគត និងជម្រើសយុទ្ធសាស្ត្រនានាត្រូវបានកំណត់

វៀរលែងតែមានការបម្រុងទុកនូវពេលវេលា និងធនធានសម្រាប់ការស្រាវជ្រាវ និងសំយោគបែបនេះ ពុំនោះ សោតទេ ព័ត៌មានដែលបានប្រមូលកាលពីពេលមុនអាចនៅតែជាទិន្នន័យ ជាជាងការយល់ដឹង។ វិធីនៃការធ្វើការងារ តាមទម្លាប់ដដែលៗនៅតែជាបទដ្ឋាននៅឡើយ ហើយឱកាសដើម្បីកែលម្អត្រូវបានខកខាន។

កិច្ចសម្ភាសន៍ក្រុមអ្នកដឹងបញ្ហា និងសិក្ខាសាលាអាចមានសារប្រយោជន៍ក្នុងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានដែលបានប្រមូលក៏ដូចជាចែករំលែកលទ្ធផលនៃការវិភាគ។ អ្នកសម្របសម្រួលម្នាក់អាចជួយប្រាប់បញ្ចូលគ្នា នូវដំណើររឿងពាក់ព័ន្ធនៃការវិភាគ ហើយបន្ថែមជាតុផ្សេងៗទៅក្នុងដំណើរការនៃការពិចារណា និងអាចផ្តួចផ្តើមកិច្ចពិភាក្សារវាងក្រុមភាគីពាក់ព័ន្ធផ្សេងៗគ្នា។ តាមពិតពួកគេមានភារកិច្ចរៀបចំ និងពិនិត្យមើលព័ត៌មានសំខាន់ៗដើម្បីធ្វើយ៉ាងណាឱ្យការវិភាគមានលក្ខណៈស៊ីសង្វាក់គ្នា និងសមស្រមសម្រាប់បរិបទនេះ។ នៅក្នុងដំណើរការទាំងមូល គប្បីមានកិច្ចប្រឹងប្រែងក្នុងការបង្កើត (បង្កើតជាថ្មី) នូវកិច្ចពិភាក្សា និងទំនុកចិត្តក្នុងចំណោមតួអង្គទាំងឡាយព្រមទាំងស្វែងរកមូលដ្ឋានរួមធ្វើជាចំណុចចាប់ផ្តើម ដើម្បីពិភាក្សាអំពីការធ្វើឱ្យមានការផ្លាស់ប្តូរ។

បណ្តាសកម្មភាពដែលផុសចេញពីដំណើរនៃការវិភាគនេះ អាចរួមមានការផ្លាស់ប្តូរគោលនយោបាយរហូតដល់ការកសាងសមត្ថភាព ឬការដោះស្រាយទំនាស់។ សកម្មភាពបែបនេះអាចយកទៅអនុវត្តនៅក្នុងដំណើរការនៃការរៀបចំការចូលរួម និងការជានាឱ្យមានសកម្មភាពទាំងនោះ ដែលមានការពិភាក្សានៅក្នុងផ្នែកបន្ទាប់។

## ឧបករណ៍គួរប្រើ

| ការវិភាគសេណារីយ៉ូ និងការកសាងផែនការ | | A5.1 |
|---|---|---|
| **នេះជាអ្វី?** | ការបំផុសគំនិតដែលមានការសម្របសម្រួលដើម្បីកំណត់លទ្ធភាពនានានៃកំណែទម្រង់ និងវិភាគលទ្ធផលនានាដែលអាចកើតមាន។ | |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការវិភាគសេណារីយ៉ូអនុញ្ញាតឱ្យអ្នករៀបចំគោលនយោបាយ ‘វាស់ស្ទង់ជាមុន’ នូវប្រតិបត្តិការណ៍នៃកំណែទម្រង់គោលនយោបាយ នៅក្នុងស្ថានភាពផ្សេងៗដែលអាចជឿទុកចិត្ត ហើយរៀបចំផែនការបម្រុង វាយតម្លៃកម្រិតនៃភាពជាម្ចាស់នៃរបៀបវារៈកែទម្រង់ក្នុងចំណោមភាគីពាក់ព័ន្ធនានា និងកសាងការគាំទ្រចំពោះរបៀបវារៈកែទម្រង់ដោយរួមបញ្ចូលភាគីពាក់ព័ន្ធដែលជាប់ទាក់ទិនទៅក្នុងកិច្ចពិភាក្សាជុំវិញសេណារីយ៉ូនានា និងធ្វើការឆ្ពោះទៅរកការយល់ដឹងរួមគ្នានូវបញ្ហាសំខាន់ៗ។ ចំណុចនេះរួមមាន ការប្រមូលទិន្នន័យយ៉ាងហ្មត់ចត់ដើម្បីពិនិត្យមើលបញ្ហាដែលបានលើកឡើងនៅក្នុងអំឡុងពេលបំផុសគំនិត និងការបង្កើតសេណារីយ៉ូអនាគតពីបីទៅប្រាំដែលអាចជឿទុកចិត្តថានឹងមានការធ្វើកំណែទម្រង់ប្រាកដមែន។ | |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | បណ្តាធាតុនៃការវិភាគសេណារីយ៉ូគឺ៖ (១) សិក្ខាសាលាសេណារីយ៉ូបឋម ខណៈដែលភាគីពាក់ព័ន្ធដែលជាប់ទាក់ទិនជួបជុំគ្នាដើម្បីបំផុសគំនិតអំពីបញ្ហាសំខាន់ៗជុំវិញរបៀបវារៈកំណែទម្រង់ (២)ការប្រមូលទិន្នន័យ ក្នុងនោះអ្នកស្រាវជ្រាវម្នាក់ប្រមូលព័ត៌មានពាក់ព័ន្ធជុំវិញបញ្ហាសំខាន់ៗ ដែលបានកំណត់នៅក្នុងសិក្ខាសាលាបឋម (៣) សិក្ខាសាលាកសាងសេណារីយ៉ូ ខណៈដែលភាគីពាក់ព័ន្ធកសាងសេណារីយ៉ូផ្សេងៗ និង(៤) ដំណើរការផ្សព្វផ្សាយ ក្នុងនោះគេបំប្រួញសេណារីយ៉ូក្នុងការកំណត់របាយការណ៍សង្ខេបមកត្រឹមមួយទំព័ររួចផ្សព្វផ្សាយដល់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។ |
| **ចំពោះព័ត៌មានបន្ថែម** | World Bank. 2007. Tools for institutional, political, and social analysis of policy reform: a sourcebook for development practitioners, Ch. 10. Washington, DC. http://siteresources.worldbank.org/EXTTOPPSISOU/Resources/ 1424002-1185304794278/TIPs_Sourcebook_English.pdf<br>Mwayafu, D.M, Kimbowa, R. & Graham, K. 2012. A toolkit to assess proposed benefit sharing and revenue distribution schemes of community REDD+ Projects. REDD-Net. London, Overseas Development Institute. http://redd-net.org/ files/Benefit%20 Sharing%20Toolkit.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B2.1, B2.2, D1.7 |

## A5.2 ការវិភាគដើមឈើបញ្ហា

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសម្រាប់បង្កើតហេតុ និងផលនៃបញ្ហាណាមួយតាមរយៈការបង្កើតឋានានុក្រមនៃកត្តាពាក់ព័ន្ធ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | សម្រាប់ញែកមូលហេតុពិតប្រាកដនៃបញ្ហាស្ថាប័នដែលបានរកឃើញចេញពីឥទ្ធិពលនៃបញ្ហាទាំងនោះ រួចហើយណែនាំអ្នកប្រើប្រាស់ទៅកាន់បញ្ហាសំខាន់ៗ ដែលចាំបាច់ត្រូវដោះស្រាយក្នុងការអភិវឌ្ឍស្ថាប័ន។ |
| **ធាតុផ្សំសំខាន់ៗ** | នៅពេលនោះបញ្ហាដែលគេផ្តោតការយកចិត្តទុកដាក់ មានការព្រមព្រៀងគ្នា។ បន្ទាប់មកគេយកចិត្តទុកដាក់លើមូលហេតុផ្សេងៗដែលនាំឱ្យមានបញ្ហា ចាប់ផ្តើមពីមូលហេតុផ្ទាល់បំផុត និងសំខាន់បំផុត។ គេក៏ពិនិត្យមើលឥទ្ធិពលនៃបញ្ហាផងដែរ។ បន្ទាប់មកគេអាចបង្វែរ 'បញ្ហា'ឱ្យទៅជា 'ដំណោះស្រាយ' ដើម្បីកំណត់ទិសដៅ និងកាលានុវត្តភាពក្នុងពេលអនាគតសំដៅឱ្យមានការផ្លាស់ប្តូរ។ |
| **ចំពោះព័ត៌មានបន្ថែម** | DFID. 2003. Problem Tree Analysis. Promoting institutional and organisational development: A source book of tools and techniques, p. 23. London. http://webarchive.nationalarchives.gov.uk/+/http://www.dfid.gov.uk/ pubs/files/ prominstdevsourcebook.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B2.1, B2.2, D1.7, C1.1 |

## ការវិភាគទ្រឹស្តីនៃការផ្លាស់ប្តូរ

**A5.3**

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍កសាងផែនការយុទ្ធសាស្ត្រដែលអនុញ្ញាតឱ្យភាគីពាក់ព័ន្ធកំណត់គោលដៅ និងដាក់ចេញនូវសកម្មភាពចាំបាច់ និងសូចនាករសំខាន់ៗលើមាគ៌ាឆ្ពោះទៅកាន់គោលដៅនោះ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការវិភាគបង្កើតបានឧបករណ៍មួយដែលអាចមើលឃើញ បានជាផែនទីបង្ហាញផ្លូវដើម្បីសម្រេចគោលដៅ។ តាមរយៈយន្តការគំហើញនេះ ភាគីពាក់ព័ន្ធអាចកំណត់ស្ថានភាពសំខាន់ៗ និងអន្តរាគមន៍ចាំបាច់ក្នុងការសម្រេចបាននូវគោលដៅរបស់ពួកគេ ហេតុនេះតម្រូវឱ្យមានការកសាងផែនការអន្តរាគមន៍ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ |
| **ធាតុផ្សំសំខាន់ៗ** | ដំណើរការនេះចាប់ផ្តើមដោយការកំណត់គោលដៅចុងក្រោយហើយធ្វើការបកក្រោយដោយផ្តើមចេញពីចំណុចនេះ។ ជំហាននីមួយៗដែលបានដាក់បញ្ចូលជាបន្តបន្ទាប់ទៅក្នុងផែនទីគឺជាលទ្ធផលនៅលើដងផ្លូវ ហើយជំហាននីមួយៗមានសូចនាករច្បាស់លាស់សម្រាប់សម្រេចបាននូវសមិទ្ធិផលរបស់វា។ សូចនាករទាំងនោះអនុញ្ញាតឱ្យមានការតាមដាន និងវាយតម្លៃល្អិតល្អន់ ហើយធ្វើយ៉ាងណាឱ្យលទ្ធផលដែលបានពិនិត្យឃើញមានភាពប្រាកដ-និយម និងអាចសម្រេចបាន។ |
| **ចំពោះព័ត៌មានបន្ថែម** | Theory of Change Community. What is Theory of Change? [Online Resource].<br>http://www.theoryofchange.org/about/what-is-theory-of-change/<br>Keystone. 2009. Developing a theory of change: A guide to developing a theory of change as a framework for inclusive dialogue, learning and accountability for social impact. Impact Planning, Assessment and Learning (IPAL) Guide 2. London. http://www.keystoneaccountability.org/sites/default/files/2%20Dev eloping%20a%20theory%20of%20change.pdf<br>Keystone. 2009. Theory of Change Template. London. http://www.keystonea ccountability.org/sites/default/files/Theory%20of%20CHANGE%20 template_July%202009.pdf<br>Organizational Research Services. 2004. Theory of Change: A Practical Tool For Action, Results and Learning. Baltimore, Maryland, USA, Annie E. Casey Foundation. http://www.aecf.org/upload/publicationfiles/cc2977k440.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | D1 |

## ការកសាងផែនការដែលផ្តោតលើសហគមន៍

**A5.4**

| | |
|---|---|
| **នេះជាអ្វី?** | ជាការណែនាំជាជំហានៗសម្រាប់អ្នកសម្របសម្រួលនដំណើរការកសាង ផែនការដែលផ្តោតលើសហគមន៍ (CBP) ។ ការណែនាំនេះពន្យល់តាំងពីសារតារហូតដល់ វិធីសាស្ត្រព្រមទាំងដំណាក់កាលទាំងប្រាំមួយនៃការកសាងផែនការដែលពាក់ព័ន្ធ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | អ្នកសម្របសម្រួលអាចប្រើប្រាស់ដំណើរការ **CBP** ដើម្បីបង្កើត អន្តរាគមន៍កាត់បន្ថយភាពក្រីក្រដែលបានរៀបចំឡើងសម្រាប់អភិវឌ្ឍសហគមន៍។ លើសពីផែនការសកម្មភាព ដំណើរការនេះក៏ត្រូវបានរៀបចំ ដើម្បីពង្រឹងសហគមន៍ក្នុងការគ្រប់គ្រង និងប្រើប្រាស់ចំណុចខ្លាំង និង ទំនាក់ទំនងដែលមានស្រាប់ ហើយបង្កើតវេទិការថ្មីៗ ។<br><br>ដោយត្រូវបានបង្កើតជាវិធីសាស្ត្រមួយសម្រាប់ប្រជាជនមូលដ្ឋានក្នុងការរួមចំណែក កសាងផែនការអភិវឌ្ឍន៍ចម្រុះរបស់ប្រទេសអាហ្វ្រិកខាងត្បូងនោះ ដំណើរការនេះ ក៏អាចអនុវត្តបានសម្រាប់ដំណើរការនានារបស់ភាគីពាក់ព័ន្ធចម្រុះដូចគ្នាដទៃទៀតផងដែរ។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | ឯកសារណែនាំពន្យល់អំពីរបៀបដែលCBP ដំណើរការ ដោយស្នើអំពីពេលវេលាសម្រាប់ជំហាននានានៅក្នុងដំណើរការនេះ និងឆ្លុះបញ្ចាំងអំពីវិធីសមស្របផ្សេងៗ។ ផែនទីបង្ហាញផ្លូវដែលមានប្រាំមួយដំណាក់កាលរួមមាន៖ ដំណាក់កាលរៀបចំ ដំណាក់កាលប្រមូលព័ត៌មានកសាងផែនការ ដំណាក់កាលបូកសរុបព័ត៌មានកសាងផែនការ ដំណាក់កាលកសាងផែនការសម្រាប់អនាគតកាល ដំណាក់កាលរៀបចំអនុវត្ត និងដំណាក់កាលតាមដាន និងអនុវត្ត។ សកម្មភាពផ្សេងៗនៅក្នុងដំណើរការនីមួយៗត្រូវបានគ្រោង ដូចជាការសម្ភាស ការរៀបចំចក្ខុវិស័យអនាគត និងការវិភាគអំពីចំណុចខ្លាំង ចំណុចខ្សោយ និងការគំរាមកំហែង( SWOT )។ ផ្នែកនីមួយៗត្រូវបានបំបែកជាសាវតារ គោលដៅ ដំណើរការ និងធនធានដែលត្រូវមាន។ |
| **ចំពោះព័ត៌មានបន្ថែម** | AICDD/Development Works. 2005. Community-Based Planning and the IDP, Guide 2: Facilitator's Guide to Community-Based Planning. Community-Based Planning Project Steering Committee. African Institute for Community- Driven Development and Development Works. http://www.ansa-africa.net/ index.php/views/pub_view/ community_based_planning_and_the_idp_ guide_2/ |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4, B, C1.2, C2.3, C2.4 |

ចំណេះដឹងដែលទទួលបាននៅក្នុងដំណាក់កាលការឈ្វេងយល់នេះ អាចជាជំនួយដល់ការរិះគិត និងការពិភាក្សាសម្រាប់ដំណាក់កាលដទៃទៀតនៃការរៀបចំ ការចូលរួម និងការជានាឱ្យឈានឆ្ពោះទៅរកដំណើរការកំណែទម្រង់ដីធ្លីមួយដែលបង្កើនប្រសិទ្ធភាពឱកាសដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់និរន្តរភាព។

កំណត់សម្គាល់

# B

## ឧបករណ៍សម្រាប់ការរៀបចំ

## វិធីប្រើសញ្ញាសម្គាល់

**កម្រិតនិងគុណភាពនៃព័ត៌មាន**
**និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

កម្រិតនិងគុណភាពព័ត៌មានដែលមានស្រាប់ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ ដែលឧបករណ៍នេះមានភាពសមស្រប។ ស្លឹមួយជាកម្រិតទាប(មានន័យថា មិនចាំបាច់មានព័ត៌មានច្រើន និងរួមបញ្ចូលភាគីពាក់ព័ន្ធដើម្បីប្រើប្រាស់ឧបករណ៍នេះឡើយ) ស្លឹបួនគឺជាកម្រិតខ្ពស់ (មានន័យថាចាំបាច់ត្រូវមានព័ត៌មានសម្បូរបែបហើយមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ ដើម្បីប្រើឧបករណ៍នេះ)។

**តម្រូវការធនធាន**

បរិមាណពេលវេលា ថវិការ និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍នេះដំណើរការទៅបាន។ ដើមឈើមួយដើម គឺបរិមាណតិច ដើមឈើបួនដើម គឺបរិមាណច្រើន។

# B. ឧបករណ៍សម្រាប់ការចងក្រង




## ហេតុអ្វីបានជាការចងក្រងមានសារសំខាន់ចំពោះអភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ

ដើម្បីឱ្យអ្នកប្រើប្រាស់ព្រៃឈើមានឥទ្ធិពលលើគោលនយោបាយ ជាទូទៅពួកគេត្រូវមានចំនួនគ្រប់គ្រាន់ ហើយត្រូវចងក្រងជាក្រុម ឬស្ថាប័នដែលមានប្រសិទ្ធភាព។ នៅកម្រិតសហគមន៍ តម្រូវឱ្យមានការអភិវឌ្ឍសមត្ថភាព និងជំនាញសមស្រប ព្រមទាំងពង្រឹងក្រុមសហគមន៍នេះផងដែរ។ ជាមួយគ្នានេះដែរ វិស័យសាធារណៈត្រូវតែឆ្លើយតបនឹងបញ្ហាដែលសហគមន៍បានលើកឡើង ឯវិស័យឯកជនក៏តម្រូវឱ្យរៀបចំនៅក្នុងដំណើរការត្រឹមត្រូវ និងប្រកបដោយបរិយាប័ន្ន។ នៅក្នុងស្ថាប័នមួយចំនួន វិធីដ៏ល្អបំផុតក្នុងការចងក្រងដែលអាចនាំមកនូវការផ្លាស់ប្តូរ នោះប្រហែលជាត្រូវបង្កើតជាសហព័ន្ធ (Alliances) ឬសម្ព័ន្ធភាព (Coalitions)។ ផ្នែកនេះផ្តោតលើឧបករណ៍ និងបច្ចេកទេសដែលនឹងជួយវិស័យផ្សេងគ្នានៃសង្គមក្នុងការរៀបចំខ្លួនឯងឱ្យបានសមស្រប ដើម្បីឱ្យវិស័យទាំងនោះមានឥទ្ធិពលប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រងប្រព័ន្ធកាន់កាប់ព្រៃឈើប្រកបដោយការទទួលខុសត្រូវ។

វិស័យសាធារណៈ ឯកជន និងក្រុមសង្គមស៊ីវិលត្រូវមានជំនាញ ប្រព័ន្ធ និងរចនាសម្ព័ន្ធចាំបាច់ ដើម្បីធ្វើឱ្យគោលនយោបាយ និងសេចក្តីសម្រេចចិត្តនានាជុំវិញសិទ្ធិកាន់កាប់មានការព្រមព្រៀងបានត្រឹមត្រូវ និងមានការទទួលខុសត្រូវ។ ការយល់ព្រមដោយពេញចិត្ត និងប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន) (FPIC) ចាំបាច់ត្រូវតែមានសម្រាប់ការផ្លាស់ប្តូរផ្សេងៗ ហើយគប្បីមានការគាំទ្រចំពោះសិទ្ធិរបស់ប្រជាជនក្នុងការទទួលបានធនធានព្រៃឈើ ដើម្បីឱ្យពួកគេអាចប្រើប្រាស់ធនធានទាំងនោះបានសមស្រប និងមានប្រសិទ្ធភាពសម្រាប់ទាំងការចិញ្ចឹមជីវិត និង ការអភិរក្ស។

នៅក្នុងប្រទេសជាច្រើន កាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ មានការផ្លាស់ប្តូរចម្បងៗចំពោះរបៀបព្រមព្រៀងលើសិទ្ធិក្នុងការទទួលបាន និងក្នុងការបែងចែកធនធានព្រៃឈើ។ វិមជ្ឈការនៃការសម្រេចចិត្តត្រូវបានពង្រឹងតាមរយៈការគ្រប់គ្រងព្រៃឈើដែលមានការចូលរួម និងការរីកលូតលាស់នូវមុខងាររបស់វិស័យឯកជនតាមរយៈឯកជនភាវូបនីយកម្មព្រៃឈើ ហើយក្នុងករណីមួយចំនួន គឺការកើតឡើងនូវទីផ្សារថ្មីៗចំពោះសេវាប្រព័ន្ធបរិស្ថានព្រៃឈើ។

ទាំងវិស័យសាធារណៈ វិស័យឯកជន និងក្រុមសង្គមស៊ីវិល គួរតែជ្រើសយកតួនាទីខុសពីសព្វដង ចំណែកឯទំនាក់ទំនងរវាងតួអង្គសំខាន់ៗទាំងអស់គួរតែមានការផ្លាស់ប្តូរជាលំដាប់។ ជារឿយៗការកសាងសមត្ថភាពលើតួនាទី និងទំនាក់ទំនងថ្មីៗទាំងនេះ គឺជាវិធីសំខាន់បំផុតដើម្បីជានាឱ្យមានការលើកកម្ពស់សន្តិសុខ និងផលប្រយោជន៍ដែលកើតចេញអំពីប្រព័ន្ធកាន់កាប់ចម្រុះមួយ។

## ការស្ទង់មើល និងការអនុវត្តឧបករណ៍នៅក្នុងផ្នែកនេះ

ឧបករណ៍នានាសម្រាប់ជាជំនួយដល់វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលក្នុងការរៀបចំខ្លួនឯង មានបញ្ជាក់និងបង្ហាញនៅក្នុងផ្នែកនេះ។ជាមួយគ្នានេះក៏មានការណែនាំ និងមានឧបករណ៍សម្រាប់ជាជំនួយក្នុងការបង្កើតសម្ព័ន្ធភាព បណ្តាញ និងសហព័ន្ធ ព្រមទាំងលើកកម្ពស់ការផ្លាស់ប្តូររវាងតួអង្គទាំងនេះ។

ឧបករណ៍ទាំងនេះត្រូវបានរៀបចំជុំវិញបញ្ហាដូចខាងក្រោម៖

**B1. ការពង្រឹងសមត្ថភាពសហគមន៍ដើម្បីចូលរួម**

- បង្កើនចំណេះ ជំនាញ និងសមត្ថភាពរបស់សហគមន៍ព្រៃឈើ និងក្រុមពលរដ្ឋក្រីក្រឱ្យយល់ដឹងអំពីសិទ្ធិរបស់ពួកគេ ផ្តោតលើការយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ខ្លួនតាមរយៈការតស៊ូមតិ និងតាមរយៈការចូលរួមពិភាក្សា និងចរចាជាមួយអ្នករៀបចំសេចក្តីសម្រេច អំពីបញ្ហាកាន់កាប់ព្រៃឈើ (ដូចជាការពង្រឹងថ្នាក់ដឹកនាំសហគមន៍ ការបណ្តុះបណ្តាល អំពីច្បាប់ ការចរចា និងការដំណើរការកិច្ចប្រជុំនៅសហគមន៍ជាដើម)។
- កសាងស្ថាប័នរឹងមាំដើម្បីបង្កលក្ខណៈឱ្យសហគមន៍រៀបចំចាត់ចែងនៅក្នុង និងរវាងពួកគេព្រមទាំងអនុវត្តសិទ្ធិរបស់ពួកគេចំពោះធនធាន និងសេវាព្រៃឈើ តាមបែបមួយដែលមានការទទួលខុសត្រូវ និងដើម្បីអភិរក្ស និងទទួលបាននូវផលប្រយោជន៍ក្នុងការចិញ្ចឹមជីវិត។ ការងារនេះរួមមានរបៀបគ្រប់គ្រងស្ថាប័នសហគមន៍ និងដើម្បីកាត់បន្ថយហានិភ័យរបស់ក្រុមឆ្មើម ដែលក្លាយទៅជាក្រុមលេចធ្លោ។ ការងារនេះក៏រួមបញ្ចូលផងដែរ នូវការបង្កើតសមត្ថភាពគ្រប់គ្រងលើទិដ្ឋភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចាត់តាំងដើម្បីឱ្យការគ្រប់គ្រងមានប្រសិទ្ធភាព និងមានសមធម៌ចំពោះសម្បត្តិ និងសេវាព្រៃឈើ គិតទាំងសហគ្រាសព្រៃឈើពាណិជ្ជកម្មផងដែរ ប្រសិនបើសមស្រប។

**B2. ការកសាងវិស័យសធារណៈដែលប្រកបដោយការទទួលខុសត្រូវ**

- បង្កើនជំនាញ និងសមត្ថភាពក្នុងចំណោម ភ្នាក់ងារព្រៃឈើ ឬវិស័យសាធារណៈដើម្បី ពង្រឹងអភិបាលកិច្ចល្អនៃធនធានព្រៃឈើ និងបង្កលក្ខណៈឱ្យបុគ្គលិកនាយកដ្ឋាន ព្រៃឈើកសាងទំនាក់ទំនងល្អ និងឆ្លើយតបជាមួយអ្នកមានសិទ្ធិលើព្រៃឈើដទៃទៀត។
- ឧបករណ៍សម្រាប់គាំទ្រ និងសម្រួលការផ្លាស់ប្តូរស្ថាប័នក្នុងវិស័យព្រៃឈើ

**B3. ការរៀបចំឱ្យវិស័យឯកជនដំណើរការត្រឹមត្រូវ និងពេញលេញ**

- កសាងអភិបាលកិច្ចល្អនៅក្នុងសហគ្រាសព្រៃឈើតូចៗ និងរៀបចំចាត់ចែងឱ្យចូលទៅកាន់ និងអភិវឌ្ឍទីផ្សារ
- វិនិយោគលើសហគ្រាសព្រៃឈើដែលមាននិរន្តរភាព និងភាពជាដៃគូលើវិស័យព្រៃឈើរវាងក្រុមហ៊ុន និងសហគមន៍។

**B4. កសាងឬពង្រឹងសម្ព័ន្ធភាព បណ្តាញ និងសហព័ន្ធ** ដើម្បីបង្កលក្ខណៈឱ្យក្រុមដែលមានផលប្រយោជន៍ផ្សេងគ្នាមានចំណែកលើធនធានព្រៃឈើ ឱ្យធ្វើការជាមួយគ្នាដើម្បីពិភាក្សា និងចរចាអំពីបញ្ហាកាន់កាប់ព្រៃឈើ (សូមអានឯកសារដែលមានចំណងជើងថា 'Tool for engaging'។

តាមរយៈការប្រើ និងការកែតម្រូវឧបករណ៍នៅក្នុងផ្នែកនេះ អ្នកនឹងមានការយល់ដឹងអំពីវិធីពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិល វិស័យសាធារណៈ និងវិស័យឯកជន ដើម្បីឱ្យពួកគេអាចចូលរួមក្នុងកិច្ចប្រឹងប្រែងរៀបចំអភិបាលកិច្ចធនធានព្រៃឈើតាមបែបមួយត្រឹមត្រូវ និងមានតម្លាភាព។

ឧបករណ៍ជាច្រើនដែលបានរំលេចនៅក្នុងផ្នែកនេះ ដូចគ្នាជាមួយឧបករណ៍ដែលលើកឡើងនៅក្នុងផ្នែកផ្សេងទៀត។ ព្រោះថាស្ថាប័នល្អ និងសមត្ថភាពល្អមានសារសំខាន់យ៉ាងខ្លាំងសម្រាប់រាល់គំនិតផ្តួចផ្តើមក្នុងការពង្រឹងអភិបាលកិច្ចនៃការកាន់កាប់ព្រៃឈើប្រកបដោយការទទួលខុសត្រូវ។ អ្នកអានគួរតែពិនិត្យទៅលើផ្នែកដទៃដែលមានការបរិយាយយ៉ាងលម្អិតអំពីឧបករណ៍ជាក់លាក់ណាមួយ។

## B1. ការពង្រឹងសមត្ថភាពសហគមន៍ដើម្បីចូលរួម

តើសហគមន៍ព្រៃឈើនានាបានចូលរួមនៅក្នុងការពិភាក្សា និងការចរចាជាមួយអ្នកសម្រេចចិត្តលើបញ្ហាកាន់កាប់ព្រៃឈើដែរឬទេ? តើពួកគេត្រូវបានរៀបចំតាមបែបមួយដែលមានប្រសិទ្ធភាព ក្នុងការបញ្ចុះបញ្ចូលដើម្បីទទួលបាន និងអនុវត្តសិទ្ធិរបស់ខ្លួនដែរឬទេ? វិសាលភាពនៃការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការសម្រេចចិត្តមានភាពខុសៗគ្នាទៅតាមបរិបទនីមួយៗ។ សូម្បីតែក្នុងស្ថានភាពដែលរដ្ឋ និងវិស័យឯកជនមានបំណងអនុញ្ញាតឱ្យសហគមន៍ និងអ្នករស់នៅតំបន់ព្រៃ មានសិទ្ធិបញ្ចេញមតិទំលំទូលាយជាងមុនក្នុងការរៀបចំសិទ្ធិកាន់កាប់ធនធានព្រៃឈើក្តី ក៏មិនប្រាកដថាសហគមន៍មានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្វែងយល់ និងចរចាអំពីសិទ្ធិរបស់ពួកគេឡើយ។

មុនពេលដែលសហគមន៍អាចធ្វើសេចក្តីសម្រេចចិត្តក្រោយពីបានទទួលព័ត៌មាន ហើយចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងកិច្ចពិភាក្សាអំពីសំណើផ្លាស់ប្តូរសិទ្ធិរបស់ខ្លួនអំពីព្រៃឈើ ពួកគេត្រូវយល់ដឹងអំពីផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងនៃការផ្លាស់ប្តូរណាមួយ។ ទាំងនេះរួមមានផលប៉ះពាល់ និងការចំណាយដែលអាចកើតមាន ផលប្រយោជន៍ដែលអាចទទួលបាន និងផលប៉ះពាល់ផ្លូវច្បាប់។ គេត្រូវការជាចាំបាច់នូវការគាំទ្រ ដើម្បីបង្កលក្ខណៈឱ្យអ្នកដែលមានសំឡេងខ្សោយនៅក្នុងសង្គមអាចសម្តែងមតិឱ្យគេបានដឹង និងចូលរួមក្នុងការសម្រេចចិត្តនិងក្នុងការពិភាក្សាជុំវិញសិទ្ធិកាន់កាប់ធនធាន និងសេវាព្រៃឈើ។

សហគមន៍ក៏ត្រូវតែចងក្រងឱ្យបានល្អផងដែរ ដើម្បីឱ្យពួកគេអាចគ្រប់គ្រងធនធាន ដែលពួកគេទទួលបានទាំងនោះ និង/ឬប្រើប្រាស់សិទ្ធិគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ហើយអាចដោះស្រាយទំនាស់នៅមូលដ្ឋាន ឬនៅសហគមន៍តាមបែបមួយដែលមានការទទួលខុសត្រូវសម្រាប់ការចិញ្ចឹមជីវិត និងដើម្បីបានទទួលផលប្រយោជន៍ពីការអភិរក្ស។

ផ្នែកនៃការគាំទ្រ រួមមាន៖

- ការគាំទ្រសហគមន៍ឱ្យយល់ពីស្ថានភាពដែលពួកគេកំពុងប្រឈមមុខ ឱ្យយល់ពីបរិបទច្បាប់ សិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេចំពោះសិទ្ធិកាន់កាប់ព្រៃឈើ ហើយជួយពួកគេក្នុងការកំណត់តម្រូវការ និងកំណត់បញ្ហារបស់ខ្លួន។ ចំណុចនេះរួមទាំងការកសាងការយល់ដឹងរបស់សហគមន៍អំពីច្បាប់ ព្រមទាំងឧបករណ៍ និងយន្តការច្បាប់ ដែលពួកគេអាចប្រើប្រាស់ដើម្បីចរចាជាមួយអ្នកសម្រេចចិត្ត។ ការវិភាគរួមគ្នា និងការយល់ដឹងគឺជាជំហានដ៏មានសារសំខាន់ឆ្ពោះទៅកាន់ការរៀបចំចាត់តាំងដែលមានប្រសិទ្ធភាព។
- កសាងអង្គការសហគមន៍នៅមូលដ្ឋានឱ្យបានរឹងមាំ អាចមានលទ្ធភាពគ្រប់គ្រងធនធានព្រៃឈើរបស់ពួកគេឱ្យមានប្រសិទ្ធភាព និងចេះទាញយកឧត្តមភាពនៃកាលានុវត្តភាពដើម្បីកាត់បន្ថយភាពក្រីក្រ ដោះស្រាយទំនាស់ផ្ទៃក្នុង និងចរចាព្រមទាំងចូលរួមជាមួយអ្នកសម្រេចចិត្ត។
- ការពង្រឹងសមត្ថភាពរបស់ថ្នាក់ដឹកនាំសហគមន៍ដើម្បីតំណាងសហគមន៍ ឬរបស់ម្ចាស់ឆ្នោតជាជនជាតិដើមភាគតិចក្នុងការដំណើរការកិច្ចប្រជុំ និងការបង្កើតឡើងនូវការចរចាដែលមានប្រសិទ្ធភាពជាមួយអ្នកសម្រេចចិត្ត។

## ឧបករណ៍គួរប្រើ

### B1.1 ការចងក្រងក្រុមអ្នកប្រើប្រាស់ធនធានព្រៃឈើដើម្បីចូលរួម

| | |
|---|---|
| **នេះជាអ្វី ?** | ក្របខ័ណ្ឌមួយសម្រាប់ណែនាំអ្នកអភិវឌ្ឍន៍ក្នុងការជួយអ្នកដាំដុះព្រៃឈើនៅមូលដ្ឋានឱ្យចេះចងក្រងក្រុមដោយខ្លួនឯង និងចូលរួមត្រឹមត្រូវតាមច្បាប់ក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ជួយសម្រួលជំហានចាំបាច់ចំពោះអ្នកដាំដុះព្រៃឈើក្នុងការចងក្រងចាត់តាំងដោយខ្លួនឯង ។ ក្នុងឋានៈជាស្ថាប័នមួយដែលមានការទទួលស្គាល់ក្នុងការចូលរួមត្រឹមត្រូវតាមច្បាប់ក្នុងការងារអភិបាលកិច្ច និងគ្រប់គ្រងព្រៃឈើ អ្នកដាំដុះព្រៃឈើអាចទទួលបានធនធាន ភាពជាដៃគូ និងទីផ្សារ បើពុំដូច្នោះទេ ពួកគេមិនអាចទទួលបានលក្ខណៈសម្បត្តិទាំងនេះឡើយ ។ |
| **ធាតុផ្សំសំខាន់ៗ** | ដំណើរការនេះរួមមានប្រាំដំណាក់កាល ៖ ការឈ្វេងយល់ពីស្ថានភាពប្រឈមមុខរបស់អ្នកច្រៀកឈើ និងសហគ្រាសរបស់ពួកគេ ការពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតស្ថាប័ន ការដំណើរការស្ថាប័ន និងការចូលរួមក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព ។ |
| **ចំពោះព័ត៌មានបន្ថែម** | Krassowska, K. & Davidson, M. 2005. Organising pitsawyers to engage. Power Tools Series. Uganda, Budongo Community Development Organisation, and London, IIED. http://www.policy-powertools.org/Tools/Organising/OPE.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B3.1, B3.4, C1.2<br>ឧបករណ៍ស៊ីជម្រៅ: XL B1.1 |

### B1.2 ការកសាងជំនាញតស៊ូមតិ ការបញ្ចុះបញ្ចូល និងការចរចា សម្រាប់ថ្នាក់ដឹកនាំជនជាតិដើមភាគតិចក្នុងការចូលរួមជាមួយ REDD+

| | |
|---|---|
| **នេះជាអ្វី ?** | ការណែនាំអំពីការបណ្តុះបណ្តាល និងព័ត៌មានគាំទ្រសម្រាប់បណ្តុះបណ្តាលថ្នាក់ដឹកនាំជនជាតិដើមភាគតិចអំពី REDD+និងជំនាញតស៊ូមតិ ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ជួយថ្នាក់ដឹកនាំជនជាតិដើមភាគតិចដើម្បីកំណត់យុទ្ធសាស្ត្រតស៊ូមតិ និងអភិវឌ្ឍជំនាញក្នុងការបញ្ចុះបញ្ចូល និងជំនាញចរចា ។ |
| **ធាតុផ្សំសំខាន់ៗ** | ការបណ្តុះបណ្តាលអំពីការតស៊ូមតិ ការបញ្ចុះបញ្ចូល និងការចរចាផ្តោតលើការតស៊ូមតិដែលមានប្រាំពីរដំណាក់កាល ៖ ការប្រមូលព័ត៌មាន ការផ្សព្វផ្សាយព័ត៌មាន ការតស៊ូមតិជាមួយប្រព័ន្ធផ្សព្វផ្សាយការកសាងសម្ព័ន្ធភាព និងកសាងបណ្តាញការបញ្ចុះបញ្ចូល និងការចូលរួមក្នុងដំណើរការសម្រេចចិត្តរបស់រដ្ឋាភិបាល ការចរចា និងការកៀរគរមហាជនព្រមទាំងសកម្មភាពមហាជន ។ |
| **ចំពោះព័ត៌មានបន្ថែម** | Erni, C. & Tugendhat, H. 2010. Advocacy, lobbying and negotiation skills. What to do with REDD? A Manual for Indigenous Trainers, Module 5. Asia Indigenous Peoples Pact (AIPP), Forest Peoples Programme, International Work Group for Indigenous Affairs (IWGIA) and Indigenous Peoples' International Centre for Policy Research and Education (TEBTEBBA). http://www.forestpeoples.org/ sites/fpp/files/ publication/2010/08/reddtrainingmanualmar10eng.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | C1.2, C1.3 |

| សម្ភារឧបទេសសម្រាប់អ្នកចងក្រងសហគមន៍ | | B1.3 |
| --- | --- | --- |
| នេះជាអ្វី? | ការណែនាំអំពីការកសាងអង្គការសហគមន៍ដែលកាន់តែមានលក្ខណៈប្រជាធិបតេយ្យ និងកាន់តែមានប្រសិទ្ធភាព | |
| តើគេអាចប្រើវាសម្រាប់ធ្វើអ្វី? | រៀបចំសម្រាប់អ្នក ចងក្រងសហគមន៍ និងអង្គការ ក្នុងគោលបំណងកសាងអង្គការសហគមន៍ឱ្យកាន់តែរឹងមាំ | |
| ធាតុផ្សំសំខាន់ៗ | ការណែនាំត្រូវបានរៀបចំជុំវិញប្រធានបទដូចតទៅ៖ ការងារក្នុងសហគមន៍ ការកសាងស្ថាប័ន/អង្គការ ការគ្រប់គ្រង ហិរញ្ញវត្ថុ រដ្ឋបាល ព័ត៌មានវិទ្យា ដំបូន្មានជំនួយការ មេធាវី អាជ្ញាធរមូលដ្ឋាន មេរោគអេដស៍ និងជម្ងឺអេដស៍ រដ្ឋាភិបាល កម្មវិធី និងគោលនយោបាយរបស់រដ្ឋាភិបាល និងអភិវឌ្ឍន៍ចំណេះដឹង។ | |
| ចំពោះព័ត៌មានបន្ថែម | Education and training unit. Community Organisers Toolbox [Online Resource]. Johannesburg. http://www.etu.org.za/toolbox/<br>Peterson, E.R. & Barron, K.A. 2007. How to get focus groups talking: new ideas that will stick. International journal of qualitative methods 6(3): 140–144. https://ejournals. l i b rary.ualber ta.ca/index.php/IJQM/article/ viewFile/640/577 | |
| ឯកសារដទៃទៀតដែលអាចមានប្រយោជន៍ | B3.2, B4.3, C1.2 | |

| ចាប់ពីក្រោមឡើងលើ៖ ការពង្រឹងសមត្ថភាពស្ថាប័នតាមរយៈស្វ័យវាយតម្លៃ ដែលមានការតម្រង់ទិស | | B1.4 |
| --- | --- | --- |
| នេះជាអ្វី? | ឧបករណ៍ និងវិធីសាស្ត្រសម្រាប់ស្វ័យវាយតម្លៃចំពោះការពង្រឹងសមត្ថភាពស្ថាប័ន | |
| តើគេអាចប្រើវាសម្រាប់ធ្វើអ្វី? | បង្កលក្ខណៈឱ្យស្ថាប័នឆ្លុះបញ្ចាំងលទ្ធផលរបស់ខ្លួនជាទៀងទាត់ និងដើម្បីលើកកម្ពស់ និងកែសម្រួលផែនការ និងសកម្មភាពទៅតាមគោលបំណង បរិបទ និងធនធានរបស់ខ្លួន។ | |
| ធាតុផ្សំសំខាន់ៗ | ដំណើរការនេះរួមមាន៖ ការវិនិច្ឆ័យ និងការចាត់អាទិភាពទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ស្ថាប័ន ការបង្កើតសូចនាករមូលដ្ឋាន សមស្រប សម្រាប់បន្តវាស់វែងសមត្ថភាពទាំងនេះ និងកំណត់សកម្មភាពច្បាស់លាស់ ដែលនឹងជួយឱ្យស្ថាប័នមានភាពចាស់ទុំ។ | |
| ចំពោះព័ត៌មានបន្ថែម | Gubbels, P. & Koss, C. 2000. From the Roots Up: Strengthening Organizational Capacity through Guided Self-Assessment. Oklahoma City, Oklahoma, USA, World Neighbors. http://www.rmportal.net/library/content/tools/biodiver sity-conservation-tools/putting-conservation-in-context-cd/capacity-building-and-organizational-development-resources/Excerpts-From-the- Roots-Up-Strengthening-Organizational-Capacity-through-Guided-Self- Assessment/view | |
| ឯកសារដទៃទៀតដែលអាចមានប្រយោជន៍ | B2.2 | |

## B1.5 ការវាយតម្លៃអភិបាលកិច្ចដោយមានការចូលរួម

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍សម្រាប់វាយតម្លៃ និងកែលម្អអភិបាលកិច្ចផ្ទៃក្នុងនៃក្រុមសហគមន៍។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | វិភាគរចនាសម្ព័ន្ធអភិបាលកិច្ច និងកិច្ចប្រតិបត្តិនៅក្នុងស្ថាប័ននៅតាមសហគមន៍ និងកំណត់ផ្នែកនានាដើម្បីកែលម្អ។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍នេះវាយតម្លៃរបៀបធ្វើការសម្រេចចិត្ត និងរបៀបគ្រប់គ្រងទូទៅធៀបនឹងសសរស្តម្ភបួនគឺ តម្លាភាព ការចូលរួម គណនេយ្យភាព និងលទ្ធភាពប៉ាន់ប្រមាណជាមុន។ គេផ្តល់ពិន្ទុចំពោះចម្លើយ (ពីមិនល្អដល់ល្អណាស់) ហើយផែនការ ពពង្រឹងអភិបាលកិច្ចត្រូវបានបង្កើតឡើង ព្រមទាំងបង្ហាញនូវសកម្មភាពសំខាន់ៗ។ |
| **ចំពោះព័ត៌មានបន្ថែម** | SAGUN Program/CARE Nepal. 2008. Tools used in Strengthened Actions for Governance in Utilization of Natural Resources (SAGUN) program. Tool 3: Participatory Governance Assessment. CARE Nepal with World Wide Fund for Nature (WWF) Nepal, Resource Identification and Management Society (RIMS) Nepal and Federation of Community Forestry Users (FECOFUN) Nepal. http://www.carenepal.org/publication/__SAGUN_PGA.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A2.2, A4.7, A4.1 |

## B1.6 ការគ្រប់គ្រងទំនាស់ធនធានព្រៃឈើនៅតាមសហគមន៍

| | |
|---|---|
| **នេះជាអ្វី?** | សម្ភារឧបទេសសម្រាប់ធ្វើការបណ្តុះបណ្តាលអំពីការគ្រប់គ្រងទំនាស់ធនធានព្រៃឈើនៅតាមសហគមន៍។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | បង្កលក្ខណៈឱ្យក្រុមសហគមន៍ពិនិត្យមើលទំនាស់ដែលទាក់ទងនឹងការប្រើប្រាស់ធនធានព្រៃឈើ និងការគ្រប់គ្រងព្រៃឈើនៅតាមសហគមន៍។ |
| **ធាតុផ្សំសំខាន់ៗ** | ធនធានទាំងនេះរួមមានការណែនាំផ្នែកទ្រឹស្តី(ភាគ១) និងសំណុំឯកសារសម្រាប់បណ្តុះបណ្តាលនៅក្នុងផ្នែកនេះ (ភាគ២)។ ធាតុផ្សំសំខាន់ៗគឺការយល់ដឹងអំពីទំនាស់ក្នុងការគ្រប់គ្រងព្រៃឈើនៅតាមសហគមន៍ វិធីសាស្ត្រសហការដើម្បីគ្រប់គ្រងទំនាស់ ការវិភាគ ការបង្កើតយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងទំនាស់ ការចរចា និងការកសាងកិច្ចព្រមព្រៀង។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2002. Community-based forest resource conflict management: training package, Vols. 1 and 2. Rome. http://www.fao.org/DOCREP/005/Y4300E/ Y4300E00.HTM and http://www.fao.org/DOCREP/005/Y4301E/Y4301E00.HTM |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3.1, A3.3, A4.9 |

## B1.7 ការប្រាស្រ័យទាក់ទងជាមួយស្ថាប័ន ដែលជាមជ្ឈមណ្ឌលសម្របសម្រួលថ្នាក់ជាតិ

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍សម្រាប់ជួយក្រុមព្រៃឈើកំណត់ស្ថាប័នគាំទ្រការសម្របសម្រួលសមស្រប។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | កំណត់ និងរួមបញ្ចូលស្ថាប័នដែលមានលក្ខណៈសម្បត្តិល្អបំផុតឱ្យសម្រួលការគាំទ្រក្នុងបរិបទផ្សេងគ្នា។ ឧបករណ៍នេះត្រូវបាន រៀបរៀងក្នុងបរិបទនៃការគាំទ្រសហគ្រាសព្រៃឈើសហគមន៍ ប៉ុន្តែអាចយកទៅអនុវត្តទូលំទូលាយជាងនេះ។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | ជំហានចម្បងៗនៅក្នុងដំណាក់កាលនេះគឺ ការដៅស្ថាប័នពាក់ព័ន្ធ ការជ្រើសយកអ្នកសម្របសម្រួលស្ថាប័នដែលមានសមត្ថភាព ការចរចាជាមួយស្ថាប័នដែលមានសក្តានុពល ជាមជ្ឈមណ្ឌលសម្របសម្រួល ការកសាងផែនការសម្រាប់អភិវឌ្ឍសមត្ថភាពសម្របសម្រួល និងការបង្កើតគណៈកម្មការដឹកនាំ។ |
| **ចំពោះព័ត៌មានបន្ថែម** | Macqueen, D.J., et al. 2012. Supporting small forest enterprises: a facilitators toolkit. Small and Medium Forest Enterprise Series, No. 29. London, IIED. [Identifying national small forest enterprise support institutions' module] http://pubs.iied. org/13558IIED. html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B3.1, C1.2 |

## ការណែនាំដើម្បីរៀបចំផែនការតស៊ូមតិ

**B1.8**

| | |
|---|---|
| **នេះជាអ្វី?** | ការណែនាំ និងឧបករណ៍សម្រាប់កសាងផែនការតស៊ូមតិទូទៅសម្រាប់អង្គការមិនមែនរដ្ឋាភិបាល |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការណែនាំនេះតម្រង់ទៅរក អង្គការមិនមែនរដ្ឋាភិបាល ផ្នែកបរិស្ថាននៅអាហ្វ្រិកខាងលិច(ឧទាហរណ៍ទាំងអស់មានប្រភពមកពីតំបន់នេះ) ប៉ុន្តែគេអាចប្រើសម្រាប់កន្លែងដទៃ ដើម្បីឱ្យ អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក និង អង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិបង្កើតផែនការតស៊ូមតិ។ |
| **ធាតុផ្សំសំខាន់ៗ** | ការណែនាំនេះបង្ហាញជំហានសំខាន់ៗក្នុងការប្រមូលព័ត៌មាន ការកសាងផែនការ និងការធ្វើយុទ្ធនាការ។ សំណុំឯកសារនេះរួមមាន ការវិភាគភាគីពាក់ព័ន្ធ ការវិភាគហានិភ័យ ការស្រាវជ្រាវច្បាប់ ការសរសេរសេចក្តីគោលជំហរ ការប្រើប្រព័ន្ធផ្សព្វផ្សាយ និងការកសាងបណ្តាញដែលមានប្រសិទ្ធភាព។ |
| **ចំពោះព័ត៌មានបន្ថែម** | Ozinga, S. & Riesco, I.L. 2006. Provoking change: a toolkit for African អង្គការមិនមែនរដ្ឋាភិបាល. Brussels and Moreton-in-Marsh, UK, FERN. http://www.fern. org/sites/fern.org/ files/provokingchange_LR.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4, C1 |

## B2. ការកសាងវិស័យសាធារណៈដែលមានការឆ្លើយតប

តើស្ថាប័នព្រៃឈើរបស់រដ្ឋ ទាំងបណ្តានាយកដ្ឋាន និងស្ថាប័ននានារបស់រដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបចំពោះបញ្ហា និងការលំបាកដែលមាននៅក្នុងវិស័យព្រៃឈើដែរឬទេ? តើនាយកដ្ឋាន និងស្ថាប័នទាំងនោះត្រូវបានរៀបចំ និងចាត់តាំងតាមបែបមួយដែលមានប្រសិទ្ធភាពដែរឬទេ? តើពួកគេមានជំនាញសមស្រប និងមានសមត្ថភាពស្តាប់ និងឆ្លើយតបទៅនឹងបញ្ហារបស់អ្នកមានសិទ្ធិកាន់កាប់ព្រៃឈើដែរឬទេ? ស្ថាប័នរដ្ឋចាំបាច់ត្រូវបំពេញមុខងារសំខាន់ក្នុងការធ្វើយ៉ាងណាឱ្យអភិបាលកិច្ចធនធានព្រៃឈើមានតម្លាភាព មានគណនេយ្យភាព និងផ្តល់អត្ថប្រយោជន៍ដល់ភាពក្រីក្រ និងបរិស្ថាន។ ដើម្បីឱ្យ 'ធានាបាននូវ' មុខងារនេះ (មាននៅក្នុងចំណុច D) មានប្រសិទ្ធភាព ការរៀបចំ (ឡើងវិញ) វិស័យព្រៃឈើរបស់រដ្ឋអាចជាកត្តានាំមុខចាំបាច់។

គេពុំឃើញមានផែនការលម្អិតសម្រាប់ការផ្លាស់ប្តូរស្ថាប័នឡើយ។ ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យកំណែទម្រង់វិស័យព្រៃឈើបង្កើតប្រព័ន្ធមួយដែលមានគណនេយ្យភាព ដែលបម្រើទាំងគោលដៅអភិរក្សនិងកាត់បន្ថយភាពក្រីក្រ ដំណើរការនៃកំណែទម្រង់ណាក៏ដោយគប្បីផ្តោតការយកចិត្តទុកដាក់លើបញ្ហាដូចខាងក្រោម៖

- ដោះស្រាយអំពើពុករលួយ និងការគប់គិតគ្នា រវាងបុគ្គលិក ក្រុមហ៊ុនឧស្សាហកម្ម និងបុគ្គលិកវិស័យសាធារណៈ។
- ដោះស្រាយបញ្ហានានានៅក្នុងប្រព័ន្ធតុលាការ ដើម្បីឱ្យប្រព័ន្ធនេះដំណើរការបានត្រឹមត្រូវក្នុងការដោះស្រាយវិវាទធនធាន និងវិវាទដីធ្លី។
- ពង្រឹងសមត្ថភាពលើសិទ្ធិកាន់កាប់ដីធ្លី និងធនធានតាមការចាំបាច់។
- ដោះស្រាយរាល់បញ្ហាការទទួលខុសត្រូវត្រួតគ្នាក្នុងចំណោមនាយកដ្ឋាន និងក្រសួងស្ថាប័នរបស់រដ្ឋាភិបាលចំពោះដីព្រៃ។
- មានប្រព័ន្ធមួយសម្រាប់កត់ត្រាបណ្តឹងប្រពៃណីចំពោះដីព្រៃ និងចំពោះប្រព័ន្ធកាន់កាប់របស់ពួកគេ។
- ពិនិត្យឡើងវិញ និងដោះស្រាយឧបសគ្គផ្នែកហិរញ្ញវត្ថុ និងផ្តត់ផ្គង់សម្រាប់អ្នកប្រើប្រាស់ព្រៃឈើដែលទទួលបានសិទ្ធិតាមច្បាប់។
- ជួយបង្កើតឱកាសស្មើៗគ្នាចំពោះសហគ្រាសព្រៃឈើធុនតូច និងមធ្យមក្នុងការប្រកួតប្រជែងជាមួយសហគ្រាសធំៗ។

ក្បួននេះមិនបង្ហាញគ្រប់ជំហានជាក់លាក់ទាំងឡាយនៃកំណែទម្រង់វិស័យព្រៃឈើឡើយ។ ប៉ុន្តែវាបង្ហាញវិធីសាស្ត្រនានាដែលមានប្រយោជន៍ និងបង្ហាញប្រភពនៃការណែនាំដែលអាចជួយនាយកដ្ឋានព្រៃឈើ និងស្ថាប័នពាក់ព័ន្ធដទៃឱ្យសម្របតាមការផ្លាស់ប្តូរមុខងាររបស់ខ្លួន និងបង្កប់ដោយកិច្ចប្រតិបត្តិសមស្របក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។ វិធីសាស្ត្រទាំងនេះអាចជួយក្នុងការពិនិត្យឡើងវិញ និងក្នុងការដោះស្រាយចំណុចខាងលើ។ ការណែនាំនៅទីនេះរួមមាន៖

- វិនិយោគនិងគ្រប់គ្រងដំណើរការផ្លាស់ប្តូរផ្នែកស្ថាប័នដើម្បីជំនះឧបសគ្គស្ថាប័នទាំងនោះនៅក្នុងវិស័យសាធារណៈដែលត្រូវបានពិនិត្យឃើញថា កំហិតអភិបាលកិច្ចល្អចំពោះសិទ្ធិកាន់កាប់ព្រៃឈើដែលមានការទទួលខុសត្រូវ។
- ធ្វើយ៉ាងណាឱ្យបុគ្គលិក រាប់ទាំងបុគ្គលិកផ្តល់សេវាផ្ទាល់ និងគណៈគ្រប់គ្រងថ្នាក់កណ្តាល និងជាន់ខ្ពស់ យល់ដឹងច្បាប់ និងទស្សនទានសំខាន់ៗទាក់ទងនឹងអភិបាលកិច្ចលើការកាន់កាប់ព្រៃឈើប្រកបដោយការទទួលខុសត្រូវ (សិទ្ធិមនុស្ស ភាពក្រីក្រ មូលហេតុដើមនៃភាពក្រីក្រ និងចំណងទាក់ទងជាមួយព្រៃឈើ យេនឌ័រ និងឥទ្ធិពលនៃទំនាក់ទំនងអំណាចលើការអនុវត្ត និងការលើកកម្ពស់សិទ្ធិចំពោះព្រៃឈើ)។
- ពង្រឹងសមត្ថភាពរដ្ឋបាល និងធនធានរបស់នាយកដ្ឋានព្រៃឈើក្នុងការកំណត់ព្រំដីជាក់ស្តែង ការពណ៌នាអំពីព្រំដី ការអនុវត្តសិទ្ធិស្តីពីសិទ្ធិកាន់កាប់ព្រៃឈើ។
- កសាងជំនាញរបស់បុគ្គលិកនាយកដ្ឋានព្រៃឈើដើម្បីបង្កលក្ខណៈ និងគាំទ្រអ្នកមានសិទ្ធិអនុវត្តសិទ្ធិរបស់ខ្លួន ព្រមទាំងគ្រប់គ្រងធនធានព្រៃឈើដោយប្រសិទ្ធភាព (ជំនាញចូលរួមរបស់សហគមន៍ដូចជា ការចូលរួម ការចរចា និងការដោះស្រាយវិវាទ ព្រមទាំងបង្កើតឱ្យមានការយល់ព្រមដោយសេរី មានការជូនដំណឹងជាមុន មុនពេលធ្វើការផ្លាស់ប្តូរណាមួយ)។

## ឧបករណ៍គួរប្រើ

| B2.1 | ការសម្រួលដល់ការផ្លាស់ប្តូរផ្នែកអង្គការចាត់តាំង និងផ្នែកស្ថាប័ន |
|---|---|
| **នេះជាអ្វី?** | ជាសៀវភៅមួយដែលផ្តល់នូវឧបករណ៍មួយចំនួនក្នុងការផ្តល់ក្របខ័ណ្ឌរួមមួយសម្រាប់ពិភាក្សាក្នុងចំណោមភាគីពាក់ព័ន្ធនៅ ក្នុងដំណើរការកំណែទម្រង់ស្ថាប័នទាំងមូល។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ត្រូវប្រើជាមួយដំណើរការផ្លាស់ប្តូរនៅក្នុងអង្គការចាត់តាំង ឬនៅក្នុងស្ថាប័ន ដើម្បីជួយសម្រួលដល់ដំណើរការនេះ។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | សៀវភៅនេះពណ៌នាអំពីដំណាក់កាលផ្សេងៗ និងឧបករណ៍សម្រាប់ដំណាក់កាលនីមួយៗ៖ ការវិភាគ និងការសិក្សាពោគវិនិច្ឆ័យនៃក្របខ័ណ្ឌទាំងមូលរបស់ស្ថាប័នការវិភាគ និងការសិក្សាពោគវិនិច្ឆ័យរបស់អង្គការនៅក្នុងក្របខ័ណ្ឌស្ថាប័នរបស់សាមីអង្គការការពិនិត្យឡើងវិញ និងការរៀបចំជាទម្រង់ប្លង់ការអនុវត្តការតាមដាននិងវាយតម្លៃ។ |
| **ចំពោះព័ត៌មានបន្ថែម** | DFID. 2003. Promoting institutional and organisational development: a source book of tools and techniques. London. http://webarchive.nationalarchives. gov.uk/+/ http://www.dfid.gov.uk/pubs/files/prominstdevsourcebook.pd |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.2, A4.7, A5 |

## ការសាកសួរបែបទទួលស្គាល់តម្លៃ — B2.2

| | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រមួយក្នុងការពិនិត្យមើលសក្តានុពលនៃការផ្លាស់ប្តូរអង្គការចាត់តាំង តាមរយៈការកំណត់ និងការពឹងផ្អែកលើទិដ្ឋភាពវិជ្ជមានដែលមានស្រាប់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីបង្កើតចំណេះដឹងថ្មី ដោយប្រើកិច្ចប្រតិបត្តិបច្ចុប្បន្ន ជាកតាលីករ ដែលពង្រីក 'អាណាចក្រអ្វីដែលអាចទៅរួច' និងជួយសមាជិករបស់អង្គការដើម្បី ប្រមើលមើលអនាគតដែលប្រាថ្នាចង់បានរួមគ្នា និងបន្តអនុវត្តទៅអនាគត។ |
| **ធាតុផ្សំសំខាន់ៗ** | ការសាកសួរបែបផ្តល់ការលើកទឹកចិត្តព្យាយាមសួរសំណួរតាមបែបមួយដែលពួកគេពិនិត្យមើលទិដ្ឋភាពរបស់អង្គការចាត់តាំងមួយ។ គោលបំណងគឺកសាង ឬកសាងជាថ្មីនូវស្ថាប័នជុំវិញអ្វីដែលដំណើរការទៅរួច ជាជាងការប្រឹងប្រែង ដោះស្រាយអ្វី ដែលមិនអាចដំណើរការទៅបាន។<br><br>វិធីសាស្ត្រនេះប្រើវដ្តមួយដែលមានបួនដំណាក់កាល៖ 'រកឃើញ' ជាការកំណត់រកដំណើរការរបស់អង្គការមួយដែលដំណើរការបានល្អ។ 'ស្រមៃ' ជាការប្រមើលមើលដំណើរការដែលអាចដំណើរការបានល្អក្នុងពេលអនាគត។ 'រៀបចំប្លង់' ជាដំណើរការកសាងផែនការ និងដំណើរការផ្តល់អាទិភាពដែលនឹងដំណើរការល្អ និង 'វាសនា' ឬ 'ប្រគល់' ជាការអនុវត្តប្លង់ដែលបានស្នើ។ |
| **ចំពោះព័ត៌មានបន្ថែម** | Serrat, O. 2008. Appreciative Inquiry. Knowledge Solutions Series. Manila, Asian Development Bank. http://www.adb.org/Documents/Information/Knowledge-Solutions/Appreciative-Inquiry.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A5, C1, C2 |

## ដំណើរការគម្រោងសាកល្បង — B2.3

| | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រមួយសម្រាប់វាស់ស្ទង់ និងយល់ដឹងអំពីឥទ្ធិពលដែលអាចកើតមាននូវវិធីធ្វើការបែបថ្មីមុនពេលពង្រីកការអនុវត្តជាទូទៅ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | សម្រាប់ប្រើមុនពេលមានការផ្លាស់ប្តូរចំពោះអង្គការ ឬការផ្លាស់ប្តូរទូទាំងប្រទេស ដើម្បីវាស់ស្ទង់ និងទទួលបាននូវការយល់ដឹងបានកាន់តែប្រសើរអំពីវិធីដំណើរការការងារផ្សេងគ្នាតាមរយៈកំណែទម្រង់ ឬតាមរយៈការប្រើវិធីសាស្ត្រខុសៗគ្នា។ |
| **ធាតុផ្សំសំខាន់ៗ** | លក្ខណៈមួយនៃគម្រោងសាកល្បងគឺថាគម្រោងទាំងនោះត្រូវមានគោលដៅដកពិសោធន៍ច្បាស់លាស់ហើយអនុវត្តវិធីសាស្ត្រ 'ដោះស្រាយបញ្ហាពិតតាមរយៈសកម្មភាព'។ គោលដៅនៃការដកពិសោធន៍នេះដាក់ចេញនូវសំណួរដែលនឹងត្រូវពិនិត្យមើលតាមរយៈការអនុវត្តសាកលល្បង ហើយអាចប្រើប្រាស់បទពិសោធន៍ដែលបានទទួលដើម្បីផ្សព្វផ្សាយដល់កិច្ចប្រតិបត្តិក្នុងពេលអនាគត ឬសម្រាប់បង្កើតគោលនយោបាយ។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Uganda Forestry Sector Policy and Strategy Project. Understanding what will work: pilot projects for extension service delivery reform. Uganda National Forest Programme (NFP) Process Learning Series, Note 3. Forestry Inspection Division, Uganda Ministry of Water, Land and Development, London, DFID, and Edinburgh, LTS International. http://webarchive.nationalarchives.gov. uk/+/http://www.dfid.gov.uk/Documents/publications/ugandanfpseries3.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A, C, D |

## B2.4 ការបង្វឹកវិធីសាស្ត្រដែលមានការចូលរួមដល់មន្ត្រីរដ្ឋាភិបាលក្នុងពេលបំពេញការងារ

| | |
|---|---|
| **នេះជាអ្វី ?** | ការបង្វឹកបុគ្គលិករដ្ឋាភិបាលនៅមូលដ្ឋានឬនៅថ្នាក់ជាតិក្នុងការជំរុញការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ដើម្បីកសាងសមត្ថភាពអនុវត្តវិធីសាស្ត្រដែលមានការចូលរួមក្នុងវិស័យព្រៃឈើ។ |
| **ធាតុផ្សំសំខាន់ៗ** | គាំទ្រការរួមបញ្ចូលវិធីសាស្ត្រដែលមានការចូលរួមទៅក្នុងការងារប្រចាំថ្ងៃដើម្បីគាំទ្រការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ការកសាងសមត្ថភាពអនុវត្តដោយនាយកដ្ឋានព្រៃឈើ និងស្ថាប័នសំខាន់ៗដូចជា សាលារុក្ខាប្រមាញ់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្ថាប័នដទៃទៀត។ |
| **ចំពោះព័ត៌មានបន្ថែម** | Gilmour, D. & Sarfo-Mensah P. 2005. Evaluation report on project ‘Strengthening Participatory Approaches to Forest Management in Ghana, Guyana & Uganda’. London, DFID. http://www.dfid.gov.uk/r4d/Project/60405/Default.aspx |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.7, C2.3, C2.4<br>ឧបករណ៍ស៊ីដរម្រៅ:XL B2.4 |

## B2.5 ប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកដើម្បីធានាដល់សិទ្ធិព្រៃឈើ

| | |
|---|---|
| **នេះជាអ្វី ?** | ធ្វើឱ្យសាធារណជនអាចទទួលបាននូវកំណត់ត្រាព័ត៌មានផ្លូវការដោយកុំព្យូទ័រ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | កុំព្យូទ័រូបនីយកម្មកំណត់ត្រាព័ត៌មានអំពីសិទ្ធិដីធ្លី ធ្វើឱ្យគេអាចរកបានកាន់តែងាយស្រួលតាមរយៈតូបកុំព្យូទ័រនៅតាមភូមិ ត្រូវបានគេប្រើប្រាស់ជាទូទៅក្នុងការចងក្រងឯកសារសិទ្ធិដីធ្លី។ ប្រព័ន្ធនេះត្រូវបានចាត់ទុកថាសមស្របសម្រាប់អនុវត្តចំពោះដីព្រៃ។ |
| **ធាតុផ្សំសំខាន់ៗ** | ខណៈដែលគោលនយោបាយបើកចំហទិន្នន័យត្រូវបានផ្តួចផ្តើមជាចម្បងដោយស្ថាប័នរដ្ឋាភិបាល ប្រសិនបើអាច អង្គការសង្គមស៊ីវិលត្រូវស្នើសុំទិន្នន័យផ្លូវការទាំងនោះ។ ការស្នើសុំនេះអាចផ្តោតលើអត្ថប្រយោជន៍ផ្សេងៗ៖ ការកាត់បន្ថយភាពមិនច្បាស់លាស់ចំពោះព្រំដី តម្លាភាពបន្ថែមទៀតអំពីកម្មសិទ្ធិ ទំនាក់ទំនងកាន់តែប្រសើររវាងអាជ្ញាធរ និងសហគមន៍ ឬផលប្រយោជន៍ហិរញ្ញវត្ថុដូចជាការកាត់បន្ថយអំពើពុករលួយជាដើម។ |
| **ចំពោះព័ត៌មានបន្ថែម** | Castrén, T & Pillai, M. 2011. Forest Governance 2.0: a primer on ICTs and governance. Washington, DC, The Program on Forests (PROFOR) and World Bank http://www.profor.info/profor/sites/profor.info/files/docs/Forest%20 Governance_web.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3.2 |

## B3. ការរៀបចំវិស័យឯកជនឱ្យដំណើរការត្រឹមត្រូវ និងប្រកបដោយបរិយាប័ន្ន

តើវិស័យឯកជនមានមុខងារខុសគ្នាអ្វីខ្លះដែលប៉ះពាល់ដល់ធនធាន និងសេវាព្រៃឈើ? តើមានប្រព័ន្ធ និងកិច្ចព្រមព្រៀងសមស្របដើម្បីឱ្យពួកគេប្រតិបត្តិតាមដែរឬទេ? វិស័យឯកជនចាំបាច់ត្រូវដំណើរការត្រឹមត្រូវ និងប្រកបដោយបរិយាប័ន្នដើម្បីឱ្យការគ្រប់គ្រងព្រៃឈើមានការទទួលខុសត្រូវ។

មុខងារចម្បងនៃវិស័យឯកជនគឺ៖

- ជាម្ចាស់ និងអ្នកគ្រប់គ្រងដីព្រៃ
- ជាអ្នកគ្រប់គ្រងសហគ្រាសព្រៃឈើខ្នាតតូច និងមធ្យម
- ជាពាណិជ្ជករនៃធនធានព្រៃឈើ (រាប់ទាំងសេវាប្រព័ន្ធអេកូឡូស៊ីផងដែរ)
- ជាគម្រោង ឬកម្មវិធីផ្តល់មូលនិធិរបស់វិនិយោគិនចំពោះដីព្រៃ

សហគ្រាសព្រៃឈើខ្នាតតូច និងមធ្យមគឺជាប្រតិបត្តិការអាជីវកម្មសំដៅស្វែងរកប្រាក់ចំណេញពីសកម្មភាពផ្អែកលើព្រៃឈើ។ ជារឿយៗ សហគ្រាសទាំងនោះ ជាសហគ្រាសខ្នាតតូចដែលត្រូវបានបង្កើតឡើងជាឱកាសសម្រាប់សហគមន៍ក្នុងការទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុ។ សហគ្រាសព្រៃឈើគឺជាយន្តការមួយមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ បញ្ចៀសការកាប់បំផ្លាញព្រៃឈើ ហើយជាយន្តការមួយក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក្តី សហគ្រាសទាំងនោះក៏ត្រូវគ្រប់គ្រងតាមបែបមួយ ដែលមានការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថានផងដែរ។ ជាមួយនឹងក្រុមសហគមន៍មូលដ្ឋាន អង្គការតូចៗជាច្រើនត្រូវការការគាំទ្រដើម្បីធានាសិទ្ធិរបស់ខ្លួន ហើយត្រូវប្រែក្លាយសិទ្ធិទាំងនេះទៅជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតដែលមាននិរន្តរភាព។

ក្រុមហ៊ុន និងធនាគារឯកជនដែលវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍដទៃទៀតលើដីព្រៃ ចាំបាច់ត្រូវអនុវត្តតាមកិច្ចប្រតិបត្តិល្អប្រសើរក្នុងការការពារបរិស្ថាន និងសង្គមដើម្បីធានាសិទ្ធិស្តីពីការចូលទៅកាន់ការប្រើប្រាស់ និងការគ្រប់គ្រងជាក់ស្តែង តាមច្បាប់ត្រូវបានពិចារណាផងដែរ។ ក្នុងនាមជាម្ចាស់ ឬជាអ្នកគ្រប់គ្រងសំខាន់ ក្រុមហ៊ុនគប្បីប្រើប្រាស់កិច្ចប្រតិបត្តិល្អប្រសើរក្នុងការរួមបញ្ចូលសហគមន៍មូលដ្ឋាន និងអ្នករស់នៅក្នុងព្រៃ ហើយទទួលបានការយល់ព្រមដោយសេរី និងជូនដំណឹងជាមុន ( សូមអាន Tools for engaging ឧបករណ៍សម្រាប់ការចូលរួម)។

ភាពជាដៃគូរវាងក្រុមហ៊ុន និងសហគមន៍ព្រៃឈើមានសក្តានុពលក្នុងការរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើ និងការអភិវឌ្ឍជនបទប្រកបដោយនិរន្តរភាព។ គេឃើញមានកិច្ចព្រមព្រៀងដែលកំពុងអនុវត្តដើម្បីផលិតធនធាន និងសេវាព្រៃឈើក្នុងនោះគូភាគីបែងចែកប្រាក់ចំណេញ ចំណាយ និងហានិភ័យជាមួយនឹងក្តីពឹងអំពីការទទួលផលពីគ្នាទៅវិញទៅមក។ កិច្ចព្រមព្រៀងទាំងនោះច្រើនតែត្រូវបានផ្តួចផ្តើមឡើង ក្រោយពីមានការផ្លាស់ប្តូរលើការចាត់ចែងអំពីសិទ្ធិកាន់កាប់ ដូចជាឯកជននីយកម្មព្រៃឈើ ឬការកើតឡើងនូវទីផ្សារផ្តល់សេវាផ្នែកប្រព័ន្ធអេកូឡូស៊ី។ ការចរចា និងការគ្រប់គ្រងភាពជាដៃគូទាំងនេះ ចាំបាច់ត្រូវគិតគូរអំពីសិទ្ធិព្រៃឈើទាំងអស់ដែលកំពុងមានក្នុងពេលបច្ចុប្បន្ន។ កត្តាសំខាន់មួយក្នុងជោគជ័យនៃទំនាក់ទំនងបែបនេះ គឺកម្រិតនៃទំនុកចិត្តដែលបានបង្កើតឡើងរវាងក្រុមហ៊ុន និងសហគមន៍។ ជាងនេះទៅទៀត ជំនួយបច្ចេកទេសមានសារសំខាន់សម្រាប់ក្រុមហ៊ុនក៏ដូចជាសម្រាប់សហគមន៍មូលដ្ឋានផងដែរ។

## ឧបករណ៍គួរប្រើ

### B3.1 ការវិភាគទីផ្សារ និងការអភិវឌ្ឍសម្រាប់សហគ្រាសដែលផ្ដោតលើឈើសហគមន៍ និងសហគ្រាសផលិតផលឈើ

| | |
|---|---|
| **នេះជាអ្វី?** | សៀវភៅណែនាំអនុវត្តជាក់ស្ដែងដែលផ្ដល់នូវក្របខ័ណ្ឌមួយសម្រាប់កសាងផែនការសហគ្រាសដើមឈើ និងផលិតផលឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ណែនាំអ្នកសម្របសម្រួលដែលនឹងជួយប្រជាជននៅក្នុងដំណើរការកំណត់ផលិតផលដែលមានសក្ដានុពល និងអភិវឌ្ឍទីផ្សារដែលផ្ដល់ប្រាក់ចំណូល និងអត្ថប្រយោជន៍ដោយមិនធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានធនធាន។ |
| **ធាតុផ្សំសំខាន់ៗ** | សៀវភៅណែនាំនេះមានកូនសៀវភៅប្រាំមួយដែលបង្ហាញបណ្ដាជំហាន និងករណីសិក្សាក្នុងបីដំណាក់កាល៖ ដំណាក់កាលទី១-វាយតម្លៃស្ថានភាពបច្ចុប្បន្ន ដំណាក់កាលទី២-កំណត់ផលិតផល ទីផ្សារ និងមធ្យោបាយពង្រីកការលក់ ដំណាក់កាលទី៣-កសាងផែនការសហគ្រាសដើម្បីឱ្យមានការអភិវឌ្ឍដែលមាននិរន្តរភាព។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2011. Community-based tree and forest product enterprises: Market analysis and development, I. Lecup. Rome. http://www.fao.org/docrep/014/ i2394e/i2394e00.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A1.1, B1.5 |

### B3.2 ការពង្រឹងអភិបាលកិច្ច និងរចនាសម្ព័ន្ធសហគ្រាសសហគមន៍

| | |
|---|---|
| **នេះជាអ្វី?** | ជាឧបករណ៍មួយសម្រាប់កំណត់រចនាសម្ព័ន្ធ និងអភិបាលកិច្ចស្ថាប័នដើម្បីឱ្យការចាត់តាំងសហគ្រាសព្រៃឈើសហគមន៍ទទួលជោគជ័យ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជួយអ្នកសម្របសម្រួលក្នុងការលើកកម្ពស់និរន្តរភាពផ្នែកសង្គមនៃផលិតករសហគ្រាសព្រៃឈើសហគមន៍ ដោយផ្ដោតលើចំណុចសំខាន់បីគឺសេដ្ឋកិច្ច បរិស្ថាន និងសង្គម។ |
| **ធាតុផ្សំសំខាន់ៗ** | បណ្ដាជំហានសំខាន់ៗនៅក្នុងដំណើរការនេះគឺ ការវិភាគអំពីស្ថានភាពចូលរួម ការសម្រួលការបង្កើតរចនាសម្ព័ន្ធចាត់តាំង និងប្រព័ន្ធអភិបាលកិច្ចដែលត្រូវបានលើកកម្ពស់ការកសាងសមត្ថភាព ការពិនិត្យមើលសកម្មភាពសមូហភាព ការបង្កើតច្រកចេញចូលតែមួយ ចំពោះព័ត៌មានស្ដីពីសេវាអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ និងអាជីវកម្ម ការសម្រួលប្រព័ន្ធព័ត៌មានទីផ្សារ។ |
| **ចំពោះព័ត៌មានបន្ថែម** | Macqueen, D.J. et al. 2012. Strengthening community enterprise organisations. Supporting small forest enterprises: A facilitators toolkit, Module 14. Small and Medium Forest Enterprise Series, No. 29. London, IIED. http://pubs.iied.org/13558IIED.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B1.5 |

## ការវិនិយោគលើសហគ្រាសព្រៃឈើប្រកបដោយនិរន្តរភាព

**B3.3**

| | |
|---|---|
| **នេះជាអ្វី ?** | ក្បួនសម្រាប់ធនាគារ និងវិនិយោគិន ក្នុងការគាំទ្រការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ដើម្បីជួយគ្រឹះស្ថានហិរញ្ញវត្ថុបង្កើតគោលនយោបាយស៊ីសង្វាក់គ្នា និងមានប្រសិទ្ធភាពរៀបចំនីតិវិធីអនុវត្ត និងតាមដានសម្រាប់ផ្តល់ហិរញ្ញប្បទានដល់សហគ្រាសព្រៃឈើប្រកបដោយនិរន្តរភាព។ |
| **ធាតុផ្សំសំខាន់ៗ** | ឯកសារជំនួយដែលមានចំណងជើងថា The Sustainable Forest Finance Toolkit ( ក្បួនហិរញ្ញប្បទានព្រៃឈើប្រកបដោយនិរន្តរភាព ) ចែកចេញជាបួនផ្នែកសំខាន់ ត្រូវបានរៀបចំ ជាទម្រង់មួយដែលមានលក្ខណៈអនុវត្តជាក់ស្តែង មានលក្ខណៈអន្តរកម្ម និងផ្តោតលើក្រុមអ្នកប្រើប្រាស់ជាក់លាក់ នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុមួយ។ ផ្នែកទាំងនោះរួមមាន ការអនុវត្តថ្មី គឺជាការណែនាំសម្រាប់វាយតម្លៃអ្នកដែលអាចក្លាយជាអតិថិជនវិស័យព្រៃឈើ ការគ្រប់គ្រងផលបត្រជាវិធីសាស្ត្រ ឆ្លុះបញ្ចាំងសម្រាប់វាយតម្លៃផលបត្រនៃមតេករបស់អតិថិជនព្រៃឈើ ការអភិវឌ្ឍគោលនយោបាយ ជាការណែនាំអំពីបញ្ហាដែលមានសារសំខាន់ជាយុទ្ធសាស្ត្រ និងសម្រាប់កិច្ចប្រតិបត្តិក្នុងការរៀបចំគោលនយោបាយព្រៃឈើដែលមានលក្ខណៈប្រាកដនិយម និងច្បាស់លាស់ លទ្ធកម្ម ជាគំរូគោលនយោបាយលទ្ធកម្មព្រៃឈើ និងទំនាក់ទំនងជាមួយធនធានសំខាន់ៗ។ |
| **ចំពោះព័ត៌មានបន្ថែម** | Pricewaterhouse Coopers/WBCSD. 2009. Sustainable Forest Finance Toolkit. New York, Pricewaterhouse Coopers, and Geneva, World Business Council for Sustainable Development. http://www.pwc.co.uk/sustainability-climate-change/ issues/ forest-finance-home.jhtml |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B1.5, C1.3, C2.6 |

## ភាពជាដៃគូរវាងក្រុមហ៊ុន និងសហគមន៍ព្រៃឈើ

**B3.4**

| | |
|---|---|
| **នេះជាអ្វី ?** | ការណែនាំអំពីធាតុផ្សំសំខាន់ៗសម្រាប់ភាពជាដៃគូ ដែលមានប្រសិទ្ធភាពរវាងក្រុមហ៊ុន និងសហគមន៍ព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ដើម្បីណែនាំក្រុមហ៊ុន និងផលិតករព្រៃឈើដែលមានមូលដ្ឋាននៅសហគមន៍ឬក្រុមអ្នកប្រើប្រាស់ក្នុងការអភិវឌ្ឍភាពជាដៃគូប្រកបដោយសមធម៌ និងមានផលិតភាពជាមួយសហគ្រាសផ្អែកលើកិច្ចសន្យា។ |
| **ធាតុផ្សំសំខាន់ៗ** | បន្ទាប់ពីពិនិត្យករណីសិក្សាស៊ីជម្រៅឡើងវិញ ការណែនាំនេះផ្តល់នូវកត្តាជោគជ័យមួយចំនួនដល់ក្រុមហ៊ុន ម្ចាស់ដី និងសហគមន៍នានាផ្តល់គោលការណ៍សម្រាប់ទទួលផលច្រើន ផ្តល់នូវធាតុផ្សំផ្សេងៗសម្រាប់កិច្ចសន្យាឬកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូដែលប្រាថ្នាចង់បាន ជាមួយនឹងការបង្កើតថ្មីផ្តើមចេញពីសមាសធាតុករណី និងសកម្មភាពសំខាន់ៗមួយចំនួនដែលក្រុមហ៊ុន សហគមន៍ រដ្ឋាភិបាល ភាគីទីបី និងម្ចាស់ជំនួយអាចទទួលយកដើម្បីឱ្យមានភាពជាដៃគូកាន់តែប្រសើរ។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Mayers, J. & Vermeulen, S. 2002. Company–community forestry partnerships: from raw deals to mutual gains? London, IIED. http://pubs.iied.org/9132IIED.html<br>Chandrasekharan Behr, D., Sander, K., Rosenbaum, K., Angeletti, I. & Dengel, C. 2009. Rethinking forest partnerships and benefit sharing: insights on factors and context that make collaborative arrangements work for communities and landowners. Washington, DC, World Bank. http://www.profor.info/profor/ sites/profor.info/files/Benefit_Sharing_WEB_0.pdf<br>Chandrasekharan Behr, D. 2012. Making benefit sharing arrangements work for forest-dependent communities: overview of insights for REDD+ initiatives. Washington, DC, The Program on Forests (PROFOR). |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.7, B1.1 |

## B3.5 ស្តង់ដារពាណិជ្ជកម្មត្រឹមត្រូវសម្រាប់ឈើដែលមានប្រភពចេញពីផលិតករខ្នាតតូច និងផលិតករនៅសហគមន៍

| | |
|---|---|
| **នេះជាអ្វី?** | គេប្រើស្តង់ដារសម្រាប់បន្ថែមទិដ្ឋភាព 'ពាណិជ្ជកម្មត្រឹមត្រូវ' ចំពោះការគ្រប់គ្រងព្រៃឈើដែលមានការទទួលខុសត្រូវរបស់ផលិតករខ្នាតតូច និងដើម្បីលើកកម្ពស់ការធ្វើពាណិជ្ជកម្មនៅកម្រិតខ្សែសង្វាក់ផ្គត់ផ្គង់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ស្តង់ដារពាណិជ្ជកម្មត្រឹមត្រូវចំពោះឈើកំណត់កិច្ចតម្រូវពាណិជ្ជកម្មត្រឹមត្រូវបន្ថែមលើវិញ្ញាបនកម្មគ្រប់គ្រងព្រៃឈើ និងវិញ្ញាបនកម្មឯកសារទិន្នានុប្បវត្តិបច្ចេកទេស (Chain-of-custody)។ |
| **ធាតុផ្សំសំខាន់ៗ** | កិច្ចតម្រូវទាំងនោះគឺសម្រាប់ (1) សហគ្រាសព្រៃឈើដែលមានរួចហើយនូវក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើត្រឹមត្រូវគួបផ្សំជាមួយវិញ្ញាបនបត្រគ្រប់គ្រងព្រៃឈើ/ឯកសារទិន្នានុប្បវត្តិបច្ចេកទេសដែលជា ឬដែលប្រភពឈើរបស់ពួកគេបានមកពីផលិតករខ្នាតតូចឬផលិតករនៅតាមសហគមន៍ និង (2) ពាណិជ្ជករនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ដែលជាបន្តបន្ទាប់ចាត់ចែងផលិតផលពាណិជ្ជកម្មត្រឹមត្រូវ ដែលអ្នកទាំងនោះក៏ត្រូវមានវិញ្ញាបនកម្មឯកសារទិន្នានុប្បវត្តិបច្ចេកទេសដែលមានសុពលភាពផងដែរ។<br><br>ស្តង់ដារនេះអនុវត្តចំពោះសហគ្រាសព្រៃឈើ ដែលផលិតផលិតផលព្រៃឈើច្រើនយ៉ាងរួមមានផលិតផលឈើ និងអាចមានផលិតផលមិនមែនព្រៃឈើផងដែរ។ ដើម្បីឆ្លើយតបនឹងស្តង់ដារនេះ សហគ្រាសត្រូវបំពេញកិច្ចតម្រូវមួយចំនួនលើការអភិវឌ្ឍសង្គម ការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍបរិស្ថាន និងលក្ខខណ្ឌការងារ។ ឯកសារស្តង់ដារដាក់ចេញនូវជំហាន ដែលត្រូវអនុវត្តតាមក្នុងករណីនីមួយៗ និងកិច្ចតម្រូវជាក់លាក់។ សហគ្រាសព្រៃឈើក៏ត្រូវបង្ហាញអនុលោមភាពតាមកាលកំណត់តាមរយៈការបន្តលើកកម្ពស់ការអនុវត្តជាអចិន្ត្រៃយ៍ផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | FLO. 2011. Fairtrade standards for timber for forest enterprises sourcing from small-scale/community-based producers. Bonn, Germany, Fairtrade Labelling Organizations International. http://www.fairtrade.net/fileadmin/user_upload/content/2009/standards/documents/2011-03-30_EN_Fairtrade_Standard_ for_Timber.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | C2.6, D3.5 |

## B4. ការកសាងឬការពង្រឹងសម្ព័ន្ធភាព បណ្តាញ និងសហព័ន្ធ

ធ្វើដូចម្តេចដើម្បីឱ្យសហគមន៍មូលដ្ឋានប្រាកដក្នុងចិត្តថាមតិយោបល់របស់ពួកគេត្រូវបានគេឮ? ធ្វើដូចម្តេចដើម្បីឱ្យពួកគេរួមកម្លាំងគ្នាក្នុងការដាក់បញ្ចូលនូវដំណើរការគោលនយោបាយ និងដំណើរការអភិបាលកិច្ច? សមាគមនិងសម្ព័ន្ធនៅតែជាមធ្យោបាយ ដែលមានប្រសិទ្ធភាពបំផុត សម្រាប់ឱ្យសហគមន៍លើកឡើងនូវអំណាចនៃការទាមទារ។

ការបង្កើតសម្ព័ន្ធភាពក្នុងចំណោមទីភ្នាក់ងារ ស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងតំណាងរបស់ពួកគេ (អង្គការកសិករ វិទ្យាស្ថានស្រាវជ្រាវ សហជីព ។ល។) អាចជំរុញឱ្យមានការចូលរួមជាទូទៅ។ ចាំបាច់ត្រូវវិនិយោគក្នុងការពង្រឹងជាថ្មីឡើងវិញនូវសហប្រតិបត្តិការ ធ្វើជាមធ្យោបាយសម្រាប់ពង្រឹងលំហូរព័ត៌មាន និងការប្រាស្រ័យទាក់ទងតាមខ្សែឈរទាំងពីរ (រវាងសង្គមស៊ីវិល និងអ្នកមានវិជ្ជាជីវៈ អាជ្ញាធរឬស្ថាប័ននានា) និងតាមខ្សែដេក (ក្នុងចំណោមតំណាងសង្គមស៊ីវិលផ្សេងៗគ្នា ឬក្នុងចំណោមតួអង្គពាក់ព័ន្ធដោយផ្ទាល់)។

ការជួបជុំគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និង/ឬអង្គការសង្គមស៊ីវិលនឹងបង្កលក្ខណៈឱ្យមានការប្រើប្រាស់ធនធានដែលមានស្រាប់បានកាន់តែប្រសើរ និងកៀរគធនធានបន្ថែម។ ជាងនេះទៀត សហប្រតិបត្តិការរបស់សហគមន៍ជាមួយអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាលនានានឹងនាំមកនូវផលប្រយោជន៍ដូចខាងក្រោម៖

- ការផ្តល់ការគាំទ្របច្ចេកទេស និងគាំទ្រផ្នែកស្ថាប័នចំពោះតួអង្គសង្គមស៊ីវិល
- ការពង្រីកបទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់កន្លែងដទៃ
- បង្កើនលទ្ធភាពទទួលបានព័ត៌មាននៅក្នុងសង្គមស៊ីវិល
- បង្កើនសមត្ថភាពសម្រេចចិត្តរបស់មន្ត្រីសាធារណៈ និងអ្នកគ្រប់គ្រងគម្រោង។

បណ្តាញ សម្ព័ន្ធភាព និងភាពជាដៃគូក៏អាចកើតមានរវាងថ្នាក់ដឹកនាំសហគមន៍ និងអង្គការនានា បង្កើនឡើងនូវលទ្ធភាពរបស់ពួកគេក្នុងកិច្ចសហការលើការចរចា និងការពិភាក្សា។

ឧបករណ៍នៅទីនេះផ្តោតលើការបង្កើតសម្ព័ន្ធភាព និងលំហូរលេូននៃព័ត៌មាននៅក្នុង និងរវាងសម្ព័ន្ធភាព និងសម្ព័ន្ធ។

## ការគ្រប់គ្រងក្រុមរៀនសូត្របែបមិត្តអប់រំមិត្តដើម្បីពង្រឹងអភិបាលកិច្ចព្រៃឈើ

**B4.1**

| | |
|---|---|
| **នេះជាអ្វី?** | ជាក្រុមមិត្តអប់រំមិត្ត និងរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីលើកកម្ពស់អភិបាលកិច្ចព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ក្រុមរៀនសូត្រដកពិសោធន៍គឺជាវិធីមានប្រសិទ្ធភាពមួយសម្រាប់បុគ្គលនៅក្នុងស្ថាប័ននានាផ្តល់ការគាំទ្រនិងរៀនសូត្រពីគ្នាទៅវិញទៅមក និងបង្កើតព្រមទាំងឆ្លៀតឱកាសកែលម្អអភិបាលកិច្ចព្រៃឈើតាមរយៈស្ថាប័នរបស់ខ្លួន។ ពួកគេបានបង្ហាញឱ្យឃើញថាមានឥទ្ធិពលមកលើ ការយល់ដឹងអំពីឧបសគ្គនិងឱកាសអភិបាលកិច្ចសំខាន់ៗ ព្រមទាំងលើមូលដ្ឋានជាក់ស្តែង មានការយល់ដឹងអំពីយុទ្ធវិធីអនុវត្តជាក់ស្តែងសម្រាប់កែប្រែអភិបាលកិច្ច លើកកម្ពស់សមត្ថភាពដើម្បីឱ្យមានឥទ្ធិពលមកលើ ឬកែប្រែអភិបាលកិច្ច ការលើកកម្ពស់យន្តការ និងដំណើរការចូលរួម ការផ្លាស់ប្តូរដំណើរការពិភាក្សា និងសម្រេចចិត្ត ព្រមទាំងធ្វើឱ្យមានឥទ្ធិពលមកលើការសម្រេចចិត្ត និងមកលើគោលនយោបាយ។ |
| **ធាតុផ្សំសំខាន់ៗ** | មានអនុសាសន៍បួនអំពីសកម្មភាពដែលមានទំនាក់ទំនងជាមួយគ្នាដោយក្រុមរៀនសូត្រដកពិសោធន៍អំពីអភិបាលកិច្ចព្រៃឈើនៅថ្នាក់ជាតិ ឬនៅថ្នាក់មូលដ្ឋានពោលគឺការបង្កើត ក្រុមអ្នក 'ដែលមានទំនាក់ទំនងជាមួយអភិបាលកិច្ច' មកពីទីភ្នាក់ងារចម្រុះ ដែលមានបទពិសោធន៍ និងគំនិតផ្សេងៗ ធ្វើការងារគោលនយោបាយស្តីពីបញ្ហាចិញ្ចឹមជីវិតពឹងផ្អែកលើព្រៃឈើ ដែលកើតឡើងនៅពេលដែលប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចចិត្ត ការបង្កើតការណែនាំដែលមានលក្ខណៈអនុវត្តជាក់ស្តែងរួមជាមួយឧបករណ៍សម្រាប់ធ្វើឱ្យមានដំណើរការ និងការបង្កើត និងចាប់យកឱកាសដើម្បីកែលម្អអភិបាលកិច្ច។ យុទ្ធវិធីគន្លឹះក្នុងការកែលម្អនេះរួមមាន ការធានាឱ្យមានសុវត្ថិភាព ជំរុញឱ្យមានការពិភាក្សាគ្នា ការកសាងមណ្ឌលអ្នកគាំទ្រ ការមានភស្តុតាងនៅក្នុងដៃ និងការប្រាស្រ័យទាក់ទងផ្នែកនយោបាយ។ |
| **ចំពោះព័ត៌មានបន្ថែម** | Mayers, J. et al. 2009. Just forest governance: how small learning groups can have big impact. IIED Briefing. London, IIED. http://pubs.iied.org/17070IIED.html?c=forestry |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A, C1.5, C1.10, C2.1, C2.3, D1.4, D1.5, D3.6 |

## B4.2 បណ្តាញសង្គមៈ ៣៨ ដឺក្រេនិងកត្តាផ្សេងទៀត

| | |
|---|---|
| **នេះជាអ្វី?** | ៣៨ ដឺក្រេ គេដាក់ឈ្មោះបែបនេះព្រោះថា ៣៨ ដឺក្រេគឺជាមុំមួយដែល ពេលណាមានទំហំធំជាងនេះការបាក់ធ្លាក់ទឹកកកនឹងកើតមាន គឺជាសហគមន៍ប្រជាពលរដ្ឋឯករាជ្យ គ្មានបក្សសម្ព័ន្ធនយោបាយ នាំគ្នាធ្វើការដើម្បីនាំមកនូវ 'ការប្រែប្រួលជាដុំកំភួន' នៅចក្រភពអង់គ្លេសតាមរយៈការចាត់វិធានការលើបញ្ហានានាដែលពលរដ្ឋយកចិត្តទុកដាក់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | គេអាចប្រើបណ្តាញសង្គមចំពោះបញ្ហាយុទ្ធនាការណាមួយ ដែលមានមូលដ្ឋានគាំទ្រច្រើន។ សមិទ្ធិផលគួរឱ្យកត់សម្គាល់នៃវិធាន ៣៨ ដឺក្រេ (ជាមួយកត្តាដទៃទៀត) គឺការបញ្ចុះបញ្ចូលរដ្ឋាភិបាលចក្រភពអង់គ្លេស និងអៀកឡង់ខាងជើងឱ្យលុបចោលផែនការរបស់ខ្លួនក្នុងការលក់ដីព្រៃ ២៥០,០០០ ហិកតារបស់រដ្ឋនៅប្រទេសអង់គ្លេសឱ្យវិស័យឯកជន។ |
| **ធាតុផ្សំសំខាន់ៗ** | ចំណុចខ្លាំង និងឥទ្ធិពលនៃបណ្តាញសង្គមអាស្រ័យលើចំនួនប្រជាជនចូលរួម ដែលមានការកើនឡើង ប្រសិនបើរបៀបវារៈមានភាពច្បាស់លាស់ហើយការចូលរួមមានភាពងាយស្រួល។ វិធាន ៣៨ ដឺក្រេ ប្រើឧបករណ៍សាមញ្ញចំពោះសមាជិកសាធារណៈពាក់ព័ន្ធ ដើម្បីធ្វើឱ្យមានឥទ្ធិពលចំពោះសេចក្តីសម្រេចចិត្ត ដែលប្រព្រឹត្តទៅនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិរួមមាន ញត្តិលើគេហទំព័រ សារអេឡិចត្រូនិក លិខិត និងការជួបជាមួយសមាជិក សភា និងថ្នាក់ដឹកនាំក្រុមហ៊ុនសាជីវកម្ម និងវិធីសាស្ត្រសន្តិភាព ដទៃទៀតនៃការធ្វើយុទ្ធនាការពីសំណាក់ប្រជាជនដែលមានចំនួនច្រើន។ សមាជិកទាំងនេះ (សាធារណជន) ដាក់ចេញនូវរបៀបវារៈ ហើយបុគ្គលមួយចំនួនតូចបង្កើតយុទ្ធវិធី ផ្អែកលើ សំណើនានាដែលបានទទួលពីសាធារណជន។ |
| **ចំពោះព័ត៌មានបន្ថែម** | ៣៨ Degrees, UK: http://www. 38degrees.org.uk<br>MoveOn, USA: http://front.moveon.org = GetUp, Australia: http://www.getup.org.au<br>Avaaz, International: http://www.avaaz.org |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.2, A4.4, A4.6 |

## B4.3 ការកសាងសម្ព័ន្ធភាព និងសម្ព័ន្ធដើម្បីតស៊ូមតិ

| | |
|---|---|
| **នេះជាអ្វី?** | ជាឧបករណ៍កំណត់វិធីដែលក្រុមសង្គមស៊ីវិលអាចកំណត់ និងកសាងសហព័ន្ធ និងសម្ព័ន្ធភាពនានាដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងបរិបទជាច្រើន ចាប់តាំងពីការស្រាវជ្រាវដែលមានការចូលរួម និងការអភិវឌ្ឍសហគមន៍ ហូតដល់ការរៀបចំតំបន់ក្បែរខាង និងការអប់រំអំពីសិទ្ធិគតិយុត្ត រហូតឈានដល់យុទ្ធនាការតស៊ូមតិដែលមានទ្រង់ទ្រាយធំ។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍ទាំងនេះរួមមានបណ្តាជំហានដែលមានលក្ខណៈអនុវត្ត ជាក់ស្តែងអមដោយមូលដ្ឋានគ្រឹះផ្នែកទ្រឹស្តីអំពីការពង្រឹង អំណាចនយោបាយលើមូលដ្ឋានសិទ្ធិ។ ឧបករណ៍ទាំងនោះផ្តល់អនុសាសន៍ និងពណ៌នាវិធីអនុវត្ត ឱកាសទាំងប្រាំនៃ ការកសាងផែនការ ពោលគឺការយល់ដឹងរូបភាពទូទៅ ការកំណត់រក និងការកំណត់និយមន័យបញ្ហា ការវិភាគចំណោទ និងការជ្រើសរើសបញ្ហាអាទិភាព ព្រមទាំងការបង្កើតយុទ្ធសាស្ត្រតស៊ូមតិ។ ឧបករណ៍ទាំងនេះរៀបរាប់អំពីផ្នាក់នយោបាយ មុំនយោបាយ មិត្ត និងសត្រូវ ហើយផ្តល់នូវការណែនាំអំពីសារ និងប្រព័ន្ធផ្សព្វផ្សាយ ការចុះអប់រំ និងការកៀរគរ ការបញ្ចុះបញ្ចូល និងការចរចា ភាពជាអ្នកដឹកនាំអំពីការតស៊ូមតិ ព្រមទាំងការកសាងសហព័ន្ធ និងសម្ព័ន្ធភាព។ |
| **ចំពោះព័ត៌មានបន្ថែម** | VeneKlasen L. & Miller, V. 2007. Alliances and Coalitions. A New Weave of Power, People and Politics: The Action Guide for Advocacy and Citizen Participation. Sterling, Virginia, USA, Stylus Publishing, and Rugby, UK, Practical Action Publishing. http:// www.justassociates.org/ActionGuide.htm<br>Colchester, M., Apte, T., Laforge, M., Mandondo, A. & Pathak, N. 2003. Bridging the gap: communities, forests and international networks. Occasional Paper 41. Bogor, Indonesia, Centre for International Forestry Research (CIFOR). http://www.cifor.org/publications/pdf_files/OccPapers/OP-41.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.4, C1.6, C1.7 |

# ឧបករណ៍សម្រាប់ការចូលរួម

## វិធីប្រើប្រាស់សញ្ញាសម្គាល់



**កម្រិត និងគុណភាពនៃព័ត៌មាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

កម្រិត និងគុណភាពព័ត៌មានដែលមានស្រាប់ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ ដែលឧបករណ៍នេះមានភាពសមស្រប។ ស្ពឺមួយជាកម្រិតទាប (មានន័យថា មិនចាំបាច់មានព័ត៌មានច្រើនឡើយ និងមានការរួមបញ្ចូលភាគីពាក់ព័ន្ធដើម្បីប្រើប្រាស់ឧបករណ៍នេះ) ស្ពឺបួនគឺជាកម្រិតខ្ពស់ (មានន័យថាចាំបាច់ត្រូវមានព័ត៌មានសម្បូណ៌បែប ហើយមានការចូលរួមរបស់ភាគីពាក់ព័ន្ធដើម្បីប្រើឧបករណ៍នេះ)។



**តម្រូវការធនធាន**

បរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍នេះដំណើរការបាន។ ដើមឈើមួយដើម គឺបរិមាណតិច ដើមឈើបួនដើម គឺបរិមាណច្រើន។

# C. ឧបករណ៍សម្រាប់ការចូលរួម




## ហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់ សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ

ការឈានដល់កិច្ចព្រមព្រៀងអំពីការផ្លាស់ប្តូរចំពោះប្រព័ន្ធកាន់កាប់ព្រៃឈើ ដែលមានយុត្តិធម៌មានលក្ខណៈពេញលេញ និងដែលទំនងជាត្រូវបានអនុវត្ត តម្រូវឱ្យមានការចូលរួមនៃក្រុមផលប្រយោជន៍ផ្សេងៗគ្នា។ ក្រុមផលប្រយោជន៍ទាំងនោះ គប្បីអាចសម្តែងសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនក្នុងកិច្ចដំណើរការចរចា និងស្ថាបនាការស្រុះស្រួលគ្នាមួយ។ នៅក្នុងផ្នែកមុននេះ យើងបានឃើញរបៀបដែលតួអង្គផ្សេងៗគ្នាអាចចងក្រងខ្លួនឯង ដើម្បីពួកគេអាចត្រៀមលក្ខណៈចូលរួម។ ក្នុងផ្នែកនេះយើងផ្តោតលើឧបករណ៍ទាំងឡាយដែលធ្វើឱ្យភាគីពាក់ព័ន្ធបានជួបជុំគ្នាដើម្បីចូលរួមជាមួយគ្នា ទន្ទឹមគ្នានឹងការធានាឱ្យបានថាកិច្ចដំណើរការនេះមានលក្ខណៈបង្រួបបង្រួម និងចូលរួម ដើម្បីឱ្យសំឡេងដែលគេមិនយកចិត្តទុកដាក់ត្រូវបានគេស្តាប់ឮ ហើយក្រុមផលប្រយោជន៍ទាំងអស់បានចូលរួមប្រកបដោយប្រសិទ្ធភាព។

ការចូលរួមក្នុងចំណោមភាគីពាក់ព័ន្ធ អាចមានទម្រង់ជាច្រើន។ វាអាចមានតាំងពីក្រុមមួយដោយឡែក ដែលធ្វើសកម្មភាពជាក់លាក់ ដើម្បីជំរុញការយល់ដឹងអំពីកង្វល់របស់ពួកគេជាមួយអ្នកដទៃ តាមរយៈការពិគ្រោះយោបល់ និងការពិភាក្សាតុមូល។ នៅពេលនេះកិច្ចដំណើរការពហុភាគីពាក់ព័ន្ធត្រូវបានសម្រួលយ៉ាងទូលាយនៅក្នុងវិស័យព្រៃឈើ ដោយជំរុញឱ្យក្រុមមានផលប្រយោជន៍ផ្សេងៗគ្នាឈានចូលក្នុងការចូលរួមក្នុងលក្ខណៈស្ថាបនា ការសន្ទនា និងការធ្វើសេចក្តីសម្រេចចិត្តរយៈពេលវែង។ ក្នុងគ្រប់បរិបទទាំងអស់ ការសន្ទនា និងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានពេញលេញ ជុំវិញការកាន់កាប់ព្រៃឈើ តម្រូវឱ្យមានការសម្របសម្រួល ដ៏ប្រយ័ត្នប្រយែង។

ក្នុងកិច្ចដំណើរការចូលរួមទាំងមូល ការយកចិត្តទុកដាក់ និងយុទ្ធវិធីជាក់លាក់គឺចាំបាច់ដើម្បីដោះស្រាយបញ្ហាវិសមភាពអំណាច និងដើម្បីគាំទ្រតួអង្គទន់ខ្សោយ ឬតួអង្គដែលមិនត្រូវបានគេយកចិត្តទុកដាក់ នៅក្នុងការចូលរួមក្នុងកិច្ចដំណើរការសន្ទនា និងបង្កើតសក្តានុពលសម្រាប់ការចរចា។ ឧទាហរណ៍៖

- កែសម្រួលនីតិវិធីដែលប្រើសម្រាប់គ្រប់គ្រងកិច្ចដំណើរការ ដោយធានាឱ្យបានថាអ្វីដែលសំខាន់សម្រាប់ភាគីពាក់ព័ន្ធខ្សោយជាង ត្រូវបានស្តាប់ឮច្បាស់ជាងដោយអ្នកដទៃ។
- កិច្ចប្រជុំនៅក្នុងបរិយាកាស ដែលនៅក្នុងនោះភាគីពាក់ព័ន្ធខ្សោយជាងមានអារម្មណ៍កក់ក្តៅ ឬដែលអនុវត្តរបៀបពិភាក្សារបស់ភាគីពាក់ព័ន្ធខ្សោយ។
- ការជ្រួតជ្រាបអំពីនីតិវិធីបែបប្រពៃណីដែលត្រូវបានប្រើដោយភាគីពាក់ព័ន្ធទន់ខ្សោយ និងដែលប្រកាន់យកទស្សនៈទាំងឡាយនៃនីតិវិធីទាំងនេះ ដែលអាចតម្រូវឱ្យមានការតស៊ូមតិស្របច្បាប់ សកម្មភាពតាមផ្លូវច្បាប់ ឬសកម្មភាពនយោបាយ ដើម្បីផ្លាស់ប្តូរក្របខ័ណ្ឌគតិយុត្តិនៃសិទ្ធិចំពោះធនធាន។
- ការធ្វើចលនា និងការចងក្រងជាស្ថាប័ន៖ បង្កើតសមាគម ឬអង្គការក្នុងមូលដ្ឋានផ្សេងទៀត ដើម្បីជំរុញការទាមទារ និងការពារផលប្រយោជន៍ ឬបង្កើតសម្ព័ន្ធភាពជាមួយអង្គការខាងក្រៅដែលផ្តល់ការជួយគាំទ្រ និងផ្តល់ធនធានក្នុងទម្រង់ផ្សេងៗ រួមទាំងការប្រឹក្សាផ្នែកច្បាប់ ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលផងដែរ។

## ការអាន និងការប្រើឧបករណ៍ក្នុងផ្នែកនេះ

មានការណែនាំច្រើនអំពីកិច្ចប្រជុំគុមូល កិច្ចដំណើរការពហុភាគីពាក់ព័ន្ធ និងវិធីនានាដែលគាំទ្រប្រជាជនក្រីក្រ និងក្រុមប្រជាពលរដ្ឋដែលមិនត្រូវបានគេគិតគូរដល់ ឱ្យចូលរួមប្រកបដោយប្រសិទ្ធភាព។ ផ្នែកនេះចង្អុលបង្ហាញទិសដៅត្រឹមត្រូវដល់លោកអ្នកដើម្បីទទួលបានការណែនាំទូទៅនេះ ទន្ទឹមគ្នានឹងផ្តោតការយកចិត្តទុកដាក់ជាក់លាក់ចំពោះឧបករណ៍ទាំងឡាយ ដែលត្រូវបានអនុវត្តប្រកបដោយជោគជ័យនៅក្នុងបរិបទនៃអភិបាលកិច្ចនៃការកាន់កាប់សម្រាប់វិស័យព្រៃឈើប្រកបដោយការទទួលខុសត្រូវ។

ការណែនាំ និងឧបករណ៍ទាំងនេះ ត្រូវបានរៀបចំជាពីរប្រធានបទដូចខាងក្រោម៖

C1. **គាំទ្រសង្គមស៊ីវិលក្នុងការប្រមូលភស្តុតាង តស៊ូមតិ ធ្វើយុទ្ធនាការ និងចរចា** ដើម្បីឱ្យមានចំណាត់ការលើការកាន់កាប់កាន់តែមានសមធម៌ ដែលឆ្លុះបញ្ចាំងការអនុវត្តបែបប្រពៃណី និងតាមទំនៀមទម្លាប់។

C2. **ធ្វើការពិគ្រោះយោបល់ ការចូលរួម និងកិច្ចដំណើរការពហុភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព** ដើម្បីជំរុញការយល់គ្នា ការទុកចិត្តគ្នាទៅវិញទៅមក និងការប្តេជ្ញាចំពោះសកម្មភាពដើម្បីគ្រប់គ្រងការកាន់កាប់ព្រៃឈើ។

ដោយប្រកាន់យក និងកែសម្រួលឧបករណ៍ទាំងឡាយនៅក្នុងផ្នែកនេះ លោកអ្នកនឹង៖

- ដឹងថាតើត្រូវទៅទីណាដើម្បីស្វែងរកការណែនាំអំពីការរៀបចំសិក្ខាសាលាបែបចូលរួម និងកិច្ចដំណើរការពហុភាគីពាក់ព័ន្ធ។
- យល់ពីរបៀបជួយគាំទ្រក្រុមភាគីពាក់ព័ន្ធផ្សេងៗគ្នា ដែលមានឥទ្ធិពលលើ និង/ឬ រងផលប៉ះពាល់ពីកិច្ចព្រមព្រៀងកាន់កាប់ធនធានព្រៃឈើរួមមាន សហគមន៍ មន្ត្រីរដ្ឋាភិបាល និងតំណាងអាជីវកម្ម ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការសម្រេចចិត្ត យល់ពីទស្សនៈ និងតម្រូវការគ្នាទៅវិញទៅមក និងឈានដល់កិច្ចព្រមព្រៀងគ្នាមួយ។

## C1. គាំទ្រសង្គមស៊ីវិលក្នុងការប្រមូលភស្តុតាង តស៊ូមតិ ធ្វើយុទ្ធនាការ និងចរចា

តើអ្នកនៅក្នុងសង្គមស៊ីវិលអាចចរចា និងធ្វើយុទ្ធនាការ ដើម្បីឱ្យមានចំណាត់ការលើការកាន់កាប់កាន់តែមានសមធម៌ ដែលឆ្លុះបញ្ចាំងការអនុវត្តបែបប្រពៃណី និងតាមទំនៀមទម្លាប់ឬទេ? តើសំឡេងរបស់ពួកគេត្រូវបានគេស្តាប់ឮឬទេ? នៅក្នុងកិច្ចដំណើរការនៃកំណែទម្រង់ការកាន់កាប់ដើម្បីវិស័យព្រៃឈើប្រកបដោយការទទួលខុសត្រូវ កិច្ចប្រឹងប្រែងជួយសម្រួល គប្បីធានាឱ្យបានថាភាគីពាក់ព័ន្ធទន់ខ្សោយ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលក្នុងនីតិវិធីសម្រេចចិត្ត និងមានលទ្ធភាពសម្តែងសេចក្តីត្រូវការ និងផលប្រយោជន៍ពាក់ព័ន្ធរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

មានវិធីសាស្ត្រ និងយុទ្ធវិធីផ្សេងគ្នាជាច្រើន ដែលសមាជិកសហគមន៍មូលដ្ឋានអាចប្រើ ដើម្បីកសាងមូលដ្ឋានភស្តុតាងមួយ និងចូលរួមជាមួយអ្នកធ្វើគោលនយោបាយ ជុំវិញតម្រូវការ និងបំណងប្រាថ្នារបស់ពួកគេ។ គេអាចប្រើវិធីសាស្ត្រ និងឧបករណ៍ទាំងឡាយដែលបង្ហាញខាងក្រោម ដើម្បីគាំទ្រសហគមន៍ក្នុងការអភិវឌ្ឍជំនាញដើម្បីចូលរួមក្នុងកិច្ចដំណើរការនយោបាយ និងចូលរួមក្នុងបណ្តាញសារព័ត៌មាន តាមរយៈការចរចា ការធ្វើឱ្យមានឥទ្ធិពល និងការធ្វើយុទ្ធនាការ។

មានឧបករណ៍ដែលស្វែងរកយន្តការសម្រាប់ការចូលរួមផងដែរ ដូចជាវិទ្យុសហគមន៍ ខ្សែវីដេអូមានការចូលរួម និងរូបថតមានការចូលរួម។ ជាមួយកំណើនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន មានប៉ុស្តិ៍ថ្មីៗសម្រាប់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋកាន់តែច្រើន និងសម្រាប់ទាក់ទាញចំណាប់អារម្មណ៍របស់ទស្សនិកជន និងអ្នកស្តាប់សំខាន់ៗ។

## ឧបករណ៍គួរប្រើ

| ឧបករណ៍តស៊ូមតិ និងគោលការណ៍ណែនាំ | | C1.1 |
|---|---|---|
| **នេះជាអ្វី?** | អង្គការ CARE បានផលិតគោលការណ៍ណែនាំសម្រាប់ ការធ្វើផែនការ<br>តស៊ូមតិ ដើម្បីជួយអ្នកអនុវត្តឱ្យមានឥទ្ធិពលលើអ្នកធ្វើគោលនយោបាយ។ គោលការណ៍ណែនាំទាំងនេះពិនិត្យមើលទស្សនាទាននានាក្នុងការតស៊ូមតិ របៀបរៀបចំផែនការអន្តរាគមន៍ក្នុងលក្ខណៈយុទ្ធសាស្ត្រ និងជាក់ស្តែង និង របៀបអនុវត្តផែនការនោះប្រកបដោយជាគជ័យ។ | |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | គាលការណ៍ណែនាំនេះ អាចត្រូវបានប្រើនៅពេលណាដែលបានកំណត់បញ្ហាណាមួយ ដែលនឹងទទួលប្រយោជន៍ពីគោលនយោបាយមួយដែលកំពុងត្រូវបានដាក់ឱ្យអនុវត្តដែលបានកែទម្រង់ ឬត្រូវបានអនុវត្ត។ គោល-ការណ៍ណែនាំនេះផ្តល់ការណែនាំតាំងពីដំណាក់កាលប្រមូលព័ត៌មានដំបូង រហូតដល់ដំណាក់កាលធ្វើផែនការ និងអនុវត្តការងារតស៊ូមតិ។ | |
| **ធាតុផ្សំសំខាន់ៗ** | គោលការណ៍ណែនាំទាំងនេះ នាំអ្នកដែលអាចក្លាយជាអ្នកតស៊ូមតិ ឆ្លងកាត់ដំណាក់កាលដំបូងនានា ដូចជាការប្រមូលព័ត៌មានសារតារស្តីពីអ្នកធ្វើសេចក្តីសម្រេចចិត្ត និងស្ថាប័នសំខាន់ៗ និងការកសាងទំនាក់ទំនង និងភាពទុកចិត្ត។ បន្ទាប់មក គោលការណ៍ណែនាំនេះផ្តល់ការណែនាំអំពីបច្ចេកទេសធ្វើផែនការនានា រួមទាំងការវិភាគគោលនយោបាយលម្អិត ការកំណត់បញ្ហា និងគោលដៅគោលនយោបាយ ការកំណត់អត្តសញ្ញាណតួអង្គសំខាន់ៗ សារផ្សេងៗ ប្រភេទនៃយុទ្ធសាស្ត្រ និងសកម្មភាពពាក់ព័ន្ធ និងការធ្វើផែនការជាក់ស្តែងនៃពេលវេលា និងសូចនាករតាមដាន និងវាយតម្លៃ។ ក្នុងដំណាក់កាលអនុវត្តចុងក្រោយ ការណែនាំត្រូវបានដាក់បញ្ចូលអំពី យុទ្ធសាស្ត្រទំនាក់ទំនងច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាព ការ កសាងសម្ព័នភាព និងសមត្ថភាពនៅមូលដ្ឋានដើម្បីធ្វើឱ្យមានឥទ្ធិពលគោលនយោបាយ និងឱវាទស្តីពីបណ្តាញសារព័ត៌មាន យុទ្ធវិធីចរចា និងការគ្រប់គ្រងហានិភ័យ។ | |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Sprechmann, S. & Pelton, E. 2011. Advocacy tools and guidelines: promoting policy change – A resource manual for CARE program managers. Atlanta, Georgia, USA, CARE. http://www.care.org/getinvolved/advocacy/tools.asp<br>WaterAid. 2011. Advocacy – what's it all about? A guide to advocacy work in the water and sanitation sector. London. http://www.wateraid.org/documents/advocacysb.pdf<br>Datta, A. 2011. Strengthening world vision policy advocacy: a guide to developing advocacy strategies. London, Overseas Development Institute (ODI).http://www.odi.org.uk/sites/odi.org.uk/files/odi-assets/publictions-opinion-files/7261.pd |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.2, A5.2 |

## C1.2 ការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយដែលផ្តល់ការណែនាំដើម្បីជួយសហគមន៍ឱ្យចូលរួមប្រកបដោយជោគជ័យក្នុងការពិគ្រោះយោបល់ និងការចរចានៅ មូលដ្ឋានទាក់ទិននឹងការគ្រប់គ្រងធនធានធម្មជាតិ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីផ្តល់សមត្ថភាពដល់សហគមន៍ក្នុងការពិគ្រោះយោបល់នៅមូលដ្ឋាន សំដៅកំណត់អត្តសញ្ញាណអ្នកដែលមានសិទ្ធិគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់មួយ និងរបៀបដែលការគ្រប់គ្រងនេះ គប្បីត្រូវបានអនុវត្ត និងតាមដាន។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍នេះដាក់ចេញជំហានបួនដើម្បីជួយសហគមន៍ក្នុងការត្រៀមលក្ខណៈសម្រាប់ពិគ្រោះយោបល់ ដើម្បីអភិវឌ្ឍចក្ខុវិស័យ និងជំហរសម្រាប់ការចរចា និងដើម្បីធានាឱ្យបានថា កិច្ចព្រមព្រៀងទាំងឡាយ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ អាចអនុវត្ត និងតាមដានបាន នាពេលអនាគត។ |
| **ចំពោះព័ត៌មានបន្ថែម** | Joaquim, E., Norfolk, S. & Macqueen, D. 2005. Avante consulta! Effetive consultation. Power Tools Series. Matumbo, Mozambique, Terra Firma, and London, IIED. http://www.policy-powertools.org/Tools/Engaging/AC.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A2.1, A4.9, A5.4 |

## C1.3 ការយល់ព្រម ដោយសេរី និងជូនដំណឹងជាមុន– តាំងពីគោលការណ៍រហូតដល់ការអនុវត្ត

| | |
|---|---|
| **នេះជាអ្វី?** | ការណែនាំស្តីពីការអនុវត្តគោលការណ៍នៃការយល់ព្រមដោយសេរី និងជូន ដំណឹងជាមុន (FPIC)។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | FPIC មានន័យថាជាការបង្កើតស្ថានភាពដែលនៅក្នុងនោះគេអាច និងពិតជាអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីចរចាលក្ខខណ្ឌនៃគោលនយោបាយ កម្មវិធី និងសកម្មភាពដែលដាក់មកពីក្រៅទាំងឡាយដែលអាចប៉ះពាល់ដី ធនធាន ឬទ្រព្យដែលពួកគេធ្វើជាម្ចាស់ កាន់កាប់ ឬប្រើប្រាស់ តាមទំនៀមទម្លាប់ និងផ្តល់ ឬមិនផ្តល់ការយល់ព្រមរបស់ពួកគេចំពោះធនធានទាំងនោះ។ ការណែនាំអំពីការអនុវត្ត FPIC មានប្រយោជន៍នៅពេលដែលជនជាតិដើមភាគតិច ឬសហគមន៍មូលដ្ឋានកំពុងចរចាជាមួយស្ថាប័នអន្តរជាតិ រដ្ឋាភិបាល ឬវិនិយោគិនឯកជនដែលព្យាយាមអនុវត្តគោលនយោបាយ កម្មវិធី ឬការវិនិយោគទាំងឡាយដែលប៉ះពាល់ធនធាន ដែលសហគមន៍ទាំងនេះមានចំណងទាក់ទងដ៏រឹងមាំ។ ការណែនាំនេះជួយយ៉ាងជាក់ស្តែងក្នុងការប្រើគោលការណ៍នៃ FPIC នៅក្នុងការជំរុញ និងធ្វើការចរចាទាំងនេះ។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | ការណែនាំនេះ ដែលត្រូវបានសរសេរក្នុងបរិបទនៃការ វិនិយោគកសិធុរកិច្ច និង REDD+ ផ្តល់នូវជំហានជាស៊េរីសម្រាប់បង្កើត និងរៀបចំប្រព័ន្ធជាឯកសារមួយ ដែលអនុញ្ញាតឱ្យជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀតអាចបង្ហាញទស្សនៈរបស់ពួកគេក្នុងការចរចា និងអាចដាក់បញ្ចូលទស្សនៈ និងបំណងប្រាថ្នាទាំងនេះនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ជំហានទាំងនេះរួមមាន៖ ការកំណត់ដីតាមទំនៀមទម្លាប់ (ឧទាហរណ៍ ការប្រើការគូសផែនទីដោយមានការចូលរួម) ការពាក់ព័ន្ធជាមួយអង្គការទាំងឡាយដែលតំណាងឱ្យសហគមន៍ ការផ្តល់ព័ត៌មានដើម្បីអនុញ្ញាតឱ្យមានការចូលរួមស្មើភាព និងការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ការធានាឱ្យបានថាការយល់ព្រមត្រូវបានផ្តល់ដោយសេរី (ដោយគ្មានការបង្ខិតបង្ខំ) ការធានាឱ្យបានថាការយល់ព្រមត្រូវបានផ្តល់ជាមុន (មុនពេលមានផែនការអភិវឌ្ឍន៍) ការធានាឱ្យបានថាមានការយល់ព្រម និងការដោះស្រាយវិវាទក្នុងកិច្ចដំណើរការនេះ។ |
| **ចំពោះព័ត៌មានបន្ថែម** | Forest Peoples Programme. 2008. Free, Prior and Informed Consent and Oil Palm Plantations: a guide for companies. Moreton-in-Marsh, UK. http://www.forestpeoples.org/sites/fpp/files/publication/2009/12/fpican drspocompaniesguideoct08eng.pdf<br>Anderson, P. 2011. Free, Prior, and Informed Consent in REDD+: Principles and Approaches for Policy and Project Development. Bangkok, Regional Community Forestry Training Center (RECOFTC), and Eschborn, Germany, GIZ. http://www. recoftc.org/site/uploads/content/pdf/FPICinREDDManual_127.pdf<br>FAO. Forthcoming. Implementation guide on land acquisition, free, prior and informed consent and customary land of indigenous peoples and other local communities, S. Chao and M. Colchester. |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3, B1.2<br>ឧបករណ៍ស៊ីជម្រៅ: XL C |

## គាំទ្រសហគមន៍ដើម្បីចរចា និងគ្រប់គ្រងផលប៉ះពាល់ និងកិច្ចព្រមព្រៀងស្តីពីអត្ថប្រយោជន៍ជាមួយក្រុមហ៊ុន

**C1.4**

| | |
|---|---|
| **នេះជាអ្វី?** | What is it? ជាក្បួនណែនាំមួយដែលត្រូវបានរៀបចំសម្រាប់ឱ្យសហគមន៍ចូលរួមក្នុងការចរចាអំពីផលប៉ះពាល់ និងកិច្ចព្រមព្រៀងស្តីពីអត្ថប្រយោជន៍ជាមួយក្រុមហ៊ុននានា។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជួយអ្នកចរចាសហគមន៍ និង/ឬអ្នកពិគ្រោះយោបល់ដែលធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច និងអង្គការនានា ដើម្បីដោះស្រាយបញ្ហានីតិវិធី និងខ្លឹមសារ ទាក់ទិននឹងការចរចាកិច្ចព្រមព្រៀង។ ការណែនាំនេះ ត្រូវបានរៀបរៀងក្នុងបរិបទនៃកសិករខ្នាតតូចនៅប្រទេសកាណាដា ប៉ុន្តែមានលក្ខណៈសមស្របយ៉ាងទូលាយចំពោះសហគមន៍ទាំងឡាយដែលពឹងអាស្រ័យលើធនធានព្រៃឈើដើម្បីជីវភាពរបស់ខ្លួន។ |
| **ធាតុផ្សំសំខាន់ៗ** | ក្បួនណែនាំនេះផ្តោតលើការត្រៀមលក្ខណៈសម្រាប់ចរចា និងកំណត់ជំហរចរចា ធ្វើការចរចា និងបង្កើតកិច្ចព្រមព្រៀង ព្រមទាំងអនុវត្តកិច្ចព្រមព្រៀង និងថែរក្សាទំនាក់ទំនង។ |
| **ចំពោះព័ត៌មានបន្ថែម** | Gibson, G. & O'Faircheallaigh, C. 2010. IBA Community Toolkit: Negotiation and Implementation of Impact and Benefit Agreements. Toronto, Walter and Duncan Gordon Foundation. http://www.ibacommunitytoolkit.ca |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B1.2 |

## C1.5 បណ្តាញសារព័ត៌មាន និងយុទ្ធវិធីបញ្ចុះបញ្ចូលសម្រាប់ក្រុមមូលដ្ឋាន

| | |
|---|---|
| **នេះជាអ្វី?** | ការប្រើប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធវិធីបញ្ចុះបញ្ចូលដើម្បីកសាងការយល់ដឹងរួមមួយអំពីបញ្ហា និង ដើម្បីចូលរួមក្នុងគោលនយោបាយ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | សម្រាប់ឱ្យអ្នកសម្របសម្រួលជួយគាំទ្រកសិករ និងអភិវឌ្ឍជំនាញសារព័ត៌មាន និងជំនាញ បញ្ចុះបញ្ចូលរបស់ពួកគេ នៅពេលដែលពួកគេចូលរួមក្នុងកិច្ចដំណើរការគោលនយោបាយជាតិ។ បទពិសោធន៍ដោយឡែកមកពីប្រទេសហ្គ្រេណាដា (Grenada) ប៉ុន្តែវិធីទាំងនេះអាចប្រើបានយ៉ាង ទូលាយចំពោះកិច្ចដំណើរការគោលនយោបាយស្តីពីធនធានធម្មជាតិ។ |
| | ជាតុផ្សំសំខាន់ៗ រួមមាន៖ ការរៀបចំនៅខាងក្រៅ៖ (ការសិក្សាបញ្ជីដីធ្លី និង សវនកម្មលើការប្រើ ប្រាស់ដីធ្លី) ការកសាងភស្តុតាងរបស់កសិករ(ឧទាហរណ៍ ការលើកទឹកចិត្តឱ្យកសិកររក្សាទុក ឯកសារ ឬរៀបចំគំនូសផែនទីការប្រើប្រាស់ដី) ការផ្សារភ្ជាប់បញ្ហាទៅនឹងទិដ្ឋភាពរួម (ដាក់បញ្ចូល បញ្ហារបស់កសិករទៅក្នុងកម្មវិធីជាតិ ឬកសាងទំនាក់ទំនងរវាងកសិករ និងបុគ្គលិកបច្ចេកទេស កសិកម្ម) និងការផ្តោតលើការប្រាស្រ័យទាក់ទង និងការចរចាជាមួយក្រុមធំ (ដូចជា ជួយកសិករ ក្នុងការត្រៀមលក្ខណៈសម្រាប់កិច្ចប្រជុំសំខាន់ៗ ឬប្រើបណ្តាញសារព័ត៌មានដើម្បីផ្សព្វផ្សាយ ការយល់ដឹង)។ យុទ្ធវិធីនេះ មានតាំងពីសកម្មភាពបច្ចេកទេសដែលត្រូវចំណាយពេលវេលាច្រើន ដូចជា ការគូសផែនទី និងសវនកម្មហូតដល់អនុសាសន៍ឱ្យចាប់យកឱកាស ជាពិសេស ជាមួយ អ្នកនយោបាយ និងបណ្តាញសារព័ត៌មាន។ |
| **ចំពោះព័ត៌មានបន្ថែម** | Williams, J. & Vermeulen, S. 2005. Media and lobby tactics: linking farmers' actions with national policy processes. Power Tools Series. Grenada Community Development Agency and London, IIED. http://www.policy-powertools.org/ Tools/Engaging/MLT.html<br>Ellsworth, L. & White, A. 2004. Deeper roots: strengthening community tenure security and community livelihood, Strategies 3 and 7. New York, Ford Foundation. http://www.fordfoundation.org/pdfs/library/deeper_roots.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3, A4, B4.1<br>ឧបករណ៍ស៊ីជម្រៅ: XL C1.5 |

## C1.6 ការប្រើធនធានមហាជន

| | |
|---|---|
| **នេះជាអ្វី?** | 'ការប្រើធនធានមហាជន' មានន័យថាជាការបើកទូលាយការងារចំពោះសហគមន៍មួយ ឬមនុស្សមិន កំណត់មួយក្រុមធំ ('ហ្វូងមនុស្ស') តាមរយៈការអំពាវនាវសុំព័ត៌មានបើកទូលាយ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការប្រើធនធានមហាជន គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ផ្សព្វផ្សាយ និងចុះបញ្ជីសមាជិក សហគមន៍ អ្នកស្ម័គ្រចិត្ត និងអង្គការមិនមែនរដ្ឋាភិបាលចំនួនច្រើន។ វាអាចទាក់ទាញចំណាប់អារម្មណ៍ លើបញ្ហាសំខាន់ៗជុំវិញការកាន់កាប់ព្រៃឈើ និងសិទ្ធិ និង ផ្សព្វផ្សាយអំពីបញ្ហាទាំងនេះ។ |
| **ធាតុផ្សំសំខាន់ៗ** | បច្ចេកវិទ្យាសាមញ្ញអាចត្រូវបានប្រើដើម្បីបង្កើតប្រព័ន្ធផ្ញើសារដុំ(Mass Messaging Systems)ដែល បញ្ជូនទៅដល់មនុស្សច្រើននាក់ដោយផ្ទាល់ ជាងបណ្តាញផ្សព្វផ្សាយធម្មតា។ គេអាចប្រើសូហ្វវែរបើក ទូលាយឥតបង់ប្រាក់ (Open-source software) ដើម្បីប្រែក្លាយកុំព្យូទ័រយួរដៃមួយ និងទូរសព្ទចល័ត មួយឱ្យក្លាយទៅជាមណ្ឌលផ្សព្វផ្សាយកណ្តាលមួយ (សូមមើលឧបករណ៍ Ushahidi នៅខាងក្រោម)។ ក្រោយពេលតម្លើងហើយ កម្មវិធីនេះ អនុញ្ញាតឱ្យលោកអ្នកផ្ញើសារទៅវិញទៅមកជាមួយក្រុមមនុស្ស តាមរយៈទូរសព្ទចល័ត។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Mobileactive គឺជាបណ្តាញពិភពលោកមួយសម្រាប់អ្នកកំពុងប្រើបច្ចេកវិទ្យាចល័តដើម្បីធ្វើឱ្យមានឥទ្ធិពលផ្នែកសង្គម ( www.mobileactive.org ) ។ |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | C4.3 |

## Ushahidi: សូហ្វវែរបើកទូលាយឥតបង់ប្រាក់ ( open-source software ) និងការគូសផែនទីក្នុងលក្ខណៈសហការ

**C1.7**

| | |
|---|---|
| **នេះជាអ្វី ?** | ឧបករណ៍មួយដែលផ្អែកលើសូហ្វវែរដែលអនុញ្ញាតឱ្យគេអាចសហការ និងចែករំលែកព័ត៌មានគ្នាតាមរយៈបណ្តាញសារព័ត៌មានផ្សេងៗ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | សូហ្វវែរនេះអនុញ្ញាតឱ្យគេសហការគ្នាដើម្បីផ្តល់ និងចែករំលែកព័ត៌មានទាន់ពេលអំពីបញ្ហានានានៅក្នុងបរិស្ថានរបស់ពួកគេ។ |
| **ធាតុផ្សំសំខាន់ៗ** | ‘Ushahidi’ គឺជាពាក្យស្វាហ៊ីលី ( Swahili ) សម្រាប់សក្ខីកម្ម។ ‘Ushahidi’ ក៏ជាអង្គការមិនរកចំណេញអាហ្វ្រិកមួយផងដែរដែលអភិវឌ្ឍសូហ្វវែរបើកទូលាយ និងមិនគិតថ្លៃ។ Ushahidi ត្រូវបានប្រើយ៉ាងទូលាយដើម្បីចែករំលែកព័ត៌មាន ជំរុញចលនាសង្គម និងបង្កើនតម្លាភាព។ វិធីសាស្ត្រនេះរួមបញ្ចូលគ្នានូវព័ត៌មានពី SMS, email, Twitter, Facebook, រូបថត វីដេអូ ។ល។ និង ។ល។ ឱ្យក្លាយទៅជាផែនទីតែមួយផ្អែកលើអ៊ីនធឺណិត។ |
| **ចំពោះព័ត៌មានបន្ថែម** | http://www.ushahidi.com<br>ឧទាហរណ៍អំពីរបៀបដែល Ushahidi ត្រូវបានប្រើ៖ http://www.youtube.com/watch?v=Hh_PiVqf8BA&feature=player_embedded |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A1, B4.3 |

## វិទ្យុសហគមន៍

**C1.8**

| | |
|---|---|
| **នេះជាអ្វី ?** | ស្ថានីយវិទ្យុសហគមន៍មួយត្រូវបានដំណើរការក្នុងសហគមន៍ ដើម្បីសហគមន៍ និងដោយសហគមន៍ ដោយមានការអធិប្បាយអំពីសហគមន៍។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ឆ្លើយតបទៅនឹងកង្វល់សង្គម និងជំរុញការផ្លាស់ប្តូរផ្នែកសង្គមក្នុងសហគមន៍មួយ។ |
| **ធាតុផ្សំសំខាន់ៗ** | ស្ថានីយវិទ្យុសហគមន៍ត្រូវបានកំណត់និយមន័យថា ជាស្ថានីយវិទ្យុមួយដែលមិនរកចំណេញមានភាពជាម្ចាស់ និងការគ្រប់គ្រងដោយសហគមន៍ និងមានការចូលរួមរបស់សហគមន៍។ ការណែនាំរៀបរាប់អំពីរបៀបចាប់ផ្តើម បញ្ហាផ្លូវច្បាប់ ជម្រើសមូលនិធិ ចំណុចនានាដែលត្រូវពិចារណានៅពេលជ្រើសរើសសម្ភារ គំនិតសម្រាប់គ្រប់គ្រងស្ថានីយវិទ្យុសហគមន៍មួយ និងឱវាទអំពីការផ្សាយ។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Barker, K. 2008. Community radio start-up information guide. Ottawa, Ontario, Canada, Farm Radio International. http://www.amarc.org/documents/ manuals/ community-radio-start-up-guide_e.pdf<br>Tabing, L. 2002. How to do community radio: a primer for community radio operators. New Delhi, UNESCO Asia-Pacific Bureau. http://unesdoc.unesco. org/ images/0013/001342/134208e.pdf<br>Olssen, M. 2005. Digital audio in Papua New Guinea. ICT Update No. 29. Wageningin, The Netherlands, Technical Centre for Agricultural and Rural Cooperation ACP–EU (CTA). http://ictupdate.cta.int/en/Feature-Articles/ Digital-audio-in-Papua-New-Guinea |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B4.3 |

## C1.9 ការចូលរួមតាមរយៈរូបថត និងខ្សែវីដេអូ

| | |
|---|---|
| **នេះជាអ្វី ?** | បច្ចេកទេសផ្សេងៗសម្រាប់ ក្រុមមួយ ឬសហគមន៍ណាមួយចូលរួមក្នុងការរៀបចំ និងការបង្កើតសាររូបភាព និងភាពយន្តរបស់ពួកគេផ្ទាល់សម្រាប់ការតស៊ូមតិ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | វិធីសាស្ត្រទាំងនេះ អាចផ្សព្វផ្សាយព័ត៌មានជាច្រើនបានយ៉ាងលឿន និងជួយឱ្យក្រុមក្នុងមូលដ្ឋានអាចផ្សព្វផ្សាយអ្វីដែលសំខាន់សម្រាប់ពួកគេ ចែករំលែកបទពិសោធន៍រវាងសហគមន៍ និងអាចធ្វើការតស៊ូមតិដើម្បីការផ្លាស់ប្តូរ ជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត។ |
| **ធាតុផ្សំសំខាន់ៗ** | ធាតុផ្សំសំខាន់ៗ នៅក្នុងកិច្ចដំណើរការនេះ ជាញឹកញាប់រួមមាន៖ ការចុះធ្វើទស្សនកិច្ចដំបូង ការស្រាវជ្រាវបឋម សិក្ខាសាលាបណ្តុះបណ្តាលអំពីរូបថត ឬវីដេអូ ដូចជាការប្រើកាម៉េរ៉ា អក្ខរកម្មរូបភាព និងការកែលម្អជំនាញ បច្ចេកទេស និងល្បែងនានាសម្រាប់ចាប់ផ្តើម ឧទាហរណ៍ គំនូរសាច់រឿង ការបញ្ចាំងខ្សែភាពយន្ត និងការផ្សព្វផ្សាយលទ្ធផល។ រូបថតនិងខ្សែវីដេអូដែលមានការចូលរួម អាចមានប្រសិទ្ធភាពល្អក្នុងការជួយឱ្យសហគមន៍ដែលមានកម្រិតអក្ខរកម្មទាប អាចប្រាស្រ័យទាក់ទងជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត។ |
| **ចំពោះព័ត៌មានបន្ថែម** | PhotoVoice. 2011. See it our way: participatory photo as a tool for advocacy. London. http://www.photovoice.org/html/ppforadvocacy/ppforadvocacy.pdf<br>Lunch, N. & Lunch, C. 2006. Insights into participatory video: a handbook for the field. Oxford, UK, InsightShare. http://insightshare.org/resources/pv-handbook<br>Examples: http://insightshare.org/resources/case-study/all |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | **C2.3**, **D1** |

## ការស្រាវជ្រាវគោលនយោបាយដើម្បីឱ្យមានការផ្លាស់ប្តូរ

**C1.10**

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសម្រាប់វិភាគឧបសគ្គខាងគោលនយោបាយ ដែលប៉ះពាល់ដល់សហគ្រាសព្រៃឈើខ្នាតតូច និងសម្រាប់ជួយសម្រួលកិច្ចដំណើរការនៃការផ្លាស់ប្តូរ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ឧបករណ៍នេះ ផ្តោតលើយុទ្ធសាស្ត្រសម្រាប់ពាក់ព័ន្ធអ្នកធ្វើគោលនយោបាយ ចាប់តាំងពីពេលចាប់ផ្តើមក្នុងការងារដើម្បីគាំទ្រសហគ្រាសព្រៃឈើខ្នាតតូច។ |
| **ធាតុផ្សំសំខាន់ៗ** | ជំហានសំខាន់ៗរួមមាន៖ ការកំណត់បរិបទគោលនយោបាយ ការបំភ្លឺការផ្លាស់ប្តូរដែលចង់បាន និងការកំណត់អត្តសញ្ញាណអ្នកដែលមានឥទ្ធិពល ការកសាងអង្គបោះឆ្នោតដើម្បីបង្កើតមូលដ្ឋានគាំទ្រនយោបាយ និងទាក់ទាញសម្ព័ន្ធមិត្តធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗតាំងពីពេលចាប់ផ្តើម ការតម្រង់ទិសការស្រាវជ្រាវគោលនយោបាយដើម្បីបង្កើនឥទ្ធិពលឱ្យបានជាអតិបរមា ការវិនិយោគលើមេដឹកនាំក្រុមមួយដែលមានប្រវត្តិល្អ និង ការបណ្តុះបណ្តាលក្រុមឱ្យបានល្អ ដើម្បីជានាគុណភាពប្រកបដោយសង្គតិភាព ការផ្សារភ្ជាប់សំណេរទៅនឹងផ្នែកច្បាស់លាស់នៃនីតិកម្ម ការធ្វើការជ្រើសរើសប្រកបដោយព័ត៌មានគ្រប់គ្រាន់ពីការប្រឈមមុខឆ្ពោះទៅកាន់កិច្ចសហប្រតិបត្តិការ ការមានយុទ្ធសាស្ត្រផ្សព្វផ្សាយ។ |
| **ចំពោះព័ត៌មានបន្ថែម** | Macqueen, D.J. et al. 2012. Policy Research for Change. Supporting small forest enterprises: a facilitators toolkit, Module 16. Small and Medium Forest Enterprise Series, No. 29. London, IIED. http://pubs.iied.org/13558IIED.html<br>Mayers, J. & Bass, S. 2004. Policy that works for forests and people: real prospects for governance and livelihoods. London, Earthscan. http://pubs.iied. org/9276IIED.html<br>Court, J. & Young, J. 2003. Bridging research and policy: insights from 50 case studies. London, Overseas Development Institute (ODI). http://www.odi.org. uk/resources/docs/180.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.1, A4.4, B4.1 |

## C2. ដំណើរការពិគ្រោះយោបល់ ការចូលរួម និងកិច្ចដំណើរការពហុភាគីពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព

តើកិច្ចដំណើរការចូលរួម និងកិច្ចដំណើរការពហុភាគីពាក់ព័ន្ធ ត្រូវបានគេគ្រប់គ្រងដើម្បីឱ្យមានលក្ខណៈពេញលេញឬទេ? តើមានភាពស្មើគ្នាសម្រាប់ការចរចា និងការកសាងភាពស្រុះស្រួលគ្នាក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ឬទេ? នៅពីក្រោមកិច្ចដំណើរការកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព គេចាំបាច់ត្រូវមានការយល់គ្នា មានទំនុកចិត្ត និងការប្តេជ្ញាចំពោះការគ្រប់គ្រងការកាន់កាប់ព្រៃឈើ។

ការចូលរួមកាន់តែប្រសើរឡើងអាចនាំមកនូវ៖

- គោលនយោបាយកាន់តែមានដោយប្រសិទ្ធភាព និងសង្គតិភាព។
- ភាពជាម្ចាស់កាន់តែច្រើនលើការសម្រេចចិត្ត។
- កំណើនគណនេយ្យភាពជាមួយគណនេយ្យភាព និងការទទួលខុសត្រូវក្នុងផ្នែកកាន់តែទូលាយនៃសង្គម។
- វិវាទថយចុះតាមរយៈទំនាក់ទំនងកាន់តែប្រសើរឡើង។
- ការផ្សព្វផ្សាយកាន់តែច្រើន និងការគាំទ្រកាន់តែច្រើនឡើងចំពោះវិស័យព្រៃឈើ។

កិច្ចដំណើរការពហុភាគីពាក់ព័ន្ធ គឺជាការបង្កើត និងការជួយសម្រួលកិច្ចដំណើរការរយៈពេលវែង ដែលបង្រួបបង្រួមឱ្យក្រុមផ្សេងៗគ្នា ចូលរួម សន្ទនា និងធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយលក្ខណៈស្ថាបនា។ កំណែទម្រង់នៃការកាន់កាប់ព្រៃឈើ គឺជាកិច្ចដំណើរការរៀនសូត្រ។ ការងារនេះតម្រូវឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធសំខាន់ៗ ការពិភាក្សានៅក្នុង និងរវាងក្រុមភាគីពាក់ព័ន្ធនានា ការចរចារវាងភាគីពាក់ព័ន្ធអំពីគោលដៅនៃការគ្រប់គ្រងព្រៃឈើ និងការផ្ដល់បទពិសោធន៍ជាក់ស្ដែង ទៅក្នុងការសន្ទនាគោលនយោបាយ។

ការធ្វើឱ្យមានតុល្យភាពគម្លាតអំណាច ការបង្កើនលទ្ធភាព និងឆន្ទៈរបស់តួអង្គ ដើម្បីចូលរួមក្នុងការសន្ទនា និងការអភិវឌ្ឍ ហើយការចែករំលែកចំណេះដឹងដែលមាន គឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ចាប់ផ្ដើមអនុវត្តកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តដោយសហការគ្នា។ លក្ខខណ្ឌអំណោយផលសម្រាប់ការចរចាត្រូវបានរៀបចំ និងថែរក្សាក្នុងកិច្ចដំណើរការដ៏វែងនៃការបញ្ជ្រាប ការប្រាស្រ័យទាក់ទាក់ ការចូលរួម និងការផ្ដល់ភាពអង់អាច និងតាមរយៈកិច្ចប្រឹងប្រែងរួមនៅកម្រិតមូលដ្ឋាន និងនៅកម្រិតខ្ពស់ជាងនេះ (សូមមើល ‘ឧបករណ៍សម្រាប់រៀបចំ’)។

សំណួរពាក់ព័ន្ធសមស្របសម្រាប់អ្នកគ្រប់គ្រងកិច្ចដំណើរការចរចា រួមមាន៖

- តើត្រូវបង្កើតការសន្ទនានៅកម្រិតខុសៗគ្នា និងជុំវិញបញ្ហាផ្សេងៗគ្នាយ៉ាងដូចម្ដេច?
- តើគោលការណ៍ជាមូលដ្ឋាននៃការចរចាមានអ្វីខ្លះ?
- តើត្រូវបង្កើតឧបករណ៍ជាមូលដ្ឋានសម្រាប់សម្របសម្រួលការចូលរួមរបស់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងកិច្ចដំណើរការចរចាយ៉ាងដូចម្ដេច?
- តើត្រូវផ្ដួចផ្ដើមការបង្កើតការស្រុះស្រួលគ្នាមួយយ៉ាងដូចម្ដេច?

## ឧបករណ៍គួរប្រើ

**C2.1** **ពីរ៉ាមីត៖ ឧបករណ៍ស្ទង់ និងធ្វើផែនការសម្រាប់អភិបាលកិច្ចព្រៃឈើ**

| | |
|---|---|
| **នេះជាអ្វី?** | ក្របខ័ណ្ឌមួយសម្រាប់ឱ្យភាគីពាក់ព័ន្ធវិភាគស្ថានភាពទាំងស្រុងនៃអភិបាលកិច្ចព្រៃឈើ នៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ និងកំណត់អាទិភាព និងធ្វើផែនការកែលម្អ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ការវាយតម្លៃ និងការធ្វើផែនការដោយមានការចូលរួម សម្រាប់លើកកម្ពស់អភិបាលកិច្ចព្រៃឈើ ដែលមានលក្ខណៈសមស្របចំពោះប្រភេទនៃអន្តរកម្មរវាងភាគីពាក់ព័ន្ធ និងស្ថានភាពនៅក្នុងបរិបទនៃប្រទេស។ |
| **ធាតុផ្សំសំខាន់ៗ** | ពីរ៉ាមីតនេះ រួមមានមូលដ្ឋាន ឬគ្រឹះ និងចែកជាប្រាំថ្នាក់ ដែលសុទ្ធតែជាធាតុផ្សំនៅក្នុងអភិបាលកិច្ចព្រៃឈើ។ ចំណុចទាំងនេះរួមមាន៖ គ្រឹះ (ឧទាហរណ៍ អចលនទ្រព្យ និងសិទ្ធិកាន់កាប់ ស្ថានភាពទីផ្សារ និងស្ថានភាពវិនិយោគ) តួនាទី (តួនាទីរបស់ភាគីពាក់ព័ន្ធ និងស្ថាប័ននៅក្នុងវិស័យព្រៃឈើ និងការប្រើប្រាស់ដី) គោលនយោបាយ (គោលនយោបាយព្រៃឈើ ស្ដង់ដារសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព [SFM] និងនីតិកម្ម) ឧបករណ៍ (កញ្ចប់ប្រកបដោយសង្គតិភាពមួយនៃ ‘រង្វាន់ និងពិន័យ’ សម្រាប់ការអនុវត្ត) ការផ្សព្វផ្សាយ (ការផ្សព្វផ្សាយ SFM ជូនដល់អ្នកប្រើប្រាស់ និងភាគីពាក់ព័ន្ធ) និងការផ្ទៀងផ្ទាត់ SFM (សវនកម្ម ការបញ្ជាក់ដោយលិខិត ឬការពិនិត្យមើលឡើងវិញដោយមានការចូលរួម)។ លំដាប់លំដោយជាក់លាក់ដែលនៅក្នុងនោះសួរថាតើឆ្លើយតបទៅនឹងថ្នាក់ និងធាតុផ្សំណានោះអាស្រ័យលើបរិបទរបស់ប្រទេស កង្វល់ និងការកំណត់ពេលនៃស្ថានភាពក្នុងប្រទេស។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Mayers, J., Bass, S. & Macqueen, D. 2005. The Pyramid: a diagnostic and planning tool for good forest governance. Power Tools Series. London, IIED. http://www.policy-powertools.org/Tools/Engaging/TP.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A, B4.1 |

## ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងកម្មវិធីព្រៃឈើជាតិ

**C2.2**

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសំណុំសម្រាប់ជួយសម្រួលការចូលរួមក្នុងកម្មវិធីព្រៃឈើថ្នាក់ជាតិ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ត្រូវបានប្រើជាបឋមក្នុងសិក្ខាសាលា ឧបករណ៍ទាំងនេះត្រូវបានរៀបចំ និងចងក្រងសម្រាប់អ្នកដែលសម្របសម្រួលការចូលរួមកម្មវិធីព្រៃឈើថ្នាក់ជាតិ ថ្វីបើឧបករណ៍ទាំងនេះភាគច្រើនអាចប្រើបានតែចំពោះកិច្ចដំណើរការពហុភាគីពាក់ព័ន្ធផ្សេងទៀតក្តី។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍ទាំងនេះត្រូវបានរៀបចំតាមដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការគោលនយោបាយៈ (ឧទាហរណ៍ ការវិភាគភាគីពាក់ព័ន្ធ និងការកំណត់ចក្ខុវិស័យ) ការរៀបចំគោលនយោបាយ និងការធ្វើផែនការ (ការធ្វើចំណាត់ថ្នាក់អាទិភាព និងការធ្វើចំណាត់ថ្នាក់សកម្មភាព) ការអនុវត្ត (ការវិភាគបញ្ហា) និងការវាយតម្លៃ (ការវិភាគ SWOT និងការធ្វើចំណាត់ថ្នាក់គោលដៅ)។ |
| **ចំពោះព័ត៌មានបន្ថែម** | FAO. 2009. Enhancing stakeholder participation in national forest program: tools for practitioners, P. O'Hara. National Forest Programme Facility, Rome. http://www.fao.org/docrep/014/i1858e/i1858e00.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4, A5, B2 |

## ផែនទីបង្ហាញផ្លូវសម្រាប់គ្រប់គ្រងកិច្ចដំណើរការសន្ទនាបែបចូលរួម

**C2.3**

| | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រ និងការណែនាំសម្រាប់គ្រប់គ្រងកិច្ចដំណើរការសន្ទនាពហុភាគីពាក់ព័ន្ធ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីធ្វើផែនការ អនុវត្ត និងទ្រទ្រង់កិច្ចដំណើរការសន្ទនាពហុភាគីពាក់ព័ន្ធ និងប្រើវិធីសាស្ត្រនានាដើម្បីជំរុញការចូលរួម។ |
| **ធាតុផ្សំសំខាន់ៗ** | ផែនទីបង្ហាញផ្លូវ រួមមានឧបករណ៍សម្រាប់រៀបចំកិច្ចដំណើរការភាគីពាក់ព័ន្ធការជួយសម្រួល និងកិច្ចដំណើរការផ្តល់មូលនិធិ និងផ្តល់វិធីសាស្ត្រសម្រាប់ 'ការសន្ទនាបួនប្រភេទ' ជំរុញការយល់គ្នា ជំរុញទស្សនៈអនាគត ជំរុញការធ្វើសេចក្តីសម្រេចចិត្ត និងកសាងសមត្ថភាព។ |
| **ចំពោះព័ត៌មានបន្ថែម** | UN. 2007. Checklist for designers of multi-stakeholder processes. Participatory dialogue: towards a stable, safe and just society for all, Ch. 3 and Annex 1. New York. http://www.un.org/esa/socdev/publications/prtcptry_dlg%28full_ver- sion%29.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.7, A5.4 , B2.4 |

## C2.4 ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដោយអ្នកដទៃ

**នេះជាអ្វី?**
ឧបករណ៍ និងការណែនាំសម្រាប់អនុវត្តកិច្ចដំណើរការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?**
ដើម្បីកែលម្អការរៀបចំ និងកិច្ចដំណើរការពិគ្រោះយោបល់សំដៅបង្កលទ្ធភាពជាអតិបរមាឱ្យភាគីពាក់ព័ន្ធចូលរួម និងសម្តែងមតិ។ ការណែនាំនេះត្រូវបានសរសេរសម្រាប់បុគ្គលិកធនាគារពិភពលោក ប៉ុន្តែមានលក្ខណៈសមស្របសម្រាប់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតដែលដឹកនាំ និងរៀបចំការពិគ្រោះយោបល់។

**ធាតុផ្សំសំខាន់ៗ**
ជំហានសំខាន់ៗក្នុងការរៀបចំ រួមមាន៖ ការបំភ្លឺគោលបំណង ការកំណត់តួនាទីនិងការទទួលខុសត្រូវ ការយល់ពីទិដ្ឋភាពនយោបាយ ការធ្វើអត្តសញ្ញាណកម្មភាគីពាក់ព័ន្ធ និងការជ្រើសរើសអ្នកចូលរួម និងការចែករំលែកព័ត៌មានជាមួយពួកគេ។ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់កិច្ចដំណើរការពិគ្រោះយោបល់រួមមាន ការពិភាក្សាតាមប្រព័ន្ធអេឡិចត្រូនិក ការប្រមូលផ្តុំ និងសវនាការសាធារណៈ សិក្ខាសាលា និងកិច្ចប្រជុំតុមូល ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងការពិភាក្សាក្រុមគោលដៅ។ ក៏មានឧបករណ៍សម្រាប់វាយតម្លៃកិច្ចដំណើរការផងដែរ។

**ចំពោះព័ត៌មានបន្ថែម**
World Bank. 2007. Consultations with civil society: a sourcebook. Washington, DC http://siteresources.worldbank.org/CSO/Resources/ConsultationsSourcebook_Feb2007.pdf

Edmunds, D. & Wollenberg, E. 2001. A strategic approach to multi-stakeholder negotiations. Development and Change 32(2): 231–253. http://portals.wi.wur.nl/files/docs/msp/EdmundsWollenberg.pdf

**ឯកសារដទៃទៀតដែលអាចមានប្រយោជន៍**
A4.7, A5.4 , B2.4

## C2.5 Pathfinder: ដឹកនាំក្រុមការងារពហុភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍស្តង់ដារព្រៃឈើ

**នេះជាអ្វី?**
ក្បួនណែនាំលើប្រព័ន្ធអ៊ីនធឺណេតមួយដើម្បីគាំទ្រការបង្កើតក្រុម ការងារសម្រាប់ស្តង់ដារបញ្ជាក់វិញ្ញាបនបត្រព្រៃឈើថ្នាក់ជាតិ។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?**
ត្រូវបានរៀបចំដើម្បីជួយដល់ការបង្កើត និងការគ្រប់គ្រងក្រុមការងារពហុភាគីពាក់ព័ន្ធថ្នាក់ជាតិ និងតំបន់ដើម្បីអភិវឌ្ឍស្តង់ដារជាតិសម្រាប់ការផ្តល់វិញ្ញាបនបត្រព្រៃឈើ។ ឧបករណ៍ Pathfinder ក៏អាចប្រើបានទូលាយផងដែរនៅទីណាដែលគេចាំបាច់ត្រូវមានក្រុមការងារ។

**ធាតុផ្សំសំខាន់ៗ**
Pathfinder បង្ហាញឧបករណ៍មួយចំនួនដែលត្រូវបានបែងចែកជាបីប្រភេទ៖ សមាសភាគមូលដ្ឋាន ឥរិយាបថក្នុងស្ថានភាពស្តង់ដារ និងឧបករណ៍បច្ចេកទេសសម្រាប់ស្ថានភាពស្តង់ដារ។ ឧបករណ៍ទាំងនេះរួមមាន៖ លក្ខខណ្ឌផ្នែកស្ថាប័នសម្រាប់ការផ្តល់វិញ្ញាបនបត្រព្រៃឈើ ការផ្តល់វិញ្ញាបនបត្រ ពេលគឺ របៀបដែលវាដំណើរការ សៀវភៅណែនាំស្តីពីខ្សែចង្វាក់គ្រប់គ្រង ឧបករណ៍កសាងការស្រុះស្រួលគ្នា និងឧបករណ៍ដោះស្រាយវិវាទ ការផ្តួចផ្តើមក្រុមការងារថ្នាក់ជាតិ និងនីតិវិធីបោះឆ្នោត មគ្គុទេសក៍អំពីការដោះស្រាយបញ្ហា និងសូហ្វវែរ (software) កំណត់ស្តង់ដារ។

**ចំពោះព័ត៌មានបន្ថែម**
Hauselman, P & Vallejo, N. 2003. The pathfinder. Switzerland, Pi Environmental Consulting and WWF. http://www.piec.biz/pathfinder/index.html

**ឯកសារដទៃទៀតដែលអាចមានប្រយោជន៍**
B2.1, C1.2

## ការផ្តល់វិញ្ញាបនបត្រព្រៃឈើ

**C2.6**

| | |
|---|---|
| **នេះជាអ្វី?** | ការផ្តល់វិញ្ញាបនបត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងកិច្ចប្រតិបត្តិការខ្សែចង្វាក់គ្រប់គ្រង បង្ហាញថា អ្នកគ្រប់គ្រងព្រៃឈើគោរពតាមស្តង់ដារសង្គម និងបរិស្ថាន ដូចជាស្តង់ដារទាំងឡាយដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ ( Forest Stewardship Council (FSC ) ) ជាដើម។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ស្លាក FSC ឬ ស្លាកស្រដៀងគ្នាមួយ អាចនាំឱ្យអ្នកប្រើប្រាស់ស្គាល់ការអនុវត្តប្រកបដោយការទទួលខុសត្រូវ និងអាចស្គាល់បុព្វលាភនៃតម្លៃ ហេតុនេះ អាចទុកចិត្តបានជាមួយអតិថិជន ដៃគូអាជីវកម្ម គ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គការឃ្លាំមើល។ រដ្ឋាភិបាលបង្កើនការកំណត់ការប្រើផលិតផលព្រៃឈើមានវិញ្ញាបនបត្រក្នុងលទ្ធកម្មរបស់ខ្លួន។ |
| **ធាតុផ្សំសំខាន់ៗ** | ក្រុមប្រឹក្សាដឹកនាំវិស័យព្រៃឈើ ( Forest Stewardship Council (FSC ) ) ដាក់ចេញប្រាំជំហានសម្រាប់ការផ្តល់វិញ្ញាបនបត្រ៖<br>ទាក់ទងស្ថាប័នផ្តល់វិញ្ញាបនបត្រជំនាញឯករាជ្យ ដើម្បីប៉ាន់ស្មានថ្លៃចំណាយ និងពេលវេលា និងព័ត៌មានបន្ថែម។<br>ជ្រើសរើសស្ថាប័នផ្តល់វិញ្ញាបនបត្រជំនាញដែលអ្នកពេញចិត្ត និងចុះកិច្ចព្រមព្រៀង។<br>ធ្វើសវនកម្មចំពោះការផ្តល់វិញ្ញាបនបត្រ។<br>ធ្វើរបាយការណ៍សវនកម្ម ដែលក្លាយជាមូលដ្ឋានសម្រាប់សេចក្តីសម្រេចចិត្តក្នុងការផ្តល់វិញ្ញាបនបត្រ។<br>ប្រសិនបើសេចក្តីសម្រេចចិត្តមានលក្ខណៈវិជ្ជមាន នោះវិញ្ញាបនបត្រនឹងត្រូវបានផ្តល់។ ប្រសិនបើគ្មានលក្ខណៈវិជ្ជមានទេ នោះនឹងមានការស្នើឱ្យកែលម្អ បន្ទាប់មកអាចមានការធ្វើសវនកម្មផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | Forest Stewardship Council. 5 steps towards FSC certification [Online Resource]. https://ic.fsc.org/5-steps-to-certification.36.htm |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | B3.3, B3.5, D3.6 |




# ឧបករណ៍សម្រាប់ធានា

## វិធីប្រើសញ្ញាសម្គាល់

**កម្រិត និងគុណភាពនៃព័ត៌មាន**
**និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

កម្រិត និងគុណភាពព័ត៌មានដែលមានស្រាប់ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ ដែលឧបករណ៍នេះ មានភាពសមស្រប។ ស្ពឺមួយជាកម្រិតទាប(មានន័យថា មិនចាំបាច់មានព័ត៌មានច្រើនឡើយ និង មានការរួមបញ្ចូលភាគីពាក់ព័ន្ធដើម្បីប្រើប្រាស់ឧបករណ៍នេះ) ស្ពឺបួនគឺជាកម្រិតខ្ពស់ (មានន័យថា ចាំបាច់ត្រូវមានព័ត៌មានសម្បូណ៌បែបហើយមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ដើម្បីប្រើឧបករណ៍ នេះ)។

**តម្រូវការធនធាន**

បរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍នេះដំណើរការបាន។ ដើមឈើមួយដើម គឺបរិមាណតិច ដើមឈើបួនដើម គឺបរិមាណច្រើន។

# D. ឧបករណ៍សម្រាប់ធានា




## ហេតុអ្វីបានជាការធានាមានសារសំខាន់ សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ព្រៃឈើ

ការឈានដល់កិច្ចព្រមព្រៀងគ្នា និងការធ្វើសកម្មភាពគឺមិនគ្រប់គ្រាន់ទេ។ យន្តការសម្រាប់តាមដានមើលវឌ្ឍនភាព និងគណនេយ្យភាពមានភាពចាំបាច់ក្នុងការធានាឱ្យបាននូវកិច្ចព្រមព្រៀង ការសន្ទនា និងការសន្យាត្រូវបានប្រែក្លាយទៅជាសកម្មភាពត្រឹមត្រូវ។ ប៉ុន្តែ ‘ការធានា’ នេះក៏មិនមែនជាសេចក្តីបញ្ចប់នៃកិច្ចដំណើរការទេ។ ប្រសិនបើការចាត់ចែងល្អ និងការចូលរួមត្រូវបានធានា ការណ៍នេះធ្វើឱ្យមានការយល់ដឹងថ្មីអំពីរបៀបកែលម្អសកម្មភាព ជាពិសេសនាំឱ្យមានវដ្តផ្ទួនៗជាប្រចាំ នៃអភិបាលកិច្ចព្រៃឈើកាន់តែមានប្រសិទ្ធភាព មានសមធម៌ និងប្រសិទ្ធផល។

ការតាមដាន និងការវាយតម្លៃមានសារសំខាន់ក្នុងការតាមដានវឌ្ឍនភាព និងឥទ្ធិពលឆ្ពោះទៅកាន់គោលដៅចុងក្រោយនៃវិស័យព្រៃឈើប្រកបដោយការទទួលខុសត្រូវ ដែលទ្រទ្រង់ជីវភាពរបស់ប្រជាពលរដ្ឋផង និងព្រៃឈើប្រកបដោយនិរន្តរភាពផង។ ការងារនេះវាយតម្លៃឥទ្ធិពលរំពឹង និងមិនរំពឹងទុកនៃអភិបាលកិច្ច និងចំណាត់ការចំពោះការកាន់កាប់ ទាំងលើជីវភាព ទាំងចំពោះព្រៃឈើ។ ជាមួយគ្នានេះផងដែរក៏ត្រូវមានយន្តការនានាដើម្បីធានាឱ្យបានថាសិទ្ធិរបស់ប្រជាពលរដ្ឋលើធនធានព្រៃឈើត្រូវបានលើកស្ទួយ សង្គមស៊ីវិលអាចតម្រូវឱ្យអ្នកធ្វើសេចកត្តីសម្រេចចិត្តទទួលខុសត្រូវ និងយន្តការដោះស្រាយវិវាទមានប្រសិទ្ធភាព ស្មើភាព និងអាចប្រើបានសម្រាប់ទាំងអស់គ្នា។

លទ្ធភាពទទួលព័ត៌មាន អនុញ្ញាតឱ្យប្រជាជនអាចពិនិត្យពិច័យឥទ្ធិពលនៃសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ និងផ្តល់តុល្យភាពអំណាច ដើម្បីផលប្រយោជន៍សាធារណៈ ដោយកាត់បន្ថយឥទ្ធិពលមិនសមស្របនៃក្រុមមានឯកសិទ្ធិ និងកាត់បន្ថយគ្រឿងលើកទឹកចិត្តដែលនាំឱ្យមានអំពើពុករលួយ។ ប្រតិបត្តិការព្រៃឈើច្រើនកើតឡើងនៅក្នុងតំបន់ជនបទដាច់ស្រយាលឆ្ងាយ ហើយសំខាន់ប្រជាពលរដ្ឋមូលដ្ឋានត្រូវមានព័ត៌មានអំពីកិច្ចប្រតិបត្តិការណាដែលអាចជាប្រតិបត្តិការស្របច្បាប់ហើយពួកគេអាចទាក់ទងនរណា ប្រសិនបើកិច្ចប្រតិបត្តិការទាំងនោះមិនស្របច្បាប់។

ការដឹងថាសេចក្តីសម្រេចចិត្ត និងកិច្ចដំណើរការនានាមានលក្ខណៈបើកចំហ ចំពោះការត្រួតពិនិត្យ អាចធ្វើឱ្យស្ថាប័នរដ្ឋាភិបាលធ្វើការងារបានកាន់តែប្រសើរឡើង ដោយជំរុញឱ្យពួកគេគ្រប់គ្រងប្រព័ន្ធព័ត៌មានរបស់ខ្លួនឱ្យសមស្រប។

សំខាន់ណាស់ត្រូវធានាឱ្យបានថាភាគីពាក់ព័ន្ធក្រីក្របំផុត និងភាគីពាក់ព័ន្ធដែលគ្មាននរណាយកចិត្តទុកដាក់សោះនោះ មិនត្រូវរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការចាត់ចែងសិទ្ធិកាន់កាប់ឡើយ។ ដោយអញ្ជើញភាគីពាក់ព័ន្ធទាំងឡាយ ដែលរងផលប៉ះពាល់ច្រើនជាងគេឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេអំពីរបៀបដែលការកាន់កាប់ព្រៃឈើត្រូវបានចរចា និងអនុវត្តហើយ ជានាឱ្យបានថារបកគំហើញទាំងនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយដល់គ្រប់ៗគ្នា នោះគេអាចអភិវឌ្ឍប្រកបដោយតម្លាភាព និងគណនេយ្យភាពកាន់តែច្រើន។ មេរៀនដែលបានទទួល គប្បីផ្តល់ជាព័ត៌មានដល់ការសម្របតាម និងដល់ការកែតម្រូវចំពោះការអនុវត្តផ្នែកអភិបាលកិច្ច។

## ការអាន និងការប្រើការណែនាំក្នុងផ្នែកនេះ

ឧបករណ៍ក្នុងផ្នែកនេះ ត្រូវបានរៀបចំនៅជុំវិញវិធីបីយ៉ាងសម្រាប់ជានាឱ្យបាននូវវិស័យព្រៃឈើប្រកបដោយការទទួលខុសត្រូវ៖

- D1. **ការតាមដាន និងការវាយតម្លៃ គណនេយ្យភាព និងតម្លាភាព**
- D2. **យន្តការសម្រាប់ការតវ៉ា ដំណោះស្រាយវិវាទ និងការជួយគាំទ្រពីជំនួយការមេធាវី** ដែលអនុញ្ញាតឱ្យសហគមន៍ព្រៃឈើអាចតវ៉ា និងដោះស្រាយវិវាទតាមរយៈប្រព័ន្ធយុត្តិធម៌នៅមូលដ្ឋាន។
- D3. **បណ្តឹងឧទ្ធរណ៍ទៅកាន់តុលាការ រដ្ឋាភិបាលជាន់ខ្ពស់ ឬគោលនយោបាយ និងមធ្យោបាយអន្តរជាតិ។**

ដោយប្រកាន់យក និងសម្របសម្រួលឧបករណ៍ក្នុងផ្នែកនេះ លោកអ្នកនឹងអាច៖

- អភិវឌ្ឍប្រព័ន្ធតាមដាន វាយតម្លៃ តម្លាភាព និងគណនេយ្យភាព ដើម្បីជានាឱ្យបាននូវអភិបាលកិច្ចល្អនៃការកាន់កាប់សម្រាប់វិស័យព្រៃឈើប្រកបដោយការទទួលខុស ត្រូវ។
- បង្កើតប្រព័ន្ធនានាដែលអនុញ្ញាតឱ្យក្រុមនានាអាចកំណត់គ្នាទៅវិញទៅមកឱ្យទទួលខុសត្រូវលើការសន្យាដែលពួកគេបានធ្វើ អនុញ្ញាតឱ្យច្បាប់ត្រូវបានអនុម័តប្រកបដោយយុត្តិធម៌ និងជួយសម្រួលដល់ដំណោះស្រាយវិវាទ។
- យល់ថាតើយន្តការ និងអន្តរាគមន៍អន្តរជាតិអាចត្រូវបានប្រើយ៉ាងដូចម្តេចដើម្បីពង្រឹងតម្លាភាព និងកំណត់ឱ្យភាគីពាក់ព័ន្ធទទួលខុសត្រូវ។

### D1. ការតាមដាន និងការវាយតម្លៃ គណនេយ្យភាព និងតម្លាភាព

តើកិច្ចព្រមព្រៀងកំពុងត្រូវបានប្រែក្លាយទៅជាសកម្មភាពជាក់ស្តែងឬទេ? តើគំនិតផ្តួចផ្តើមនេះបានធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ ទោះជាវិជ្ជមាន ឬអវិជ្ជមាន ដូចការគ្រោងទុក ឬមិនបានដូចការគ្រោងទុក? តើគេអាចរៀនសូត្រមេរៀនអ្វីខ្លះ ហើយតើមានអ្វីខ្លះដែលគប្បី ឬអាចបានធ្វើបានផ្សេងពីនេះ? ការតាមដាន និងការវាយតម្លៃ គឺជាកិច្ចដំណើរការមួយនៃការប្រមូល និងវាយតម្លៃព័ត៌មាន ដើម្បីធ្វើការវិនិច្ឆ័យអំពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលបំណង និងគោលដៅ និងដើម្បីកំណត់បច្ច័យនៃទង្វើ ទោះវិជ្ជមាន ឬអវិជ្ជមានក្តី។

ទោះបីជាការអនុវត្តគោលនយោបាយមួយ កិច្ចដំណើរការពហុភាគីពាក់ព័ន្ធមួយ កិច្ចព្រមព្រៀង FPIC មួយ ឬគម្រោងមួយទៀតក្តី សំខាន់ត្រូវមានយន្តការសម្រាប់វាយតម្លៃ ថាតើគំនិតផ្តួចផ្តើមមួយកំពុងសម្រេចបានគោលដៅរបស់វាឬទេ និងសម្រាប់តាមដានការប្រែប្រួលនៅក្នុងស្ថានភាពដែលធ្វើឱ្យក្រុមភាគីពាក់ព័ន្ធសំខាន់ៗមានកង្វល់។ ការប្រើសូចនាករអាចផ្តល់មូលដ្ឋានគោលផ្នែកព័ត៌មាន និងមូលដ្ឋានគោលដែលអាចប្រៀបធៀបបាន ដើម្បីវិភាគស្ថានភាពនៃអភិបាលកិច្ច និងកំណត់វិស័យសំខាន់ៗសម្រាប់ធ្វើកំណែទម្រង់ និងអាចជួយក្នុងការតាមដានវឌ្ឍនភាព

ឆ្ពោះទៅកាន់អភិបាលកិច្ចកាន់តែប្រសើរឡើង។ មានការណែនាំច្រើនអំពីការតាមដាន និងការវាយតម្លៃ។

ការតាមដាន និងការវាយតម្លៃ (PM&E) ដែលមានការចូលរួម គឺជាកិច្ចដំណើរការមួយដែលតាមរយៈនោះ ភាគីពាក់ព័ន្ធនៅកម្រិតផ្សេងៗចូលរួមក្នុងការតាមដាន ឬការវាយតម្លៃគម្រោង កម្មវិធី ឬគោលនយោបាយដោយឡែកណាមួយ។ ភាគីពាក់ព័ន្ធគ្រប់គ្រងរួមគ្នាលើខ្លឹមសារ នីតិវិធី និងលទ្ធផលនៃសកម្មភាពតាមដាន និងវាយតម្លៃ ហើយពួកគេចូលរួមក្នុងការធ្វើ ឬការកំណត់សកម្មភាពកែតម្រូវ។ លទ្ធផលនៃការងារនេះ បង្កើតនូវឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ឱ្យសង្គមស៊ីវិលលើកស្ទួយតម្លាភាព និងតម្រូវឱ្យអ្នកធ្វើគោលនយោបាយ និងផ្នែកឯកជន ទទួលខុសត្រូវលើការសន្យារបស់ពួកគេ។ ចំណុចសំខាន់បំផុតនៃការពង្រឹងតម្លាភាព និងគណនេយ្យភាព គឺលទ្ធភាពទទួលព័ត៌មាន។

ឧបករណ៍ដែលត្រូវបានរាប់បញ្ចូលនៅទៅនេះ គឺជាឧបករណ៍បែបចូលរួម ដែលអនុញ្ញាតឱ្យសង្គមស៊ីវិលអាចចូលរួមក្នុងកិច្ចដំណើរការតាមដាន និងវាយតម្លៃទទួលបានព័ត៌មាន និងធានាបាននូវគណនេយ្យភាព និងតម្លាភាព។ គេគប្បីកត់សម្គាល់ថាឧបករណ៍ជាច្រើននៃឧបករណ៍ទាំងឡាយនៅក្នុងផ្នែក ‘ឧបករណ៍សម្រាប់យល់ដឹង’ អាចត្រូវបានប្រើជាឧបករណ៍សម្រាប់ធានា។ ការអនុវត្តកិច្ចដំណើរការយល់មួយរយៈពេល បង្ហាញថាតើស្ថានភាពកំពុងប្រែប្រួលប្រសើរឡើង ឬកាន់តែអាក្រក់ឡើង។ ឧទាហរណ៍ ការធ្វើអង្កេតព្រៃឈើច្រើនដងនឹងបង្ហាញថាតើគម្របព្រៃឈើកំពុងកើនឡើងឬថយចុះក្នុងរយៈពេលមួយ ហើយការវិភាគច្រើនដងអំពីអំណាចនៃភាគីពាក់ព័ន្ធ នឹងបង្ហាញការប្រែប្រួលនៅក្នុងឥទ្ធិពល និងសំឡេងនៃក្រុមដែលត្រូវគេមើលរំលងនៅក្នុងពេលធ្វើសេចក្ដីសម្រេចចិត្ត។

## ឧបករណ៍គួរប្រើ

### ប័ណ្ណរាយការណ៍ពលរដ្ឋ

**D1.1**

| | |
|---|---|
| **នេះជាអ្វី?** | ការស្ទង់មតិដោយមានការចូលរួមដែលផ្ដល់មតិកែលម្អបែបបរិមាណនិង/ឬបែបគុណភាព។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីស្វែងយល់ពីទស្សនៈរបស់អ្នកប្រើប្រាស់អំពីគុណភាព ភាពគ្រប់ គ្រាន់ និងប្រសិទ្ធភាពនៃសេវាសាធារណៈ។ |
| **ធាតុផ្សំសំខាន់ៗ** | ប័ណ្ណរាយការណ៍ពលរដ្ឋ ប្រើទម្រង់ស្ដង់ដារ និងកញ្ចប់នៃសូចនាករវាយតម្លៃ ងាយចម្លងតាមដែលធ្វើឱ្យវាក្លាយជាឧបករណ៍ដ៏មានប្រយោជន៍ សម្រាប់ការប្រៀបធៀបនៅពេលក្រោយ និង/ឬរវាងកន្លែងផ្សេងៗគ្នា។ វាមិនត្រឹមតែគឺជាការប្រមូលទិន្នន័យប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាឧបករណ៍មួយសម្រាប់បង្កើនគណនេយ្យភាពសាធារណៈ និងសម្រាប់ផ្ដល់ព័ត៌មានដល់ការងារតស៊ូមតិរបស់សង្គមស៊ីវិលទៀតផង។ |
| **ចំពោះព័ត៌មានបន្ថែម** | Public Affairs Centre/Asian Development Bank. Citizen report card learning toolkit [Online Resource]. http://www.citizenreportcard.com/index.html<br>Global Witness. How do report cards help? [Online Resource]. http://www.foresttransparency.info/background/how-do-report-cards-help/<br>Global Witness. 2010. Making the forest sector transparent: annual forest sector transparency report card 2010 – Ghana. London. http://www.forest transparency.info/cms/file/457 |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | A2.4 |

## D1.2 ប័ណ្ណពិន្ទុសហគមន៍

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍តាមដានបែបគុណភាពសម្រាប់ការតាមដាន និងការវាយតម្លៃការអនុវត្តការងារនៅថ្នាក់មូលដ្ឋាន។ |
| **តើគេអាចប្រើវា សម្រាប់ធ្វើអ្វី?** | សហគមន៍វាយតម្លៃសេវា គម្រោង និងអង្គភាពរដ្ឋបាលរបស់រដ្ឋាភិបាល ដែលផ្តល់នូវទស្សនៈរបស់អ្នកប្រើ។ |
| **ធាតុផ្សំ សំខាន់ៗ** | កិច្ចដំណើរការប័ណ្ណពិន្ទុរបស់សហគមន៍ (CSC) គឺជាការច្របាច់បញ្ចូលគ្នានូវបច្ចេកទេសនានានៃការធ្វើសវនកម្មសង្គម ការឃ្លាំមើលរបស់សហគមន៍ និងប័ណ្ណរាយការណ៍ពលរដ្ឋ។ ដូចជាប័ណ្ណរាយការណ៍ពលរដ្ឋអញ្ចឹង កិច្ចដំណើរការប័ណ្ណពិន្ទុរបស់សហគមន៍ (CSC) គឺជាឧបករណ៍មួយសម្រាប់ធានាឱ្យមានគណនេយ្យភាពសាធារណៈ និងភាពឆ្លើយតបរបស់អ្នកផ្តល់សេវា។ ដោយសារមានដាក់បញ្ចូលនូវការជួបប្រជុំមួយរវាងអ្នកផ្តល់សេវា និងសហគមន៍ ដែលអនុញ្ញាតឱ្យមានការផ្តល់មតិកែលម្អភ្លាមៗ កិច្ចដំណើរការនេះក៏ជាឧបករណ៍ដ៏រឹងមាំមួយផងដែរសម្រាប់ការពង្រឹងអំណាច។ |
| **ចំពោះព័ត៌មានបន្ថែម** | World Bank. Citizen Report card and community score card [Online Resource]. http://go.worldbank.org/QFAVL64790 |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | B1 |

## D1.3 ប័ណ្ណរាយការណ៍តម្លាភាពវិស័យព្រៃឈើ

| | |
|---|---|
| **នេះជាអ្វី?** | ប័ណ្ណរាយការណ៍មួយ ដែលត្រូវបានរៀបចំយ៉ាងជាក់លាក់សម្រាប់វាស់វែងឧ្សនភាពរបស់រដ្ឋាភិបាលក្នុងការកែលម្អអភិបាលកិច្ចព្រៃឈើ។ |
| **តើគេអាចប្រើវា សម្រាប់ធ្វើអ្វី?** | ត្រូវបានអភិវឌ្ឍសម្រាប់ឱ្យសង្គមស៊ីវិលតម្រូវឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើអភិបាលកិច្ច និងតម្លាភាពនៃវិស័យព្រៃឈើ។ |
| **ធាតុផ្សំសំខាន់ៗ** | ប័ណ្ណរាយការណ៍នេះគ្របដណ្តប់លើរាល់ទិដ្ឋភាពទាំងអស់នៃអភិបាល-កិច្ចព្រៃឈើ រួមមានប្រធានបទជាក់លាក់មួយអំពីការកាន់កាប់ព្រៃឈើ ការប្រើដី និងការបែងចែកសិទ្ធិអ្នកប្រើ ដែលមានលក្ខណៈសមស្រប ជាពិសេសចំពោះការណែនាំនេះ។ ថ្វីបើបញ្ហានៃការកាន់កាប់គ្រាន់តែគឺជាផ្នែកមួយនៃឧបករណ៍នេះក្តី ក៏ការធ្វើលំហាត់នេះទាំងស្រុងគឺជាប្រការមានប្រយោជន៍ដែរ។ របៀបដែលបញ្ហានៃការកាន់កាប់ព្រៃឈើត្រូវបានដោះស្រាយ ទាក់ទិននឹងទិដ្ឋភាពផ្សេងទៀតនៃអភិបាលកិច្ចព្រៃឈើ និងតម្លាភាពជារួមនៃវិស័យព្រៃឈើ។ |
| **ចំពោះព័ត៌មានបន្ថែម** | Global Witness. 2010. Making the forest sector transparent: annual transparency report 2009. London. http://www.foresttransparency.info/cms/file/231 |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.5, A4.10<br>ឧបករណ៍ស៊ីជម្រៅៈ XL D1.3 |

## ក្របខ័ណ្ឌសម្រាប់វាយតម្លៃ និងតាមដានអភិបាលកិច្ចព្រៃឈើ

**D1.4**

| | |
|---|---|
| **នេះជាអ្វី?** | ក្របខ័ណ្ឌមួយនៃគោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ និងតាមដានអភិបាលកិច្ចព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ក្របខ័ណ្ឌជាប្រព័ន្ធមួយ គិតគូរដល់ការរៀបរាប់ ការស្វែងមើលបញ្ហា ការតាមដាន ការវាយតម្លៃ និងការរាយការណ៍អំពីស្ថានភាពនៃអភិបាលកិច្ចនៅក្នុងវិស័យព្រៃឈើរបស់ប្រទេស។ ក្របខ័ណ្ឌនេះ ត្រូវបានអភិវឌ្ឍដោយ PROFOR ធនាគារពិភពលោក អង្គការស្បៀងនិងកសិកម្ម (FAO) និងអង្គការផ្សេងទៀត ហើយបើប្រើជាទូទៅ វាបង្ហាញសក្តានុពលជៀសវាងបាននូវការធ្វើត្រួតគ្នានៃកិច្ចប្រឹងប្រែងតាមដាន និងវាយតម្លៃសម្រាប់អ្នកផ្តល់មូលនិធិផ្សេងៗគ្នា។ |
| **ធាតុផ្សំសំខាន់ៗ** | ក្របខ័ណ្ឌនេះរួមមានសសរស្តម្ភចំនួនបី៖ គោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត ស្ថាប័ន និងគ្រប់គ្រង (រួមមានគោលនយោបាយ ច្បាប់ និង ក្របខ័ណ្ឌស្ថាប័នទាក់ទិននឹងព្រៃឈើ) កិច្ចដំណើរការធ្វើផែនការ និង ធ្វើសេចក្តីសម្រេចចិត្ត (រួមមានការចូលរួមរបស់ភាគីពាក់ព័ន្ធ តម្លាភាព និងគណនេយ្យភាព) និងការអនុវត្ត ការបង្ខំអនុវត្ត និងអនុលោមភាព (រួមមានរដ្ឋបាលនៃធនធានព្រៃឈើ ការបង្ខំអនុវត្តច្បាប់ព្រៃឈើ និងវិធានការដោះស្រាយអំពើពុករលួយ)។ ការងារកំពុងដំណើរការដើម្បីបង្កើតសូចនាករដែលមានការឯកភាពគ្នា។ |
| **ចំពោះព័ត៌មានបន្ថែម** | PROFOR/FAO. 2011. Framework for assessing and monitoring forest governance. Washington, DC, and Rome. http://www.profor.info/profor/sites/ profor.info/files/ForestGovernanceFramework_0.pdf<br>Kishor, N. & Rosenbaum, K. 2012. Assessing and monitoring forest governance: a user's guide to a diagnostic tool. Washington, DC, Program on Forests (PROFOR). http://www.profor.info/sites/profor.info/files/docs/AssessingMonitoringForestGovernance-guide.pdf<br>IMAZON/ICV/WRI. 2009. The governance of forests toolkit (Version 1): a draft framework of indicators for assessing governance of the forest sector. Instituto do Homem e Meio Ambiente da Amazônia, Instituto Centro de Vida, and Washington, DC, World Resources Institute. http://pdf.wri.org/working_papers/gfi_tenure_indicators_sep09.pdf |
| **ឯកសារដទៃ ទៀតដែលអាចមានប្រយោជន៍** | A4.4, A4.5, A4.8, A4.10, B4.1 |

## ការតាមដានគោលនយោបាយរដ្ឋាភិបាល៖ ក្បួនណែនាំមួយសម្រាប់ អង្គការសង្គមស៊ីវិល

**D1.5**

| | |
|---|---|
| **នេះជាអ្វី?** | ក្បួនណែនាំមួយសម្រាប់តាមដានប្រសិទ្ធភាព និងឥទ្ធិពលនៃគំនិតផ្តួចផ្តើមគោលនយោបាយរបស់រដ្ឋាភិបាល។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ត្រូវបានអភិវឌ្ឍសម្រាប់អង្គការសង្គមស៊ីវិលដែលធ្វើការនៅទ្វីបអាហ្វ្រិក វាផ្តល់ជូនអង្គការនូវឧបករណ៍សម្រាប់តាមដានមើលគោលនយោបាយរដ្ឋាភិបាល។ វាត្រូវបានសរសេរសម្រាប់គំនិតផ្តួចផ្តើមគោលនយោបាយទាំងអស់ និងអាចប្រើបានលើវិស័យព្រៃឈើ។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | ជំហានសំខាន់ៗមួយចំនួននៅក្នុងកិច្ចដំណើរការនេះរួមមាន៖ ការពិនិត្យមើលគោលនយោបាយ និងការស្រង់ព័ត៌មានពាក់ព័ន្ធ ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធគោលនយោបាយ ការវិភាគខ្លឹមសារគោលនយោបាយ ការកំណត់គោលដៅតាមដាន ការវិភាគថវិកាគោលនយោបាយ ការប្រមូលភស្តុតាងស្តីពីការអនុវត្តគោលនយោបាយ និងការប្រើភស្តុតាងគោលនយោបាយសម្រាប់ធ្វើការតស៊ូមតិដើម្បីការផ្លាស់ប្តូរ។ មានឧបករណ៍ពាក់ព័ន្ធសមស្របសម្រាប់ដំណាក់កាលនីមួយៗ។ |
| **ចំពោះព័ត៌មានបន្ថែម** | CAFOD/Christian Aid/Trócaire. 2006. Monitoring government policies: a toolkit for civil society organisations. UK, Catholic Agency for Overseas Development and Christian Aid,and Ireland, Trócaire. http://www.commdev.org/content/ document/ detail/1818 |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4, B4.1 |

## D1.6 ការទទួលបានព័ត៌មានសាធារណៈ

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសំណុំ – អភិក្រមវិធីសាស្ត្រ យុទ្ធសាស្ត្រ យុទ្ធវិធី ឬ បច្ចេកទេសនានា – ដែលអាចត្រូវបានប្រើប្រាស់ដើម្បីបង្កើនតម្លាភាព និង គណនេយ្យភាព នៅតាមស្ថាប័នរដ្ឋាភិបាល។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ក្បួនណែនាំនេះ អាចត្រូវបានប្រើសម្រាប់ទទួលបានព័ត៌មានដែលស្ថាប័នរដ្ឋាភិបាលរក្សាទុក។ ក្បួននេះផ្តោតជាពិសេសលើអង្គការមិនមែនរដ្ឋាភិបាល សកម្មជន និងក្រុមសង្គមស៊ីវិល ដែលកំពុងធ្វើការងារលើការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ ក៏ដូចជាបញ្ហាជីវភាពផងដែរ។ |
| **ធាតុផ្សំសំខាន់ៗ** | មានដំណាក់កាលសំខាន់ៗពីរ៖ ដំណាក់កាលត្រៀមលក្ខណៈ និងដំណាក់កាលអនុវត្ត រួមជាមួយឧបករណ៍ពាក់ព័ន្ធ។ ដំណាក់កាលត្រៀមលក្ខណៈ រួមមានការស្វែងយល់ពីបរិបទច្បាប់ និងគោលនយោបាយក្នុងមូលដ្ឋានដែលនៅក្នុងនោះ ព័ត៌មាននឹងត្រូវយកពីស្ថាប័នរដ្ឋាភិបាល។ មានជំហានទូលាយចំនួនបីក្នុងដំណាក់កាលអនុវត្ត៖ កសាងការយល់ដឹងនិងសមត្ថភាពរបស់ក្រុមគោលដៅ ការចូលរួមក្នុងនីតិវិធីទទួលបានព័ត៌មាន និងការប្រើព័ត៌មានដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរដែលចង់បាន ឧទាហរណ៍ តាមរយៈសវនាការសាធារណៈ ឬយុទ្ធនាការចុះហត្ថលេខា។ |
| **ចំពោះព័ត៌មានបន្ថែម** | Winrock International India. 2005. Accessing 'Public' information. Power Tools Series. New Delhi, Winrock International India, and London, IIED. http://www.policy-powertools.org/Tools/Ensuring/API.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4, B4, C1, D3.3<br>ឧបករណ៍ស៊ីជម្រៅ: XL D1.6 |

## ការពិនិត្យពិច័យនីតិកម្មដោយសហគមន៍

D1.7

| | |
|---|---|
| **នេះជាអ្វី?** | ឧបករណ៍មួយសម្រាប់ពិនិត្យពិច័យ និងកែលម្អលទ្ធផលជាក់ស្តែងនៃនីតិកម្មសម្រាប់សហគមន៍ ដែលគេមិនបានយកចិត្តទុកដាក់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីកំណត់អ្វីដែលមានប្រសិទ្ធភាពនៅក្នុងនីតិកម្មបច្ចុប្បន្ន អ្វីដែលនៅខ្វះចន្លោះ និងការកែតម្រូវច្បាប់អ្វីខ្លះ ដែលចាំបាច់ដើម្បីកែលម្អស្ថានភាព។ ឧបករណ៍នេះត្រូវបានអភិវឌ្ឍក្នុងបរិបទនៃសម្បទានព្រៃឈើនៅប្រទេសម៉ូហ្សំប៊ិក ប៉ុន្តែអាចអនុវត្តបានចំពោះអង្គការ នៅកន្លែងផ្សេងដែលចង់វាយតម្លៃច្បាប់ និងគោលនយោបាយនានាទាក់ទិននឹងអភិបាលកិច្ចនៃការកាន់កាប់សម្រាប់ធនធានព្រៃឈើ។ |
| **ធាតុផ្សំសំខាន់ៗ** | នៅទីណាដែលនីតិកម្មមានឥទ្ធិពលជាក់ស្តែងផ្សេងគ្នា (‘ល្អ’ ‘មធ្យម’ និង ‘អាក្រក់’) ឧបករណ៍នេះកំណត់ថាតើការកែលម្អចំពោះនីតិកម្មអាចធ្វើបាននៅកម្រិតណា (ពោលគឺ ក្នុងអំឡុងពេលរៀបចំអនុវត្ត ឬបង្ខំឱ្យអនុវត្ត)។ ជំហានទាំងឡាយដែលគេប្រើដើម្បីវាយតម្លៃគម្លាតគោលនយោបាយរវាងបំណងផ្នែកច្បាប់ និងឥទ្ធិពលជាក់ស្តែងរួមមាន៖ ការកំណត់មាត្រាច្បាប់ស្តីពីសិទ្ធិ និងអត្ថប្រយោជន៍របស់សហគមន៍ ឥទ្ធិពលយល់ឃើញជាក់ស្តែងការវាយតម្លៃអំពីអ្វីដែលមានប្រសិទ្ធភាព អ្វីដែលកំពុងខ្វះខាត និងអ្វីដែលគេអាចធ្វើបាន និងការកំណត់ការកែតម្រូវច្បាប់ដែលអាចការពារសិទ្ធិ និងអត្ថប្រយោជន៍របស់សហគមន៍បានកាន់តែប្រសើរឡើង។ |
| **ចំពោះព័ត៌មានបន្ថែម** | Johnstone, R., Cau, B., Norfolk, S. & Macqueen D. 2005 Good, average, bad: law in action. Power Tools Series. Maputo, Mozambique, Terra Firma and London, IIED. http://www.policy-owertools.org/Tools/Ensuring/GAB.html |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A3.1, A4.2, A4.8, A5, D3.3 |

## សកម្មភាពពលរដ្ឋដើម្បីកាត់បន្ថយអំពើពុករលួយព្រៃឈើ

D1.8

| | |
|---|---|
| **នេះជាអ្វី?** | គំនិតសម្រាប់គម្រោងប្រឆាំងអំពើពុករលួយនៅក្នុងវិស័យព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ផ្អែកលើឧបករណ៍របស់អង្គការតម្លាភាពអន្តរជាតិ (TI) ដែលគេបានប្រើនៅក្នុងវិស័យផ្សេងៗសម្រាប់គម្រោងប្រឆាំងអំពើពុករលួយរបស់សង្គមស៊ីវិល។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍ខ្លះនៃឧបករណ៍ទាំងនេះ ដែលត្រូវបានកែសម្រួលទៅនឹងវិស័យព្រៃឈើ ដោយផ្អែកលើបទពិសោធន៍របស់អង្គការតម្លាភាពអន្តរជាតិ (TI) រួមមាន៖ ការជំរុញការយល់ដឹងការទទួលព័ត៌មាន ការចងក្រងឯកសារអំពីស្នាដៃអនុវត្តរបស់រដ្ឋាភិបាល ការបង្កើត និងការអនុវត្តគំរូកតិកាសញ្ញាស្តីពីសុចរិតភាពព្រៃឈើ ការបង្កើតសន្ទស្សន៍នៃទស្សនៈអំពើពុករលួយនៃវិស័យព្រៃឈើ ការបង្កើតសៀវភៅកំប្លែងប្រឆាំងអំពើពុករលួយ និងការប្រមូលស្ថិតិអំពីការអនុវត្តច្បាប់ព្រៃឈើ។ |
| **ចំពោះព័ត៌មានបន្ថែម** | Rosenbaum, K. 2005. Tools for civil society action to reduce forest corruption: drawing lessons from Transparency International. Washington, DC, World Bank. http://www.profor.info/profor/sites/profor.info/files/docs/Tools-for-civil- society.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B4.3, C1.6, C1.7 |

## D1.9 គេហទំព័រប្រឆាំងអំពើពុករលួយៈ ចូរផ្លុំកញ្ចែរបស់អ្នក

| | |
|---|---|
| **នេះជាអ្វី?** | គំនិតផ្តួចផ្តើមផ្អែកលើបច្ចេកវិទ្យាសារគមនាគមន៍មួយសម្រាប់ឱ្យពលរដ្ឋប្រយុទ្ធប្រឆាំងអំពើពុករលួយ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជួយឱ្យពលរដ្ឋអាចរាយការណ៍អំពីអំពើពុករលួយ តាមទូរសព្ទចល័ត និងអ៊ីនធឺណិត ដោយដាក់បង្ហោះអត្ថបទឯកសារសំឡេង និងវីដេអូ។ |
| **ធាតុផ្សំសំខាន់ៗ** | ធាតុផ្សំសំខាន់ៗ "ផ្លុំកញ្ចែរបស់អ្នក" គឺជាគំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយមួយដែលគាំទ្រដោយបច្ចេកវិទ្យារបស់ គណៈកម្មការឃ្លាំមើលកណ្តាលនៃប្រទេសឥណ្ឌា ( Central Vigilance Commission of India ) ដែលត្រូវបានគេហៅផងដែរថា Project Vigeye។ វាជួយឱ្យពលរដ្ឋសម្តែងការតវ៉ារបស់ខ្លួនតាមរយៈទូរសព្ទចល័តរបស់ពួកគេ ដោយទាញយកកម្មវិធីចល័តមួយ ( mobile application ) តាមអ៊ីនធឺណិត ដោយបំពេញទម្រង់បណ្តឹងតាមអ៊ីនធឺណិត និងភ្ជាប់ភស្តុតាងជាសំឡេង វីដេអូ ឬរូបភាព ឬតាមរយៈខ្សែទូរសព្ទជំនួយ។ អ្នកប្តឹងត្រូវបានទាក់ទងដោយផ្ទាល់តាមទូរសព្ទ អ៊ីមែល ឬដោយជួបផ្ទាល់មុខ ដើម្បីសាកសួរបន្ថែម និងដើម្បីសាកសួរព័ត៌មានអំពីស្ថានភាពនៃបណ្តឹងរបស់ពួកគេ។ គេហទំព័រផ្លុំកញ្ចែរបស់អ្នក ( Blow Your Whistle ) ក៏មានវេទិកាពិភាក្សា podcasts ( ឯកសារសំឡេងអេឡិចត្រូនិក ) អំពីអំពើពុករលួយក្នុងប្រទេស វីដេអូ និងការតភ្ជាប់ទៅធនធានផ្សេងទៀតផងដែរ។ |
| **ចំពោះព័ត៌មានបន្ថែម** | Central Vigilance Commission. Blow Your Whistle [Online Resource]. India. http://cvc.nic.in/ |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B4.2 |

## D1.10 គណៈវិនិច្ឆ័យរបស់ពលរដ្ឋ

| | |
|---|---|
| **នេះជាអ្វី?** | គណៈវិនិច្ឆ័យរបស់ពលរដ្ឋ គឺជាវេទិកាមួយសម្រាប់ចែករំលែកចំណេះដឹង សម្រាប់សន្ទនា និងសម្រាប់ផ្តល់ព័ត៌មានដល់ការសម្រេចចិត្តផ្នែកគោលនយោបាយតាមរយៈកិច្ចដំណើរការមួយនៃលទ្ធិប្រជាធិបតេយ្យផ្អែកលើការពិភាក្សា ដែលព្យាយាមពាក់ព័ន្ធរាល់ភាគីពាក់ព័ន្ធទាំងអស់យ៉ាងពេញលេញ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | គណៈវិនិច្ឆ័យរបស់ពលរដ្ឋ អនុញ្ញាតឱ្យអ្នកផលិតតូចតាចអាចវាយតម្លៃចំណេះដឹងឯកទេស និងបង្ហាញអាទិភាពស្រាវជ្រាវជាយុទ្ធសាស្ត្រ និងអនុសាសន៍គោលនយោបាយ ដែលបំពេញសេចក្តីត្រូវការរបស់ពួកគេ។ វាមានប្រយោជន៍ជាពិសេសជាវេទិកាមួយសម្រាប់ការពិភាក្សាអំពីបញ្ហាចម្រូងចម្រាស់ ដែលនៅក្នុងនោះ រាល់ទស្សនៈទាំងអស់អាចត្រូវបានបញ្ចេញ និងស្តាប់ឮ។ |
| **ធាតុផ្សំសំខាន់ៗ** | សុចរិតភាព ភាពពេញលេញ និងភាពអាចទុកចិត្តបាន គឺមានលក្ខណៈសំខាន់បំផុតចំពោះការធានាឱ្យបានថាគណៈវិនិច្ឆ័យមួយរបស់ពលរដ្ឋជះឥទ្ធិពលលើគោលនយោបាយប្រកបដោយជោគជ័យ។ គណៈកម្មា-ធិការត្រួតពិនិត្យមួយ ជាធម្មតាធ្វើការប្រឹងប្រែងដោយឡែកក្នុងការត្រៀមលក្ខណៈសម្រាប់កិច្ចដំណើរការនេះ។ ធាតុផ្សំទាំងនេះក៏ធានាផងដែរថាចំណាត់ការមានលក្ខណៈអាចទុកចិត្តបាន និងមានយុត្តិធម៌។<br>ជាធម្មតា 'គណៈវិនិច្ឆ័យ' មួយរបស់ពលរដ្ឋមូលដ្ឋានដែលទំនងជារងឥទ្ធិពលនៃគម្រោងផ្លាស់ប្តូរ ឬសកម្មភាពគោលនយោបាយ – ដូចជាការដាក់ឱ្យប្រើភាវៈដែលបានប្តូរទម្រង់ហ្សែន ( genetically modified organisms ) ជាដើម – ត្រូវបានបង្ហាញជាមួយភស្តុតាងពីមន្ត្រីរដ្ឋាភិបាល អ្នកវិទ្យាសាស្ត្រ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត។ បន្ទាប់មកសមាជិកនៃគណៈវិនិច្ឆ័យចេញ 'សេចក្តីសម្រេច' របស់ខ្លួន ជាមួយនឹងសំណើសកម្មភាព។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | Coote, A. & Lenaghan, J. 1996. Citizens' juries: theory into practice. London, Institute for Public Policy Research. Link to purchase: http://www.ippr.org/publications/55/1187/citizens-juries-theory-into-practice<br>Pimbert, M. & Wakeford, T. (eds.) 2001. Deliberative democracy and citizen empowerment. PLA Notes, 40. http://pubs.iied.org/6345IIED.html<br>IIED. Deliberative democracy: citizens' juries [Online Resource]. http://www.iied. org/deliberative-democracy-citizens-juries |
| **ឯកសារផ្សេងទៀតដែលអាចមានប្រយោជន៍** | A4.1, B1.2, B4.1, C2.3, D2.3 |

## D2. យន្តការសម្រាប់តវ៉ាដោះស្រាយវិវាទ និងការទទួលបានការគាំទ្រពីជំនួយការមេធាវី (Paralegal Support)

តើសហគមន៍អាច និងមានឱកាសដាក់បណ្តឹងឬទេ? តើគេមានធ្វើសកម្មភាពអ្វីទេនៅពេលដែលសិទ្ធិរបស់ពួកគេត្រូវបានគេបំពាន? សហគមន៍ចាំបាច់ត្រូវអាចមានឧបាស្រ័យទៅតុលាការ រដ្ឋាភិបាលកម្រិតខ្ពស់ និងគោលនយោបាយ និងមធ្យោបាយអន្តរជាតិ ប្រសិនបើការប្តេជ្ញាចំពោះវិស័យព្រៃឈើប្រកបដោយការទទួលខុសត្រូវ មិនត្រូវបានលើកស្ទួយ។

យន្តការឧបាស្រ័យ គប្បីមានលក្ខណៈដូចខាងក្រោម៖

- អាចប្រើបានដើម្បីឱ្យប្រជាជន និងសហគមន៍ជនជាតិដើមភាគតិចដែលពឹងអាស្រ័យលើព្រៃឈើអាចរកបាន និងប្រើប្រាស់យន្តការនេះបាន។
- ឯករាជ្យ និងមិនលំអៀង ដើម្បីកុំឱ្យយន្តការនេះទទួលរងឥទ្ធិពលពីផលប្រយោជន៍បុគ្គល។
- មានប្រសិទ្ធផល និងប្រសិទ្ធភាព។
- ផ្អែកលើគោលការណ៍នៃវិមជ្ឈការ ពោលគឺ វិវាទគប្បីត្រូវបានដោះស្រាយនៅកៀកនឹងកម្រិតរដ្ឋបាលដែលជាកន្លែងដែលវិវាទបានកើតឡើង តាមដែលអាចធ្វើទៅបាន និងប្រើស្ថាប័នដោះស្រាយវិវាទមូលដ្ឋាននៅពេលណាដែលអាចធ្វើទៅបាន។
- ជាមាគ៌ាឆ្ពោះទៅកាន់លទ្ធផល ពោលគឺការផ្លាស់ប្តូរនៅក្នុងសកម្មភាព គោលនយោបាយ និង/ឬ នីតិវិធី។
- មានថវិកាគ្រប់គ្រាន់។

យន្តការតវ៉ាអាចផ្តល់មធ្យោបាយដំបូងនៃឧបាស្រ័យដើម្បីដោះស្រាយបណ្តឹង ហើយប្រសិនបើមានប្រសិទ្ធភាព វាអាចជាជម្រើសដែលមានប្រសិទ្ធផលបំផុត។ នេះគឺជាកិច្ចដំណើរការមួយដើម្បីដោះស្រាយកង្វល់ និងបណ្តឹងរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយមិនចាំបាច់ត្រូវពឹងផ្អែកលើតុលាការ និងនីតិវិធីពីខាងក្រៅ។ វាជាយន្តការមួយសម្រាប់ឱ្យរដ្ឋាភិបាល ក្រុមហ៊ុន និង/ឬ សហគមន៍ កំណត់បញ្ហា និងរកឃើញដំណោះស្រាយរួមគ្នា។ ខណៈដែលយន្តការដោះស្រាយវិវាទបែបប្រពៃណី ឬយន្តការដោះស្រាយវិវាទក្រៅតុលាការ ច្រើនតែគឺជាជម្រើសពេញចិត្តបំផុតក្តី ជាប្រការសំខាន់ផងដែរដែលពលរដ្ឋត្រូវអាចទទួលបានការជួយគាំទ្រផ្នែកច្បាប់ និងអាចចូលដល់តុលាការផងដែរ ប្រសិនបើយន្តការនេះជាអតិក្រមដែលពួកគេពេញចិត្ត។ ឧបករណ៍ដែលបានរាប់បញ្ចូលនៅទីនេះ រួមមានការធានាឱ្យបានថា មានការផ្តល់ជំនួយគាំទ្រមេធាវីជូនដល់សហគមន៍រហូតដល់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងយន្តការប្តឹងតវ៉ា។

## ឧបករណ៍គួរប្រើ

### D2.1 បង្កើតនីតិវិធីប្តឹងតវ៉ា

| | |
|---|---|
| **នេះជាអ្វី?** | គោលការណ៍ និងជំហានទាំងឡាយសម្រាប់បង្កើតនីតិវិធីប្តឹងតវ៉ាសហគមន៍មួយក្នុងបរិបទនៃគម្រោងឯកជន និងក្រុមហ៊ុន។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជួយក្រុមហ៊ុនក្នុងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការដោះស្រាយកង្វល់ និងបណ្តឹងប្រកបដោយជោគជ័យ។ |
| **ធាតុផ្សំសំខាន់ៗ** | នីតិវិធីទាំងនេះផ្តល់ការណែនាំអំពីគោលការណ៍ជាមូលដ្ឋាន និងជំហានដំណើរការដែលអង្គការគប្បីគិតគូរដល់នៅពេលបង្កើត និងអនុវត្តយន្តការប្តឹងតវ៉ា។ ជំហានទាំងនេះរួមមាន៖ ការផ្សព្វផ្សាយជាសាធារណៈនូវនីតិវិធីគ្រប់គ្រងបណ្តឹងតវ៉ា ការទទួល និងការតាមដានបណ្តឹងតវ៉ា ការពិនិត្យមើល និងការស៊ើបអង្កេតបណ្តឹងតវ៉ា ការអភិវឌ្ឍជម្រើសដំណោះស្រាយ និងការរៀបចំការឆ្លើយតបការតាមដាន យន្តការរាយការណ៍ និងការវាយតម្លៃ។ |
| **ចំពោះព័ត៌មានបន្ថែម** | IFC. 2009. Good practice note: addressing grievances from project-affected communities – guidance for projects and companies on designing grievance mechanisms. Washington, DC, International Finance Corporation, World Bank Group.http://www1.ifc.org/wps/wcm/connect/cbe7b18048855348ae6cfe6a6515bb18/IFC%2BGrievance%2BMechanisms.pdf?MOD=AJPERES&CACHEID=cbe7b18048855348ae6cfe6a6515bb8<br>Example:<br>Rao, Y.G., Dash, T. & Mishra, S. 2011. Forest rights act: a field guide. WWF India. http://awsassets.wwfindia.org/downloads/forest_rights_act_a_field_guide.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | C2.4 |

### D2.2 ពង្រឹងសមត្ថភាពមេធាវីនៅក្នុងសហគមន៍ព្រៃឈើ

| | |
|---|---|
| **នេះជាអ្វី?** | ការណែនាំ និងឧបករណ៍សម្រាប់មេធាវីដែលធ្វើការជាមួយសហគមន៍នៅក្នុងវិស័យព្រៃឈើ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីផ្តល់ជំនួយការមេធាវីនៅក្នុងសហគមន៍ជាយព្រៃឈើ នូវចំណេះដឹងជាមូលដ្ឋាន និងឧបករណ៍ជាក់ស្តែងដែលចាំបាច់ដើម្បីធ្វើការប្រកបដោយប្រសិទ្ធភាព។ ការងារនេះក៏បំពេញមុខងារជាមូលដ្ឋានផងដែរសម្រាប់ការបណ្តុះបណ្តាលអ្នកតស៊ូមតិ និងភាគីពាក់ព័ន្ធទាំងឡាយនៅក្នុងសហគមន៍ព្រៃឈើដែលរងផលប៉ះពាល់។ ថ្វីបើពង្រឹងសមត្ថភាពមេធាវីនៅក្នុងសហ-គមន៍ព្រៃឈើត្រូវបានសរសេរយ៉ាងជាក់លាក់សម្រាប់ពលរដ្ឋហ្កាណាក្តីក៏គោលការណ៍ទាំងនេះជាច្រើនអាចយកទៅអនុវត្តនៅកន្លែងដទៃបានផងដែរ។ |
| **ធាតុផ្សំសំខាន់ៗ** | ការណែនាំនេះ ពិភាក្សាតួនាទីរបស់មេធាវី (និងឧបករណ៍ទាំងឡាយដែលចាំបាច់) អាណត្តិ មុខងារ និងអត្ថប្រយោជន៍នៃស្ថាប័នរដ្ឋាភិបាលផ្សេងដែលត្រួតពិនិត្យវិស័យព្រៃឈើ ច្បាប់ផ្សេងៗដែលប៉ះពាល់ការគ្រប់គ្រងវិស័យព្រៃឈើ នីតិវិធី និងកិច្ចដំណើរការដើម្បីទទួលបានសិទ្ធិធ្វើអាជីវកម្មឈើដើម្បីធ្វើអាជីវកម្មលើធនធានឈើ (នៅប្រទេសហ្កាណា) សិទ្ធិ និងកាតព្វកិច្ចរបស់សហគមន៍ទាំងឡាយដែលរស់នៅក្នុង និងនៅជុំវិញតំបន់ព្រៃឈើ និង របៀបដែលពួកគេអាចឆ្លៀតប្រើសិទ្ធិទាំងនោះ រួមចំណែកដល់កិច្ចការពារព្រៃឈើ និងកិច្ចព្រមព្រៀងស្តីពីការទទួលខុសត្រូវសង្គម។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | CEPIL. 2009. Handbook for paralegals in forest communities in Ghana. Accra, Ghana, Center for Public Interest Law, and London, IIED. http://pubs.iied.org/ pdfs/G02754.pdf |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | A3.1, A4.8, D1.6 |

## ជំរំអក្ខរកម្មច្បាប់ — D2.3

| | |
|---|---|
| **នេះជាអ្វី?** | សៀវភៅណែនាំមួយសម្រាប់ឱ្យគ្រូបង្គោលរៀបចំ ‘ជំរំ’ ឬ សិក្ខាសាលាអក្ខរកម្មច្បាប់ជូនសហគមន៍។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងរបៀបអនុវត្តចំពោះសហគមន៍។ |
| **ធាតុផ្សំសំខាន់ៗ** | កិច្ចដំណើរការនេះមានបីផ្នែកៈ វាយតម្លៃពេលណាដែលជំរំអក្ខរកម្មច្បាប់គប្បីត្រូវបានប្រើ និងបុរេលក្ខខណ្ឌចាំបាច់ទាំងឡាយដើម្បីឱ្យជំរំទាំងនោះដំណើរការបានល្អ ផ្តល់ការបណ្តុះបណ្តាលអក្ខរកម្មច្បាប់ ការណែនាំ ឱវាទ ឧបករណ៍ វិភាគចំណុចខ្លាំង និងចំណុចខ្សោយនៃការដំណើរការជំរំអក្ខរកម្មច្បាប់។ |
| **ចំពោះព័ត៌មានបន្ថែម** | ELDF. 2005. Legal literacy camps. Power Tools Series. New Delhi, Enviro-Legal Defence Firm, and London, IIED. http://www.policy-powertools.org/Tools/ Ensuring/LLC.html |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | A4.8, C1.3 |

## សវនាការសាធារណៈ និងការធ្វើសវនកម្ម — D2.4

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | សវនការសាធារណៈគឺជាកិច្ចដំណើរការចូលរួម ដែលនៅក្នុងនោះ ក្នុង ករណីនេះ ក្រុមអ្នកប្រើប្រាស់ (ម្ចាស់សិទ្ធិ) ពិភាក្សា ចោទសួរ និងវាយតម្លៃយ៉ាងហ្មត់ចត់នូវកាតព្វកិច្ច និងការទទួលខុសត្រូវនៃគណៈ កម្មាធិការប្រតិបត្តិ (អ្នកអនុវត្តកាតព្វកិច្ច) ពាក់ព័ន្ធនឹងផែនការដែលបានរៀបចំកិច្ចប្រជុំដែលបានធ្វើ និងការពិភាក្សាដែលបានធ្វើ និងដែលបាន អនុវត្ត។ ការធ្វើសវនាការសាធារណៈគឺជាកិច្ចដំណើរការនៃការចែករំលែក ការវាយតម្លៃ និងការធ្វើសវនកម្មលើគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុ សេចក្តីសម្រេចចិត្ត និងកិច្ចដំណើរការទាំងអស់។ ព័ត៌មានដែលទទួលបានត្រូវបានពិនិត្យពិច័យតាមរយៈការចោទសួរសំណួរ ចម្លើយ និងការពិភាក្សាក្នុងលក្ខណៈម៉ឺងម៉ាត់ និងស្ថាបនា។ |
| **ចំពោះព័ត៌មានបន្ថែម** | Maharjan, M. & Shrestha, B. 2006. Public hearing and public auditing in the community forestry user groups: a summary of process, outcomes and lessons learned from the SAGUN programme in Nepal. SAGUN Forestry Buffer Zone Team, CARE Nepal. http://www.forestrynepal.org/images/Insight-1-2006.pdf |
| **ឯកសារដទៃទៀតដែលអាចមាន ប្រយោជន៍** | D.1.10 |

## D3. ឧបាស្រ័យទៅកាន់តុលាការ កម្រិតខ្ពស់នៃរដ្ឋាភិបាល ឬគោលនយោបាយ និងមធ្យោបាយអន្តរជាតិ

តើប្រជាពលរដ្ឋរស់នៅតំបន់ព្រៃឈើអាចប្រើយន្តការសិទ្ធិមនុស្សកម្រិតតំបន់ និងអន្តរជាតិដើម្បីជំរុញ និងស្វែងរកការបង្ខំអនុវត្តសិទ្ធិរបស់ពួកគេឬទេ? យន្តការទាំងនេះគប្បីមានលក្ខណៈអាចប្រើបានដោយជនជាតិដើមភាគតិច និងប្រជាពលរដ្ឋរស់នៅតំបន់ព្រៃឈើ ហើយការប្រើជាយុទ្ធសាស្ត្រនូវយន្តការនេះ អាចដោះស្រាយបញ្ហាជាក់លាក់នានាដែលប៉ះពាល់ដល់បុគ្គល សហគមន៍ ឬប្រជាពលរដ្ឋ និងរួមចំណែកផងដែរដល់ការបកស្រាយ និងការបង្កើតច្បាប់អន្តរជាតិ។

ប្រសិនបើប្រទេស ឬក្រុមហ៊ុនជាហត្ថលេខីចំពោះអន្តរាគមន៍អន្តរជាតិ យន្តការនេះអាចផ្តល់មធ្យោបាយ និងឱកាសបន្ថែមទៀត ដើម្បីលើកស្ទួយតម្លាភាព និងដោះស្រាយបញ្ហាអយុត្តិធម៌ទាំងឡាយទាក់ទិននឹងសិទ្ធិរបស់ប្រជាពលរដ្ឋចំពោះធនធានព្រៃឈើ។ ការប្តេជ្ញាចំពោះអន្តរាគមន៍ និងកិច្ចព្រមព្រៀងអន្តរជាតិ ច្រើននាំទៅដល់កិច្ចតម្រូវឱ្យមានតម្លាភាពកាន់តែច្រើន និងការប្រតិបត្តិអភិបាលកិច្ចល្អផ្សេងទៀត។ ប្រទេសហត្ថលេខីអាចត្រូវបានតម្រូវឱ្យផលិតយ៉ាងម៉ឺងម៉ាត់នូវរបាយការណ៍ប្រចាំឆ្នាំច្បាស់លាស់ ដែលអាចបង្កើនបរិមាណព័ត៌មាននៅក្នុងវិស័យសាធារណៈ។ ម្យ៉ាងទៀតអន្តរាគមន៍ និងកិច្ចព្រមព្រៀងទាំងនេះជំរុញស្តង់ដារអប្បរមាមួយចំនួននៃការប្រតិបត្តិ និងអាចផ្តល់គ្រឿងលើកទឹកចិត្ត (លទ្ធភាពទទួលមូលនិធិ និង/ឬជំនាញឯកទេស) ដើម្បីគាំទ្រការកែលម្អនៅក្នុងអភិបាលកិច្ច តម្លាភាព និងសិទ្ធិ។

អន្តរាគមន៍ និងកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗចំពោះចំណុចនេះរួមមាន៖

- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។
- សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (UNDRIP)។
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)។
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)។
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)។

ប៉ុន្តែក្នុងករណីជាច្រើនអន្តរាគមន៍អន្តរជាតិមិនអាចកំណត់ដោយផ្ទាល់ឱ្យការប្រតិបត្តិរបស់រដ្ឋាភិបាល ឬ ក្រុមហ៊ុនទទួលខុសត្រូវឡើយ។ ជាញឹកញាប់ ការអនុវត្តប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាលតម្រូវឱ្យមានការប្រែក្លាយគោលការណ៍ឱ្យក្លាយទៅជាច្បាប់ជាតិ និងការប្រើយន្តការច្បាប់ក្នុងប្រទេស។ ប៉ុន្តែគោលការណ៍ និងការប្តេជ្ញា ដែលមានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងអន្តរជាតិទាំងនេះត្រូវបានប្រើប្រកបដោយជោគជ័យនៅថ្នាក់ជាតិ ជាស្តង់ដារទទួលស្គាល់អន្តរជាតិសម្រាប់ប្រៀបធៀបការប្រតិបត្តិរបស់ធនាគារ ក្រុមហ៊ុន និងរដ្ឋាភិបាល។

មានអង្គការអន្តរជាតិផ្សេងៗដែលជំរុញសិទ្ធិមនុស្ស យុត្តិធម៌បរិស្ថាន និងលទ្ធភាពទទួលព័ត៌មានដែលសង្គមស៊ីវិលអាចប្រើបានដើម្បីទាក់ទាញការយកចិត្តទុកដាក់លើអយុត្តិធម៌ដែលគេសង្កេតឃើញ (ឧទាហរណ៍ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International មាត្រា ១៩ អង្គការមិត្តនៃផែនដី (Friends of the Earth) និងអង្គការគំនិតផ្តួចផ្តើមតម្លាភាពអន្តរជាតិ (Global Transparency Initiative)។ ដោយធ្វើប្រតិបត្តិការនៅក្រៅប្រទេសគោលដៅ ប៉ុន្តែច្រើនតែសហការជាមួយអង្គការជាតិ អង្គការទាំងនេះបំពេញតួនាទីដ៏សំខាន់មួយក្នុងការកំណត់ និងជំរុញស្តង់ដារអន្តរជាតិ ការបង្កើនការយល់ដឹង និងការធ្វើយុទ្ធការការប្រឆាំងនឹងអយុត្តិធម៌ តាមវិធីមួយដែលអង្គការជាតិអាចយល់ថាមិនអាចធ្វើបាន និងការជះឥទ្ធិពលលើគោលនយោបាយ និងការប្រតិបត្តិរបស់អង្គការ អង្គការប្រចាំតំបន់ អង្គការអន្តររដ្ឋាភិបាល និងអង្គការអន្តរជាតិដែលស្ថិតនៅក្រោយយុត្តិសាស្ត្រជាតិ។

## ឧបករណ៍គួរប្រើ

### ធានាឱ្យបានសិទ្ធិរបស់ស្ត្រី ដោយប្រើប្រព័ន្ធសិទ្ធិមនុស្សនៅអាហ្វ្រិក — D3.1

| | |
|---|---|
| **នេះជាអ្វី?** | ក្បួនណែនាំមួយដើម្បីណែនាំស្ត្រីជនជាតិដើមភាគតិច និងអង្គការដែលតំណាងឱ្យពួកគេ ស្គាល់ប្រព័ន្ធសិទ្ធិមនុស្សអាហ្វ្រិក។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីជួយស្ត្រីជនជាតិដើមភាគតិចនៅអាហ្វ្រិកដើម្បីឱ្យបានយល់កាន់តែប្រសើរឡើងអំពីប្រព័ន្ធសិទ្ធិមនុស្សអាហ្វ្រិក និងរបៀបប្រើវាប្រកបដោយប្រសិទ្ធភាពដើម្បីទទួលបានសិទ្ធិរបស់ពួកគេ។ |
| **ធាតុផ្សំសំខាន់ៗ** | ក្បួនណែនាំនេះ មានព័ត៌មានដោយឡែកដែលរួមមាន៖ សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗនៃសហភាពអាហ្វ្រិក គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងសិទ្ធិរបស់ប្រជាជន សិទ្ធិរបស់ស្ត្រី និងក្រុមការងារស្តីពីប្រជាជន/សហគមន៍ជនជាតិដើមភាគតិច។ ការណែនាំនេះរួមមាន ព័ត៌មានអំពីរបៀបចូលរួម និងប្រើប្រព័ន្ធនេះជាក់ស្តែង៖ ចូលរួមក្នុងសម័យប្រជុំគណៈកម្មការអាហ្វ្រិក កិច្ចដំណើរការរាយការណ៍ប្រចាំប្រទេស ការស្នើសុំបេសកកម្មស៊ើបអង្កេតមួយ និងការតស៊ូមតិថ្នាក់ជាតិជាមួយគណៈកម្មការ និងក្រុមការងាររបស់គណៈកម្មការ។ |
| **ចំពោះព័ត៌មានបន្ថែម** | Vig, S. 2011. Indigenous women's rights and the African human rights system: a toolkit on mechanisms. Moreton-in-Marsh, UK, Forest Peoples Programme.<br>http://www.forestpeoples.org/topics/african-human-rights-system/publication/2011/toolkit-indigenous-women-s-rights-africa<br>Braun, T. & Mulvagh, L. 2008. The African human rights system: a guide for indigenous peoples. Moreton-in-Marsh, UK, Forest Peoples Programme.<br>http://www.forestpeoples.org/sites/fpp/files/publication/2010/08/africanhrsystemguideoct08eng.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.1, A4.10, B1.2, D2.3 |

### សិទ្ធិរបស់ជនជាតិដើមភាគតិចនៅក្នុងអង្គការពលកម្មអន្តរជាតិ (ILO) — D3.2

| | |
|---|---|
| **នេះជាអ្វី?** | ការណែនាំ និងយន្តការសម្រាប់ដាក់បណ្តឹងទៅកាន់អង្គការអន្តរជាតិខាងការងារ (ILO)។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | ដើម្បីផ្តល់ជូនជនជាតិដើមភាគតិចនូវការយល់ដឹងកាន់តែប្រសើរឡើងអំពីសិទ្ធិរបស់ពួកគេទាក់ទិននឹងអង្គការអន្តរជាតិខាងការងារ (ILO) និងលើកទឹកចិត្តឱ្យពួកគេប្រើនីតិវិធីអន្តរជាតិទាំងនេះដើម្បីទទួលបានការកែតម្រូវ។ |
| **ធាតុផ្សំសំខាន់ៗ** | ឧបករណ៍នេះផ្តល់ការណែនាំអំពីរបៀបដាក់បណ្តឹងទៅកាន់ក្រុមប្រឹក្សាភិបាលនៃអង្គការអន្តរជាតិខាងការងារ(ILO)។ សេចក្តីសង្ខេបនៃករណី និងសេចក្តីសម្រេចពាក់ព័ន្ធនានាដែលបានឆ្លងកាត់ប្រព័ន្ធនេះរួចហើយ ក៏ត្រូវបានដាក់បញ្ចូលផងដែរ។ ករណី និងសេចក្តីសម្រេចទាំងនេះបង្ហាញរបៀបដែលប្រព័ន្ធនេះដោះស្រាយសិទ្ធិជនជាតិដើមភាគតិច និងផ្តល់ឧទាហរណ៍ជាក់ស្តែងអំពីរបៀបដែលករណីមួយអាចត្រូវបានដាក់ឆ្លងកាត់ប្រព័ន្ធនេះ។ ឧបករណ៍នេះក៏សង្ខេបផងដែរនូវសិទ្ធិអ្វីដែលត្រូវបានការពារក្រោមអន្តរាគមន៍នៃអង្គការអន្តរជាតិខាងការងារ (ILO) ដែលមានលក្ខណៈសមស្របបំផុតចំពោះជនជាតិដើមភាគតិច។ |

| | |
|---|---|
| **ចំពោះព័ត៌មានបន្ថែម** | MacKay, F. 2003. A guide to indigenous peoples' rights in the International Labour Organization. Moreton-in-Marsh, UK, Forest Peoples Programme. http://www.forestpeoples.org/sites/fpp/files/publication/2010/09/ iloguideiprightsjul02eng.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | B1.2, D2.3 |

## D3.3 សិទ្ធិដឹងរបស់សាធារណជនៈ គោលការណ៍ស្តីពីច្បាប់សេរីភាពព័ត៌មាន

| | |
|---|---|
| **នេះជាអ្វី?** | គោលការណ៍សម្រាប់វាស់វែងថាតើច្បាប់ក្នុងស្រុកពិតជាអនុញ្ញាតឱ្យមានលទ្ធភាពទទួលបានព័ត៌មានផ្លូវការប្រាកដមែន ឬយ៉ាងណា។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | គោលការណ៍មួយកញ្ចប់ដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ដែលកំណត់យ៉ាងច្បាស់ និងយ៉ាងជាក់លាក់វិធីទាំងឡាយ ដែលនៅក្នុងនោះ រដ្ឋាភិបាលអាចសម្រេចបានការបើកទូលាយជាអតិបរមាស្របតាមស្តង់ដារ និងកិច្ចប្រតិបត្តិការអន្តរជាតិប្រសើរបំផុត។ |
| **ធាតុផ្សំសំខាន់ៗ** | គោលការណ៍ទាំងនេះគឺផ្អែកលើច្បាប់ និងស្តង់ដារអន្តរជាតិ និងតំបន់ ការប្រតិបត្តិវិវត្តតាមរដ្ឋ (ដូចដែលត្រូវបានឆ្លុះបញ្ចាំង ជាអាទិ៍ ក្នុងច្បាប់ជាតិ និងសេចក្តីសម្រេចរបស់តុលាការជាតិ) និងគោលការណ៍ទូទៅនៃច្បាប់ដែលត្រូវបានទទួលស្គាល់ដោយសហគមន៍នៃប្រទេសជាតិនានា។ គោលការណ៍ទាំងនេះរួមមាន៖ ការបញ្ចេញព័ត៌មានជាអតិបរមា កាតព្វកិច្ចផ្សព្វផ្សាយ ការជំរុញរដ្ឋាភិបាលបើកទូលាយ វិសាលភាពករណីលើកលែងមានកម្រិត នីតិវិធីជួយសម្រួលលទ្ធភាពទទួលព័ត៌មាន ថ្លៃចំណាយផ្សេងៗ កិច្ចប្រជុំបើកទូលាយ ការបញ្ចេញព័ត៌មានមានអាទិភាព និងកិច្ចការពារជូនអ្នករាយការណ៍ព័ត៌មាន។ |
| **ចំពោះព័ត៌មានបន្ថែម** | Article 19. 1999. The public's right to know: principles on freedom of information legislation. London. http://www.article19.org/pdfs/standards/righttoknow.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | D2.3 |

## D3.4 ប្រើយន្តការពិនិត្យមើលអនុលោមភាពនៃអនុសញ្ញាអារុស (Aarhus Convention)

| | |
|---|---|
| **នេះជាអ្វី?** | ការណែនាំស្តីពីការលើកឡើងក្តីបារម្ភអំពីអនុលោមភាពរបស់ភាគីមួយដោយផ្ទាល់ជូនគណៈកម្មាធិការមួយនៃជំនាញការអន្តរជាតិផ្នែកច្បាប់ ដែលត្រូវបានផ្តល់អំណាចឱ្យពិនិត្យមើលគុណសម្បត្តិនៃករណីនេះ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | យន្តការពិនិត្យមើលអនុលោមភាពមួយ អនុញ្ញាតឱ្យភាពទន់ខ្សោយក្នុងការអនុវត្តអនុសញ្ញានៃគណៈកម្មការសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប ស្តីពីការទទួលព័ត៌មាន ការចូលរួមសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងលទ្ធភាពទទួលបានយុត្តិធម៌ក្នុងកិច្ចការបរិស្ថាន (អនុសញ្ញាអារុស (Aarhus Convention) អាចត្រូវបានលើកឡើង ហើយរិះរកដំណោះស្រាយក្នុងលក្ខណៈស្ថាបនា។ |

| | |
|---|---|
| **ធាតុផ្សំសំខាន់ៗ** | អនុសញ្ញាអារុស ( Aarhus Convention ) ផ្តល់សិទ្ធិជូនសាធារណជន និងដាក់កាតព្វកិច្ចដល់ភាគី និងអាជ្ញាធរសាធារណៈពាក់ព័ន្ធនឹងការទទួលព័ត៌មាន និងការចូលរួមជាសាធារណៈ និងលទ្ធភាពទទួលបានភាពយុត្តិធម៌។ អនុសញ្ញានេះត្រូវបានប្រែក្លាយទៅជាច្បាប់សហភាពអឺរ៉ុប ក្លាយទៅជាច្បាប់ជាតិ និងត្រូវបានអនុវត្តនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុប។ យន្តការពិសេសពិនិត្យមើលអនុលោមភាពនេះ អាចត្រូវបានចាប់ផ្តើមអនុវត្តប្រសិនបើមានសមាជិកសាធារណៈម្នាក់ ប្តឹងពីអនុលោមភាពនៃភាគីណាមួយ។ |
| **ចំពោះព័ត៌មានបន្ថែម** | UNECE. 2010. Guidance document on the Aarhus Convention compliance mechanism. Geneva, United Nations Economic Commission for Europe. http://www.unece.org/env/pp/compliance/CC_GuidanceDocument.pdf |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.5, D2.3 |

## ការបញ្ជាក់អំពីតម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម

**D3.5**

| | |
|---|---|
| **នេះជាអ្វី ?** | ឧបករណ៍មួយសម្រាប់ពិនិត្យមើលថាតើក្រុមហ៊ុន និងរដ្ឋាភិបាល កំពុងគោរពតាមការប្តេជ្ញារបស់ខ្លួនចំពោះតម្លាភាពនៃចំណូលនៅក្នុងឧស្សាហកម្មនិស្សារណកម្មដែរ ឬយ៉ាងណា។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី ?** | ដើម្បីវាយតម្លៃអនុលោមភាពក្នុងប្រទេសជាមួយនឹងស្តង់ដារពិភពលោកសម្រាប់តម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម។ គំនិតផ្តួចផ្តើមនេះត្រូវបានអភិវឌ្ឍសម្រាប់វិស័យប្រេងកាត ឧស្ម័ន និង រ៉ែ ប៉ុន្តែមានសក្តានុពលសម្រាប់ប្រើបានក្នុងវិស័យផ្សេងទៀត រួមទាំងវិស័យព្រៃឈើផងដែរ។ |
| **ធាតុផ្សំសំខាន់ៗ** | អង្គការគំនិតផ្តួចផ្តើមស្តីពីតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម ( EITI ) កំណត់ស្តង់ដារពិភពលោកសម្រាប់តម្លាភាពនៅក្នុងវិស័យប្រេងកាត ឧស្ម័ន និងរ៉ែ។ អង្គការនេះជាសម្ព័ន្ធភាពមួយនៃរដ្ឋាភិបាល ក្រុមហ៊ុន និងសង្គមស៊ីវិល និងជាស្តង់ដារមួយសម្រាប់ឱ្យក្រុមហ៊ុនផ្សព្វផ្សាយអ្វីដែលពួកគេបានបង់ និងសម្រាប់ឱ្យរដ្ឋាភិបាលផ្សព្វផ្សាយអ្វីដែលពួកគេទទួល។ ឧបករណ៍របស់អង្គការគំនិតផ្តួចផ្តើមស្តីពីតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម ( EITI ) បង្កើតវិធីសាស្ត្រដែលប្រទេសទាំងឡាយត្រូវតែអនុវត្តតាម ដើម្បីឱ្យមានអនុលោមភាពពេញលេញ។ បន្ទាប់មកគេចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ជាទៀងទាត់។ |
| **ចំពោះព័ត៌មានបន្ថែម** | EITI. 2009. Extractive industries transparency initiative: validation guide. Oslo. http://eitransparency.org/document/validationguide |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | D1.3, D2.3 |

## D3.6 កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPAs) ស្តីពីអភិបាលកិច្ចព្រៃឈើ

| | |
|---|---|
| **នេះជាអ្វី?** | កិច្ចព្រមព្រៀងឧបតោភាគីរវាងសហភាពអឺរ៉ុប និងប្រទេសនាំចេញឈើ ដែលសំដៅជានាឱ្យបានថា ឈើដែលបាននាំចេញទៅកាន់សហភាពអឺរ៉ុបគឺចេញពីប្រភពស្របច្បាប់។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPAs) សម្រាប់ការបង្ខំអនុវត្តច្បាប់ អភិបាលកិច្ច និងពាណិជ្ជកម្មព្រៃឈើ (FLEGT) ក៏ជួយគាំទ្រប្រទេសជាដៃគូផងដែរក្នុងការកែលម្អបទប្បញ្ញត្តិ និងអភិបាលកិច្ចរបស់ពួកគេលើវិស័យនេះ។ កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPAs) ដំណើរការដើម្បីធានាអ្នកប្រើប្រាស់នៃសហភាពអឺរ៉ុបអំពីភាពស្របច្បាប់នៃឈើនាំចូល ទន្ទឹមគ្នានឹងការកែលម្អការគ្រប់គ្រង និងអភិបាលកិច្ចព្រៃឈើ រួមមានការពង្រឹងសិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃឈើ ការបង្កើនតម្លាភាពក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការធានាឱ្យបាននូវការចូលរួមរបស់សង្គមស៊ីវិលក្នុងការធ្វើគោលនយោបាយ។ |
| **ធាតុផ្សំសំខាន់ៗ** | កិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPAs) គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មឧបតោភាគីក្នុងលក្ខណៈភ្ជាប់កាតព្វកិច្ចស្របច្បាប់ ដែលកំណត់សកម្មភាពដែលសហភាពអឺរ៉ុប និងប្រទេសនាំចេញឈើ ចាំបាច់ត្រូវធ្វើដើម្បីដោះស្រាយបញ្ហាកាប់ឈើខុសច្បាប់។ កិច្ចដំណើរការនៃកិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPA) ផ្តល់ឱកាសឱ្យសហគមន៍ព្រៃឈើ និងអង្គការបរិស្ថាននៅក្នុងប្រទេសដៃគូ បំភ្លឺ និងពង្រឹងសិទ្ធិរបស់សហគមន៍ព្រៃចំពោះដី និងព្រៃឈើ និងតម្រូវឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការសន្យាដែលបានធ្វើ។<br>នៅចំកណ្តាលបេះដូងនៃកិច្ចព្រមព្រៀងភាពជាដៃគូដោយស្ម័គ្រចិត្ត (VPA) គឺជាប្រព័ន្ធធានានីត្យានុកូលភាព (LAS) ដែលតម្រូវឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ដើម្បីធានា៖ និយមន័យច្បាស់លាស់មួយនៃឈើស្របច្បាប់ យន្តការគ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់ឈើ ការផ្ទៀងផ្ទាត់អនុលោមភាព ការផ្តល់អាជ្ញាប័ណ្ណជូនឈើផលិត និងផលិតផលឈើស្របច្បាប់សម្រាប់នាំចេញ និងការធ្វើសវនកម្មឯករាជ្យលើប្រព័ន្ធធានាភាពស្របច្បាប់ (LAS) ដើម្បីធានាឱ្យបានថាប្រព័ន្ធនេះត្រូវបានអនុវត្តយ៉ាងពេញលេញ។ |
| **ចំពោះព័ត៌មានបន្ថែម** | EFI. 2012. The elements of voluntary partnership agreements [Online Resource]. Joensuu, Finland, European Forestry Institute. http://www.euflegt.efi.int/portal/home/vpas/the_elements/ |
| **ឯកសារដទៃទៀតដែលអាចមានប្រយោជន៍** | A4.8, B4.1, C2.6, D2.3 |

កំណត់សម្គាល់



# ឧបសម្ព័ន្ធ

## វិធីប្រើប្រាស់សញ្ញាសម្គាល់

**កម្រិត និងគុណភាពនៃព័ត៌មាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**

កម្រិត និងគុណភាពព័ត៌មានដែលមានស្រាប់ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ ដែលឧបករណ៍នេះមានភាពសមស្រប។ ស្លឹមួយជាកម្រិតទាប (មានន័យថា មិនចាំបាច់មានព័ត៌មានច្រើនឡើយ និងមានការរួមបញ្ចូលភាគីពាក់ព័ន្ធដើម្បីប្រើប្រាស់ឧបករណ៍នេះ) ស្លឹបួនគឺជាកម្រិតខ្ពស់ (មានន័យថាចាំបាច់ត្រូវមានព័ត៌មានសម្បូណ៌បែបហើយមានការចូលរួមរបស់ភាគីពាក់ព័ន្ធដើម្បីប្រើឧបករណ៍នេះ)។

**តម្រូវការធនធាន**

បរិមាណពេលវេលា ប្រាក់កាស និងជំនាញចាំបាច់ដើម្បីធ្វើឱ្យឧបករណ៍នេះដំណើរការបាន។ ដើមឈើមួយដើម គឺបរិមាណតិច ដើមឈើបួនដើម គឺបរិមាណច្រើន។

# ឧបសម្ព័ន្ធ ១៖ ឧបករណ៍ស៊ីជម្រៅ

ឧបករណ៍មួយចំនួនមានប្រយោជន៍ និងអាចសម្របតាមបរិបទខុសគ្នាជាច្រើននៃអភិបាលកិច្ចលើការកាន់កាប់ព្រៃឈើ។ ឧបករណ៍ទាំងនោះអាចជួយបំភ្លឺ និងធានាបានកាន់តែប្រសើរនូវសិទ្ធិ ឬកសាងសមត្ថភាពនៅទីកន្លែង ដែលមានតម្រូវការពិតប្រាកដ ឬមួយធ្វើឱ្យអ្នកធ្វើសេចក្ដីសម្រេចទទួលខុសត្រូវ។ ផ្នែកនេះរំលេចនូវការជ្រើសរើសឧបករណ៍ទាំងនេះកាន់តែស៊ីជម្រៅ ជាងដែលអាចទៅរួចនៅក្នុងផ្នែកទាំងបួនពីខាងដើម។ ឧបករណ៍ទាំងនេះបាន បង្ហាញឱ្យឃើញថា ជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្ដែងមានន័យថា គេបានសាកល្បង និង អនុវត្ត ហើយទទួលបានលទ្ធផលល្អ។ ខណៈដែលឧបករណ៍នីមួយៗនៃឧបករណ៍ស៊ីជម្រៅដូចបង្ហាញខាងក្រោមដែលបានសង្ខេបពីមុនហើយនោះគោលបំណងគឺ ផ្ដល់ចំណេះដឹង ចំណេះធ្វើ ដែលអាចអនុវត្តបានដើម្បីឱ្យលោកអ្នក មិនគ្រាន់តែដឹងថាឧបករណ៍មួយអាចមានប្រយោជន៍ដូចសេចក្ដីសង្ខេបនៅក្នុងផ្នែកមុនប៉ុណ្ណោះទេ ប៉ុន្តែលោកអ្នកក៏យល់អំពីរបៀបប្រើប្រាស់ឧបករណ៍នោះឱ្យមានប្រសិទ្ធភាពផងដែរ។

| **ការសិក្សាវាយតម្លៃរហ័សអំពីសិទ្ធិកាន់កាប់ដីធ្លី ( RaTA )** | |
|---|---|
| **នេះជាអ្វី?** | វិធីសាស្ត្រមួយសម្រាប់ពិនិត្យមើលការដណ្ដើមគ្នាកាន់កាប់ដីធ្លី និងព្រៃឈើ។ វិធីសាស្ត្រនេះទទួលស្គាល់ថាតួអង្គផ្សេងគ្នាមានសិទ្ធិ និងអំណាចខុសគ្នា ហើយការដណ្ដើមគ្នាកាន់កាប់នេះច្រើនតែជាប់ទាក់ទិនជាមួយការដណ្ដើម ឬការផ្លាស់ប្ដូរគោលនយោបាយកាន់កាប់ដីធ្លីដែលបានបង្កើតឡើងនៅក្នុងអំឡុងពេលខុសៗគ្នាកន្លងមក។ វិធីនេះមានប្រភពចេញមកពីឧបករណ៍អនុវត្តជាក់ស្ដែងដែលត្រូវបានបង្កើត ឡើងនៅទូទាំងប្រទេសឥណ្ឌូនេស៊ី នៅមជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក - ជាគម្រោងតំបន់អាស៊ីអាគ្នេយ៍ និងត្រូវបានប្រើដោយភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតប្រើក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | RaTA អាចផ្ដល់ប្រយោជន៍ច្រើន៖<br>• នៅពេលដែលមាន ឬអាចមានទំនាស់កើតឡើង និងមានការដណ្ដើមធនធានព្រៃឈើ និងដីធ្លី<br>• ក្នុងការឈ្វេងយល់អំពីមូលហេតុនៃវិវាទផ្ទៃក្នុង និងរវាងសហគមន៍<br>• នៅពេលដែលមានហានិភ័យដែលថាការទាមទារធនធានពីមុន ឬធនធានប្រពៃណីត្រូវបានដកចេញពីគោលនយោបាយ និងពីច្បាប់នានា<br>• ក្នុងការជូនដំណឹងអំពីកិច្ចប្រឹងប្រែងផ្លាស់ប្ដូរការចាត់ចែង សិទ្ធិកាន់កាប់ និងគោលនយោបាយ ឬដោះស្រាយវិវាទ<br>• ជាផ្នែកមួយនៃការវិភាគស្ថានភាពដើមក្នុងដំណាក់កាលដំបូងនៃគម្រោង REDD+<br>គេអាចកែតម្រូវឧបករណ៍នេះសម្រាប់អនុវត្តក្នុងទំហំតូចធំអាស្រ័យលើគោលបំណងនៃកិច្ចការដែលត្រូវធ្វើ។ |
| **នរណាខ្លះគប្បីប្រើឧបករណ៍នេះ?** | RaTA ពាក់ព័ន្ធជាមួយអ្នកធ្វើការក្នុងស្ថាប័នជាតិទទួលបន្ទុកទំនាស់ដីធ្លី ឬទំនាស់ធនធាន និងការដណ្ដើមគ្នាកាន់កាប់ ជាអាទិ៍ អ្នកជំនាញរបស់NGO ដែលបម្រើការផ្ទាល់នៅតាមមូលដ្ឋាន មន្ត្រីរដ្ឋាភិបាល និងទីប្រឹក្សាដែលបំពេញការងារលើបញ្ហាទំនាស់ដែលសិក្សាអំពីសិទ្ធិកាន់កាប់ ឬការលើកសំណើគោលនយោបាយដើម្បីកែកលម្អការកាន់កាប់។ |
| **ជំនាញនិងធនធានដែលត្រូវមាន** | ជំនាញដែលត្រូវមានគឺ៖<br>• ការពិនិត្យឯកសារ<br>• ការថតរូបពីលើអាកាស<br>• វិធីសាស្ត្រស្រាវជ្រាវបែបចូលរួម និងការស្រាវជ្រាវបែបគុណភាព<br>• ជំនាញសម្របសម្រួល ( ដើម្បីពិនិត្យមើលទស្សនៈអ្នកស្រុក និងឥទ្ធិពលនៃអំណាចមកដល់ការទាមទាររបស់ប្រជាជន ព្រមទាំងលទ្ធភាពប្រើប្រាស់ធនធាន<br>• គ្រប់គ្រងដំណើការពហុភាគីពាក់ព័ន្ធ និង/ឬការផ្លាស់ប្ដូរគោលនយោបាយ |

**XL A3.1**
ផ្នែកស៊ីជម្រៅនៃ A3.1

**តើគេអាចប្រើ RaTA យ៉ាងដូចម្តេច**

មានប្រាំមួយដំណាក់កាល៖

**ដំណាក់កាលទី១៖ ការគូសផែនទីបឋម**

ការងារកំណត់វិសាលភាពបឋមដើម្បីកំណត់កន្លែងដែលមាន ឬដែលអាចកើតមានការដណ្តើមកាន់កាប់ ឬទំនាស់។ ទិន្នន័យបន្ទាប់អាចមានប្រភពមកពីគេហទំព័រ សារព័ត៌មាន ឬរបាយការណ៍ផ្លូវការ ដែលគេអាចប្រើ និងវិភាគចំពោះវិវាទដែលកំពុងកើតឡើង។ រូបថតពីផ្កាយរណប ឬរូបថតពីអាកាសអាចផ្តល់ទិដ្ឋភាពទូទៅនៃការប្រើប្រាស់ជាចម្បងនូវដីធ្លី ឬធនធាននៅទីកន្លែងនោះក្នុងទ្រង់ទ្រាយធំ។ ការគូសផែនទីដែលមានការចូលរួម (អានឧបករណ៍ A3.2) នឹងអាចបញ្ចូលនូវទស្សនៈរបស់អ្នករស់នៅក្នុងតំបន់ និងការយល់ដឹងអំពីស្ថាប័នមូលដ្ឋានទៅក្នុងការវាយតម្លៃនេះ។

**ដំណាក់កាលទី២៖ វិមាត្រនៃការដណ្តើមកាន់កាប់**

នេះគឺជាការវិភាគអំពីការដណ្តើមកាន់កាប់របស់ប្រជាជនចំពោះការទទួលបានឬការប្រើប្រាស់ធនធាន និងសារៈសំខាន់ដែលតួអង្គម្នាក់ៗផ្តល់ ចំណែករបស់ពួកគេក្នុងធនធានទាំងនេះ។ ចំណុចនេះរួមមាន ការវិភាគអំពីផលប្រយោជន៍ ប៉ុន្តែក៏រួមទាំងទស្សនៈ និងអារម្មណ៍របស់ពួកគេ ហើយនិងទំនាក់ទំនងរវាងគូភាគីប្រជែងគ្នាផងដែរ។ កិច្ចការទាំងនេះមួយចំនួនអាចសម្រេចបាន តាមរយៈការពិនិត្យមើលឡើងវិញនូវទិន្នន័យបន្ទាប់ គិតទាំងសាវតារនៃការប្រជែងទាមទារផងដែរ។

**ដំណាក់កាលទី៣៖ ការវិភាគតួរអង្គ**

កំណត់អត្តសញ្ញាណកម្មតួអង្គ(បុគ្គល តំណាងក្រុម ឬរដ្ឋាភិបាល) នៅក្នុងការប្រជែងទាមទារសិទ្ធិ។ ជំហានដំបូងត្រូវកំណត់រកតួអង្គសំខាន់ៗដែលមានចំណែកស្របច្បាប់នៅក្នុងទំនាស់។ ជំហានបន្ទាប់គឺរកមើលផលប្រយោជន៍របស់តួអង្គ និងឥទ្ធិពលនៃផលប្រយោជន៍របស់ពួកគេអំពីដីធ្លី និងធនធានមកលើទំនាស់។ ជំហានទីបីត្រូវការឈ្វេងយល់ទំនាក់ទំនងរវាង តួអង្គ និងការស្រាវជ្រាវកត្តាពាក់ព័ន្ធក្នុងទំនាស់ដោយគិតទាំងការយល់ឃើញអំពីសិទ្ធិរបស់អ្នកដទៃផងដែរ។ ទីបួន និងជាជំហានចុងក្រោយគឺវាយតម្លៃកម្លាំង និងឥទ្ធិពលរបស់តួអង្គផ្សេងគ្នា និងសក្តានុពលមុខងាររបស់ពួកគេក្នុងការដោះស្រាយទំនាស់ដីធ្លី (ចំពោះសេចក្តីពណ៌នាលម្អិតនៃការវិភាគកម្លាំងរបស់ភាគីពាក់ព័ន្ធសូមអានឧបករណ៍ XL A4.6)។

**ដំណាក់កាលទី៤៖ ការវាយតម្លៃ**

ការងារនេះបង្កើតបានជាចំណុចស្នូលនៃការវិភាគ។ តួអង្គសំខាន់ៗ (ចាប់ពីដំណាក់កាលទី៣ ដូចបានបញ្ជាក់ខាងលើ) ត្រូវបានសម្ភាសអំពីការទាមទារតាមការយល់ឃើញរបស់ពួកគេ និងតាមច្បាប់អំពីសិទ្ធិចំពោះដីធ្លី និងធនធាននានា។ ឧបករណ៍ដែលមានការចូលរួមត្រូវបានប្រើប្រាស់ ដូចជាកិច្ចសម្ភាសន៍ដែលបានរៀបចំកម្រងសំណួរជាមុន ការធ្វើការងារកសាងផែនទីដែលមានការចូលរួម(អានឧបករណ៍ A3.2) និងការកំណត់ពេលវេលាអនុវត្ត។ គេអាចប្រើតារាងម៉ាទ្រីសដើម្បីសង្ខេប និងប្រៀបធៀបការទាមទាររបស់តួអង្គមូលដ្ឋាននៃការទាមទារទាំងនេះ ព្រមទាំងឥទ្ធិពលខាងក្រៅ និងខាងក្នុងដែលបណ្តាលឱ្យតួអង្គធ្វើការទាមទារ។

**ដំណាក់កាលទី៥៖ ការវិភាគគោលនយោបាយ**

ការវាយតម្លៃច្បាប់ និងគោលនយោបាយផ្សេងៗដែលទាក់ទងជាមួយបញ្ហាកាន់កាប់ ការវិភាគចំណុចមិនត្រូវគ្នា កង្វះខាត និងភាពប្រាកដប្រជានៅក្នុងច្បាប់ភូមិបាល គោលនយោបាយ និងរបបនានារបស់សាមីប្រទេស។ សំខាន់ ការវិភាគត្រូវទទួលស្គាល់ថាគោលនយោបាយជាលាយលក្ខណ៍អក្សរអាចខុសពីការអនុវត្តគោលនយោបាយ។ ទិដ្ឋភាពនានានៃការវិភាគគោលនយោបាយរួមមាន៖

- ការវិភាគខ្លឹមសារ-ខ្លឹមសារនៃសេចក្តីប្រកាសគោលនយោបាយ និងច្បាប់
- ការវិភាគសាវតារ - របៀបដែលសាវតារមានទម្ងន់មកលើគោលនយោ-បាយ
- ការវិភាគដំណើរការ - របៀបដែលប្រព័ន្ធនយោបាយមានឥទ្ធិពលមកលើគោលនយោបាយ
- ការវាយតម្លៃ - សង្គតិភាពរវាងគោលនយោបាយ និងតថភាពជាក់ស្តែង និងឥទ្ធិពលនៃគោលនយោបាយមកលើផែនការនានាដែលបានគ្រោងទុក។

**ដំណាក់កាលទី៦៖ ជម្រើសគោលនយោបាយ**

រកមើលឱកាសដើម្បីប្រើប្រាស់របកគំហើញនៃជំហានទី១-៥ ដើម្បីដោះស្រាយការទាមទារដណ្តើមគ្នាកាន់កាប់ តាមរយៈការធ្វើកំណែទម្រង់គោលនយោបាយ និងច្បាប់ការប្រើប្រាស់តុលាការ និងគណៈកម្មការទទួល និងដោះស្រាយបណ្តឹងទាមទារ ក៏ដូចជាប្រើប្រាស់ដំណើរការមិនមែនច្បាប់ ដូចជាដំណោះស្រាយវិវាទតាមយន្តការបែបផ្សេង និងយន្តការដែលមានមូលដ្ឋាននៅសហគមន៍។

| | |
|---|---|
| **ព្រំដែននិងកំណត់សម្គាល់ដី** | ការទាមទារធនធានដីធ្លី និងព្រៃឈើរបស់ប្រជាជនស្ថិតក្រោមឥទ្ធិពលគោលនយោបាយ ច្បាប់ និងសិទ្ធិប្រពៃណី ប៉ុន្តែក៏ស្ថិតក្រោមឥទ្ធិពលអំណាចផងដែរ។ នៅពេលណាដែលភាគីពាក់ព័ន្ធមានអំណាចកាន់តែខ្លាំង ពួកគេនឹងមានលទ្ធភាពពង្រីកឥទ្ធិពលកាន់តែខ្លាំងទៅលើរបៀបបែងចែកសិទ្ធិ របៀបរៀបចំគោលនយោបាយ និងរបៀបដោះស្រាយទំនាស់។ ដំណើរការនៃការវាយតម្លៃនេះតម្រូវឱ្យក្រុមស្រាវជ្រាវពិចារណាអំពីអំណាច និងឥទ្ធិពលរបស់វាទាំងស្រុង(អានឧបករណ៍ XL A4.6 អំពីការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធ)។ |
| **ព័ត៌មានបន្ថែម** | ICRAF. Rapid Land Tenure Assessment (RaTA): a tool for identifying the nature of land tenure conflicts [Online Resource]. http://www.worldagroforestrycentre. org/Sea/Projects/tulsea2/node/19 |

## ការគូសផែនទីដែលមានការចូលរួមនៃសិទ្ធិកាន់កាប់ព្រៃឈើ

**XL A3.2**
ផ្នែកស៊ីជម្រៅនៃ A3.2

| | |
|---|---|
| **នេះជាអ្វី?** | ការគូសផែនទី មានការពាក់ព័ន្ធទៅនឹងមានការបង្កើតផែនទីគំនូររូបភាពជាក់ស្តែងពីសំណាក់សហគមន៍មូលដ្ឋាន ដោយចងក្រងលក្ខណៈសម្គាល់សំខាន់ៗនៃបរិស្ថានក្នុងតំបន់តាមទស្សនៈរបស់ពួកគេ។ ដំណើរការនៃការបង្កើតផែនទី និងផលិតផលផែនទីដែលទទួលបាន សុទ្ធតែព្យាយាមបង្ហាញឱ្យឃើញអំពីចំណងទាក់ទងគ្នារវាងដីធនធានធម្មជាតិ និងសហគមន៍មូលដ្ឋាន។<br>គោលការណ៍រួមនៃការងារកសាងផែនទីដែលមានការចូលរួមនេះគឺសមត្ថកិច្ច និងការត្រួតពិនិត្យលើការសម្រេចចិត្ត ត្រូវបានបង្វែរជូនទៅសហគមន៍ ដើម្បីឱ្យគេអាចដឹកនាំដំណើរការរៀបចំផែនទី និងការប្រើប្រាស់ផែនទី។ គេក៏អាចហៅការណ៍នេះថា ការកសាងផែនទីដែលមានការចូលរួម ការកសាងផែនទីសហគមន៍ ឬការកសាងផែនទីជនជាតិដើមភាគតិច។ |
| **តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** | មានមូលហេតុផ្សេងៗដើម្បីប្រើការគូសផែនទីដោយមានការចូលរួម៖<br>• ជួយសហគមន៍ឱ្យបញ្ជាក់ច្បាស់ និងផ្តល់ព័ត៌មានអំពីទីតាំងទៅកាន់ទីភ្នាក់ងារក្រៅមូលដ្ឋានរបស់ពួកគេ<br>• អនុញ្ញាតឱ្យសហគមន៍កត់ត្រា និងរក្សាទុកចំណេះដឹងនៅថ្នាក់មូលដ្ឋានរបស់ពួកគេ<br>• ជួយសហគមន៍ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធាន<br>• បង្កលក្ខណៈឱ្យសហគមន៍ជំរុញឱ្យមានការផ្លាស់ប្តូរ<br>• បង្កើនសមត្ថភាពនៅក្នុងសហគមន៍<br>• ដោះស្រាយទំនាស់ទាក់ទងនឹងធនធានធម្មជាតិ |
| **នរណាខ្លះគប្បីប្រើឧបករណ៍នេះ?** | គេអាចធ្វើកិច្ចការគូសផែនទីដែលមានការចូលរួម និងដែលសម្របសម្រួលដោយក្រុមបុគ្គលិកនៃនាយកដ្ឋានរុក្ខាប្រមាញ់ អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក ឬទីប្រឹក្សា។ គេឃើញកិច្ចការនេះត្រូវបានក្រុមជនជាតិដើមភាគតិចប្រើប្រាស់ធ្វើជាឧបករណ៍មួយក្នុងការចងក្រងឯកសារកាន់តែច្រើនឡើងហើយជំរុញឱ្យមានការគាំទ្រសិទ្ធរបស់ពួកគេចំពោះដីធ្លី និងធនធានធម្មជាតិ។<br>គេអាចប្រើប្រាស់ការគូសផែនទីដោយមានការចូលរួមជាផ្នែកមួយនៃដំណើរការវាយតម្លៃរបស់ REDD+ លើសង្គម និងបរិស្ថាន។ កម្មវិធីគាំទ្រ REDD+ ផ្តល់អនុសាសន៍ថា ដំណើរការដែលមានការចូលរួមត្រូវបានបង្កើតឡើងដើម្បីចុះបញ្ជីសារពើភណ្ឌព្រមទាំងគូសផែនទីដី ដែនដី ការកាន់កាប់ធនធាន និងការប្រើប្រាស់តាមច្បាប់និងតាមប្រពៃណីព្រមទាំង សិទ្ធិទទួលបានការប្រើប្រាស់ និងគ្រប់គ្រងទាក់ទងជាមួយនឹងកម្មវិធីនេះ។ ការគូសផែនទីដែលមានការចូលរួមក៏ជាជំណាក់កាលសំខាន់មួយ ក្នុងការបង្កើតការយល់ព្រមជាមុនដោយស្ម័គ្រចិត្តសម្រាប់ការផ្តួចផ្តើមនានានៃការវិនិយោគ។ |
| **ជំនាញនិងធនធានដែលត្រូវមាន** | ក្រុមអនុវត្តការគូសផែនទីដែលមានការចូលរួមត្រូវមានជំនាញច្បាស់លាស់អំពី៖<br>• វិធីសាស្ត្រដែលមានការចូលរួម<br>• ការសម្របសម្រួលដើម្បីធានាឱ្យសហគមន៍បានចូលរួមពេញលេញនិងត្រឹមត្រូវ<br>• បច្ចេកទេសគូសផែនទី ប្រសិនបើប្រើ GIS ឬប្រើកម្មវិធីកុំព្យូទ័រផ្សេងទៀត<br>ដំណើរការនៃការគូសផែនទីអាចចាប់ផ្តើមជាមួយការចំណាយតិច តម្រូវការលើផ្នែកសម្ភារតិចតួចសម្រាប់ចាប់ផ្តើមសកម្មភាពដូចជាក្រដាស និងប៊ិចរហូតដល់ការប្រើបច្ចេកវិទ្យាទំនើប ចំណាយខ្ពស់លើធាតុចូលដែលត្រូវការក្នុងដំណើរការគូសផែនទីដូចជាពាក់ព័ន្ធនឹងប្រព័ន្ធ GIS ដែលតែងតែមានតម្លៃថ្លៃ និងត្រូវមានជំនាញ និងពេលវេលាពីក្រុមអ្នកជំនាញ។ |

| | |
|---|---|
| **តើគេអាចប្រើ RaTA យ៉ាងដូចម្តេច** | ការគូសផែនទីដែលមានការចូលរួមចែកចេញជាដំណាក់កាលសំខាន់ៗចំនួនប្រាំមួយ៖<br>**សំណាក់កាលទី១៖ ចូលរួមជាមួយសហគមន៍ដើម្បីត្រៀមលក្ខណៈក្នុងការគូសផែនទី**<br>ចែករំលែកព័ត៌មានជាមួយសហគមន៍អំពីការគូសផែនទីដែលមានការចូលរួមក្នុងកិច្ចប្រជុំសហគមន៍។ ការចែករំលែកនេះគប្បីរួមមានឧបករណ៍សម្រាប់ប្រើប្រាស់ ដំណើរការ វិធីប្រើប្រាស់ផែនទី រួមជាមួយហានិភ័យពាក់ព័ន្ធផ្សេងៗនៅក្នុងដំណើរការដែលសហគមន៍គួរតែបានដឹង (អាន Limiations and cautionary notes)។ ការងារនេះអាចធ្វើឡើង តាមរយៈកិច្ចប្រជុំសហគមន៍។ គប្បីយកចិត្តទុកដាក់ក្នុងការកំណត់អត្តសញ្ញាណក្រុមពលរដ្ឋដែលមិនត្រូវបានគេគិតគូរ(ក្រីក្រ) ដែលមានតម្រូវការ ជាក់លាក់ហើយគួរឱ្យពួកគេបានចូលរួមក្នុងដំណាក់កាលរៀបចំ។<br>**ដំណាក់កាលទី២៖ កំណត់គោលបំណងនៃផែនទី**<br>ការឈានទៅរកការឯកភាពចំពោះគោលបំណងនៃផែនទីតម្រូវឱ្យមានការសម្របសម្រួលដោយប្រុងប្រយ័ត្ន ដើម្បីឱ្យប្រាកដថាមានសមាជិកសហគមន៍ជាច្រើនអ្នកបានចូលរួម ហើយពួកគេឯកភាពលើដំណើរការនៃការគូសផែនទី។ នេះក៏ជាជំហានមួយសំខាន់ផងដែរក្នុងការបង្កលក្ខណៈឱ្យសមាជិកសហគមន៍គ្រប់គ្រងលើដំណើរការនេះ។ ដើម្បីជួយកំណត់គោលបំណងនៃការបង្កើតផែនទី គេអាចលើកសំណួរដូចខាងក្រោមនៅក្នុងកិច្ចប្រជុំសហគមន៍៖<br>• ហេតុអ្វីបានជាយើងចង់បង្កើតផែនទី?<br>• តើយើងគិតថានឹងយកផែនទីនោះទៅបង្ហាញនរណា?<br>• តើបញ្ហាសំខាន់មួយចំនួនដែលទាក់ទងនឹងដីធ្លី និងធនធានមានអ្វីខ្លះ?<br>• ក្នុងរយៈពេលខ្លី តើយើងអាចប្រើប្រាស់ផែនទីសម្រាប់ធ្វើអ្វី?<br>• ក្នុងរយៈពេលវែង តើយើងអាចប្រើប្រាស់ផែនទីសម្រាប់ធ្វើអ្វី?<br>• តើមានមូលហេតុដែលគេកំណត់ជាមុនៗពេលបង្កើតផែនទីដែរឬទេ?<br>នៅពេលដែលមានការព្រមព្រៀងរួចហើយនោះ សមាជិកសហគមន៍អាចសម្រេចចិត្តថាត្រូវប្រមូលព័ត៌មានអ្វីខ្លះដើម្បីឆ្លើយតបនឹងគោលបំណងរបស់ពួកគេ។<br>**ដំណាក់កាលទី៣៖ ការប្រមូលព័ត៌មាន**<br>របៀបបញ្ចប់ដំណាក់កាលនេះអាស្រ័យលើវិធីសាស្ត្រគូសផែនទីជាក់លាក់និងអាស្រ័យលើបច្ចេកទេសគាំទ្រ។ ការកសាងសមត្ថភាពគឺជាផ្នែកសំខាន់មួយនៃការគូសផែនទីដែលមានការចូលរួម ខណៈដែលសមាជិកសហគមន៍ទាំងអស់ដែលមានចំណាប់អារម្មណ៍រៀនពីរបៀបអានផែនទី និងការរៀនសូត្រខ្លះអំពីប្រព័ន្ធកំណត់ទីតាំងសាកល (GPS), GIS, ផែនទីឋានលេខា និងការផ្តុំព័ត៌មានសហគមន៍បញ្ចូលគ្នាជាមួយផែនទីគោលតាមការចាំបាច់។ គេអាចប្រមូលព័ត៌មានតាមរយៈដំណើរការចូលរួមបែបប្រពៃណីដូចជា ការដើរកាត់ទទឹង និងការពិភាក្សាជាក្រុមជាមួយអ្នកដឹងសាវតារពាក់ព័ន្ធ(អាន 'ព័ត៌មានបន្ថែម' ខាងក្រោម)។ យកល្អគប្បីបែងចែកសហគមន៍ទៅជាក្រុមសង្គមផ្សេងគ្នាដើម្បីធ្វើ យ៉ាងណាឱ្យទស្សនៈផ្សេងគ្នាត្រូវបានដាក់បញ្ចូល។ បន្ទាប់មកសហគមន៍ (រួមជាមួយអ្នកសម្របសម្រួល) ត្រូវប្រមូលព័ត៌មាននេះយកមកពិចារណាថាត្រឹមត្រូវឬយ៉ាងណាជាមួយគ្នានេះដែរដោះស្រាយព័ត៌មានដែលមិនត្រូវគ្នា ខណៈពេលទទួលស្គាល់អំពីភាពខុសគ្នា។<br>**ដំណាក់កាលទី៤៖ ការកសាងផែនទី**<br>ព័ត៌មានលម្អិតជាក់លាក់នៃដំណាក់កាលនេះអាស្រ័យលើវិធីសាស្ត្រដែលបានយកមកប្រើប្រាស់(អាន 'ព័ត៌មានបន្ថែម')។ សំខាន់គឺសមាជិកសហគមន៍ទាំងអស់ឯកភាពគ្នា និងយល់ដឹងអំពីនិមិត្តសញ្ញា ឬចំណងជើងដែលគេតំណាងលក្ខណៈរូបវន្តផ្សេងគ្នា ការប្រើប្រាស់ ការទាមទារធនធាន។ គេអាចផ្ទៀងផ្ទាត់ជាមួយ ឬបន្ថែមលើផែនទីលំហ (ប្រសិនបើមាន)។ ចូរយកចិត្តទុកដាក់នៅពេលកំណត់ព្រំប្រទល់ ឬរកមើលការទាមទាររបស់ប្រជាជនចំពោះធនធានណាមួយ ខណៈដែលតាមពិតធនធាននោះត្រូវបានគេប្រជែងគ្នា ជាធនធានដែលគ្មានការប្រកាសជាសាធារណៈ ធនធានត្រួតគ្នា និងគនគ្នា។ បរិធាន GIS ឬសូហ្វវែរ ដូចជា Google Maps ឬ Google Earth អាចយកមកប្រើមកផ្តុំព័ត៌មានប្រភេទផ្សេងគ្នាអំពីសិទ្ធិបច្ចុប្បន្ន និងសិទ្ធិកាលពីមុនរបស់ប្រជាជន ឬតំបន់ទំនាស់ (ដែលអាចតម្រូវឱ្យមានជំនួយពីអ្នកជំនាញ)។<br>**ដំណាក់កាលទី៥៖ ការវិភាគ និងការវាយតម្លៃព័ត៌មាន**<br>ដំណាក់កាលនេះគឺជាការប្រមូលអ្នកពាក់ព័ន្ធក្នុងដំណើរការនេះឱ្យពិនិត្យមើលភាពត្រឹមត្រូវ ភាពពេញលេញ និងភាពទាក់ទងនៃព័ត៌មាន។<br>**ដំណាក់កាលទី៦៖ ការប្រើប្រាស់ និងការបញ្ជូនព័ត៌មាន**<br>ដំណាក់កាលនេះនឹងប្រែប្រួលទៅតាមបំណងនៃកិច្ចការកសាងផែនទី។ ទោះជាយ៉ាងណាក្តី សំខាន់គឺថាព័ត៌មាន និងផែនទីនោះត្រូវបានរក្សាទុកជាសម្បត្តិរបស់សហគមន៍ ដែលនឹងត្រូវយកមកប្រើប្រាស់តាមកាលកំណត់ដែលពួកគេយល់ថាចាំបាច់។ ផែនទីនោះមិនអាចដោះស្រាយបានបញ្ហាដែលទាក់ទងនឹងសិទ្ធិកាន់កាប់ឡើយ ប៉ុន្តែគឺជាឧបករណ៍សំខាន់មួយជាផ្នែកមួយនៃផែនការធំក្នុងការដោះស្រាយវិវាទ ឬចូលរួមក្នុងការតស៊ូមតិជុំវិញសិទ្ធិស្តីពីការកាប់កាប់ដីធ្លី។ |

**ព្រំដែន និង កំណត់សម្គាល់**

- ផែនទីគឺជាឧបករណ៍នយោបាយមួយដែលមានថាមពល និងអាចមានឥទ្ធិពលច្រើន។ ដំណើរការនៃការកសាងផែនទី ចាំបាច់ត្រូវតែសម្របសម្រួលដោយយកចិត្តទុកដាក់ និងដោយប្រុងប្រយ័ត្នដើម្បីឱ្យភាគីពាក់ព័ន្ធចូលរួមបានពេញលេញ និងធានាឱ្យមានការប្រើប្រាស់ព័ត៌មានដែលបានប្រមូលឱ្យបានត្រឹមត្រូវ។
- ផែនទីគ្រាន់តែបង្ហាញទិដ្ឋភាពក្នុងពេលផលិតតែប៉ុណ្ណោះ។ គេឃើញមានបញ្ហាដែលថាផែនទីទាំងនោះអាចជាផែនទី តំណាងរូបភាព "តែម៉្យាង" អំពីសិទ្ធិក្នុងការទទួល និងការប្រើប្រាស់ ប៉ុន្តែសភាពពិតអាចជារូបដែលមានចរិតរជូវកាលមានការប្រែប្រួល និងវិវត្ត។
- ការកសាងផែនទីដែលមានការចូលរួមអាចចងក្រងព័ត៌មានរសើបដែលអាចធ្វើឱ្យព័ត៌មាននោះ ឬសហគមន៍ពាក់ព័ន្ធនោះកាន់តែប្រឈមមុខខ្លាំងថែមទៀតចំពោះការកេងប្រវ័ញ្ច។ សំខាន់គឺសហគមន៍ត្រូវគ្រប់គ្រងព័ត៌មានដែលបានប្រមូល និងវិធីប្រើប្រាស់ព័ត៌មានទាំងនោះ។
- ខណៈដែលការប្រើប្រាស់ព័ត៌មានវិទ្យាផ្តល់អត្ថប្រយោជន៍ច្រើន ក៏ត្រូវការវិនិយោគច្រើនលើការបណ្តុះបណ្តាលដែលត្រូវចំណាយខ្ពស់ និងបណ្តាលឱ្យមានគ្រោះថ្នាក់ ដែលអ្នកអនុវត្តនឹងផ្តោតលើបច្ចេកវិទ្យាធ្វើឱ្យខូចប្រយោជន៍ដល់ការចូលរួម និងភាពជាម្ចាស់របស់សហគមន៍។ ការណ៍នេះក៏អាចបង្ការមិនឱ្យសហគមន៍ធ្វើបច្ចុប្បន្នភាព និងកែសម្រួលផែនទីរបស់ពួកគេបានឡើយ។

**ព័ត៌មានបន្ថែម**

IFAD. 2009. Good practices in participatory mapping. Rome, International Fund for Agricultural Development. http://www.ifad.org/pub/map/pm_web.pdf
Di Gessa, S. 2008. PAFID: participatory 3-D modelling in Mindanao – The Philippines. Participatory mapping as a tool for empowerment experiences and lessons learned from the ILC network, pp. 21–28. International Land Coalition. http://www.landcoalition.org/publications/participatory-mapping-tool-empowerment
Galudra, G. et al. 2010. RaTA: a rapid land tenure assessment manual for identifying the nature of land tenure conflicts Bogor, Indonesia, World Agroforestry Centre (ICRAF). http://www.worldagroforestrycentre.org/sea/ Publications/files/book/BK0143-10.PDF
FAO. 2009. Participatory land delimitation. An innovative development model based on securing rights acquired through customary and other forms of occupation, C. Tanner, P. De Wit & S. Norfolk. FAO Land Tenure Working Paper No. 13. Rome. ftp://ftp.fao.org/docrep/fao/012/ak546e/ak546e00.pdf
Rambaldi, G. et al. (eds.) Mapping for change. Participatory learning and action, 54. http://www.planotes.org/pla_backissues/54.html
Example: Minang, P. & McCall, M. 2006. Participatory GIS and local knowledge enhancement for community carbon forestry planning: an example from Cameroon. Participatory Learning and Action, 54: 85–91. http://pubs.iied.org/ G02954.html

## ការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធ

**XL A4.6**
ផ្នែកស៊ីជម្រៅនៃ A4.6

**នេះជាអ្វី?** ការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធគឺជាឧបករណ៍មួយ សម្រាប់យល់ដឹង ពីឥទ្ធិពលរបស់ប្រជាជនមកលើគោលនយោបាយ និងមកលើស្ថាប័ននិងផលប៉ះពាល់នៃគោលនយោបាយ និងស្ថាប័នមកលើប្រជាជន។ វាក៏មានសារប្រយោជន៍ក្នុងការកំណត់រកអ្នកឈ្នះ និង និងអ្នកចាញ់ ព្រមទាំងសម្រាប់ រំលេចចេញនូវការលំបាកដែលត្រូវប្រឈមមុខក្នុងការផ្លាស់ប្តូរ ឥរិយាបថ ការអភិវឌ្ឍសមត្ថភាព និងការដោះស្រាយវិសមភាព។ ដំណើរការនេះរួមមានការពិនិត្យមើលបញ្ហាផ្សេងៗជាអាទិ៍ តើនេះជាបញ្ហារបស់នរណា? នរណាទទួលផល?នរណាបាត់បង់ផលប្រយោជន៍? តើរវាងភាគីពាក់ព័ន្ធនានាពួកគេមានអំណាចខុសគ្នាលើចំណុចអ្វីខ្លះ? តើទំហំទាំងនោះមានឥទ្ធិពលអ្វីខ្លះ?

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** គេអាចប្រើការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធក្នុងបរិបទជាច្រើននៅកម្រិតផ្សេងគ្នា និងក្នុងគោលបំណងខុសគ្នា៖

- ដំណើរការយុទ្ធសាស្ត្ររយៈពេលវែង ក្នុងការពិនិត្យ កសាងកម្លាំងជំរុញ និងតាមដានដំណើរការណាមួយ
- ស្ថាប័ន ឬធុរកិច្ចក្នុងការពិនិត្យមើលសុខភាពរបស់អង្គការមួយ និងគ្រោងធ្វើការផ្លាស់ប្តូរ។
- គម្រោង ឬកម្មវិធីក្នុងការរៀបចំដឹកនាំ និងតាមដានគម្រោង
- សេចក្តីសម្រេចចិត្តជាក់លាក់ក្នុងការព្យាករណ៍ផលវិបាកនៃការសម្រេចចិត្ត និងផែនការដែលត្រូវដោះស្រាយបញ្ហាទាំងនោះ

ដោយឡែកចំពោះព្រៃឈើវិញ ដំណើរការនេះក៏អាចពិនិត្យមើលភាពស្របច្បាប់នៃការទាមទាររបស់ប្រជាជនចំពោះដីព្រៃ និងធនធាននានា កំណត់អត្តសញ្ញាណក្រុមមានអំណាច និងក្រុមអ្នកក្រីក្រ និងអាចជួយកំណត់អ្នកដែលគួរតែចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីសិទ្ធិកាន់កាប់ព្រៃឈើ និងកំណត់លើការគាំទ្រផ្សេងៗដែលពួកគេត្រូវការ។ ការតាមដាន និងការរាយការណ៍ពីការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធអាចក្លាយជាឧបករណ៍មួយសម្រាប់ធ្វើឱ្យមានការរីកចម្រើន។ តាមរយៈការជជែកជាទៀងទាត់ជាមួយភាគីពាក់ព័ន្ធ ស្ថាប័នមួយចំនួនបានយល់ដឹងមិនត្រឹមតែអំពីវិធីប្រសើរបំផុតក្នុងការរួមបញ្ចូលពួកគេទៅក្នុងដំណើរការ រៀបចំសេចក្តីសម្រេចចិត្តប៉ុណ្ណោះទេ ប៉ុន្តែក៏ក្លាយជាការដែលមានភាពទទួលខុសត្រូវកាន់តែច្រើនជាងមុនផងដែរ។

**នរណាខ្លះគប្បីប្រើឧបករណ៍នេះ?**

ការវិភាគអំណាចភាគីពាក់ព័ន្ធអាចអនុវត្តដោយវិជ្ជាជីវៈជាច្រើនក្នុងបរិបទផ្សេងៗគ្នា។ ឧទាហរណ៍ អ្នកវិភាគឯករាជ្យ និងអ្នកវាយតម្លៃ អ្នកធ្វើផែនការ ប្រធានគ្រប់គ្រងស្ថាប័ន ប្រធានសហគ្រាស អ្នកបញ្ចុះបញ្ចូល និងសកម្មជន ភាគីពាក់ព័ន្ធនីមួយៗ ក្រុមភាគីពាក់ព័ន្ធ ឬក្រុមភាគីពាក់ព័ន្ធចម្រុះអាចប្រើការវិភាគនេះ។

**ជំនាញ និង ធនធាន ដែលត្រូវមាន**

អាចត្រូវការជំនាញ និងឥរិយាបថជាក់លាក់ដើម្បីការវិភាគអំណាចភាគីពាក់ព័ន្ធ។ ជំនាញ និងឥរិយាបថមួយចំនួនគេអាចជួល ឬបណ្តុះបណ្តាលបាន ប៉ុន្តែជំនាញ និងឥរិយាបថផ្សេងទៀតអាចទទួលបានតែតាមរយៈបទពិសោធន៍តែប៉ុណ្ណោះ៖

- សម្រួលដំណើរការដោយភាគីពាក់ព័ន្ធច្រើន
- ការកសាងទំនុកចិត្ត និងការព្រមព្រៀងជាឯកច្ឆន្ទ និងការគ្រប់គ្រងទំនាស់
- ការដឹកនាំកិច្ចប្រជុំ និងសិក្ខាសាលា
- ការបង្កើតឱ្យមានការសោទរ តម្លាភាព និងការប្តេជ្ញាចិត្ត
- ភាពអត់ធ្មត់ - ត្រូវការពេលវេលាសម្រាប់ភាគីពាក់ព័ន្ធដើម្បីពិគ្រោះ យោបល់ជាមួយមណ្ឌលរបស់ខ្លួន។

**តើគេអាចប្រើការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធយ៉ាងដូចម្តេច**

វិធីខាងក្រោមនេះត្រូវបានដកស្រង់មកពីការអនុវត្តនៅក្នុងផ្នែកផ្សេងគ្នា ប៉ុន្តែត្រូវបានលើកឡើងជុំវិញប្រភេទនៃការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធដែលគេត្រូវការដើម្បីយល់ និងអាចផ្លាស់ប្តូរអភិបាលកិច្ចលើការកាន់កាប់ព្រៃឈើដែលមានការទទួលខុសត្រូវ

**ដំណាក់កាលទី១៖ បង្កើតគោលបំណង និងនីតិវិធីនៃការវិភាគ និងការយល់ដឹងបឋមចំពោះប្រព័ន្ធ**

បង្កើតការយល់ដឹងច្បាស់លាស់នូវគោលដៅ និងព្រំដែននៃការវិភាគយល់ដឹងអំពីបញ្ហាសំខាន់ៗដែលក្រុមសំខាន់ៗបានរកឃើញ រៀបចំដំណើរការនៃការគ្រប់គ្រង និងការចូលរួម។

**ដំណាក់កាលទី២៖ ការកំណត់រកភាគីពាក់ព័ន្ធសំខាន់ៗ**

មានវិធីជាច្រើនក្នុងការចាប់ផ្តើមកំណត់រកអ្នកពាក់ព័ន្ធ។ អ្នកដឹងព័ត៌មានសំខាន់ៗ កំណត់ត្រាលាយលក្ខណ៍អក្សរការជ្រើសរើស ការកំណត់ដោយភាគីពាក់ព័ន្ធខ្លួនឯង និងការផ្ទៀងផ្ទាត់ដោយភាគីពាក់ព័ន្ធដទៃគឺជាវិធីសាស្ត្រដ៏ល្អក្នុងការប្រើប្រាស់។ ត្រូវមានកិច្ចខិតខំប្រឹងប្រែងពិសេសក្នុងការរួមបញ្ចូលអ្នកគ្មានសំឡេង និងបង្កើតសុពលភាពនៃភាពជាតំណាង។ នៅក្នុងដំណាក់កាលដំបូងនេះអាចមានប្រយោជន៍ក្នុងការចាប់ផ្តើមបង្រួមបញ្ជីភាគីពាក់ព័ន្ធ និងកំណត់តែភាគីសំខាន់បំផុតក្នុងការចូលរួមក្នុងដំណើរការវិភាគជាបន្ត។ ជាមួយគ្នានេះ ក៏អាចមានប្រយោជន៍ក្នុងការចាត់ប្រភេទភាគីពាក់ព័ន្ធតាមភេទអាយុ សុខុមាលភាពនិង ទំនាក់ទំនងជាមួយព្រៃឈើក្នុងចំណោមកត្តាដទៃទៀត។

**ដំណាក់កាលទី៣៖ ស៊ើបអង្កេតផលប្រយោជន៍ ចរិតលក្ខណៈ និងកាលៈទេសៈរបស់ភាគីពាក់ព័ន្ធ**

នៅពេលដែលមានការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធហើយនោះ ចាំបាច់ត្រូវយល់ឱ្យបានកាន់តែច្បាស់នូវកង្វល់ ផលប្រយោជន៍ លក្ខណៈ និងកាលៈទេសៈរបស់ពួកគេ។ ក្នុងដំណាក់កាលនេះ សំខាន់គឺភាគីពាក់ព័ន្ធបង្ហាញពីកង្វល់ផ្ទាល់ខ្លួន។បញ្ជីសំណួរសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗអាចរួមមាន:

- តើភាគីពាក់ព័ន្ធមានបទពិសោធន៍ ឬការរំពឹងទុកអ្វីខ្លះអំពីគោលនយោបាយឬស្ថាប័ន?
- ចំពោះភាគីពាក់ព័ន្ធតើមាន ឬទំនងជាមានអត្ថប្រយោជន៍ និងការចំណាយអ្វីខ្លះ?
- តើអ្វីដែលជាអត្ថប្រយោជន៍របស់ភាគីពាក់ព័ន្ធដែលមានទំនាស់ជាមួយគោលដៅនៃគោលនយោបាយ ឬគោលដៅរបស់ស្ថាប័ន?
- តើភាគីពាក់ព័ន្ធបានប្រមូល ឬដែលមានឆន្ទៈក្នុងការប្រមូលធនធានធនធានអ្វីខ្លះ? បច្ចេកទេសពីការបំផុសគំនិតជាក្រុមដល់កិច្ចសម្ភាសន៍ដែលមានសំណួររៀបចំជាស្រេច រហូតដល់ការប្រមូលទិន្នន័យបន្ថែម ជួយក្នុងការអភិវឌ្ឍ និងចែករំលែកការយល់ដឹងនេះ។

**ដំណាក់កាលទី៤: កំណត់លំនាំ និងបរិបទនៃទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ**

ជំហាននេះមានគោលបំណងស្វែងរកទំនាក់ទំនងរវាងក្រុមអ្នកពាក់ព័ន្ធ និងលំនាំនៃជម្លោះ និងកិច្ចសហប្រតិបត្តិការបង្ហាញឱ្យឃើញចំណុចរួមឬជម្លោះដែលកំពុងកើតមាន និងសក្តានុពលនៃផ្លូវកណ្តាលរវាងចំណុចរួមនិងជម្លោះ (សូមមើល 'The Four Rs' ", tool A4.7) ។

**ដំណាក់កាលទី៥: វាយតម្លៃអំណាច និងសក្តានុពលរបស់ភាគីពាក់ព័ន្ធ**

ភាគីពាក់ព័ន្ធមានកម្រិតអំណាចខុសគ្នាជាខ្លាំងក្នុងការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ ឬស្ថាប័ន។ ពួកគេក៏មានសក្តានុពលផ្សេងគ្នាក្នុងការធ្វើឱ្យប៉ះពាល់ ឬទទួលរងផលប៉ះពាល់ពីគោលនយោបាយ និងស្ថាប័ននានា។

បញ្ជីសំណួរសម្រាប់វាយតម្លៃថាតើភាគីពាក់ព័ន្ធណាខ្លះមានអំណាច និង សក្តានុពល (ឬសារសំខាន់) លើផ្នែកគោលនយោបាយ ស្ថាប័ន ឬ ដំណើរការដែលមានបញ្ហាអាចរួមមាន៖

- តើនរណាពឹងផ្អែកលើនរណា?
- ភាគីពាក់ព័ន្ធណាខ្លះដែលត្រូវបានរៀបចំ? ធ្វើដូចម្តេចឱ្យស្ថាប័ននោះទទួលឥទ្ធិពល ឬត្រូវបានកសាង?
- នរណាជាអ្នកគ្រប់គ្រងលើធនធាន? នរណាជាអ្នកត្រួតពិនិត្យលើព័ត៌មាន?
- មានបញ្ហាណាខ្លះ ប៉ះពាល់ដល់អ្នកពាក់ព័ន្ធណាខ្លះដែលជាបញ្ហាអាទិភាពក្នុងការដោះស្រាយ ឬកាត់បន្ថយ?
- សេចក្តីត្រូវការផលប្រយោជន៍ និងក្តីរំពឹងរបស់ភាគីពាក់ព័ន្ធ គប្បីផ្តល់ការយកចិត្តទុកដាក់ជាអាទិភាពទៅនឹងគោលនយោបាយ ឬស្ថាប័នពាក់ព័ន្ធ?

ព័ត៌មានរួមអំពីអំណាច និងសក្តានុពលរបស់ភាគីពាក់ព័ន្ធអាចរួមបញ្ចូលគ្នាក្នុងតារាងមួយ ឬដ្យាក្រាមរួមមួយ។

**ដំណាក់កាលទី៦៖ ជម្រើសស្តីពីការវាយតម្លៃ និងប្រើប្រាស់របកគំហើញដើម្បីធ្វើឱ្យរីកចម្រើន**

ដើម្បីឱ្យមានប្រយោជន៍ ចាំបាច់ត្រូវបានសង្ខេបការវិភាគជំហានចំនួនប្រាំដំបូងក្នុងទម្រង់មួយដែលគេអាចមើលឃើញទាំងអស់គ្នានូវផលប្រយោជន៍និងបញ្ហានានារបស់អ្នកទាំងឡាយ។ គេអាចប្រើតារាងភាគីពាក់ព័ន្ធលក្ខណៈជាស៊េរីដើម្បីរៀបចំព័ត៌មានអំពីផលប្រយោជន៍ អំណាច ឥទ្ធិពល និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ឬក្រុមសំខាន់នីមួយៗ។ ការវាយតម្លៃ របៀបធ្វើឱ្យមានភាពរីកចម្រើនតម្រូវឱ្យទាញយកជម្រើសនានា ដែលបានបង្កើតតាមរយៈប្រាំជំហានដំបូង។ លទ្ធផលនៃការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធត្រូវដាក់បញ្ចូលនៅក្នុងសំណើផ្លាស់ប្តូរគោលនយោបាយ ស្ថាប័ននិងដំណើរការ និងនៅក្នុងការត្រួតពិនិត្យរបាយការណ៍ និងការពិនិត្យឡើងវិញ។

---

**ព្រំដែន និង កំណត់សម្គាល់**

ដំណើរការនេះគឺជាដំណើរការនយោបាយ។ ផលប្រយោជន៍របស់មនុស្សមួយចំនួនអាចត្រូវបានលាក់បាំង ឬផ្ទុយនឹងផលប្រយោជន៍របស់អង្គការរបស់ពួកគេ។ ប្រជាជនអាចមានហេតុផលផ្ទាល់ខ្លួន និង / ឬហេតុផលនយោបាយ ដើម្បីបំផ្លាញការរកឃើញនៃដំណើរការនេះ។

ផលប្រយោជន៍ និងរបៀបវារៈរបស់អ្នកញុះញង់ និងការដឹកនាំវិភាគចាំបាច់ត្រូវពន្យល់ប្រកបដោយតម្លាភាព និងសួរចម្លើយជាទៀងទាត់។ការធ្វើបែបនេះនឹងជួយក្នុងការកសាងទំនុកចិត្ត។

ខណៈពេលដែលការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធអាចបំភ្លឺឱ្យឃើញនូវផលប្រយោជន៍របស់ក្រុមប្រជាពលរដ្ឋដែលមិនត្រូវបានយកចិត្តទុកដាក់ការវិភាគនេះមិនអាចធានាពួកគេឱ្យមានតំណាងរឹងមាំឡើយ។ ត្រូវយកចិត្តទុកដាក់ក្នុងដំណើរការចាត់ថ្នាក់ភាគីពាក់ព័ន្ធតាមអំណាច និងសក្តានុពល។

---

**ព័ត៌មានបន្ថែម**

Mayers, J. 2005. Stakeholder power analysis. Power tools series. London, IIED. http://www.policy-powertools.org/Tools/Understanding/SPA.html

Grimble, R. 1998. Socioeconomic methodologies for natural resources research. Stakeholder methodologies in natural resource management. Greenwich, UK, Natural Resources Institute. http://www.nri.org/publications/bpg/bpg02.pdf

ODA. 1995. Guidance note on how to do stakeholder analysis of aid programmes. London, Social Development Department, Overseas Development Administration.

## XL B1.1
ផ្នែកស៊ីជម្រៅនៃ B1.1

## ការរៀបចំក្រុមអ្នកប្រើប្រាស់ព្រៃឈើដើម្បីចូលរួម

**នេះជាអ្វី?** ឧបករណ៍មួយដើម្បីជួយដល់អ្នកផលិតព្រៃឈើក្រីក្ររៀបចំដោយ ខ្លួនឯងក្នុងគោលបំណងដើម្បីទទួលបានការទទួលស្គាល់កាន់តែច្រើន។ គោលបំណងគឺថាជាមួយនឹងការរៀបចំបន្ថែម និងភាពស្របច្បាប់ អ្នករៀបចំគោលនយោបាយ និងស្ថាប័នពាក់ព័ន្ធក្នុងអភិបាលកិច្ចព្រៃឈើ ការគ្រប់គ្រង និងការអនុវត្តច្បាប់នឹងទទួលស្គាល់អង្គការព្រៃឈើតូចៗថាជាប្រតិបត្តិករស្របច្បាប់ និងដាក់បញ្ចូលពួកគេនៅក្នុងដំណើរការគ្រប់គ្រងគោលនយោបាយ និងព្រៃឈើ។

ឧបករណ៍នេះត្រូវបានរៀបចំឡើងដោយIIED ផ្អែកលើបទពិសោធន៍ និងមេរៀនបានមកពីការបង្កើត និងប្រតិបត្តិការ Budongo Sub-county Pitsawyers របស់នៅអ៊ូហ្គង់ដា។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** គោលបំណងនៅពីក្រោយឧបករណ៍នេះគឺបង្កើតអង្គការសហគមន៍ត្រូវបានទទួលស្គាល់ដែលត្រូវបានគេមើលឃើញថានឹងត្រូវចូលរួមដោយស្របច្បាប់ក្នុងអភិបាលកិច្ច និងការគ្រប់គ្រងព្រៃឈើ។ អ្នកផលិតព្រៃឈើក្រីក្រអាចប្រើប្រាស់ធនធាន ភាពជាដៃគូ និងទីផ្សារ ពុំនោះសោត ពួកគេមិនអាចមានលទ្ធភាពធ្វើបែបនេះឡើយ។

**នរណាប្រើប្រាស់ក្រុមនេះ** ការរៀបចំក្រុមអ្នកប្រើប្រាស់ព្រៃឈើដើម្បីចូលរួមត្រូវបានរៀបរៀងសម្រាប់អ្នកអភិវឌ្ឍន៍ដែលផ្តល់ការគាំទ្រដល់អ្នកផលិតឈើនៅមូលដ្ឋានដូចជា អ្នកអារឈើជាដើមឱ្យពួកគេរៀបចំខ្លួន និងចូលរួមដោយស្របច្បាប់ក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព។

**ជំនាញ និង ធនធាន ដែល ត្រូវការ** ជំនាញចាំបាច់ រួមមាន៖
- ជំនាញសម្របសម្រួល
- វិធីសាស្ត្រដែលមានការចូលរួម
- ជំនាញ និងបទពិសោធន៍អភិវឌ្ឍន៍ស្ថាប័ន
- គ្រប់គ្រងដំណើរការ និង/ឬការផ្លាស់ប្តូរគោលនយោបាយរបស់អ្នកពាក់ព័ន្ធចម្រុះភាគី

**របៀបដែលគេអាចប្រើវាបាន** មានដំណាក់កាលសំខាន់ៗចំនួនប្រាំ៖

**ដំណាក់កាលទី១៖ យល់ស្ថានភាពដែលកំពុងប្រឈមមុខចំពោះក្រុម និងសហគ្រាស**

គោលបំណងនៅក្នុងដំណាក់កាលនេះគឺការឈ្វេងយល់លក្ខណៈពិសេសនៃការអារឈើ បណ្តាបញ្ហាដែលក្រុមនេះជួបប្រទះហើយតើពួកគេត្រូវការការគាំទ្រអ្វី។

បុគ្គលដែលចូលរួមដំបូងត្រូវកំណត់អត្តសញ្ញាណ និងប្រវត្តិរបស់ក្រុមរបស់ពួកគេ។ ការយល់ដឹងអំពីមុខងារនៅក្នុងក្រុម នរណាជាអ្នកអនុវត្ត ហើយតើមានទំនាក់ទំនងនឹងគ្នាយ៉ាងណាមានសារសំខាន់។សំខាន់ក៏ត្រូវយល់ផងដែរថា តើក្រុមនោះមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះជីវភាពរស់នៅរបស់ប្រជាជន និងចំពោះបរិស្ថាន ហើយត្រូវគិតគូរអំពីវិធីសម្រេចចិត្ត និងអំពីរបៀបរៀបចំក្រុម (ប្រសិនបើមាន)។

**ដំណាក់កាលទី២៖ ពិភាក្សាអំពីចំណុចវិជ្ជមាន និងអវិជ្ជមានអី ការបង្កើតស្ថាប័នមួយ**

នៅពេលដែលបានកំណត់ឧបសគ្គរបស់ពលរដ្ឋក្រីក្រម្នាក់ៗហើយនោះមានការពិចារណាថាតើពួកគេ ក្នុងឋានៈជាក្រុមអាចនឹងចាប់យកឱកាសនានាដែរឬយ៉ាងណា។ ការណ៍នេះរួមមានការពិនិត្យមើលនូវអ្វីដែលស្ថាប័ននោះអាចសម្រេចបាន តើសមស្រប ឬអាចទៅរួចដែរឬទេ មានហានិភ័យអ្វីខ្លះ ហើយតើគប្បីរួមបញ្ចូល ឬបញ្ចេញនរណាខ្លះ។ គប្បីរៀបចំដំណើរការនៃការសម្រេចចិត្តសម្រាប់សមាជិកដែលមានសក្តានុពលទាំងឡាយ។

**ដំណាក់កាលទី៣៖ បង្កើតស្ថាប័ន**

ប្រសិនបើសម្រេចចិត្តថាត្រូវបង្កើត អ្នកបម្រុងក្លាយជាសមាជិកត្រូវសម្រេចចិត្តលើ បញ្ហាសំខាន់បំផុតសម្រាប់ការបង្កើតស្ថាប័ន។ សំខាន់សមាជិកបម្រុងក្លាយជាសមាជិកចូលរួមនៅក្នុងដំណើរការនេះ ដើម្បីឱ្យមានការឯកភាពគ្នាអំពីគោលការណ៍គ្រឹះ និងរចនាសម្ព័ន្ធនានាផ្នែកស្ថាប័ន។ អ្នកចូលរួមចាំបាច់ត្រូវកំណត់គោលដៅនិងសកម្មភាពរបស់ស្ថាប័ន ប្រភេទ និងលក្ខណៈវិនិច្ឆ័យសម្រាប់សមាជិកភាព ពោលគឺ នរណាខ្លះត្រូវចូលរួម នរណាខ្លះមិនត្រូវចូលរួមមុខងារ និងគោលការណ៍សម្រាប់ដំណើរការស្ថាប័ន បន្ថែមពីលើនេះត្រូវចាត់មុខងារ

នរណាធ្វើអ្វី ហេតុអ្វីបានជាត្រូវធ្វើកិច្ចការនោះ ហេតុអ្វីបានជាធ្វើបែបនេះ ពួកគេទទួលបានផលប្រយោជន៍ដោយខ្លួនឯង និងផលប្រយោជន៍សម្រាប់ស្ថាប័ន ហើយតើ មានអ្វីកើតឡើងប្រសិនបើពួកគេមិនធ្វើកិច្ចការនោះជាមួយនឹងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរកត់ត្រាចំណុចទាំងអស់នេះ។

**ដំណាក់កាលទី៤៖ ប្រតិបត្តិការស្ថាប័ន**

ប្រព័ន្ធប្រតិបត្តិការដែលមានលក្ខណៈអនុវត្តជាក់ស្តែងជួយឱ្យស្ថាប័នមានកម្មវត្ថុច្បាស់លាស់អំពីអ្វីដែលស្ថាប័នត្រូវសម្រេចឱ្យ និងវិធីអនុវត្ត ព្រមទាំងផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់គ្រប់គ្រងស្ថាប័ន។ ចាំបាច់ត្រូវមានប្រព័ន្ធសាមញ្ញនៅក្នុង៖

- ការកសាងផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រង ឧទាហរណ៍ ផែនការការងារប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ និងការផ្ទេរភារកិច្ច និងការទទួលខុសត្រូវទៅឱ្យអ្នកនៅក្នុងស្ថាប័ននោះ
- ការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជាការកាន់បញ្ជីគណនេយ្យ និងការបង្កើតគណនីក្រុមហ៊ុន
- ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ
- អភិវឌ្ឍ និងបណ្តុះបណ្តាលជំនាញដោយកំណត់ជំនាញដែលត្រូវការហើយនរណាអាចផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាលនេះ។ កិច្ចការនេះអាចមានប្រភពមកពីអង្គការមិនមែនរដ្ឋាភិបាលដទៃ ឬរុក្ខាប្រម៉ាញ់ស្រុក ឬពីមន្ទីរកសិកម្ម
- ការតាមដាន និងការវាយតម្លៃ គឺជាការតាមដានជាទៀងទាត់ដើម្បីជួយវាយតម្លៃពីការរីកចម្រើនក្នុងរយៈពេលវែង ឬក្រោយពីសម្រេចបានគោលដៅណាមួយ។

**ដំណាក់កាលទី៥: ចូលរួមក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព**

គោលបំណងសំខាន់មួយសម្រាប់រៀបចំជាក្រុមណាមួយគឺដើម្បីបានការទទួលស្គាល់អំពីភាពស្របច្បាប់។ បន្ទាប់ពីមានការទទួលស្គាល់រួចហើយនឹងអាចមានសក្តានុពលចូលរួមជាមួយអ្នកឯទៀតលើបញ្ហាកង្វល់ក្នុងឋានៈជាដៃគូដែលមានប្រសិទ្ធភាព។ ដំណាក់កាលនេះ រួមមាន៖

- កំណត់រកមើលជំនាញដែលត្រូវការចាំបាច់ (តើចំណងទាក់ទងណាដែលមានសារសំខាន់ ហើយចំណងទាក់ទងណាដែលត្រូវជៀសវាង)
- ចាប់ផ្តើមចរចាជាមួយដៃគូសក្តានុពល
- ទៅមុខក្នុងឋានៈជាដៃគូ

សំណួរគន្លឹះសម្រាប់វាយតម្លៃទំនាក់ទំនងជាមួយដៃគូគឺ៖

- តើស្ថាប័ននោះ និងដៃគូសម្រេចបានគោលដៅរបស់ពួកគេដែរ ឬទេ?
- តើមានទំនាក់ទំនងល្អដែរឬទេរវាងស្ថាប័ននោះនិងដៃគូរបស់ពួកគេ
- តើពួកគេប្រាស្រ័យទាក់ទងបានល្អដែរឬទេ? តើពួកគេមានកិច្ចប្រជុំទៀងទាត់ដែរឬទេ? តើពួកគេចាំបាច់ត្រូវតែប្រជុំទៀងទាត់ ឬយ៉ាងណា?
- តើស្ថាប័នយល់ថាពួកគេត្រូវបានត្រួតពិនិត្យពីសំណាក់ដៃគូដែរឬទេ? តើស្ថាប័ននោះក្លាយជាស្ថាប័នដែលពឹងផ្អែកលើដៃគូដែរឬទេ?

| | |
|---|---|
| **ព្រំដែន និង កំណត់សម្គាល់** | រឿងនេះតម្រូវឱ្យធ្វើកិច្ចការដោយប្រុងប្រយ័ត្នដើម្បីជួយដល់ក្រុមនានាដែលមិនត្រូវបានឱ្យចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗដែលមានផលប៉ះពាល់មកលើពួកគេឱ្យរៀបចំបានកាន់តែប្រសើរ និងចូលរួមនៅក្នុងការសម្រេចចិត្ត។ វាជាការសំខាន់ឱ្យមានការចង្អុលបង្ហាញពីដំបូងថាស្ថាប័ន និងការចូលរួមនេះអាចនាំមកនូវលទ្ធផលដើម្បីឱ្យអាចគ្រប់គ្រងបានគម្រោងការ និងការរំពឹងទុកដែលមានលក្ខណៈប្រាកដនិយម។ គោលបំណងរួមមានសារសំខាន់ ហើយសូម្បីតែជាមួយនឹងគោលបំណងរួមទាំងនេះក៏ដោយក៏ត្រូវដឹងថា នឹងមានការមិនពេញចិត្តពីខាងក្រៅ និងការបែកបាក់ផ្ទៃក្នុងហើយគួរតែគ្រោងជាមុនផងដែរ។ |
| **ព័ត៌មានបន្ថែម** | Krassowska, K. & Davidson, M. 2005. Organising pitsawyers to engage. Power Tools Series. Uganda, Budongo Community Development Organisation, and London, IIED. http://www.policy-powertools.org/Tools/Organising/OPE.html<br>Education and Training Unit. Community organisers toolbox [Online Resource]. Johannesburg. http://www.etu.org.za/toolbox/ |

**XL B2.4**
ផ្នែកស៊ីជម្រៅនៃ B2.4

## ការផ្តល់ប្រឹក្សាធ្វើការបណ្តើរអនុវត្តបណ្តើរនូវវិធីសាស្ត្រ ដែលមានការចូលរួមដល់មន្ត្រីរដ្ឋាភិបាល

**នេះជាអ្វី?** អ្នកផ្តល់ប្រឹក្សាមានគោលបំណងដើម្បីជួយបុគ្គលដើម្បីគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេដូច្នេះពួកគេអាចអភិវឌ្ឍជំនាញរបស់ពួកគេបង្កើនការអនុវត្តរបស់ពួកគេ និងការអភិវឌ្ឍសក្តានុពលរបស់ពួកគេ។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** វិធីសាស្ត្របង្រៀនមានប្រសិទ្ធភាពអាចនាំឱ្យមានការផ្លាស់ប្តូរយូរអង្វែងតាមរយៈ៖

- ការផ្លាស់ប្តូរឥរិយាបថ និងការប្រព្រឹត្តរបស់អ្នកដែលត្រូវបានផ្តល់ប្រឹក្សាតាមរយៈការទទួលបាន និងការប្រើប្រាស់ជំនាញថ្មីៗ
- ការបង្កលក្ខណៈឱ្យបុគ្គលអភិវឌ្ឍទំនុកចិត្តបន្ថែមទៀតក្នុងការអនុវត្ត
- ការលើកកម្ពស់ទំនាក់ទំនង និងការប្រាស្រ័យទាក់ទងក្នុងចំណោមបុគ្គលិក និងរវាងបុគ្គលិកព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀតដូចជាសហគមន៍មូលដ្ឋានជាដើម។

**នរណាប្រើប្រាស់ក្រុមនេះ** ការផ្តល់ប្រឹក្សាមានលក្ខណៈសមរម្យសម្រាប់ការប្រើប្រាស់ដោយស្ថាប័នឬក្រុមមនុស្សឆ្លងកាត់ដំណើរការផ្លាស់ប្តូរផ្នែកស្ថាប័ន។ ការផ្តល់ប្រឹក្សាអាចបំពេញបន្ថែម និងពង្រឹងទម្រង់ផ្សេងទៀតនៃការកសាងសមត្ថភាពដូចជាការបណ្តុះបណ្តាល និងអាចជួយឱ្យបុគ្គលផ្លាស់ប្តូរឥរិយាបថ ឬការប្រព្រឹត្តរបស់ពួកគេ។

ភាពជោគជ័យនៃកម្មវិធីផ្តល់ប្រឹក្សានេះពឹងផ្អែកលើជំនាញរបស់អ្នកផ្តល់ប្រឹក្សា ទំនាក់ទំនងរវាងអ្នកផ្តល់ប្រឹក្សា និងអ្នកទទួលការប្រឹក្សាហើយកម្រិតនៃការប្តេជ្ញាចិត្តរបស់ស្ថាប័ន និងបុគ្គលិកតាមរយៈដំណើរការផ្តល់ប្រឹក្សានេះ។

**ជំនាញនិងធនធានដែលត្រូវការ** អ្នកផ្តល់ប្រឹក្សាត្រូវមានឥរិយាបថ និងជំនាញទូលំទូលាយដើម្បីឱ្យមានប្រសិទ្ធភាព៖

- ជំនាញអនុវត្តជាក់ស្តែង និងបទពិសោធន៍ក្នុងបញ្ហានេះ
- សមត្ថភាពក្នុងការសម្របខ្លួន និងការប្រាស្រ័យទាក់ទងចំណេះដឹងរបស់ពួកគេអំពីប្រធានបទនេះតាមបែបមួយដែលពាក់ព័ន្ធទៅនឹងតម្រូវការពិសេសរបស់អ្នកទទួលការប្រឹក្សា
- សមត្ថភាពស្តាប់ និងសមត្ថភាពសាកសួរភាពចាប់អារម្មណ៍ខ្ពស់ ការយល់ចិត្ត និងការយល់ដឹង។

'ប្រធាននៃអ្នកផ្តល់ប្រឹក្សា' ម្នាក់សម្របសម្រួល និងត្រួតពិនិត្យដំណើរការទាំងមូល។ តួនាទីរបស់ពួកគេគឺដើម្បីធានាថាមានការប្តេជ្ញាចិត្តរបស់ស្ថាប័នចំពោះដំណើរការផ្តល់ប្រឹក្សា និងដើម្បីទទួលបានលទ្ធផលនៃដំណើរការនេះ ពោលគឺ ការផ្លាស់ប្តូរក្នុងការអនុវត្តរបស់បុគ្គលិក។

អ្នកតាមដានផ្តល់នូវការត្រួតពិនិត្យគុណភាព និងមុខងារលើទិដ្ឋភាពទូទៅចំពោះកម្មវិធីផ្តល់ប្រឹក្សា ដោយធានាថាទំនាក់ទំនងរវាង អ្នកផ្តល់ និងអ្នកទទួលប្រឹក្សាប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងសង្កេតឃើញពីរបៀបដែលអ្នកទទួលការប្រឹក្សាកំពុងប្រើឧបករណ៍និងវិធីសាស្ត្រក្នុងស្ថានភាពពិតជាក់ស្តែង។

ចាំបាច់ត្រូវមានទំនាក់ទំនងញឹកញាប់ជាបន្ត រវាងអ្នកផ្តល់ប្រឹក្សានិងអ្នកកំពុងទទួលការប្រឹក្សាសម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង។ អ្នកទាំងពីរ ត្រូវទុកពេលយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយខែសម្រាប់ទំនាក់ទំនងនេះ។ អង្គការ FAO ប៉ាន់ប្រមាណថាដំណើរការនេះតម្រូវឱ្យមានការប្តេជ្ញាចិត្តរយៈពេលវែងប្រហែលបីឆ្នាំដើម្បីធានាឱ្យបាននូវការអនុវត្តថ្មីៗទាំងនេះត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងវប្បធម៌ និងការអនុវត្តស្ថាប័នប្រកបដោយចីរភាព។ ប្រសិនបើធ្វើការជ្រើសរើសអ្នកផ្តល់ប្រឹក្សា និងទទួលការបណ្តុះបណ្តាលនៅក្នុងស្ថាប័ន (ជាជាងអ្នកផ្តល់ប្រឹក្សាដែលជួលពីខាងក្រៅ) ការចំណាយនេះនឹងមានចំនួនតិចជាងចំណាយក្នុងព្រឹត្តិការណ៍បណ្តុះបណ្តាលដែលធ្លាប់បានអនុវត្តពីមុន។

**តើអាចប្រើប្រាស់យ៉ាងដូចម្តេច?** មានប្រាំដំណាក់កាលក្នុងការដំណើរការផ្តល់ប្រឹក្សា៖

**ដំណាក់កាលទី១៖ ជ្រើសរើសអ្នកផ្តល់ប្រឹក្សា**

ជ្រើសអ្នកណែនាំ និងអ្នកតាមដានផ្អែកលើជំនាញសមត្ថភាព និងស្ថានភាពរបស់ពួកគេ។ ពួកគេអាចជាបុគ្គលិកជាន់ខ្ពស់ដែលកំពុងធ្វើការនៅក្នុងស្ថាប័នអតីតបុគ្គលិក ឬបុគ្គលផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធមានជំនាញត្រឹមត្រូវ និងសម្បទានសម្រាប់ការផ្តល់ប្រឹក្សា។

**ដំណាក់កាលទី២៖ បង្កើតឯកសារបណ្តុះបណ្តាល**

រៀបចំឯកសារបណ្តុះបណ្តាសមសម្របសម្រាប់គ្រូផ្តល់ប្រឹក្សាដោយធ្វើការជាមួយអ្នកទទួលការប្រឹក្សា។ ឧទាហរណ៍អាចជា CD អន្តរកម្មជាមួយដែលមានភារកិច្ច និងកិច្ចការដែលអ្នកទទួលការប្រឹក្សាអាចពិនិត្យមើលជាបន្តបន្ទាប់ដោយមានការគាំទ្រពីអ្នកផ្តល់ប្រឹក្សា។ប្រធានផ្តល់ប្រឹក្សាបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សាគ្រូ និងអ្នកតាមដានអំពីឧបករណ៍ និងវិធីសាស្ត្រជាក់លាក់។

**ដំណាក់កាលទី៣៖ ជ្រើសរើសអ្នកទទួលការប្រឹក្សា**

ជ្រើសបុគ្គលិកដើម្បីទទួលបានការផ្តល់ប្រឹក្សាក្នុងពេលបំពេញការងារដោយត្រូវដឹងនូវតួនាទី សមត្ថភាព និងចំណាប់អារម្មណ៍របស់ខ្លួន។

**ដំណាក់កាលទី៤៖ ជំហានទី១ នៃការផ្តល់ប្រឹក្សា**

អ្នកផ្តល់ប្រឹក្សាផ្តល់ការណែនាំដល់អ្នកទទួលការប្រឹក្សា នីមួយៗក្នុងការបង្រៀនឧបករណ៍ និងបច្ចេកទេសដែលការចូលរួម (មួយថ្ងៃក្នុងមួយខែសម្រាប់អ្នកទទួលការប្រឹក្សាម្នាក់)។ ផ្តោតលើការធានាឱ្យមានការយល់ដឹងល្អអំពីឧបករណ៍ និងបច្ចេកទេសអាទិភាពមួយចំនួនជាជាងផ្តោតលើភាពខុសគ្នាច្រើននោះទេ។

**ដំណាក់កាលទី៥៖ ជំហានទី២ នៃការផ្តល់ប្រឹក្សា**

អ្នកផ្តល់ប្រឹក្សា(ក្នុងការពិគ្រោះយោបល់ជាមួយអ្នកទទួលការប្រឹក្សា) បញ្ចប់ផែនការការងារមួយដែលមានមូលដ្ឋានលើបញ្ហាផ្ទាល់ខ្លួន ជាមួយអ្នកទទួលការប្រឹក្សាម្នាក់ៗ។ កិច្ចការនេះចាប់ផ្តើមកំណត់កន្លែង និងរបៀបដែលឧបករណ៍ និងបច្ចេកទេសបានរៀនពីមុនមក នឹងត្រូវអនុវត្តជារចនាសម្ព័ន្ធដើម្បីដោះស្រាយបញ្ហានៃការព្រួយបារម្ភដោយផ្ទាល់ទៅកាន់អ្នកទទួលការប្រឹក្សានេះ (មួយថ្ងៃក្នុងមួយខែចំពោះអ្នកទទួលការប្រឹក្សាម្នាក់)។ ក្នុងដំណើរការនេះ៖

- អ្នកឃ្លាំមើលការផ្តល់នូវការត្រួតពិនិត្យគុណភាពដោយត្រួតពិនិត្យជាទៀងទាត់ក្នុងដំណាក់កាលទី១ និងទី២។ អ្នកឃ្លាំមើលទាំងនោះពិភាក្សាគ្នាអំពីការរីកចម្រើនជាមួយអ្នកទទួលការប្រឹក្សា ហើយសង្កេតមើលពួកគេធ្វើការជាក់ស្តែង។
- ប្រធានអ្នកផ្តល់ប្រឹក្សាបន្តពិនិត្យ សម្របសម្រួល និងពង្រឹងវិធីសាស្ត្រទាំងមូល។

| | |
|---|---|
| **ព្រំដែននិងកំណត់សម្គាល់** | ការផ្តល់ប្រឹក្សាដែលទទួលជោគជ័យតម្រូវឱ្យមានទំនាក់ទំនងរយៈពេលវែងសមហេតុផល និងក្របខ័ណ្ឌស្ថាប័នដែលមានសុវត្ថិភាព។ប្រសិនបើមិនអាចធានាបាននូវចំណុចទាំងពីរនេះទេនោះ យកល្អត្រូវប្រើឧបករណ៍សម្រាប់កសាងសមត្ថភាពរយៈពេលខ្លី។ |
| **ព័ត៌មានបន្ថែម** | Deans, F., Oakley, L., James, R. & Wrigley, R. 2006. Coaching and mentoring for leadership development in civil society. Praxis Paper No. 14. Oxford, UK, International NGO Training and Research Centre (INTRAC). http://www.intrac. org/resources.php?action=resource&id=371<br>Gilmour, D. & Sarfo-Mensah P. 2005. Evaluation report on project ‘Strengthening Participatory Approaches to Forest Management in Ghana, Guyana & Uganda’. London, DFID. http://www.dfid. gov.uk/r4d/Project/60405/Default.aspx |

## ការធានាឱ្យមានការយល់ព្រម ជាមុនដោយស្ម័គ្រចិត្ត (FPIC)

**XL C1.3**
ផ្នែកស៊ីជម្រៅនៃ C1.3

**នេះជាអ្វី?** ការយល់ព្រម ជាមុនដោយស្ម័គ្រចិត្តត្រូវបានកំណត់ថាជាការបង្កើតលក្ខខណ្ឌដែលប្រជាជនអាច និងអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងការចរចាលក្ខខណ្ឌនៃគោលនយោបាយកម្មវិធី និងសកម្មភាពដែលតម្រូវពីខាងក្រៅ ដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅ ឬសុខុមាលភាពរបស់ពួកគេ និងដើម្បីផ្តល់ ឬបដិសេធការព្រមព្រៀងរបស់ពួកគេ។

ឧបករណ៍នេះកំណត់ធាតុមានសក្តានុពលនានាក្នុងការអភិវឌ្ឍដំណើរការរឹងមាំសម្រាប់ឱ្យពលរដ្ឋផ្តល់ការបដិសេធ និងការលើកកម្ពស់ការព្រមព្រៀងចំពោះគម្រោង និងកម្មវិធីនានា។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?**

ដើម្បីជួយជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាននៅតាមតំបន់ជនបទក្នុងការជួយផ្សព្វផ្សាយមតិយោបល់របស់ពួកគេ និងទទួលបានអំណាចនយោបាយ។ ជាពិសេសឧបករណ៍នេះផ្តោតលើការគិតគូរសារប្រយោជន៍របស់ពួកគេនៅពេលដែលស្ថាប័នអន្តរជាតិ រដ្ឋាភិបាល និងវិនិយោគិន ឯកជនធ្វើការសម្រេចចិត្តអំពីធនធានដែលប្រជាជនក្នុងតំបន់មានទំនាក់ទំនងរឹងមាំ។ EFPIC ក៏កាន់តែមានទំនាក់ទំនងទៅនឹងសិទ្ធិរបស់មនុស្សទាំងឡាយជាមួយដីធ្លី និងទឹកដីរបស់ពួកគេដោយផ្អែកលើចំណងទាក់ទងផ្នែកប្រពៃណី និងប្រវត្តិសាស្ត្រជាមួយពួកគេ។ FPIC ក៏វិវត្តនៅក្នុងបរិបទនៃការវិនិយោគពីខាងក្រៅក្នុងការប្រើប្រាស់ដីធ្លី និងគំនិតផ្តួចផ្តើមអំពីកាបូនព្រៃឈើ។ ជាមួយនឹងការទទួលស្គាល់ប្រវត្តិសាស្ត្រនៃការរើសអើងកាន់តែខ្លាំងឡើង ប្រឆាំងនឹងជនជាតិដើមភាគតិច និងការដកហូតដីបុព្វការីជននិងដីប្រពៃណីរបស់ពួកគេ គេឃើញមានការទទួលស្គាល់កាន់តែច្រើនឡើងនូវសិទ្ធិស្វ័យសម្រេច (សម្រាប់ព័ត៌មានបន្ថែមសូមមើលខ្លឹមសារ FPIC ក្នុងសទ្ទានុក្រម)។

បើនិយាយអំពីហានិភ័យដែលអាចមាននៅក្នុងការវិនិយោគលើការប្រើប្រាស់ដីធ្លី និងគោលនយោបាយកម្មវិធី REDD+ ការតាក់តែង និងការអនុវត្ត FPIC បានក្លាយជាចំណុចស្នូលនៃការទាមទាររបស់ក្រុមជនជាតិដើមភាគតិចជាច្រើន ទោះជាសិទ្ធិដីធ្លីត្រូវបានទទួលស្គាល់ ឬមិនទទួលស្គាល់នៅថ្នាក់ជាតិក្តី។

**នរណាខ្លះគប្បីប្រើឧបករណ៍នេះ?**

ឧបករណ៍នេះកំណត់បញ្ហាដែលអ្នកគាំទ្រគម្រោង ឬអ្នកធ្វើគោលនយោបាយគួរលើកឡើងជាមួយជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ដើម្បីឱ្យមានការព្រមព្រៀងលើផែនការ សកម្មភាពជាមួយសហគមន៍ រងផលប៉ះពាល់នីមួយៗសំដៅគោរពដំណើរការFPIC។ ឧបករណ៍នេះត្រូវបានបង្កើតឡើងពីទស្សនៈនៃការចូលរួមជាមួយនឹងមេដឹកនាំសហគមន៍ និងបណ្តាសហគមន៍នៅថ្នាក់ភូមិជុំវិញសកម្មភាពសហគមន៍ ឬសកម្មភាពព្រៃឈើជាក់លាក់ជាជាងការចរចា FPIC នៅថ្នាក់ជាតិ។

**ជំនាញនិងធនធានដែលត្រូវមាន**

ជំនាញដែលត្រូវការរួមមាន៖

- មានជំនាញសម្របសម្រួល
- ចំណេះដឹង និងបទពិសោធន៍ក្នុងការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម
- ចំណេះដឹងបច្ចេកទេស និងចំណេះដឹងច្បាប់ស្តីពីFPIC
- ការកសាងសមត្ថភាពនៅតាមផ្នែកពាក់ព័ន្ធ
- ការគ្រប់គ្រងដំណើរការរបស់ភាគីពាក់ព័ន្ធពហុវិស័យ និង / ឬការផ្លាស់ប្តូរគោលនយោបាយ។

ដំណើរការនេះអាចមានរយៈពេលច្រើនខែ ឬហូតដល់ច្រើនឆ្នាំ។ ការអនុវត្តដំណើរការ FPIC រឹងមាំ និងត្រឹមត្រូវគឺជាដំណើរការដែលតម្រូវឱ្យមានធនធានល្អិតល្អន់ ដូចជាការវិនិយោគឱ្យបានច្រើនទៅលើមនុស្ស ពេលវេលា សម្ភារ និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង សកម្មភាពបណ្តុះបណ្តាលសមត្ថភាព ឯករាជ្យភាពនៃការផ្ទៀងផ្ទាត់ ការប្រឹក្សាបច្ចេកទេស និងប្រឹក្សាច្បាប់ ជាដើម។ កិច្ចខំប្រឹងប្រែងទាំងនេះ គឺជាតម្រូវការចំពោះមុខរបស់កម្មវិធីមួយ។

**តើគេអាចប្រើការវិភាគអំណាចរបស់ភាគីពាក់ព័ន្ធយ៉ាងដូចម្តេច**

មានដំណាក់កាលសំខាន់ៗចំនួនបួន៖

**ដំណាក់កាលទី១៖ កំណត់មូលដ្ឋានគតិយុត្តសម្រាប់ FPIC**

- យល់ពីក្របខ័ណ្ឌច្បាប់។ ពិនិត្យឡើងវិញនូវច្បាប់ជាតិ និងអន្តរជាតិដើម្បីកំណត់ពីកាតព្វកិច្ចផ្លូវច្បាប់របស់រដ្ឋក្នុងការគោរពសិទ្ធិ រកឱ្យឃើញអ្នកទទួលខុសត្រូវតាមផ្លូវច្បាប់ សំដៅទទួលបាននូវការព្រមព្រៀងពីសហគមន៍ និងកំណត់ផលប៉ះពាល់ផ្លូវច្បាប់ដែលអាចកើតមានប្រសិនបើគម្រោងមិនគោរពសិទ្ធិរបស់ប្រជាជន។
- យល់ដឹងអំពីក្របខ័ណ្ឌរដ្ឋបាល។ កំណត់អាជ្ញាប័ណ្ណស្របច្បាប់ដើម្បីធានាដល់ការចូលក្នុងព្រៃ និងប្រើប្រាស់ធនធានព្រៃឈើ និងនីតិវិធីរដ្ឋបាលដែលធ្វើឱ្យសិទ្ធិរបស់មនុស្សមានឬគ្មានសុវត្ថិភាព

**ដំណាក់កាលទី២៖ ការរៀបចំសម្រាប់ការចូលរួមរបស់ម្ចាស់សិទ្ធិនៅក្នុងFPIC**

- ពិនិត្យមើលសិទ្ធិកំណត់អត្តសញ្ញាណម្ចាស់សិទ្ធិ និងការប្រើប្រាស់ដីធ្លី។ ការងារកសាងផែនទីដែលមានការចូលរួម (សូមមើល A3.2 ឧបករណ៍) អាចប្រើដើម្បីផ្តល់នូវភាពច្បាស់លាស់អំពីព្រំដី និងសិទ្ធិទាមទារសម្រាប់សហគមន៍មួយជាក់លាក់។
- កំណត់ស្ថាប័នធ្វើសេចក្តីសម្រេចរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការប្រើប្រាស់ស្ថាប័នធ្វើសេចក្តីសម្រេចរបស់ពួកគេផ្ទាល់ ជាជាងការប្រើប្រាស់ប្រព័ន្ធដែលត្រូវបានកំណត់។ ការសម្របសម្រួលអាចផ្តល់ដោយអ្នកគាំទ្រគម្រោងជាជម្រើសមួយដើម្បីពង្រីកការចូលរួមក្នុងការប្រមូលចែករំលែកព័ត៌មានការពិភាក្សា និងការសម្រេចចិត្ត ព្រមទាំងគោរពការសម្រេចចិត្តរបស់សហគមន៍ក្នុងការប្រើប្រាស់ស្ថាប័នសម្រេចចិត្តរបស់ពួកគេផ្ទាល់។

- កំណត់រចនាសម្ព័ន្ធការគាំទ្រថ្នាក់ជាតិចំពោះការតស៊ូមតិអំពីសិទ្ធិ។ ផ្តល់ជំនួយដល់ជនជាតិដើមភាគតិចដើម្បីឱ្យពួកគេយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងតស៊ូមតិដើម្បីឱ្យសិទ្ធិត្រូវបានទទួលស្គាល់ និងគោរពដោយរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។
- បង្កើតដំណើរមួយការសម្រាប់ការព្រមព្រៀង។ ដាក់ចេញនូវដំណើរការមួយសម្រាប់ការព្រមព្រៀងរាប់ទាំងកាលវិភាគសម្រាប់គ្រប់ដំណាក់កាលនៃការទទួលបានការព្រមព្រៀងពីការពិភាក្សាជំហានដំបូង ការប្រមូលព័ត៌មាន និងពិចារណាផលប៉ះពាល់ផលប្រយោជន៍ និងជម្រើសនានា រហូតដល់ការចរចា និងការអនុវត្តកិច្ចព្រមព្រៀង។ ដំណើរការនៃការព្រមព្រៀងនេះត្រូវតែបង្ហាញថាគ្មានការបង្ខិតបង្ខំ និងគ្មានឧបាយកលឡើយ។
- បង្កើតទម្រង់នៃកិច្ចព្រមព្រៀងស្តីពីការព្រមព្រៀងនានា។ សណ្ឋាន និងទម្រង់សម្រាប់ការព្រមព្រៀងត្រូវតែមានការទទួលស្គាល់ពីភាគីទាំងពីរ ដោយប្រើរួមគ្នានូវការសរសេរ ការនិយាយផ្ទាល់មាត់ និង/ឬមធ្យោបាយពិធីបែបប្រពៃណី។
- ឯកភាពលើផែនការប្រាស្រ័យទាក់ទង។ ចាំបាច់ត្រូវមានផែនការប្រា-ស្រ័យទាក់ទងសម្រាប់ដំណើរការ FPIC ដើម្បីអោយគ្រប់ទិដ្ឋភាពនៃ ការព្រមព្រៀងត្រូវបានជូនដំណឹងដល់សមាជិកនានានៃសហគមន៍ និងដល់ភាគីដែលមានចំណាប់អារម្មណ៍ផ្សេងទៀត រាប់ទាំងសហគមន៍នៅក្បែរៗគ្នា អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុននានាដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់នោះ។
- បង្កើតយុទ្ធសាស្ត្រកសាងសមត្ថភាព។ យុទ្ធសាស្ត្រកសាងសមត្ថភាពសម្រាប់សមាជិកសហគមន៍ត្រូវស្របគ្នាទៅនឹងជំនាញដែលបុគ្គលិករបស់ខ្លួនត្រូវការក្នុងការចូលរួមក្នុងដំណាក់កាលនីមួយៗនៃដំណើរការព្រមព្រៀងដែលកំពុងប្រព្រឹត្តទៅ។ ការស្ទង់មតិបឋមគួរកំណត់តម្រូវការសមត្ថភាពនៅក្នុងសហគមន៍ទាក់ទងនឹងដំណាក់កាលព័ត៌មាននៃដំណើរការFPIC។

**ដំណាក់កាលទី៣៖ អនុវត្តដំណើរការយល់ព្រម**

- រួមបញ្ចូលប្រជាពលរដ្ឋឱ្យចូលរួមនៅក្នុងការរៀបចំកម្មវិធី។ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានគួរចូលរួមយ៉ាងសកម្មក្នុងដំណាក់កាលរៀបចំគម្រោងទាំងមូល តាមរយៈការវាយតម្លៃការអភិវឌ្ឍយន្តការបែងចែកផលប្រយោជន៍។ល។ (សូមមើលឧបករណ៍ស្តីពីការចូលរួមរបស់អ្នកពាក់ព័ន្ធ)។
- ធានាលទ្ធភាពទទួលបានព័ត៌មានដទៃ និងដំបូន្មានឯករាជ្យ។ សិទ្ធិរបស់សហគមន៍ក្នុងការទទួលបានព័ត៌មាន និងដំបូន្មានឯករាជ្យនៃអ្នកគាំទ្រគម្រោងនេះគឺគ្រឹះនៃដំណើរការយល់ព្រមដែលមានការជូនដំណឹង។ សហគមន៍ជនបទភាគច្រើនដែលរងផលប៉ះពាល់ដោយគម្រោងណាមួយនឹងត្រូវការជំនួយ ដើម្បីកំណត់ប្រភពព័ត៌មានឯករាជ្យ និងដំបូន្មានស្តីពីបញ្ហាច្បាប់ សង្គមសេដ្ឋកិច្ច និងបរិស្ថាន ក៏ដូចជាជួយបង់ប្រាក់សម្រាប់ការផ្តល់ដំបូន្មានផងដែរ - ដូចជាការបង្កើតមូលនិធិអាណត្តិព្យាបាលភាព (Trust Fund) ជាដើម។
- ចរចា និងឈានដល់ការយល់ព្រម។ ការចរចាមានការពិភាក្សាទៅវិញទៅមករវាង សហគមន៍ និងអ្នកគាំទ្រគម្រោង ឬអ្នកសម្របសម្រួល (រដ្ឋាភិបាល វិស័យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល) លើសំណើ ចំណាប់អារម្មណ៍ និងការព្រួយបារម្ភនានា។ បរិបទនៃកម្មវិធីREDD+ ឬកម្មវិធីផ្តួចផ្តើមគំនិតអំពីការប្រើប្រាស់ដីព្រៃដែលបញ្ហាគន្លឹះទំនងជារួមមានប្រភេទ និងទំហំនៃការផ្លាស់ប្តូរណាមួយចំពោះការប្រើប្រាស់ព្រៃឈើ តួនាទីរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ និងការតាមដាន និងរបៀបដែលសហគមន៍ធានាបាននូវការគ្រប់គ្រងផលប្រយោជន៍ដែលបានរំពឹងទុក។

**ដំណាក់កាលទី៤៖ ការតាមដាន និងឧបាស្រ័យ ការរក្សា ការយល់ព្រម**

- តាមដាននូវអ្វីដែលបានយល់ព្រមក្នុងការអនុវត្ត ។តាមដានការអនុវត្តកិច្ចព្រមព្រៀងបង្កលក្ខណៈឱ្យភាគីនានាទទួលខុសត្រូវទៅវិញទៅមកចំពោះលទ្ធផលដែលបានការយល់ព្រមគ្នាក៏ដូចជាការគ្រប់គ្រងទៅតាមសភាពការណ៍ប្រសិនបើលទ្ធផលជាក់ស្តែងខុសពីការព្យាករណ៍ (ឧទាហរណ៍ ការចំណាយរបស់សហគមន៍ ឬផលប្រយោជន៍) ។ម្ចាស់សិទ្ធិសហគមន៍គួរចូលរួមឱ្យបានច្រើននៅគ្រប់ដំណាក់កាលនៃការតាក់តែង និងការតាមដានកិច្ចព្រមព្រៀងដែលបានឯកភាពគ្នា (ជាជាងគ្រាន់តែប្រមូលទិន្នន័យសម្រាប់ការទូទាត់)។ (សូមមើលផ្នែក D ចំពោះបច្ចេកទេសតាមដានដែលមានការចូលរួម។)
- បង្កើតដំណើរការសារទុក្ខ ។គោលបំណងរួមនៃដំណើរការសារទុក្ខគឺដើម្បីស្តារការព្រមព្រៀង។ យន្តការនេះគប្បីរួមបញ្ចូលទាំងលទ្ធភាពនៃមជ្ឈត្តកម្មឯករាជ្យ និងឧបាស្រ័យចំពោះដំណោះស្រាយផ្លូវច្បាប់ឬរដ្ឋបាលប្រសិនបើការចរចាមិនអាចទៅរួច។ (ព័ត៌មានបន្ថែមអំពីយន្តការដោះស្រាយបណ្តឹងសូមមើលផ្នែក C) ។
- ផ្ទៀងផ្ទាត់ការព្រមព្រៀង។ វាគឺជាកិច្ចតម្រូវរបស់FPICឱ្យមានភាគីឯករាជ្យផ្ទៀងផ្ទាត់ថាមានការយល់ព្រមដោយសេរី និងជូនដំណឹងជាមុន ប្រសិនបើអ្នកគាំទ្រកម្មវិធីបានដឹងអំពីដំណើរការផ្ទៀងផ្ទាត់នេះគេអាចប្រើវាជាមូលដ្ឋានមួយសម្រាប់ធានាឱ្យដំណើរការ FPIC បំពេញរាល់ធាតុទាំងឡាយនៃការផ្ទៀងផ្ទាត់។

**ព្រំដែននិងកំណត់សម្គាល់**

FPIC ជាតម្រូវការនិងជាបុរេលក្ខខណ្ឌមួយដែលសម្តែងដោយជនជាតិដើមភាគតិចជាពិសេស អស់រយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែទើបតែកាលពីប៉ុន្មានឆ្នាំនេះតែប៉ុណ្ណោះ FPIC បានក្លាយជាការរំពឹងទុកដ៏រឹងមាំ និងជាការពិតដូចកាន់តែខ្លាំងឡើងទៅនឹងច្បាប់ជាតិ ការអនុវត្តរបស់សាជីវកម្ម និងកម្មវិធីអន្តរជាតិដែលតម្រូវឱ្យមាន FPIC។ ដូច្នេះបទពិសោធន៍ជាមួយនឹងដំណើរការ FPIC ទទួលជោគជ័យក្នុងវិស័យប្រើប្រាស់ដីធ្លីនៅមានតិចតួចនៅឡើយ។ ហេតុនេះហើយបានជាឧបករណ៍ដែលមាននៅដំណាក់កាល "ជំនាន់ដំបូង" ចាំបាច់ត្រូវកែលម្អ។ ប្រសិនបើអ្នកប្រើឧបករណ៍នេះសូមចងក្រងឯកសារ និងពង្រីកបទពិសោធន៍របស់អ្នក។

**ព័ត៌មានបន្ថែម**

Forest Peoples Programme. Forthcoming. Guidebook on FPIC in REDD+.
UN-REDD. 2010. Programme guidelines for seeking the free, prior, and Informed consent of indigenous peoples and other forest dependent communities [Draft]. Geneva, United Nations Collaborative Programme on Reducing Emissions from Deforestation and Forest Degradation in Developing Countries.
WWF. 2011. Free, prior, informed consent and REDD+: guidelines and resources. Gland, Switzerland. http://awsassets.panda.org/downloads/report_free_ pdf_final3.pdf
Forest Peoples Programme. 2008. Free, prior and informed consent and oil palm plantations: a guide for companies. Moreton-in-Marsh, UK. http:// www.forestpeoples.org/sites/fpp/files/publication/2009/12/fpicandrspo companiesguideoct08eng.pdf
Example: Forest Trends. 2010. Free, prior, informed consent: Surui carbon project (Brazil). Brazil, Amazon Conservation Team (ACT), Metareila Association of the Surui People, Institute for the Conservation and Sustainable Development of Amazonas (IDESAM), and Brazilian Biodiversity Fund (FUNBIO). http://www. forest-trends.org/documents/files/doc_2693.pdf
FAO. Forthcoming. Implementation guide on land acquisition, free, prior and informed consent and customary land of indigenous peoples and other local communities, S. Chao and M. Colchester.

## XL C1.5
ផ្នែកស៊ីជម្រៅនៃ C1.5

## ប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធវិធីបញ្ចុះបញ្ចូលសម្រាប់ក្រុមនៅមូលដ្ឋាន

**នេះជាអ្វី?**

ឧបករណ៍នេះកំណត់ក្បួនមួយចំនួនដែលក្រុមអង្គការ អាចប្រើដើម្បីលើកទឹកចិត្តដល់គោលនយោបាយជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងសេចក្តីប្រាថ្នារបស់ពួកគេ។ ក្បួនទាំងអស់រួមមានសកម្មភាពបច្ចេកទេសត្រឹមត្រូវ សកម្មភាពប្រើប្រាស់ពេលវេលាវែង ដូចជាការកសាងផែនទី និងសវនកម្ម រហូតដល់សំណើដទៃទៀតដើម្បីក្តាប់ឱកាសជាមួយនឹងអ្នកនយោបាយនិងប្រព័ន្ធផ្សព្វផ្សាយក្នុងការទាញ ការចាប់អារម្មណ៍លើបញ្ហានៃការព្រួយបារម្ភ។ ឧបករណ៍នេះជាច្រើនមានគោលបំណងជំរុញការយល់ដឹង និងពិភាក្សាជាសាធារណៈ ។

ឧបករណ៍នេះត្រូវបានផលិតក្នុងបរិបទនៃកសិករខ្នាតតូចនៅហ្វ្រេណាដា ប៉ុន្តែក្របខ័ណ្ឌ និងក្បួនយុទ្ធវិធីអាចមានប្រយោជន៍ សម្រាប់អង្គការសហគមន៍ ភ្នាក់ងារតស៊ូមតិ និង អភិវឌ្ឍន៍ជាច្រើន។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?**

មានភាពទាក់ទងគ្នានៅពេលដែលក្រុមអ្នកពាក់ព័ន្ធណាមួយមានបំណងលើកឡើងនូវដំណើររឿងនៃបញ្ហានានាដែលធ្វើឱ្យពួកគេព្រួយបារម្ភ និងជំរុញអ្នកធ្វើគោលនយោបាយឱ្យឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។ ឧទាហរណ៍ ក្នុងករណីដែល រដ្ឋាភិបាលមិនបានប្រឹងប្រែងឱ្យបានគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាណាមួយ រីឯភាគីពាក់ព័ន្ធខ្វល់ខ្វាយថាគ្មានការយកចិត្តទុកដាក់គ្រប់គ្រាន់ទៅនឹងបញ្ហានេះ។

**នរណាគួរប្រើប្រាស់ឧបករណ៍នេះ**

ឧបករណ៍នេះត្រូវបានរៀបចំដោយអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នដទៃទៀតដើម្បីគាំទ្រក្រុមដែលគួរតែទទួលបានផលប្រយោជន៍ក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេទៅលើ បញ្ហាដែលជាកង្វល់របស់ពួកគេផ្ទាល់ និងការចូលរួមជាមួយអ្នកបង្កើតគោលនយោបាយនានា។

**ជំនាញនិងធនធានដែលត្រូវការ**

ជំនាញសំខាន់ៗរួមមាន៖
- ជំនាញសម្របសម្រួល(រាប់ទាប់ចំណងទាក់ទងរវាងរុក្ខបាល) និងស្ថាប័នដទៃទៀត
- ការយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយពាក់ព័ន្ធ និងអង្គភាពនយោបាយ
- ជំនាញជាក់លាក់ផ្អែកលើក្បួនយុទ្ធវិធីដែលបានប្រើដូចជាការផលិតខ្សែវីដេអូ ជាដើម។

រាល់ការងារអ្វីក៏ដោយជាមួយសហគមន៍ត្រូវកសាងជុំវិញគោលការណ៍សមូហភាព និងភាពត្រឹមត្រូវ។ ដើម្បីធ្វើឱ្យមានទំនុកចិត្ត កសាងទំនាក់ទំនង និងធ្វើឱ្យមានការគោរពគ្នាទៅវិញទៅមក ត្រូវចំណាយពេលវេលាយូរ។

| | |
|---|---|
| **តើអាចប្រើប្រាស់យ៉ាងដូចម្តេច?** | គេអាចធ្វើដំណាក់កាលនេះឱ្យសាមញ្ញទៅជាបួនដំណាក់កាលដូចខាងក្រោម៖<br>**ដំណាក់កាលទី១៖ ការរៀបចំ**<br>• កំណត់រកច្រកចូលដែលអាចទៅរួចក្នុងដំណើរការគោលនយោបាយដែលអាចកំណត់ជាគោលដៅតាមរយៈការបញ្ចុះបញ្ចូលជាបន្តបន្ទាប់។ កសាងចំណេះដឹងអំពីគោលនយោបាយដែលប៉ះពាល់ដល់ក្រុមនេះនិងដែលធ្វើឱ្យមានការព្រួយបារម្ភ។ បង្កើតសំណុំឯកសារគោលនយោបាយ និងកម្មសិទ្ធិដីធ្លីពាក់ព័ន្ធដែលអាចផ្តល់ឱ្យសាធារណជន។ រិះគន់ចំណុចមួយចំនួននៃគោលនយោបាយដូចជា វិធីដំណើរការគោលនយោបាយដែលមានការចូលរួមជាដើម។ ប្រមូលព័ត៌មានអំពីកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់។<br>• ទាក់ទងទៅប្រព័ន្ធផ្សព្វផ្សាយឱ្យចូលរួមតាំងពីដំបូង។ ទាក់ទាញប្រព័ន្ធផ្សព្វផ្សាយឱ្យស៊ើបអង្កេតជាជាងដែលពួកគេគ្រាន់តែប្រើប្រាស់សេចក្តីជូនព័ត៌មានព្រោះការធ្វើបែបនេះនឹងនាំមកនូវព័ត៌មានល្អ និងការចូលរួមក្នុងរយៈពេលយូរ។ កុំនាំកសិករមកជួបជាមួយអ្នកសារព័ត៌មាន ប៉ុន្តែត្រូវនាំអ្នកសារព័ត៌មានទៅជួបជាមួយកសិករ។<br>**ដំណាក់កាលទី២៖ កសាងភស្តុតាងរបស់កសិករ**<br>• បង្ហាញពីការប្រើប្រាស់ដី។ សម្រាប់កសិករ ភស្តុតាងពិតប្រាកដគឺស្ថិតនៅលើដី មិនមែនស្ថិតនៅលើក្រដាសនោះទេ ដូច្នេះត្រូវប្រើប្រព័ន្ធផ្សព្វផ្សាយដូចជាវីដេអូ ការថតរូប និងថតសំឡេងដើម្បីកត់ត្រាការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន តាមបែបមួយដែលទាក់ទាញការយកចិត្តទុកដាក់របស់ប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ (សូមមើលឧបករណ៍ C1.9 រូបភាព និងវីដេអូដែលមានការចូលរួម) ។<br>• កសាងផែនទីកម្មសិទ្ធិដីពិតប្រាកដ។ សិទ្ធិកាន់កាប់ជាក់ស្តែងច្រើនតែខុសពីប័ណ្ណកម្មសិទ្ធិ ហើយផែនទីផ្លូវការជួយកសិករក្នុងការរៀបចំផែនការ និងអះអាងករណីរបស់ពួកគេ។ ការកសាងផែនទីអាចកំណត់អត្តសញ្ញាណម្ចាស់ អ្នកប្រើប្រាស់ ឬក្បាលដី ពង្រឹងការទាមទារដីធ្លី បញ្ជាក់ការចុះបញ្ជីរុក្ខបាលព្រៃឈើជាមួយសេវាអាជ្ញាធរពាក់ព័ន្ធដោយទ្រទ្រង់ការងារកសាងផែនការ។ល។ (សូមមើលឧបករណ៍ A3.9 ការកសាងផែនទីដែលមានការចូលរួម)។<br>• ជំរុញនិងគាំទ្រដល់រុក្ខបាលក្នុងកំណត់ត្រា។ ជួយពួកគេឱ្យបង្កើតប្រព័ន្ធសាមញ្ញសម្រាប់កត់ត្រាសកម្មភាពសំខាន់ៗនានា។ ការធ្វើបែបនេះបង្កើតបានជាមូលដ្ឋានភស្តុតាងមួយដើម្បីប្រើប្រាស់នៅក្នុងការបញ្ចុះបញ្ចូលរដ្ឋាភិបាល។<br>• ជំរុញវិធីអភិវឌ្ឍរុក្ខបាលតាមបែបផ្សេងទៀត។ ប្រើផែនទីផ្លូវការ និងការពិភាក្សារបស់កសិករដើម្បីរៀបចំអំណះអំណាងសម្រាប់ការប្រើប្រាស់ដីធ្លីឱ្យមាននិរន្តរភាព និងសមធម៌ដូចជាការរួមបញ្ចូលគ្នារវាងការប្រើប្រាស់ព្រៃឈើ និងការប្រើប្រាស់ដីធ្លី។ ការធ្វើបែបនេះជួយរៀបចំសម្រាប់ការសន្ទនា និងការតស៊ូមតិនាពេលអនាគតជាមួយនឹងអ្នករៀបចំគោលនយោបាយ។<br>**ដំណាក់កាលទី៣៖ ការពង្រឹករូបភាព**<br>• លើកកម្ពស់ការយល់របស់រុក្ខបាលលើតួនាទីរបស់ពួកគេនៅក្នុងសេដ្ឋកិច្ចជាតិ។ ជួយពួកគេបង្កើតអំណះអំណាងរបស់ពួកគេសម្រាប់ការប្រើប្រាស់ព្រៃឈើក្នុងបរិបទគោលនយោបាយជាតិ និងអន្តរជាតិ។<br>• ភ្ជាប់បញ្ហាព្រៃឈើបញ្ហាជាមួយកម្មវិធីជាតិដូចជាកម្មវិធីសន្តិសុខស្បៀង កម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីជីវចំរុះ។ កសាងករណីអំពីសារសំខាន់នៃព្រៃឈើដោយបង្ហាញពីការប្រព្រឹត្តចំពោះព្រៃឈើរួមចំណែកដល់គោលនយោបាយ និងកម្មវិធីផ្សេងៗ។<br>• កសាងទំនាក់ទំនងរវាងរុក្ខបាលជាមួយបុគ្គលិកបច្ចេកទេសព្រៃឈើ។ ជួយសម្រួលដល់មន្ត្រីផ្សព្វផ្សាយកសិកម្មក្នុងការបំពេញការងារនៅមូលដ្ឋានរីឯរុក្ខបាលព្រៃឈើវិញជំរុញឱ្យសេវាផ្សព្វផ្សាយកសិកម្មប្រព្រឹត្តបានពេញលេញ។ជួយរុក្ខបាលព្រៃឈើឱ្យយល់ពីសិទ្ធិរបស់ពួកគេ និងជំរុញឱ្យមានការផ្តល់សេវាបានល្អ។<br>• កត់ត្រានិងចែករំលែកបទពិសោធន៍ពីស្ថានភាពស្រដៀងគ្នានៅទីកន្លែងដទៃដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់រុក្ខបាលព្រៃឈើអំពីអ្វីដែលអាចធ្វើបាន។ ពិភាក្សាអំពីទិដ្ឋភាពទាំងនេះដើម្បីយល់ដឹងថា អ្វីដែលបានធ្វើ និងអ្វីដែលធ្វើមិនបាន។<br>**ជំហានទី៤៖ ការកំណត់គោលដៅ ការទាក់ទង និងការចរចាជាមួយក្រុមធំ**<br>• ជួយរុក្ខបាលព្រៃឈើត្រៀមខ្លួនសម្រាប់កិច្ចប្រជុំសំខាន់ៗ និងការអភិវឌ្ឍជំនាញចរចា។ រៀបចំកិច្ចប្រជុំជាមុនដើម្បីពិភាក្សាអំពីការអនុវត្តជាក់ស្តែង និងអំពីទិដ្ឋភាព "នឹងមានអ្វីកើតឡើងប្រសិនបើ"។<br>• ប្រើដំណើរការនយោបាយប្រកបដោយយុទ្ធវិធី ដូចជាការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិជាដើម។<br>• ប្រើប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយសារ និងជំរុញការពិភាក្សាជាសាធារណៈ។ ត្រូវប្រុងប្រយ័ត្នអំពីការផ្សព្វផ្សាយទស្សនៈរបស់កសិករដោយគ្មានការព្រមព្រៀង។ |

**ព្រំដែននិងកំណត់សម្គាល់** ក្រុមសង្គមស៊ីវិលមានភាពខុសគ្នាជាខ្លាំងអំពីកម្រិតនៃការចាត់ចែងនិងគណនេយ្យភាព។ ការចូលទៅមានមតិលើដំណើរការគោលនយោបាយអាចមានការលំបាកខ្លាំងណាស់ហើយក្រុមសង្គមស៊ីវិលចាំបាច់ត្រូវដឹងច្បាស់លាស់អំពីភស្តុតាង ជំហរ និងភាពស្របច្បាប់របស់ពួកគេនៅក្នុងការតស៊ូមតិ និងប្រព័ន្ធផ្សព្វផ្សាយ។

**ព័ត៌មានបន្ថែម** Williams, J. & Vermeulen, S. 2005. Media and lobby tactics: linking farmers' actions with national policy processes. Power Tools Series. Grenada Community Development Agency and London, IIED. http://www.policy-power tools.org/Tools/Engaging/MLT.html

## XL D1.3
ផ្នែកស៊ីជម្រៅនៃ D1.3

## ប័ណ្ណរាយការណ៍អំពីតម្លាភាពលើវិស័យព្រៃឈើ

**នេះជាអ្វី?** គោលបំណងនៃការបង្កើតប័ណ្ណរាយការណ៍អំពីតម្លាភាពលើវិស័យព្រៃឈើគឺដើម្បីបង្កការប្រៀបធៀបរវាងគុណភាពបរិមាណ និងលទ្ធភាពទទួលបានព័ត៌មានព្រៃឈើដែលរដ្ឋាភិបាលបានផ្តល់ទៅកាន់សាធារណជននៅបណ្តាប្រទេសសម្បូរព្រៃឈើ។ ឧបករណ៍ត្រូវបានបង្កើតឡើងដោយដៃគូគម្រោងក្នុងគម្រោងស្តីពីការធ្វើឱ្យមានតម្លាភាពក្នុងវិស័យឈើរបស់អង្គការGlobal Witness (២០០៨-២០១៣)។ គម្រោងនេះគាំទ្រដល់ក្រុមសង្គមស៊ីវិលនៅបណ្តាប្រទេសដែលសម្បូរព្រៃឈើក្នុងការចូលរួមជាមួយអ្នកធ្វើគោលនយោបាយ និងអ្នកតស៊ូមតិដើម្បីឱ្យអភិបាលកិច្ចលើវិស័យព្រៃឈើមានគណនេយ្យភាព។ អង្គការ Global Witness កំពុងអនុវត្តសាកល្បងឧបករណ៍នេះជាមួយនឹងអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកាមេរូន សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ អេក្វាឌ័រ ប្រទេសហ្គាណា ហ្គាតេម៉ាឡា លីបេរីយ៉ា និងប្រទេសប៉េរូ។

**តើគេអាចប្រើវាសម្រាប់ធ្វើអ្វី?** ប័ណ្ណរាយការណ៍អាចជួយឱ្យមានតម្លាភាពក្នុងវិស័យព្រៃឈើតាមវិធីផ្សេងគ្នា៖

- សង្ខេបស្ថានភាពបច្ចុប្បន្នអំពីតម្លាភាពក្នុងវិស័យព្រៃឈើនៅក្នុងបណ្តាប្រទេសជាច្រើន
- វាយតម្លៃការផ្លាស់ប្តូរ និងវឌ្ឍនភាពអំពីគណនេយ្យភាពដោយចម្លងវិធីសាស្ត្រប្រមូលទិន្នន័យទៅអនុវត្តនៅកន្លែងដទៃទៀតតាមពេលវេលា
- រាយការណ៍ពីវឌ្ឍនភាពឆ្ពោះទៅកាន់ការសម្រេចបាននូវការប្តេជ្ញារបស់ជាតិជុំវិញអភិបាលកិច្ចព្រៃឈើ និងលទ្ធភាពទទួលបានព័ត៌មាន។

លើមូលដ្ឋាននៃទិន្នន័យទាំងនេះ យុទ្ធសាស្ត្រតស៊ូមតិអាចមានមូលដ្ឋានផ្អែកលើភស្តុតាង និងអាចបង្កើតអនុសាសន៍សម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗដើម្បីបង្កើនតម្លាភាពវិស័យព្រៃឈើ។

វិធីសាស្ត្រសម្រាប់ឧបករណ៍នេះនៅបណ្តាប្រទេសផ្សេងគ្នាមិនដូចគ្នាឡើយ អាស្រ័យលើគោលបំណងជាក់លាក់ និងរបៀបប្រើប្រាស់ព័ត៌មានដែលបានប្រមូល ។

**នរណាប្រើប្រាស់ក្រុមនេះ** ឧបករណ៍នេះត្រូវបានរចនាឡើងសម្រាប់ឱ្យអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការយ៉ាងសកម្មលើវិស័យអភិបាលកិច្ចព្រៃឈើនិងតម្លាភាពប្រើប្រាស់។ ចាំបាច់ត្រូវមានជំនាញ និងការយល់ដឹងពីវិស័យនេះ។ ដំណើរការនេះនឹងមានប្រយោជន៍ច្រើនបំផុត ប្រសិនបើទីភ្នាក់ងារនាំមុខមានចំណាប់អារម្មណ៍ និងមានសមត្ថភាពក្នុងការជូនដំណឹងអំពីលទ្ធផលនៃដំណើរការប័ណ្ណរបាយការណ៍ និងប្រើប្រាស់លទ្ធផលទាំងនោះក្នុងការតស៊ូមតិនាពេលអនាគតនៅជុំវិញតម្លាភាពក្នុងវិស័យព្រៃឈើ។ ប័ណ្ណរបាយការណ៍នេះត្រូវបានបង្កើតឡើងតាមរយៈដំណើរការចូលរួមជាមួយ សង្គមស៊ីវិលដែលយល់ដឹងនិងមានចំណាប់អារម្មណ៍ក្នុងវិស័យព្រៃ។

ភាគីពាក់ព័ន្ធផ្សេងគ្នាមកពីផ្នែកនានាចាប់ពីសហគមន៍មូលដ្ឋាន តំណាងក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាលចូលរួមក្នុងការបំពេញប័ណ្ណរាយការណ៍។

**ជំនាញនិងធនធានដែលត្រូវការ** ជំនាញចាំបាច់រួមមាន៖

- ជំនាញសម្របសម្រួលសិក្ខាសាលា និងការស្ទង់មតិតាមបែបគុណភាព
- ចំណេះដឹង និងបទពិសោធន៍ក្នុងការប្រើប្រាស់អភិក្រមដែលមានការចូលរួម
- ធ្វើការសម្ភាស និងលើកសំណួរ អាចគោរពតាមបទដ្ឋានយ៉ាងហ្មត់ចត់
- ចាត់ចែងទិន្នន័យកម្រងសំណួរ និងសម្រាំងយកចំណុចគន្លឹះធ្វើជាចំណុចសកម្មភាពនាពេលអនាគតសម្រាប់ការតស៊ូមតិ។

ចាំបាច់ត្រូវធ្វើការច្រើនខែពីក្រុមតូចមួយ ដើម្បីផលិតបានលទ្ធផលថ្នាក់ជាតិ មានប្រសិទ្ធភាព ជាមួយនឹងឧបករណ៍នេះហើយលទ្ធផលទាំងនេះនឹងកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ប្រសិនបើការងារនេះត្រូវបានធ្វើម្តងហើយម្តងទៀតជារៀងរាល់ឆ្នាំ។

| | |
|---|---|
| **តើអាចប្រើប្រាស់យ៉ាងដូចម្តេច?** | វិធីសាស្ត្រនេះនឹងប្រែប្រួលក្នុងបរិបទនីមួយៗស្របតាមគោលបំណង និងព័ត៌មានដែលអាចរកបាន ប៉ុន្តែនឹងអនុវត្តតាមដំណាក់កាលទាំងប្រាំនេះ៖<br>**ដំណាក់កាលទី១៖ ការរចនា**<br>អង្គការនានាគួរចំណាយពេលព្រមព្រៀងអំពីបញ្ហាទស្សនៈ និងវិធីសាស្ត្រសំខាន់ៗដែលជាប់ទាក់ទងជាមួយការវាស់ស្ទង់តម្លាភាពដើម្បីឱ្យប័ណ្ណពាយការណ៍ផ្អែកលើការយល់ដឹងដែលបានព្រមព្រៀងជាទូទៅអំពីតម្លាភាព និងការទំនាក់ទំនងរវាងតម្លាភាព និងគណ-នេយ្យភាព។ ធ្វើឱ្យពួកគេយល់ដឹងច្បាស់លាស់នូវគោលបំណងនៃប័ណ្ណពាយការណ៍ និងរបៀបដែលត្រូវប្រើ និងកំណត់ឱ្យបានច្បាស់លាស់នូវអ្វីដែលនឹងត្រូវវាយតម្លៃ។<br><br>ត្រូវមានការសម្រេចចិត្តអំពីចំនួនសំណួរដោយគិតគូរចំណុចដូចតទៅ៖ ទំហំកម្រិតនៃភាពជាក់លាក់ដែលចង់បានបញ្ហាស្តីពីលទ្ធភាពអនុវត្ត និងលទ្ធភាពអាចរកព័ត៌មានបាន ព្រមទាំងអ្នកចូលរួម។ សំខាន់ត្រូវពណ៌នាឱ្យច្បាស់លាស់អំពីលក្ខណៈវិនិច្ឆ័យនិងសូចនាករនានាដែលបានប្រើ ព្រមទាំងពន្យល់ហេតុផល។<br>ការធ្វើបែបនេះនឹងផ្តល់ការជឿជាក់លើការស្រាវជ្រាវក៏ដូចជាជួយក្នុងការពន្យល់លទ្ធផលដែលបានរកឃើញ។<br>**ដំណាក់កាលទី២៖ ការបំពេញប័ណ្ណពាយការណ៍**<br>អាស្រ័យលើគោលបំណងដែលបានព្រមព្រៀង ដៃគូ គម្រោងប្រើកម្រងសំណួរចម្រុះ ការស្ទង់មតិតាមបែបគុណភាព ការសម្ភាស និងការពិនិត្យឯកសារដើម្បីបំពេញប័ណ្ណពាយការណ៍ចាប់យកទស្សនៈចម្រុះនៃសង្គមស៊ីវិល មន្ត្រីរដ្ឋ និងរដ្ឋាភិបាលព្រមទាំងក្រុមហ៊ុនឯកជន។ ផ្នែកសំខាន់មួយនៃដំណើរការនេះគឺដើម្បីវាយតម្លៃថាឯកសារណាខ្លះស្ថិតក្នុងដែនសាធារណៈដើម្បីកំណត់វិសាលភាពដែលអាជ្ញាធរបំពេញកាតព្វកិច្ចដោយតម្លាភាព។<br>**ដំណាក់កាលទី៣៖ ការវិភាគ និងសុពលភាព**<br>ដៃគូគម្រោងបញ្ជាក់ភាពត្រឹមត្រូវនៃចម្លើយរបស់ភាគីតបនឹងកម្រងសំណួរ ឬកិច្ចសម្ភាសន៍ដោយស្នើសុំឱ្យផ្តល់ឧទាហរណ៍ និងភស្តុតាង ក៏ដូចជាតាមរយៈ ការប្រៀបធៀបអត្ថិភាព និងគុណភាពនៃឯកសារតាមអ៊ីនធឺណិតឬការិយាល័យនានារបស់រដ្ឋាភិបាល។ រាល់ព័ត៌មានដែលបានប្រមូលត្រូវពិនិត្យឡើងវិញ និងវិភាគកម្មវត្ថុចម្បង ( Themes ) និងសូចនាករដែលបានឯកភាពគ្នា។<br>**ដំណាក់កាលទី៤៖ ការតាមពិនិត្យបន្ត និងការតស៊ូមតិ**<br>សម្រាប់ដៃគូគម្រោងតាមពិនិត្យបន្តគឺកំណត់ចំណុចសំខាន់ និងមានភាពងាយស្រួលក្នុងការបញ្ចុះបញ្ចូលអាជ្ញាធរឱ្យបោះពុម្ពផ្សាយសម្រាប់សង្គមស៊ីវិល ស្ថាប័នព្រៃឈើរបស់រដ្ឋ និងអាជីវករវិស័យឯកជន ។<br>**ដំណាក់កាលទី៥៖ ធ្វើម្តងហើយម្តងទៀតរៀងរាល់ឆ្នាំ**<br>ខណៈពេលដែលកិច្ចការនេះមានតម្លៃៗពិសេសរបស់វាក្នុងឋានៈជាឧបករណ៍តាមដានកើតមាននៅពេលដែលប័ណ្ណពាយការណ៍ត្រូវបានធ្វើឡើងវិញជារៀងរាល់ឆ្នាំ ដោយអនុញ្ញាឱ្យមានការផ្លាស់ប្តូរដែលត្រូវចងក្រងជាឯកសារពីពេលមួយទៅពេលមួយ។ ការផ្លាស់ប្តូរជាវិជ្ជមានអាចទទួលបាននូវការអបអរសាទរ បញ្ហាមិនអាចដោះស្រាយបានត្រូវបានកត់សម្គាល់ រីឯការផ្លាស់ប្តូរអវិជ្ជមានត្រូវបានគរ។ ដំណើរការនេះក៏អាចផ្តល់នូវវេទិកាមួយដ៏មានតម្លៃសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងវិស័យព្រៃឈើឱ្យរួមគ្នានិងពិភាក្សារកវិធីធ្វើឱ្យការប្រើប្រាស់ព័ត៌មានឱ្យបានកាន់តែប្រសើរ នៅពេលមានព័ត៌មាន។ |
| **ព្រំដែននិងកំណត់សម្គាល់** | មុនពេលការចាប់ផ្តើម ត្រូវឱ្យច្បាស់លាស់អំពីគោលបំណងនៃប័ណ្ណពាយការណ៍ ពិសេសគឺភាពខុសគ្នារវាងទស្សនៈរបស់ប្រជាពលរដ្ឋ និងវត្តមានជាក់ស្តែងនៃការឯកសារ - និងរបៀបប្រើប្រាស់ព័ត៌មាន។<br>ចាំបាច់ត្រូវពិចារណាហេតុផលចំពោះការវាយតម្លៃរបស់ប្រជាជនដោយមានឧទាហរណ៍ និងភស្តុតាងឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន។ |
| **ព័ត៌មានបន្ថែម** | Making the Forest Sector Transparent http://www.foresttransparency.info<br>Global Witness. 2010. Making the forest sector transparent: annual transparency report 2009. London. www.foresttransparency.info/cms/file/231<br>Global Witness. 2011. Making the forest sector transparent: annual transparency report 2010. London. http://www.foresttransparency.info/cms/file/419<br>Global Witness. 2012. Fourth annual report. London. http://www.foresttranspar ency.info/cms/file/541 |

**XL D1.6**
ផ្នែកស៊ីជម្រៅនៃ D1.6

## ការទទួលបានព័ត៌មានសាធារណៈ (API)

**API ជាអ្វី?**

ប្រអប់ឧបករណ៍ស្ដីពីការទទួលបានព័ត៌មាន (API) សាធារណៈគឺជាសំណុំនៃឧបករណ៍សម្រាប់ទទួលបានព័ត៌មាននៅតាមស្ថាប័នសាធារណៈ (រដ្ឋាភិបាល) ដើម្បីកែលម្អអភិបាលកិច្ច។

ខណៈពេលដែលការទទួលព័ត៌មានសាធារណៈជាប្រការដែលគួរឱ្យចង់បានក៏ដោយ ប៉ុន្តែមិនមែនតែងតែទទួលបានដោយងាយស្រួលនោះទេ។ សម្ភារឧបទេស API ត្រូវបានរចនាឡើងដើម្បីជួយជម្នះឧបសគ្គជាមួយនឹងឧបករណ៍ជាច្រើនដែលត្រូវបានប្រើប្រាស់ដោយជោគជ័យកន្លងមកនេះ ដោយអង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនមួយចំនួននៅក្នុងប្រទេសឥណ្ឌា។

**តើគេអាចប្រើ API សម្រាប់ធ្វើអ្វី?**

គេអាចប្រើសម្ភារឧបទេស API ក្នុងស្ថានភាពជាច្រើន នៅពេលដែលជារណជនមាន "សិទ្ធិក្នុងការដឹង"។ ស្ថានភាពមួយចំនួននៃស្ថានភាពទាំងនោះគឺ៖

- ជានាសិទ្ធិដីធ្លី។ ក្នុងករណីដែលប័ណ្ណកម្មសិទ្ធិដីមិនច្បាស់លាស់ សហគមន៍ជាច្រើនដូចជាកុលសម្ព័ន្ធនានាដែលរស់នៅក្នុងព្រៃ ប្រឈមមុខនឹងការគំរាមកំហែងនៃការបណ្ដេញចេញ បើទោះបីបានរស់នៅក្នុងតំបន់នេះរាប់ជំនាន់មកហើយក្ដី។ គេអាចប្រើសម្ភារឧបទេស API សម្រាប់ទប់ទល់នឹងការដោយទទួលបាន និងពិនិត្យមើលកំណត់ត្រានានាទាក់ទងទៅនឹងស្ថានភាពនៃបេបកម្មសិទ្ធិដីធ្លី និងព្រៃឈើ។
- ការពារបរិស្ថាន។ ប្រជាពលរដ្ឋមានការពាក់ព័ន្ធអាចស្វែងរកព័ត៌មានទាក់ទងនឹងបញ្ហាដូចជាការបំពុលបរិស្ថាន ឬការរេចរឹលធនធាន។ សហគមន៍អាចប្រើប្រាស់ព័ត៌មាននេះ ដើម្បីការពារ និងលើកកម្ពស់បរិស្ថានធម្មជាតិរបស់ពួកគេ។
- សំណងត្រឹមត្រូវ និងការស្ដារនីតិសម្បទា។ គេអាចប្រើក្បួនណែនាំ API ដើម្បីធានាសំណងឱ្យបានត្រឹមត្រូវ និងធានាការស្ដារនីតិសម្បទាចំពោះប្រជាជនដែលរងផលប៉ះពាល់ដោយគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងឧស្សាហកម្មធំ។ ជាមួយគ្នានេះគេក៏អាចប្រើសម្ភារឧបទេសនេះ ដើម្បីធានាយុត្តិធម៌ដល់ជនរងគ្រោះនៃគ្រោះថ្នាក់ឧស្សាហកម្ម និងគ្រោះមហន្តរាយផងដែរ។

**នរណាប្រើប្រាស់ API**

សម្ភារឧបទេស API ត្រូវបានផ្ដោតជាចម្បងចំពោះអង្គការមិនមែនរដ្ឋាភិបាល សកម្មជន និងក្រុមអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការលើការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ចវិមជ្ឈការក៏ដូចជាបញ្ហាជីវភាពរស់នៅ។ សម្ភារឧបទេស API នឹងមានប្រយោជន៍ពិសេសសម្រាប់បុគ្គល និងអង្គការដែលធ្វើការលើសិទ្ធិមនុស្ស យុត្តិធម៌ និងបញ្ហាអំពើពុករលួយ។ សមាជិកសហគមន៍ (ជាលក្ខណៈបុគ្គល ឬសមូហភាព) ក៏អាចប្រើសំណុំឧបករណ៍ API នេះផងដែរ។

សំណុំឧបករណ៍ API នឹងមានប្រយោជន៍ជាពិសេសសម្រាប់ អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនដែលធ្វើការក្នុងបណ្ដាប្រទេស ឬតំបន់ដែលសិទ្ធិក្នុងការទទួលព័ត៌មាន (RTI) ត្រូវបានផ្ដល់នៅលើក្រដាស ប៉ុន្តែការអនុវត្តជាក់ស្ដែងរបស់ប្រទេសទាំងនោះមិនបានល្អ។ ខណៈពេលដែលបរិយាកាសអំណោយផលក្នុងទម្រង់ជាច្បាប់ RTI ជាក់លាក់ណាមួយអាចជួយបាន គេក៏អាចប្រើប្រាស់ក្បួនណែនាំ API ប្រកបដោយប្រសិទ្ធភាពនៅតាមតំបន់ ឬប្រទេសដែលគ្មានច្បាប់ជាក់លាក់ស្ដីពី RTI ។ ក្នុងករណីបែបនេះគួរិះរកមធ្យោបាយដទៃទៀតក្នុងការទទួលបានព័ត៌មាន។

**ជំនាញនិងធនធានដែលត្រូវការ**

ជំនាញរួមមាន៖

- ការយល់ដឹងពីច្បាប់ និងគោលនយោបាយមូលដ្ឋាន
- ការទទួលបានប្រភពនៃព័ត៌មាន
- ការកសាងសមត្ថភាពលើបណ្ដាផ្នែកខាងលើ
- ជំនាញក្នុងការប្រើប្រាស់ព័ត៌មានដើម្បីឱ្យមានការផ្លាស់ប្ដូរដែលចង់បានដូចជាការធ្វើសវនាការសាធារណៈជាដើម។

**របៀបដែលគេអាចប្រើវាបាន**

ការប្រើប្រាស់វិធីសាស្ត្រ API ពាក់ព័ន្ធនឹងជំហានជាបន្តបន្ទាប់ដែលអាចចាត់ថ្នាក់ទូទៅជាពីរដំណាក់កាល៖ ដំណាក់កាលត្រៀម និងដំណាក់កាលអនុវត្ត។

**ដំណាក់កាលទី១៖ ដំណាក់កាលត្រៀមលក្ខណៈ**

ដើម្បីប្រើប្រាស់សម្ភារឧបទេស API ដោយប្រសិទ្ធភាពសំខាន់ត្រូវយល់ដឹងពីបរិបទច្បាប់ និងគោលនយោបាយក្នុងស្រុកដែលអនុញ្ញាតឱ្យទទួលព័ត៌មានពីស្ថាប័នរបស់រដ្ឋាភិបាល។ ចំណុចនេះពាក់ព័ន្ធនឹងការអប់រំ ការឈ្វេងយល់ជាក់ស្តែង និងបទពិសោធន៍ - "គំរូ 3-E"។

- ការអប់រំ៖ សិក្សាច្បាប់ស្តីពី RTI និងច្បាប់ពាក់ព័ន្ធដទៃទៀត ច្បាប់រដ្ឋធម្មនុញ្ញ បទបញ្ញារដ្ឋបាល និងនីតិវិធីនានាក៏ដូចជាការបកស្រាយតាមផ្លូវច្បាប់។
- ការឈ្វេងយល់ជាក់ស្តែង៖ ការឈ្វេងយល់អំពីអង្គការ និងបុគ្គលផ្សេងៗដែលកំពុងធ្វើការលើបញ្ហាស្រដៀងគ្នា ដើម្បីយល់ដឹងអំពីយុទ្ធសាស្ត្រ និងយុទ្ធវិធីក៏ដូចជាការចងបណ្តាញជាមួយនឹងពួកគេដើម្បីទទួលបានការគាំទ្រ។
- បទពិសោធន៍៖ បទពិសោធន៍កន្លងមកក៏ដូចជាដំណើរការកំពុងកើតមានអាចផ្តល់មេរៀនដែលមានតម្លៃអំពីរបៀបប្រើសំណុំវិធី API ឱ្យមានប្រសិទ្ធភាព។ ការវិនិច្ឆ័យកន្លងមក បទពិសោធន៍របស់អង្គការដទៃទៀត និងរឿងទទួលបានជោគជ័យ ក៏ដូចជាបរាជ័យទាំងអស់សុទ្ធតែអាចជាព័ត៌មាន។

**ដំណាក់កាលទី២៖ ដំណាក់កាលអនុវត្ត**

នៅក្នុងដំណាក់កាលនេះ មានបីជំហានដ៏ធំទូលាយ គឺមានការកសាងការយល់ដឹង និងការកសាងសមត្ថភាពរបស់ក្រុមគោលដៅ ការចូលរួមក្នុងដំណើរការទទួលព័ត៌មាន និងការប្រើប្រាស់ព័ត៌មានដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរដែលប្រាថ្នាចង់បាន។

- ការកសាងសមត្ថភាព និងការយល់ដឹង។ គេអាចប្រើសម្ភារឧបទេស API យ៉ាងមានប្រសិទ្ធភាពប្រសិនបើប្រជាពលរដ្ឋ មានការយល់ដឹងអំពីសិទ្ធិរបស់ពួកគេហើយចាប់ផ្តើមអនុវត្តសិទ្ធិ ទាំងនោះ។ សំខាន់អង្គការក្រៅរដ្ឋាភិបាល និងសកម្មជនកសាង ការយល់ដឹងអំពីអំណាចនៃវិធីសាស្ត្រ API ក្នុងចំណោមក្រុមគោលដៅរបស់ពួកគេ។ គេអាចប្រើយុទ្ធសាស្ត្រមួយចំនួន ដូចជាការបង្កើតមជ្ឈមណ្ឌលព័ត៌មាន ឬការបង្កើត និងការផ្សព្វផ្សាយ កូនសៀវភៅផ្ទាំងរូបភាព និងក្រាហ្វិក។ នៅក្នុងតំបន់ដែលមនុស្សជាច្រើនមិនចេះអក្សរ កិច្ចប្រជុំបទចម្រៀង ការសម្តែងតាមដងផ្លូវ និងការបង្ហាញអាយ៉ងជាវិធីមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះគេក៏អាចកសាងសមត្ថភាពតាមរយៈអន្តរកម្មមួយទល់មួយ កម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ។
- ការចូលរួមនៅក្នុងដំណើរការទទួលព័ត៌មាន។ ដំណាក់កាលនេះពាក់ព័ន្ធនឹងការរកឱ្យឃើញនូវព័ត៌មានពិតប្រាកដ ប្រភពនៃព័ត៌មាននិងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ពួកគេ ហើយបន្ទាប់មកធ្វើសេចក្តីព្រាងសំណួរដើម្បីទទួលបានជាក់ព័ត៌មានដែលត្រូវទទួល។ ព្រោះថាសំណើមិនច្បាស់លាស់ ឬសំណើទូទៅមិនសូវមានប្រសិទ្ធភាពឡើយ សំខាន់ត្រូវមានលក្ខណៈជាក់លាក់នៅពេលស្នើសុំព័ត៌មាន។
- ការប្រើព័ត៌មានដើម្បីនាំមកនូវការផ្លាស់ប្តូរដែលចង់បាន។ នៅពេលណាដែលបានប្រមូលព័ត៌មានរួចហើយនោះ ជំហានបន្ទាប់គឺត្រូវផ្ទៀងផ្ទាត់ព័ត៌មានតាមរយៈអន្តរកម្មជាមួយបុគ្គល ឬសហគមន៍ពាក់ព័ន្ធរួចហើយប្រើព័ត៌មានទាំងនោះឱ្យនាំមកនូវការផ្លាស់ប្តូរ។ គេអាចផ្ទៀងផ្ទាត់ព័ត៌មានរដ្ឋាភិបាលតាមរយៈមធ្យោបាយនានា ដូចជាសវនកម្មសង្គម (ការតាមដានការផ្តល់សេវាដោយសមាជិកសហគមន៍មូលដ្ឋាន) បញ្ជីវត្តមានស្របគ្នា (បញ្ជីដែលរក្សាទុកដោយសមាជិកសហ-គមន៍) និងកំណត់ត្រាផ្សេងទៀតដែលរក្សាទុកដោយបុគ្គល និងសហគមន៍សក្ខីកម្ម និងអធិការកិច្ចនៅនឹងកន្លែង។ យុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាព ក្នុងការផ្លាស់ប្តូរ ឥរិយាបថនិងការប្រព្រឹត្តរបស់មន្ត្រីរដ្ឋាភិបាលគឺសវនាការជាសាធារណៈ (សូមមើលឧបករណ៍D2.4) ឬយុទ្ធនាការចុះហត្ថលេខា។

ប្រសិនបើទាំងអស់នេះទទួលបរាជ័យ ឧបាស្រ័យទៅកាន់តុលាការ គឺជាជម្រើសមួយ ដែលគេអាចអនុវត្តបាន។

**ព្រំដែននិងកំណត់សម្គាល់**

នៅក្នុងករណីដែលការបង្ហាញព័ត៌មានទំនងជាធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់អ្នកមានអំណាច ការព្យាយាមទទួលព័ត៌មានអាចនាំទៅកាន់ការសងសឹករាប់ទាំងអំពើហិង្សាផងដែរ។

**ព័ត៌មានបន្ថែម**

Winrock International India. 2005. Accessing 'public' information. Power Tools Series. New Delhi, Winrock International India, and London, IIED. http://www. policy-powertools.org/Tools/Ensuring/API.html

Article 19. 1999. The public’s right to know: principles on freedom of information legislation. London. http://www.article19.org/pdfs/standards/righttoknow. pdf

National Campaign for people’s right to information, India. http://right toinformation.info/

# ឧបសម្ព័ន្ធ២៖ សន្ទានុក្រម

**ការទទួលបានព័ត៌មាន** ( Access to information )

សំដៅដល់សិទ្ធិទទួលបានព័ត៌មានក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ គោលការណ៍នេះ មានន័យថា សាធារណជនអាចរកបាននូវព័ត៌មាន រដ្ឋាភិបាល (ដោយមានការលើកលែងតាមការចាំបាច់ ហើយការលើកលែងទាំងនោះគប្បីមានចំនួនតិចតួច និងជាក់លាក់) ជាមួយគ្នានេះ សេចក្តីសម្រេចចិត្តក្នុងការបញ្ចេញព័ត៌មានណាមួយរបស់រដ្ឋាភិបាល ជានិច្ចកាលគប្បីត្រូវបានពិនិត្យមើលឡើងវិញដោយឯករាជ្យ មិនចំណុះរដ្ឋាភិបាល។ ការទទួលបានព័ត៌មាន បង្កលក្ខណៈឱ្យប្រជាពលរដ្ឋឃ្លាំមើល ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងបង្កើនការត្រួតពិនិត្យ ព្រមទាំងធ្វើឱ្យមានតុល្យភាពដើម្បីផលប្រយោជន៍សាធារណៈ សំដៅកាត់បន្ថយឥទ្ធិពលហួសហេតុរបស់ក្រុមអ្នកមានបុព្វសិទ្ធិ និងកាត់បន្ថយភាពងាយនឹងប្រព្រឹត្តអំពើពុករលួយ។

**គណនេយ្យភាព** ( Accountability )

មានន័យថាការតម្រូវឱ្យប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈទទួលខុសត្រូវចំពោះទង្វើ និងសេចក្តីសម្រេចចិត្តរបស់ខ្លួនស្របតាមគោលការណ៍នីតិរដ្ឋ។ គណនេយ្យភាពអាចអនុវត្តតាម ទិសដៅពីរ។ គណនេយ្យភាពពីលើចុះក្រោម តម្រូវឱ្យបុគ្គល ឬស្ថាប័នដែលមានការទទួលខុសត្រូវជាក់លាក់ចំពោះបុគ្គលដទៃ ត្រូវតែអាចឆ្លើយតបទៅកាន់បុគ្គលទាំងនោះចំពោះរាល់ទង្វើនានារបស់ខ្លួន។ គណនេយ្យភាព ពីក្រោមឡើងលើ តម្រូវឱ្យអ្នកទទួលសេវា ឬអ្នកដែលទទួលបានការប្តេជ្ញាឬសន្យា ត្រួតពិនិត្យថាតើអ្វីៗគឺដំណើរការទៅតាមផែនការ ហើយត្រូវតែស្វែងរកការពន្យល់សមស្រប ប្រសិនបើមិនបានដំណើរការដូចការគ្រោងទុក ហើយប្រសិនបើចាំបាច់ត្រូវធ្វើការជ្រើសតាំង អ្នកដែលមានសមត្ថភាពពិតប្រាកដឱ្យមកបំពេញមុខងាររបស់ខ្លួន។

**កសិរុក្ខកម្ម** ( Agroforestry )

ជាសមាសនាមចំពោះប្រព័ន្ធប្រើប្រាស់ដីធ្លី និងកិច្ចប្រតិបត្តិនានាដែលដំណាំដើមឈើដែលមានអាយុកាលវែងត្រូវបានគេយកមកដាំជាមួយដំណាំកសិកម្ម និង/ឬការចិញ្ចឹមសត្វនៅលើផ្ទៃដីតែមួយ។ ការរួមបញ្ចូលគ្នានេះអាចមានលក្ខណៈជាដាំឃ្លាតគ្នា ( spatial mixture ) ឬដាំបន្តបន្ទាប់គ្នា ( temporal sequence ) ។ តាមធម្មតានៅក្នុងកសិរុក្ខកម្មទម្រង់ទាំងពីរនេះ មានទំនាក់ទំនងផ្នែកបរិស្ថាន និងសេដ្ឋកិច្ចរវាងសមាសភាពរុក្ខជាតិ និងមិនមែន រុក្ខជាតិ ។

**សហព័ន្ធ** ( Alliance )

សំដៅដល់កិច្ចព្រមព្រៀងរវាងភាគីពីរ ឬច្រើនជាងនេះ ដែលត្រូវបានរៀបចំឡើងដើម្បីឈានទៅសម្រេចបាន នូវគោលដៅ និងប្រយោជន៍រួម។

**ជីវចម្រុះ ឬជីវសាស្ត្រចម្រុះ** ( Biodiversity or Biological Diversity )

គឺជាបច្ចេកសព្ទមួយដែលត្រូវបានប្រើប្រាស់ដើម្បីពណ៌នាអំពីជីវិតនានានៅលើភពផែនដី។ ពាក្យនេះយោងដល់ ប្រភេទទូលំទូលាយ និងភាពប្រែប្រួលធំធេងនៃប្រព័ន្ធអេកូឡូស៊ី និងភាវៈរស់រួមមាន៖ សត្វ រុក្ខជាតិ ជម្រក និងហ្សែន នៃសត្វ និងរុក្ខជាតិទាំងនោះ។

**មជ្ឈដ្ឋានស្រូប និងប្រភពបញ្ចេញកាបូន** ( Carbon sinks and sources )

មជ្ឈដ្ឋានស្រូបកាបូន គឺជាគុទាំងឡាយណាដែលស្រូបយកកាបូនច្រើនជាងបញ្ចេញកាបូន ចំណែកឯប្រភពកាបូនជាមជ្ឈដ្ឋានទាំងឡាយណា ដែលបញ្ចេញកាបូនច្រើនជាងស្រូបយកកាបូន។ ព្រៃ ដី សមុទ្រ និងបរិយាកាស ទាំងអស់នេះសុទ្ធសឹងផ្ទុកកាបូន ហើយកាបូននេះផ្លាស់ទីរវាងមជ្ឈដ្ឋានទាំងនេះក្នុងវដ្តប្រែប្រួលជាបន្តបន្ទាប់។ចលនាមិនប្រែប្រួលនៃកាបូនមានន័យថាព្រៃដើរតួជាប្រភពកាបូន ឬជាមជ្ឈដ្ឋានស្រូបយកកាបូនក្នុងពេលផ្សេងគ្នា។

**សន្និធិកាបូន** ( **Carbon Stock** )

សំដៅដល់បរិមាណកាបូនដែលមាននៅក្នុង "អាងប្រមូលផ្តុំ" មួយ ពោលគឺអាងស្តុក ឬប្រព័ន្ធមួយដែលអាចបង្កើនជាបន្តបន្ទាប់ ឬបញ្ចេញកាបូន។ ក្នុងបរិបទនៃព្រៃឈើ ពាក្យនេះសំដៅដល់បរិមាណកាបូនដែលមាននៅក្នុងប្រព័ន្ធបរិស្ថានព្រៃឈើពិភពលោក ពិសេសនៅក្នុងជីវម៉ាស់រស់ និងនៅក្នុងដី ហើយក៏មានខ្លះៗផងដែរនៅក្នុងឈើងាប់ និងសំរាម។

**សម្ព័ន្ធភាព** ( **Coalition** )

សំដៅដល់កតិកាសញ្ញា ឬសន្ធិសញ្ញារវាងបុគ្គល ឬក្រុមក្នុងអំឡុងពេលដែលពួកគេធ្វើសហប្រតិបត្តិការក្នុងសកម្មភាពរួមគ្នាដើម្បីទទួលបាននូវផលប្រយោជន៍ផ្ទាល់របស់ពួកគេ ជាការរួមកម្លាំងគ្នាដើម្បីសម្រេចបាននូវបុព្វហេតុរួម។

**សង្គមស៊ីវិល** ( **Civil Society** )

សំដៅដល់មជ្ឈដ្ឋានដែលប្រជាពលរដ្ឋ និងចលនាសង្គមរៀបចំចាត់ចែងដោយខ្លួនឯងជុំវិញគោលដៅមណ្ឌលគាំទ្រ និងចំណាប់អារម្មណ៍តាមផ្នែកសំខាន់ៗ។

**ព្រៃឈើនៅសហគមន៍** ( **Community-based Forestry** )

សំដៅដល់ ការគ្រប់គ្រងព្រៃឈើដែលអនុវត្តលើព្រៃសហគមន៍ដោយមានការព្រមព្រៀងពីសហគមន៍ ឬនៅតំបន់ព្រៃដែលត្រូវបានទទួលស្គាល់ នៅមូលដ្ឋានក្នុងទំនាក់ទំនងជាមួយសមាជិកនានា ក្នុងសហគមន៍តែមួយដែលសម្របសម្រួលកិច្ចប្រឹងប្រែងនានា ដើម្បីគ្រប់គ្រងធនធានព្រៃឈើ និង/ឬលក់ផលិតផលព្រៃឈើ។

**ការកែលម្អជាបន្តបន្ទាប់** ( **Continuous Improvement** )

គឺជាការតាមដានដែលមានលក្ខណៈជាប្រព័ន្ធ និងការវិភាគអភិបាលកិច្ចលើសិទ្ធិកាន់កាប់ និងការធ្វើកំណែទម្រង់។

**សិទ្ធិកាន់កាប់តាមបែបប្រពៃណី** ( **Customary Tenure Rights** )

រួមមាន សិទ្ធិសមូហភាពរបស់សមាជិកសហគមន៍ចំពោះសម្បត្តិធម្មជាតិ ក៏ដូចជា សិទ្ធិឯកជនរបស់សមាជិកសហគមន៍ចំពោះដីកសិកម្ម និងដីលំនៅដ្ឋានផងដែរ។ នៅប្រទេសមួយចំនួនសិទ្ធិកាន់កាប់តាមបែបប្រពៃណីត្រូវបានទទួលស្គាល់ជាផ្លូវការស្របច្បាប់ ដូចសិទ្ធិកាន់កាប់តាមច្បាប់ដទៃទៀតដែរ ប៉ុន្តែនៅប្រទេសខ្លះទៀតគ្មានការទទួលស្គាល់ជាផ្លូវការឡើយ។

**តាមព្រឹត្តិន័យ និងតាមផ្លូវច្បាប់** ( **De facto and de jure** )

De facto ជាពាក្យឡាតាំង មានន័យថា "ដែលទាក់ទងនឹងការពិត"។ តាមន័យច្បាប់ពាក្យនេះច្រើនមានន័យថា "ក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែពុំមែនសុទ្ធតែបញ្ញត្តិដោយច្បាប់នោះទេ" ឬ "ក្នុងការអនុវត្តជាក់ស្តែង ឬសភាពជាក់ស្តែង ប៉ុន្តែមិនត្រូវបានបង្កើតឡើងជាផ្លូវការនោះទេ" ។ ពាក្យនេះច្រើនត្រូវបានប្រើផ្ទុយពីតាមផ្លូវច្បាប់ (de jure) ដែលមានន័យថា "ដែលទាក់ទងនឹងផ្លូវច្បាប់" នៅពេលយោងដល់បញ្ហាច្បាប់ បញ្ហាអភិបាលកិច្ច ឬបញ្ហាបច្ចេកទេស (ដូចជាស្តង់ដារជាដើម) ដែលឃើញមាននៅក្នុងការអនុវត្តទូទៅ ប៉ុន្តែបានប្រព្រឹត្តទៅដោយគ្មាន ឬផ្ទុយនឹងបទប្បញ្ញត្តិណាមួយឡើយ។ ក្នុងកិច្ចពិភាក្សាអំពីទិដ្ឋភាពច្បាប់ តាមផ្លូវច្បាប់ សំដៅដល់អ្វីដែលច្បាប់ចែង ផ្ទុយទៅវិញ តាមព្រឹត្តិន័យសំដៅដល់អ្វីដែលកើតឡើងជាក់ស្តែង ដូចគ្នាទៅនឹងពាក្យថា "សម្រាប់ចេតនា និងគោលបំណងទាំងអស់" ឬពាក្យថា "តាមពិត"។

**ពាណិជ្ជកម្មដែលមានភាពយុត្តិធម៌** ( **Fair Trade** )

ភាពជាដៃគូពាណិជ្ជកម្ម ផ្អែកលើការពិភាក្សាតម្លាភាព និងការគោរពដែលស្វែងរកសមធម៌ នៅក្នុងពាណិជ្ជកម្មអន្តរជាតិ។ ពាណិជ្ជកម្មដែលមានភាពយុត្តិធម៌រួមចំណែកចំពោះការអភិវឌ្ឍដែលមាននិរន្តរភាព តាមរយៈការផ្តល់លក្ខខណ្ឌពាណិជ្ជកម្មកាន់តែប្រសើរទៅកាន់

ផលិតករ និងកម្មករតូចតាច ពិសេសនៅប្រទេសក្រីក្រ។ គ្រឹះស្ថានពាណិជ្ជកម្មដែលមានភាពយុត្តិធម៌ ទទួលការគាំទ្រពីសំណាក់អ្នកប្រើប្រាស់ ចូលរួមសកម្មក្នុងការគាំទ្រផលិតករ បង្កើនការយល់ដឹង និងធ្វើយុទ្ធនាការដើម្បីឱ្យមានការផ្លាស់ប្តូរវិធាន និងការធ្វើពាណិជ្ជកម្មអន្តរជាតិសាមញ្ញ។

**សហព័ន្ធ** ( Federation )

ជាការចូលរួមគ្នារវាងអង្គភាព ស្ថាប័នមួយដែលត្រូវបានបង្កើតឡើងដាច់ដោយឡែក ក្រុម ឬអង្គភាពឯករាជ្យនានា ក្នុងគោលបំណងរួមគ្នាគាំទ្រសកម្មភាពតែមួយ។

**វិញ្ញាបនបត្រព្រៃឈើ** ( Forest Certification )

គឺមួយក្នុងចំណោមលិខិតូបករណ៍ទីផ្សារមួយ ចំនួនដែលអាចរួមចំណែកក្នុងការលើកកម្ពស់ការគ្រប់គ្រងព្រៃឈើ និងលើក កម្ពស់ការអភិវឌ្ឍព្រៃឈើ។ គោលដៅគឺការផ្សាភ្ជាប់ពាណិជ្ជកម្មផលិតផលព្រៃឈើ ជាមួយនឹងការគ្រប់គ្រងធនធាន ព្រៃឈើប្រកបដោយនិរន្តរភាព តាមរយៈការផ្តល់ព័ត៌មានដល់អ្នកទិញអំពីស្តង់ដារនៃការគ្រប់គ្រងព្រៃឈើ ដែលជា ប្រភពនៃដើមឈើ។

**សហគ្រាសព្រៃឈើ** ( Forest Enterprise )

អាចជាសហគ្រាសពាណិជ្ជកម្ម សហករណ៍គ្រប់គ្រងដោយខ្លួនឯង សហគមន៍ជនជាតិដើមភាគតិច ឬទម្រង់ចាត់តាំងដទៃទៀត ដែលគ្រប់គ្រងព្រៃឈើដើម្បីប្រាក់ចំណេញជាមួយនឹងជម្រើស សកម្មភាពកែច្នៃផលិតផលព្រៃឈើបន្ថែម។

**ការយល់ព្រម ជាមុន ដោយស្ម័គ្រចិត្ត** ( Free, prior and informed consent )

ជាគោលការណ៍ដែលសហគមន៍មួយមានសិទ្ធិក្នុងការផ្តល់ ឬមិនផ្តល់ការយល់ព្រមចំពោះគម្រោងស្នើនានាដែលអាចប៉ះពាល់ដីធ្លីដែលសមាជិកសហគមន៍ធ្វើជាម្ចាស់កាន់កាប់ ឬប្រើប្រាស់។ សព្វថ្ងៃគោលការណ៍នេះជាគោលការណ៍សំខាន់នៅក្នុងច្បាប់អន្តរជាតិ និងយុត្តិសាស្ត្រ ( Juriprudence ) ទាក់ទងនឹងជនជាតិដើមភាគតិច។ គោលការណ៍នេះមានន័យថាអ្នកទាំងឡាយណា ដែលមានបំណងប្រើប្រាស់ដីព្រៃពណីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវធ្វើការចរចាជាមួយពួកគេ។ សហគមន៍គឺជាអ្នកមានសិទ្ធិសម្រេចថា តើពួកគេយល់ព្រមជាមួយគម្រោងនោះដែរ ឬយ៉ាងណានៅពេលណាដែលពួកគេមានការយល់ដឹងពេញលេញ និងត្រឹមត្រូវអំពីផលប៉ះពាល់របស់គម្រោងមកលើពួកគេ និងប៉ះពាល់ដល់ដីប្រពៃណីរបស់ខ្លួន។ ដូចតែងមានការបកស្រាយថា សិទ្ធិក្នុងការយល់ព្រមជាមុនដោយស្ម័គ្រចិត្ត គឺអនុញ្ញាតឱ្យពលរដ្ឋជនជាតិដើមភាគតិចឈានដល់ការមូលមតិគ្នា និងឈានដល់ការធ្វើសេចក្តីសម្រេចចិត្តស្របតាមប្រព័ន្ធប្រពៃណីនៃការសម្រេចចិត្ត។

**អភិបាលកិច្ច** ( Governance )

ជាដំណើរការនៃការគ្រប់គ្រង។ ជាវិធីដែលសង្គមត្រូវបានគ្រប់គ្រង និងរបៀបសម្រុះសម្រួលអាទិភាព និងផលប្រយោជន៍របស់ក្រុមផ្សេងគ្នា។ អភិបាលកិច្ចរួមមានស្ថាប័នផ្លូវការរបស់រដ្ឋាភិបាល ប៉ុន្តែក៏រួមមានការចាត់ចែងមិនផ្លូវការផងដែរ។ អភិបាលកិច្ចមានទំនាក់ទំនងជាមួយដំណើរការនានាក្នុងនោះប្រជាពលរដ្ឋចូលរួមក្នុងការសម្រេចចិត្ត តើរដ្ឋាភិបាលមានគណនេយ្យភាពយ៉ាងដូចម្តេចចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងវិធីដែលសង្គមតម្រូវឱ្យសមាជិករបស់ ខ្លួនសង្កេតមើលវិធាន និងច្បាប់នានា។អង្គការសហប្រជាជាតិព៌ណនា"អភិបាលកិច្ចល្អ" ថាជាការលើកកម្ពស់ សមធម៌ ការចូលរួម ពហុបក្សតម្លាភាព គណនេយ្យភាព និងនីតិរដ្ឋតាមបែបមួយដែលមានប្រសិទ្ធភាព ប្រសិទ្ធផល និងឋិតថេរ។

**ជនជាតិដើមភាគតិច** ( Indigenous People )

ជាក្រុមជាតិពន្ធុដែលត្រូវបានកំណត់ន័យថាជា "ជនជាតិដើមភាគតិច" យោងតាមនិយមន័យមួយនៃនិយមន័យនានា នៃពាក្យនេះ។ ភាគច្រើនពាក្យនេះសំដៅដល់ "និវាសជនដើម" នៃទឹកដីមួយ។ ពាក្យនេះត្រូវបានប្រើប្រាស់ចំពោះ ក្រុមជាតិពន្ធុដែលមានទំនាក់ទំនងប្រវត្តិសាស្ត្រជាមួយក្រុមនានា ដែលមានវត្តមាននៅលើទឹកដីមួយ មុនពេលអាណានិគម ឬមុនពេលបង្កើតរដ្ឋប្រជាជាតិ ហើយដែលជាធម្មតារក្សាកម្រិតមួយនៃការ

បែងចែកវប្បធម៌ និងនយោបាយពីចន្លេវប្បធម៌ និងពីប្រព័ន្ធនយោបាយចម្បងរបស់រដ្ឋប្រជាជាតិដែលជនជាតិដើមភាគតិចរស់នៅក្នុងព្រំដែនទាំងនោះ។ ន័យនយោបាយនៃពាក្យនេះផ្តល់និយមន័យក្រុមទាំងនេះថា មានភាពងាយរងគ្រោះបំផុតទៅនឹងការកេងប្រវ័ញ្ច និងការសង្កត់សង្កិនពីរដ្ឋប្រជាជាតិនានា។

**បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍** ( **Information and Communication Technologies** )

ជាសំណុំឧបករណ៍ និងធនធានបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់ ដើម្បីទំនាក់ទំនង និងបង្កើតផ្សព្វផ្សាយ ទុកដាក់ និងគ្រប់គ្រងព័ត៌មាន។ បច្ចេកវិទ្យាទាំងនេះរួមមានកុំព្យូទ័រ អ៊ិនធើណិត បច្ចេកវិទ្យាផ្សាយព័ត៌មាន(វិទ្យុ និងទូរទស្សន៍) និងទូរសព្ទ។

**ស្ថាប័ន** ( **Institution** )

សំដៅដល់រចនាសម្ព័ន្ធ ឬយន្តការណាមួយនៃសណ្តាប់ធ្នាប់សង្គម និងកិច្ចសហប្រតិបត្តិការស្តីពីការប្រព្រឹត្តរបស់បុគ្គលនានានៅក្នុងសហគមន៍មនុស្សណាមួយ ។ ពាក្យថា "ស្ថាប័ន" ត្រូវបានប្រើជាទូទៅចំពោះលំនាំប្រពៃណីនិងឥរិយាបទសំខាន់របស់សង្គមមួយ និងចំពោះការចាត់តាំងជាផ្លូវការដាក់លាក់របស់រដ្ឋាភិបាល និងសេវាសាធារណៈ។

**អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ** ( **International Conventions and Agreements** )

អាចប្រៀបប្រដូចកិច្ចសន្យា អនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងជាមធ្យោបាយរបស់គូភាគី ដែលមានសុឆន្ទៈក្នុងការបំពេញកាតព្វកិច្ចរវាងគ្នានិងគ្នា ហើយភាគីដែលមិនបានអនុវត្តតាមកាតព្វកិច្ចចែងក្នុងអនុសញ្ញា ឬក្នុងកិច្ចព្រមព្រៀង អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវតាមច្បាប់អន្តរជាតិ។ ចំពោះអភិបាលកិច្ច និងសិទ្ធិកាន់កាប់ព្រៃឈើ អនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងពាក់ព័ន្ធសំខាន់ៗបំផុតរួមមាន៖

- សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- សេចក្តីថ្លែងការណ៍របស់សហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

**ការតាមដាន និងការវាយតម្លៃ** ( **Monitoring and Evaluation** )

ជាដំណើរការនៃការប្រមូល និងវាយតម្លៃព័ត៌មាន ដើម្បីធ្វើការវិនិច្ឆ័យអំពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅ និងគោលបំណងព្រមទាំងកំណត់ផលវិបាកវិជ្ជមាន ឬអវិជ្ជមានដែលកើតឡើងដោយចៃដន្យពីទង្វើ។

**បណ្តាញ** ( **Network** )

សំដៅដល់យន្តការមួយដែលផ្សាភ្ជាប់មនុស្ស និង/ឬស្ថាប័នដែលមានគោលដៅរួមប្រហាក់ប្រហែលគ្នា។

**សណ្តាប់ធ្នាប់** ( **Organization** )

សំដៅដល់រចនាសម្ព័ន្ធជាក់លាក់ នៅក្នុងបរិបទសង្គម។

**ជំនួយការច្បាប់** ( **Paralegal** )

សំដៅដល់អ្នកមានគុណវុឌ្ឍិតាមរយៈការអប់រំ និងការបណ្តុះបណ្តាលដើម្បីធ្វើការងារសំខាន់ៗ ផ្នែកច្បាប់ដែលតម្រូវឱ្យមានចំណេះដឹងអំពីច្បាប់ និងនីតិវិធីនានា ហើយអ្នកនោះពុំមែនជាអ្នកច្បាប់ ឬពុំមែនជាមេធាវីដែលមានគុណវុឌ្ឍិឡើយ។

**ការតាមដាន និងការវាយតម្លៃដែលមានការចូលរួម** ( **Participatory Monitoring and Evaluation** )

ជាដំណើរការមួយ ដែលភាគីពាក់ព័ន្ធនៅតាមកម្រិតនានាចូលរួមក្នុងការតាមដាន ឬក្នុងការវាយតម្លៃគម្រោងកម្មវិធី ឬគោលនយោបាយណាមួយ។ ជាការចូលរួមគ្រប់គ្រងលើខ្លឹមសារដំណើរការ និងលទ្ធផលនៃសកម្មភាព

តាមដាន និងវាយតម្លៃរួចចាត់វិធានការ ឬកំណត់សកម្មភាពកែតម្រូវ។

**ការបង់ថ្លៃសេវាបរិស្ថាន** ( **Payments for Environmental Services** )

សំដៅដល់យន្តការលើកទឹកចិត្តដែលច្រើនតែផ្អែកលើទីផ្សារខណៈដែលកសិករ ម្ចាស់ព្រៃ ឬម្ចាស់ដីត្រូវបានផ្តល់ប្រាក់លើកទឹកចិត្តចំពោះការគ្រប់គ្រងដី ឬព្រៃឈើរបស់ពួកគេ ក្នុងការផ្តល់សេវាជាក់លាក់ ដូចជា ដំណើរការចាប់យក និងរក្សាទុកកាបូន (Carbon sequestration) ការការពារទីជម្រាល ការអភិរក្សជីវចម្រុះ ឬសោភ័ណភាពទេសភាព។

**វិស័យឯកជន** ( **Private Sector** )

សំដៅដល់ផ្នែកនៃសេដ្ឋកិច្ច ដែលដំណើរការដោយបុគ្គល ឬក្រុមឯកជន តាមធម្មតាជាមធ្យោបាយសហគ្រាសរកប្រាក់ចំណេញ ហើយមិនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋឡើយ។

**វិស័យសាធារណៈ** ( **Public Sector** )

ជួនកាលសំដៅដល់វិស័យរដ្ឋ ឬវិស័យរដ្ឋាភិបាល។ វិស័យសាធារណៈជាផ្នែករបស់រដ្ឋ ដែលចាត់ចែងទំនិញ និងសេវា សម្រាប់រដ្ឋាភិបាល និងពលរដ្ឋនៃវិស័យសាធារណៈ។

**ការកាត់បន្ថយការបំភាយឧស្ម័នពីការបំផ្លាញព្រៃឈើ និងការខូចគុណភាពព្រៃឈើ** ( **Reducing Emissions from Deforestation and Forest Degradation, REDD** )

គឺជាកិច្ចប្រឹងប្រែងក្នុងការបង្កើតតម្លៃហិរញ្ញវត្ថុចំពោះកាបូនដែលស្តុកទុកក្នុងព្រៃ តាមរយៈការផ្តល់ប្រាក់លើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៍ឱ្យកាត់បន្ថយការបំភាយឧស្ម័នពីដីដែលមានព្រៃឈើ និងវិនិយោគលើគន្លង កាបូនទាប (Low-carbon paths) ដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព។ REDD+មានទំហំធំជាងការកាប់បំផ្លាញព្រៃឈើ និងការខូចគុណភាពព្រៃឈើទៅទៀត និងរួមមានមុខងារអភិរក្ស ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការលើកកម្ពស់សន្និធិកាបូនព្រៃឈើ។

**សហគ្រាសព្រៃឈើធុនតូច** ( **Small Forest Enterprise** )

សំដៅដល់ប្រតិបត្តិការអាជីវកម្មធុនតូចដែលស្វែងរកប្រាក់ចំណេញពីសកម្មភាពពាក់ព័ន្ធនឹងព្រៃឈើ។ និយមន័យជាក់លាក់នៃទំហំមានការប្រែប្រួល ហើយច្រើនតែទាក់ទងនឹងបរិបទ ដូចជា នៅក្នុងបរិបទមួយចំនួនសហគ្រាសព្រៃឈើធុនតូចអាចមាននិយោជិតធ្វើការពេញម៉ោង ១០-១០០នាក់ ដែលមានចំណូលពី ១០,០០០ ដុល្លារអាមេរិក-៣០លានដុល្លារអាមេរិក ឬប្រើឈើមូលពី ៣,០០០-២០,០០០ម៉ែត្រគូប។ ក្នុងបរិបទផ្សេងទៀតសហគ្រាសទាំងនោះអាចជាសហគ្រាសដែលសកម្មភាពសេដ្ឋកិច្ចប្រព្រឹត្តទៅជាចម្បងនៅកម្រិតបុគ្គល ឬកម្រិតគ្រួសារ តាមធម្មតាប្រើសមាជិកគ្រួសារ ឬសាច់ញាតិ និងអ្នកជិតខាងហើយផ្តល់ប្រាក់ឈ្នួលតិចតួច។

**ផលិតករខ្នាតតូច** ( **Small-scale Producers** )

ជាក្រុមជនធ្វើការដោយខ្លួនឯងដូចជា ឬគ្រប់គ្រងព្រៃឈើឈានទៅរកការផលិតដើមឈើ ឬការប្តូរទ្រង់ទ្រាយដើមឈើដោយរណារ ឬរោងម៉ាស៊ីនអារឈើចល័តនៅក្នុងព្រៃដែលរួមចំណែកចំពោះការចាប់ផ្តើមខ្សែសង្វាក់តម្លៃចំពោះផលិតផលព្រៃឈើ ប៉ុន្តែមិនមែនជាអ្នកដែលត្រូវបានជួល ឬប្រើផ្ទាល់ដោយសហគ្រាសព្រៃឈើណាមួយនោះទេ។

**ភាគីពាក់ព័ន្ធ** ( **Stakeholder** )

នៅក្នុងបរិបទនៃសិទ្ធិ និងសិទ្ធិកាន់កាប់ព្រៃឈើ សំដៅដល់បុគ្គល ឬសហគមន៍ ក្រុម ឬស្ថាប័ន សង្គមដែលកំពុងមានសិទ្ធិផ្លូវការ ឬក្រៅផ្លូវការចំពោះដី ឬធនធានព្រៃឈើ មានការពឹងផ្អែកផ្នែកសេដ្ឋកិច្ចឬផ្នែកសង្គមមួយចំនួនលើធនធានព្រៃឈើអាចប្រឈមមុខ ឬខាតបង់ ខូចខាតជាក់ស្តែង ឬប្រឈមមុខនឹងផលប៉ះពាល់ដទៃពីសេចក្តីសម្រេចចិត្តអំពីធនធានរងឥទ្ធិពលក្នុងពេលបច្ចុប្បន្ន ឬអាចរងឥទ្ធិពលក្នុងពេលអនាគតពីសំណាក់សកម្មភាពពាក់ព័ន្ធនឹងមូលដ្ឋានធនធានព្រៃឈើ

មានទំនាក់ទំនងជាបន្តបន្ទាប់ជាមួយដីព្រៃ និងធនធានព្រៃឈើមានទំនាក់ទំនងប្រវត្តិសាស្ត្រ និងវប្បធម៌ជាមួយធនធានពាក់ព័ន្ធ បានបង្ហាញកិច្ចប្រឹងប្រែងមួយចំនួនក្នុងការគ្រប់គ្រង និងគិតគូរផលប្រយោជន៍ព្រៃឈើ ឬមានបទពិសោធន៍ ឬមានក្តីពឹងអំពីអន្តរាគមន៍ ផ្នែកគោលនយោបាយឬអន្តរាគមន៍ផ្នែកស្ថាប័ន។ ភាគីពាក់ព័ន្ធមួយក៏មានធនធានដែលត្រូវកៀរគរ ឬមានឆន្ទៈក្នុងការកៀរគរដែរ។

**ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព**

( **Sustainable Forest Management** )

សំដៅដល់ការទទួលខុសត្រូវ និងការប្រើប្រាស់ព្រៃឈើ និងដីព្រៃតាមបែបមួយ និងតាមអត្រាមួយដែលរក្សាជីវៈចម្រុះ ផលិតភាព សមត្ថភាពកកើតឡើងវិញ លទ្ធភាពដែលអាចយកមកប្រើបាន និងសក្តានុពលក្នុងការបំពេញមុខងារបរិស្ថាន សេដ្ឋកិច្ច និងសង្គមពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងកម្រិតសាកល ហើយកិច្ចការនេះមិនបំផ្លាញប្រព័ន្ធអេកូឡូស៊ីដទៃទៀត។

**យុទ្ធវិធី** ( **Tactics** )

ជានីតិវិធីឬសំណុំនៃវិធីនានា ដែលត្រូវបានអនុវត្តដើម្បីសម្រេចគោលដៅណាមួយ។

**សិទ្ធិកាន់កាប់** ( **Tenure** )

ជាចំណងទាក់ទងដែលកំណត់ដោយច្បាប់ ឬដោយប្រពៃណីចំពោះប្រជាជនអំពីដីធ្លី (រាប់ទាំងអគារ និងសំណង់ដែលពាក់ព័ន្ធផងដែរ) ដលផល ព្រៃឈើ និងធនធានធម្មជាតិដទៃទៀត។ វិធាននៃសិទ្ធិកាន់កាប់កំណត់វិធីផ្តល់ការប្រើប្រាស់ និងការគ្រប់គ្រងធនធានទាំងនេះក៏ដូចជាការទទួលខុសត្រូវ និងកម្រិតកំណត់ពាក់ព័ន្ធ។ ហេតុនេះសិទ្ធិកាន់កាប់តាមធម្មតាឆ្លុះបញ្ចាំងរចនាសម្ព័ន្ធ អំណាចនៅក្នុងសង្គម និងស្ថេរភាពសង្គមអាចអាស្រ័យលើ ឬមិនអាស្រ័យលើការមូលមតិជាទូទៅអំពីភាពយុត្តិធម៌នៃប្រព័ន្ធកាន់កាប់នោះ។

**ឧបករណ៍** ( **Tool** )

សំដៅដល់នីតិវិធី ឬដំណើរការមួយដែលមានគោលបំណងជាក់លាក់។ នៅក្នុងបរិបទនេះឧបករណ៍អាចជាអភិក្រម វិធីសាស្ត្រ យុទ្ធសាស្ត្រ យុទ្ធវិធី ឬបច្ចេកទេសនានា។

**តម្លាភាព** ( **Transparency** )

មានន័យថាជាគោលនយោបាយ ច្បាប់ និងនីតិវិធីដែលកំណត់ច្បាស់លាស់ និងផ្សព្វផ្សាយទូលំទូលាយជាសាធារណៈដោយភាសាពាក់ព័ន្ធ និងសេចក្តីសម្រេចផ្សព្វផ្សាយទូទៅជាសាធារណៈដោយភាសាពាក់ព័ន្ធ។

# ឧបសម្ព័ន្ធ៣៖ គន្ថនិទ្ទេស

## លក្ខណៈទូទៅ


**Christy, L.C., Di Leva, C.E., Lindsay, J.M. & Talla Takoukam, P.** 2007. *Forest law and sustainable development: addressing contemporary challenges through legal reform.* Law, Justice, and Development Series No. 40003. Washington, DC, World Bank. https://openknowledge.worldbank.org/bitstream/handle/10986/6671/400030PAPER0Fo101OFFICIAL0USE0ONLY1.pdf?sequence=1

**Colchester, M. with Boscolo, M., Contreras-Hermosilla, A., Del Gatto, F., Dempsey, J., Lescuyer, G., Obidzinski, K., Pommier, D., Richards, M., Sembiring, S.N., Tacconi, N., Vargas Rios, M.T. & Wells, A.** 2006. *Justice in the forest: rural livelihoods and forest law enforcement*. Bogor, Indonesia, Center for International Forestry Research (CIFOR). http://www.cifor.org/publications/pdf_files/Books/BColchester0601.pdf

**Contreras-Hermosilla, A. & Fay, C.** 2005. *Strengthening forest management in Indonesia through land tenure reform: issues and framework for action*. Bogor, Indonesia, World Agroforestry Center (ICRAF) and Washington, DC, World Bank and Forest Trends. http://www.forest-trends.org/documents/files/doc_107.pdf

**Cotula, L. & Mayers, J.** 2009. *Tenure in REDD: start point or afterthought?* Natural Resource Issues, No. 15. London, IIED. http://pubs.iied.org/13554IIED.html

**Cronkleton, P., Barry, D., Pulhin, J.M. & Saigal, S.** 2010. The devolution of management rights and the co-management of community forests. In A.M. Larson, D. Barry, G.R. Dahal and C.J.P. Colfer, eds. F*orests for People: Community Rights and Forest Tenure Reform*, pp. 43–68. London, Earthscan. http://www.cifor.org/publications/pdf_files/Books/BLarson1001.pdf

**Ellsworth, L. & White, A.** 2004. *Deeper roots: strengthening community tenure security and community livelihoods.* New York, Ford Foundation. http://www.fordfoundation.org/pdfs/library/deeper_roots.pdf

**Fisher, R., Maginnis, S., Jackson, W., Barrow, E. & Jeanrenaud, S.** 2005. *Poverty and conservation: landscapes, people and power*. Landscapes and Livelihoods Series, No. 2. Gland, Switzerland, IUCN. http://www.iucn.org/about/work/programmes/forest/fp_our_work/fp_our_work_thematic/fp_our_work_fpr/fp_forests_poverty_resources/?687/Poverty-and-Conservation-Landscapes-People-and-Power

**Fisher, R., Maginnis, S., Jackson, W., Barrow, E. & Jeanrenaud, S.** 2008. *Linking conservation and poverty reduction: landscapes, people and power*. London, Earthscan.

**FAO.** 2006. *Understanding forest tenure in South and Southeast Asia*. FAO Forestry Policy and Institutions Working Paper No. 14. Rome. http://www.fao.org/docrep/009/j8167e/j8167e00.htm

**FAO.** 2008. *Understanding forest tenure in Africa: opportunities and challenges for forest tenure diversification*. FAO Forestry Policy and Institutions Working Paper No. 19. Rome. http://www.fao.org/docrep/010/i0161b/i0161b00.htm

**FAO.** 2009. *Forest tenure in Latin American countries: an overview.* FAO Forestry Policy and Institutions Working Paper No. 24. Rome.

**FAO.** 2010. *Forest tenure in West and Central Asia, the caucasus and the russian federation,* F. Romano, I. Buttoud- Kouplevatskaya and D. Reeb. FAO Forestry Policy and Institutions Working Paper No. 25. Rome. http://www.fao.org/docrep/012/k7544e/k7544e00.pdf

**FAO.** 2011a. *Reforming forest tenure: issues, principles and process.* FAO Forestry Paper No. 165. Rome. http://www.fao.org/docrep/014/i2185e/i2185e00.pdf

**FAO.** 2011b. *Community-based tree and forest product enterprises: Market analysis and development,* I. Lecup. Rome. http://www.fao.org/docrep/014/i2394e/i2394e00.pdf

**FAO.** 2012a. *Voluntary Guidelines on the responsible governance of tenure of land, fisheries and forests in the context of national food security.* Rome. http://www.fao.org/fileadmin/user_upload/newsroom/docs/VG_en_Final_March_2012.pdf

**FAO.** 2012b. S*trengthening effective forest governance monitoring practice*, A.J. van Bodegom, S. Wigboldus, A.G. Blundell, E. Harwell and H. Savenije. FAO Forestry Policy and Institutions Working Paper No. 29. Rome. http://www.fao.org/docrep/015/me021e/me021e00.pdf

**FAO.** Forthcoming. *Implementation guide on land acquisition, free, prior and informed consent and customary land of indigenous peoples and other local communities*, S. Chao and M. Colchester.

**FAO/PROFOR.** 2011. *Framework for assessing and monitoring forest governance.* Rome and Washington, DC. http://www.fao.org/climatechange/27526-0cc61ecc084048c7a9425f64942df70a8.pdf

**Forest Peoples Programme.** Forthcoming. *Respecting the right to free, prior and informed consent: practical guidance for governments, companies, NGOs, indigenous peoples and local communities in relation to land acquisition.*

**Larson, A.M., Cronkleton, P., Barry, D. & Pacheco, P.** 2008. *Tenure rights and beyond: community access to forest resources in Latin America.* Occasional Paper No. 50. Bogor, Indonesia, Center for International Forestry Research (CIFOR). http://www.pefc.org/images/stories/documents/external/OP-50.pdf

**Lesniewska, F.** 2005. *Laws for forests: an introductory guide to international forest and forest related legal materials that*

*shape forest ethics and practice.* London, IIED. http://pubs.iied.org/13505IIED.html

**Macqueen, D.J., Chakrabarti, L., Baral, S., Dangal, S., du Plessis, P., Griffiths, A., Grouwels, S., Gyawali, S., Heney, J., Hewitt, D., Kamara, Y., Katwal, P., Magotra, R., Pandey, S., Panta, N., Subedi, B. & Vermeulen, S.** 2012. *Supporting small forest enterprises: a facilitators toolkit.* Small and Medium Forest Enterprise Series, No. 29. London, IIED. http://pubs.iied.org/13558IIED.html

**Mayers, J. & Bass, S.** 2004. *Policy that works for forest and people: real prospects for governance and livelihoods.* London, Earthscan. http://pubs.iied.org/pdfs/9276IIED.pdf

